# មាគ៌ាឆ្ពោះទៅរកយុត្តិធម៌

# សិទ្ធិទទួលបានយុត្តិធម៌ ដោយផ្តោតលើ

# ជនក្រីក្រ ស្ត្រី និងជនជាតិភាគតិច

## ជំពូកទី៣

## ការផ្តល់សេវាកម្មយុត្តិធម៌

ក្រសួងយុត្តិធម៌ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

២០០៥

# ជំពូក III
# ការផ្តល់សេវាកម្មយុត្តិធម៌

**នៅក្នុងជំពូកនេះ យើងនឹងវិភាគអំពី*ការផ្តល់សេវាកម្មយុត្តិធម៌* រួមទាំងយន្តការដោះស្រាយវិវាទនៅតាមសហគមន៍ ច្បាប់ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច នគរបាល យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងប្រព័ន្ធតុលាការផងដែរ។** យើងនឹងធ្វើការពិចារណាទៅលើក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងការប្រតិបត្តិនៅក្នុងប្រព័ន្ធនីមួយៗ។ ទិន្នន័យនេះបានមកពីការចុះស្រាវជ្រាវដល់ទីកន្លែងដែលបានធ្វើនៅក្នុងខេត្តចំនួន ៨ នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាព័ត៌មានដែលទទួលបានពីស្ថាប័ននានាដែលយើងបានជួបពិភាក្សា ការស្ទង់មតិ បទសម្ភាសន៍ និងសិក្ខាសាលាពិគ្រោះយោបល់នានា។

## ម ា តិ កា


១. ទិដ្ឋភាពរួមនៃសេវាយុត្តិធម៌..........១៤៥

២. ការផ្តល់សេវាយុត្តិធម៌តាមស្ថាប័ន ឬភ្នាក់ងារនីមួយៗ..........១៤៧
- ២.១. អាជ្ញាធរមូលដ្ឋាននៅថ្នាក់ភូមិ..........១៤៧
- ២.២. អាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ..........១៥៣
  - ២.២.១. ក្រុមប្រឹក្សាឃុំៈ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន..........១៥៣
  - ២.២.២. តម្រូវការយុត្តិធម៌ដែលបានប្តឹងទៅអាជ្ញាធរមូលដ្ឋាន..........១៥៧
  - ២.២.៣. សមត្ថភាពការងារ..........១៥៩
  - ២.២.៤. វាយតម្លៃលើតួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងការដោះស្រាយវិវាទ..........១៧១
    - ២.២.៤.(១). ចំណុចខ្លាំង និងអត្ថប្រយោជន៍របស់យុត្តិធម៌មូលដ្ឋានៈ..........១៧២
    - ២.២.៤.(២). ចំណុចខ្សោយ និងការរិះគន់ចំពោះក្រុមប្រឹក្សាឃុំរួមមានៈ..........១៧៦
- ២.៣. ជនជាតិដើមភាគតិច..........១៧៩
  - ២.៣.១. ក្របខ័ណ្ឌច្បាប់..........១៨០
  - ២.៣.២. សហគមន៍ជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី..........១៨៣
- ២.៤.នគរបាល..........១៨៥
  - ២.៤.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័នៈ..........១៨៥
  - ២.៤.២. តម្រូវការយុត្តិធម៌នៅចំពោះមុខនគរបាល..........១៩១
  - ២.៤.៣. ការវាយតម្លៃលើនគរបាល..........១៩៥
- ២.៥. អាជ្ញាធរនយោបាយ (អភិបាលស្រុក និងអភិបាលខេត្ត)..........១៩៦
  - ២.៥.១. ក្របខ័ណ្ឌផ្លូវច្បាប់ និងស្ថាប័ន..........១៩៦
  - ២.៥.២. តម្រូវការយុត្តិធម៌ពីអភិបាលស្រុក និងខេត្ត..........២០០
- ២.៦. គណៈកម្មការសុរិយោដី..........២០៣

២.៦.១. ក្របខ័ណ្ឌច្បាប់និងស្ថាប័ន....................២០៣

២.៦.២. តម្រូវការយុត្តិធម៌ពីគណៈកម្មការសុរិយោដី....................២០៥

២.៦.៣. ការវាយតម្លៃ....................២១៧

២.៧. ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ....................២២០

២.៧.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន....................២២០

២.៧.២. តម្រូវការយុត្តិធម៌នៅចំពោះមុខគណៈកម្មការសុរិយោដី....................២២៥

២.៧.៣. ការវាយតម្លៃ....................២២៨

២.៨. ប្រព័ន្ធតុលាការ....................២២៩

២.៨.១. ក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន....................២២៩

២.៨.២. តម្រូវការយុត្តិធម៌ពីនៅចំពោះមុខតុលាការ....................២៣៤

២.៨.៣. សមត្ថភាពការងារ....................២៣៦

២.៨.៤. ការវាយតម្លៃ....................២៤១

៣. ការផ្តល់សេវាច្បាប់....................២៤២

៣.១. ជំនួយការច្បាប់....................២៤២

៣.២. សិទ្ធិមានអ្នកបកប្រែ....................២៤៣

៣.៣. អ្នកជំនាញៈ ធ្វើកោសល្យវិច្ច័យដោយឥតគិតថ្លៃ....................២៤៥

៤. តារាងសង្ខេប ស្តីពីការផ្តល់សេវាយុត្តិធម៌តាមស្ថាប័ននីមួយៗ....................២៤៧

## ១. និន្នាការរួមនៃសេវាយុត្តិធម៌

តម្រូវការយុត្តិធម៌ក្នុងសង្គម គឺរាប់បញ្ចូលទាំងសេចក្តីត្រូវការរបស់សង្គមទាំងឡាយដូចជា សេចក្តីត្រូវការនៃដំណោះស្រាយវិវាទនានា ត្រួតពិនិត្យការរំលោភអំណាច និងការអនុវត្តនិងគោរពសិទ្ធិបុគ្គល និងសិទ្ធិសង្គមជាដើម។ ទោះជាយ៉ាងនេះក្តី *ព្រឹត្តិការណ៍ដែលអាចជារឿងក្តី* ខ្លះមិនត្រូវបានគេប្តឹងដើម្បីរកដំណោះស្រាយឡើយ ជាពិសេសករណីដែលពាក់ព័ន្ធ និងការរំលោភអំណាច និងការរំលោភសិទ្ធិសង្គមនិងសិទ្ធិបុគ្គល។ ការរំលោភអំណាច និងការរំលោភសិទ្ធិបុគ្គលនិងសិទ្ធិសង្គម ដោយភ្នាក់ងាររបស់រដ្ឋនានា គឺជាតម្រូវការយុត្តិធម៌ជាសក្តានុពល។ តែផ្ទុយទៅវិញតម្រូវការយុត្តិធម៌ជាក់ស្តែង គឺសំដៅលើវិវាទ ឬទំនាស់ទាំងឡាយដែលភាគច្រើនកើតឡើងរវាងបុគ្គល។ ឫសគល់នៃរាល់វិវាទដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច គឺមានលក្ខណៈខុសប្លែក។ វិវាទដែលដែលកើតមាន នៅក្នុងសង្គមមានប្រភពមកពីមូលហេតុផ្សេងៗ ដូចជា : ក). វិវាទដែលមាននៅមូលដ្ឋានរវាងពលរដ្ឋ ខ). អំពើហិង្សាខាងយេនឌ័រ គ). វិវាទដីធ្លី និង ឃ) បញ្ហាព្រហ្មទណ្ឌនានា។ ទាំងនេះជាបាតុភូតនៃវិវាទនានាដែលបានកើតមាននៅក្នុងសង្គម។

**វិវាទដែលមាននៅក្នុងមូលដ្ឋាន:** វិវាទខ្លះមានទាក់ទងនឹងបញ្ហាតូចតាច ដែលកើតឡើងជារៀងរាល់ថ្ងៃ កើតឡើងពីទំនាក់ទំនងដែលមាននៅក្នុងសង្គមនៅតំបន់ជនបទ ដូចជាវិវាទព្រំដី សត្វពាហនៈស៊ីដំណាំ ការប្រើប្រាស់ស្រះ បំណុល វិវាទក្នុងគ្រួសារ ជម្លោះជាមួយអ្នកជិតខាង ការបរិហាកេរ្តិ៍ និងរឿងក្តីព្រហ្មទណ្ឌតូចតាចនានា។

***អំពើហិង្សាខាងយេនឌ័រ:*** វិវាទចម្បងផ្សេងទៀតទាក់ទងនឹងអំពើហិង្សាខាងយេនឌ័រប្រឆាំងនឹងស្ត្រី និងកុមារ ដូចជាអំពើហិង្សាក្នុងគ្រួសារ និងការបំពានខាងផ្លូវភេទ រួមទាំងរំលោភសេពសន្ថវៈផង។ ជនដែលប្រព្រឹត្ត ជាទូទៅជាជនដែលជនរងគ្រោះស្គាល់។ អំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុចម្បងនាំឱ្យមានការប្តឹងសុំផ្តាច់សង្វាស និងការលែងលះ។ ហិង្សាខាងយេនឌ័រ គឺជាបញ្ហាចម្បងនៅក្នុងសង្គម។

**វិវាទដីធ្លីធំៗ:** វិវាទដីធ្លីមានប្រភពមកពីមូលហេតុជាច្រើន។ ក្នុងចំណោមមូលហេតុទាំងនោះ មានមូលហេតុមួយទាក់ទិននឹងទីផ្សារនៃការទិញដីកេងយកចំណេញ។ បញ្ហានេះកើតមានដោយសារតែពុំមានការកំណត់ព្រំដី និងពុំមានប័ណ្ណកម្មសិទ្ធលើដីធ្លីច្បាស់លាស់ (លើសពី ៨០% នៃដីធ្លីមិនទាន់បានចុះបញ្ជីនៅឡើយទេ) និងការរីករាលដាលនៃអំពើពុករលួយ។ អ្នកភូមិប្រឈមមុខនឹងការបាត់បង់ដីរបស់ពួកគេ ឬឱកាសរុករកធនធានព្រៃឈើ ដោយសារការផ្តល់សម្បទានដីធ្លី ដែលមិនមានតម្លាភាព ការចាប់យកដីធ្លី និងការវាតយកដីដោយខុសច្បាប់ ធ្វើឡើងដោយអ្នកមានអំណាច ក្រុមហ៊ុន ក្រុមយោធា និងមន្ត្រីថ្នាក់ខ្ពស់មួយចំនួន។ ការប្រមូលផ្តុំដីធ្លីនិងធនធានធម្មជាតិ ធ្វើឡើងដោយពុំមានការណែនាំពីច្បាប់ ដោយសារភាពខ្វះខាតនៃបទបញ្ញត្តិបន្ទាប់បន្សំ ភាពខ្វះខាតនៃការអនុវត្តច្បាប់ ហើយភាគច្រើនតាមរយៈអំពើពុករលួយ។ ការទន្ទ្រានយកដីរបស់សហគមន៍ជនជាតិដើមភាគតិចដោយអ្នកខាងក្រៅ គឺជាបញ្ហាធ្ងន់ធ្ងរ ដែលពួកគេកំពុងជួបប្រទះ ហើយអាចគំរាមកំហែងដល់អត្ថិភាពរបស់ពួកគេថែមទៀត។

**បទល្មើសព្រហ្មទណ្ឌនានា:** បទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈធ្ងន់ធ្ងរ ក៏កើតមានម្តងម្កាលផងដែរ ហើយបទល្មើសបែបថ្មីៗទាំងនេះ ក៏មានការកើនឡើងដែរ ដូចជាករណីបងតូចបងធំជាដើម។

សរុបសេចក្តីមក កម្មវត្ថុនៃបញ្ហារឿងក្តីដែលបានលើកឡើងដោយអ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ដើម្បីទាមទាររកសេវាកម្មយុត្តិធម៌ផ្សេងៗ គឺមានដូចខាងក្រោម :

តារាង: សេវាយុត្តិធម៌យោងតាមកម្មវត្ថុ និងរឿងហេតុនានា

| តម្រូវការយុត្តិធម៌យោងតាមកម្មវត្ថុ និងរឿងហេតុនានា | | | ផ្តល់សេវាយុត្តិធម៌ |
|---|---|---|---|
| អ្នកក្រីក្រ  | ស្ត្រី  |  | ភ្នាក់ងារដែលផ្តល់សេវាយុត្តិធម៌ |
| **វិវាទនៅតាមមូលដ្ឋាន**<br>- រឿងហេតុផ្សេងៗ | **អំពើហិង្សាផ្អែកលើយេនឌ័រ**<br>- អំពើហិង្សាក្នុងគ្រួសារ<br>- អំពើរំលោភសេពសន្ថវៈ និងអំពើបំពានផ្លូវភេទ ការផ្តាច់សង្វាស និង ការលែងលះ | វិវាទកើតនៅក្នុងសហគមន៍ជនជាតិដើមភាគតិចត្រូវបានប្តឹងទៅអាជ្ញាធរជនជាតិដើមភាគតិច ។ ករណីរឿងក្តីខ្លះបានប្តឹងទៅមេភូមិ និងខ្លះប្តឹងទៅក្រុមប្រឹក្សាឃុំ | **អាជ្ញាធរមូលដ្ឋាន**<br>- មេភូមិ<br>- ក្រុមប្រឹក្សាឃុំ ។ រឿងក្តីដែលទទួលបានក្នុងមួយឆ្នាំមានប្រហែល **៤០.៥២៥**ករណី (២៥ករណី ក្នុងឃុំមួយក្នុងមួយឆ្នាំ) |
| - **បទល្មើសព្រហ្មទណ្ឌ**<br>- រឿងក្តីផ្សេងៗទៀត (បំណុល ដីធ្លី) | - អំពើហិង្សាក្នុងគ្រួសារ<br>- អំពើរំលោភសេពសន្ថវៈ និងអំពើបំពានផ្លូវភេទ | **រឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ** | **នគរបាល** |
| **វិវាទដីធ្លី**<br>ក-រវាងអ្នកភូមិ<br>ខ-រវាងអ្នកភូមិ និងអ្នកមានអំណាច | **ដីធ្លី** | - **ការទន្ទ្រានយកដីសហគមន៍ដោយខុសច្បាប់** ដោយអ្នកមានអំណាច | **គណៈកម្មការសុរិយោដី :**<br>រឿងក្តីដែលទទួលបានក្នុងឆ្នាំ ២០០៣ និង ២០០៤ នៅក្នុង ២៤ ខេត្ត-ក្រុង មានចំនួន ២.០៧៩ ករណី |
| - រឿងក្តី**ព្រហ្មទណ្ឌ**<br>- រឿងក្តី**រដ្ឋប្បវេណី** | - ការលែងលះ : ៨០%នៃរឿងក្តីលែងលះត្រូវបានដាក់ពាក្យប្តឹងដោយស្ត្រី<br>- ការបង្ករបួសស្នាមធ្ងន់ធ្ងរ និងអំពើរំលោភសេពសន្ថវៈ | - ជនជាតិដើមភាគតិចជាប់ចោទពីបទព្រហ្មទណ្ឌ : ខ្វះខាតមេធាវីការពារ និងអ្នកបកប្រែភាសា | **តុលាការ :**<br>រឿងក្តីទទួលបានក្នុងឆ្នាំ ២០០៣ មានចំនួន ១២.០៤៣ ករណី |
| វិវាទការងាររួម (ភាគច្រើននៅក្នុងទីក្រុង) | វិវាទការងាររួម (ភាគច្រើននៅក្នុងទីក្រុង) | | **ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ :**<br>រឿងក្តីដែលទទួលបានពីឆ្នាំ ២០០៣-២០០៤ មានប្រមាណ : ១៤៥ |

## ២. ការផ្តល់សេវាយុត្តិធម៌តាមស្ថាប័ន ឬភ្នាក់ងារនីមួយៗ

ភ្នាក់ងារដែលផ្តល់សេវាកម្មយុត្តិធម៌មានដូចជា :

- អាជ្ញាធរមូលដ្ឋាន : មេភូមិ ក្រុមប្រឹក្សាឃុំ ដែលមាននៅថ្នាក់ភូមិ និងថ្នាក់ឃុំ ។
- អាជ្ញាធរជនជាតិដើមភាគតិចនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ។
- នគរបាល នៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ ។
- អភិបាលស្រុក អភិបាលខេត្ត ដែលមាននៅថ្នាក់ស្រុក និងខេត្ត ។
- គណៈកម្មការសុរិយោដី ( មានទីតាំងនៅថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ) ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ មាននៅតែភ្នំពេញ
- ប្រព័ន្ធតុលាការនៅថ្នាក់ខេត្ត/ក្រុង និងថ្នាក់ជាតិ ។

តារាងស្តីពីភ្នាក់ងារដែលមានស្រាប់សម្រាប់ដោះស្រាយរឿងក្តី ( ដែលបានទៅដល់ដៃពួកគេ)




### ២.១. អាជ្ញាធរមូលដ្ឋាននៅថ្នាក់ភូមិ

ក. ចាស់ទុំ និងអង្គការនៅថ្នាក់ភូមិ

នៅថ្នាក់ភូមិ មុនពេលប្រជាពលរដ្ឋប្តឹងទៅរកអាជ្ញាធរ ពួកគេព្យាយាមដោះស្រាយបញ្ហា និងវិវាទរបស់ពួកគេដោយមធ្យោបាយផ្សេងៗដូចជាទៅរកសាច់ញាតិ និងចាស់ទុំ និងពេលខ្លះអាចទៅវត្តអារាមផងដែរ ។

**សាច់ញាតិនិងចាស់ទុំ:** ជាពិសេសក្នុងរឿងគ្រួសារ ដូចជាអំពើហិង្សាក្នុងគ្រួសារ វិវាទរវាងប្តីប្រពន្ធ និងវិវាទគ្រួសារដែលជាការជេរប្រទេចផ្តាសារ ការបរិហារកេរ្តិ៍ រឿងក្តីមរតក និងក្នុងចំណោមរឿងដទៃទៀត ប្រជាពលរដ្ឋតែងព្យាយាមដោះស្រាយរឿងក្តីនៅមូលដ្ឋាន ដោយមានការជួយជ្រោមជ្រែងពីសាច់ញាតិនិងចាស់ទុំ។ ប្រសិនបើធ្វើដូចនេះបរាជ័យ

គូភាគីនឹងទៅរកមេភូមិ។

គណៈកម្មការវត្ត ព្រះសង្ឃ និងអ្នកផ្សេងៗទៀតៈ នៅក្នុងច្បាប់ភូមិបាល មានផ្នែកមួយបានចែងកំណត់ អំពីដីវត្តអារាម។ មានគណៈកម្មការមួយទទួលបន្ទុកក្នុងការគ្រប់គ្រង និងកិច្ចការទូទៅរបស់វត្តអារាម។ ក្រោយរបប ប៉ុល ពត បានដួលរលំទៅ ការហាមប្រាមលើជំនឿសាសនាក៏ត្រូវបានបញ្ចប់។ មានវត្តអារាមជាច្រើននៅស្ទើរតែគ្រប់ភូមិ លើកលែងតែភូមិណាដែលប្រជាពលរដ្ឋមិនមែនជាពុទ្ធសាសនិក។ ជាធម្មតាគណៈកម្មការវត្ត ត្រូវបានបង្កើតឡើងដោយមានចាស់ទុំ តាមការបោះឆ្នោតតាមវិធីមិនផ្លូវការមួយ ដោយអ្នកតំណាងក្នុងគ្រួសារនីមួយៗនៅក្នុងភូមិ។ ក្នុងករណីខ្លះ សមាជិកត្រូវបានជ្រើសរើសឡើងដោយគណៈកម្មការដែលមានពីមុន។ គណៈកម្មការទាំងនេះទទួលបន្ទុកលើបញ្ហា ដែលទាក់ទងនឹងវត្តអារាមរបស់ខ្លួន ប៉ុន្តែក៏ធ្វើអន្តរាគមន៍ផងដែរចំពោះបញ្ហានានា ដែលកើតឡើងក្នុងភូមិខ្លួន ដូចជាការប្រមូលមូលនិធិសម្រាប់កសាងស្ពាន សាលា ផ្លូវលំក្នុងភូមិ។ល។ ពួកគេក៏ជួយដោះស្រាយវិវាទ ដែលទាក់ទងនឹងករណីខាងលើនេះដែរ។ ក្នុងករណីខ្លះ ដូចជាជម្លោះក្នុងគ្រួសារ ប្រជាពលរដ្ឋស្វែងរកព្រះសង្ឃ ឬចាស់ទុំឱ្យជួយ ជាពិសេសប្រសិនបើអ្នកទាំងនោះមានទំនាក់ទំនងជិតស្និទ្ធ ឬជាប់សាច់ញាតិជាមួយគូភាគីវិវាទ។

ខ. អាជ្ញាធរក្នុងភូមិៈ មេភូមិ និងអនុប្រធានភូមិ

អាជ្ញាធរផ្លូវច្បាប់តែមួយគត់ដែលនៅថ្នាក់ភូមិ គឺមេភូមិ។

ក្របខ័ណ្ឌច្បាប់ៈ

យោងតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ ២០០១ មេភូមិត្រូវបានតែងតាំងឡើងដោយក្រុមប្រឹក្សាឃុំ[១៦១]។ មេភូមិ គឺជាអ្នកតំណាងឱ្យប្រជាពលរដ្ឋក្នុងភូមិ ហើយជាបណ្ដាញទំនាក់ទំនងសំខាន់រវាងប្រជាពលរដ្ឋក្នុងភូមិ ជាមួយនឹងក្រុមប្រឹក្សាឃុំ។ មុខងាររបស់មេភូមិគឺៈ ស្វែងរកអត្ថប្រយោជន៍ជូនភូមិអនុវត្តន៍ករណីយកិច្ច ដែលបានចាត់តាំងដោយក្រុមប្រឹក្សាឃុំ ផ្ដល់អនុសាសន៍ ទៅឱ្យឃុំទាក់ទងនឹងអត្ថប្រយោជន៍ដល់ភូមិរបស់ខ្លួន ក៏ដូចជាគ្រប់គ្រង និងសម្របសម្រួលការងារជាមួយក្រុមប្រឹក្សាឃុំ។

ទោះបីជាច្បាប់ស្ដីពីមុខងាររបស់មេភូមិអាចជាអ្វីដែលថ្មីក៏ដោយ តែមេភូមិមានជាយូរយារណាស់មកហើយ។ មេភូមិគឺជាអាជ្ញាធរថ្នាក់ភូមិនៅមុនរបបខ្មែរក្រហម។ វាត្រូវបានបង្កើតឡើងម្ដងទៀត នៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។ ច្បាប់ដែលមានបច្ចុប្បន្នបានផ្ដល់ឱ្យអាជ្ញាធរនេះនូវ "សមត្ថកិច្ចដែលធ្វើប្រតិភូកម្មអំណាច" ពីក្រុមប្រឹក្សាឃុំ។ មេភូមិដើរតួនាទីសំខាន់ នៅក្នុងការដោះស្រាយវិវាទនៅមូលដ្ឋាន ដោយសារតែជាអាជ្ញាធរទីមួយក្នុងការទទួល និងដោះស្រាយវិវាទនៅមូលដ្ឋាន ទោះបីជាមុខងារទាំងនេះមិនត្រូវបានកំណត់ច្បាស់លាស់ នៅក្នុងច្បាប់យ៉ាងណាក្ដី។

**តារាងៈ បទបញ្ញត្តិច្បាប់នៃមុខងាររបស់មេភូមិ**

| ប្រធានបទ | ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ (ឆ្នាំ ២០០១) |
|---|---|
| គណៈកម្មការដែលត្រូវតែងតាំងឡើងដោយមេឃុំ | មាត្រា ២៧ : មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មការនានា ដើម្បីផ្ដល់យោបល់ និងជួយកិច្ចការនានា តាមការចាំបាច់ (...)។ |

[១៦១] សូមមើលបទបញ្ញត្តិស្ដីពីតួនាទី និងមុខងារ នៅក្នុងឧបសម្ព័ន្ធទី១

| | |
|---|---|
| **មេភូមិអាចតែងតាំងអនុប្រធាន និងជំនួយការ** | មាត្រា ៣០ : ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន។ មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូប និងសមាជិកមួយជាជំនួយការ ។ |
| **ភារកិច្ចរបស់មេភូមិ** | មាត្រា ៣១ : មេភូមិមានភារកិច្ចៈ<br>- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬ មេឃុំ ចៅសង្កាត់ប្រគល់ឱ្យ ដើម្បីធានាសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងភូមិ។<br>- ផ្ដល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិខ្លួន<br>- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ មេឃុំ ចៅសង្កាត់ ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។ |
| **អនុក្រឹត្យស្ដីពីការផ្ទេរមុខងារ អំណាច តួនាទី និងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ (ឆ្នាំ២០០២)** | |
| ប្រធានភូមិ តំណាងឱ្យប្រជាពលរដ្ឋក្នុងភូមិនៅចំពោះមុខក្រុមប្រឹក្សាឃុំ | មាត្រា ២៣ :<br>- មេភូមិជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់តភ្ជាប់ទំនាក់ទំនងរវាងភូមិនិងក្រុមប្រឹក្សាឃុំ-សង្កាត់។ ក្នុងការសម្រេចបញ្ហាណាមួយដែលពាក់ព័ន្ធនឹងភូមិ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវពិគ្រោះយោបល់ជាមួយមេភូមិជាមុនសិន។ |
| **សិទ្ធិប្រជាពលរដ្ឋក្នុងការធ្វើសំណើ ឬពាក្យបណ្ដឹង** | មាត្រា ៣១ :<br>- ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬធ្វើការប្ដឹងតវ៉ា ជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវឆ្លើយតបនឹងសំណើ ឬការប្ដឹងតវ៉ានោះជាកំហិត។ |

ក្របខណ្ឌស្ថាប័ន

មានមេភូមិនៅគ្រប់ភូមិទាំងអស់នៅទូទាំងប្រទេស។ នោះមានន័យថា មានមេភូមិចំនួន ១៣.៦៩៤ នាក់។ នៅជាមួយមេភូមិ ក៏មានអនុប្រធានភូមិផងដែរនៅតាមភូមិនីមួយៗ។

**តារាងស្ដីពីការរៀបចំរដ្ឋបាលនៅកម្ពុជា[១៦២]**

| ខេត្ត/ក្រុង | ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ |
|---|---|---|---|
| ២៤ | ១៨៥ | ១៦២១ | ១៣.៦៩៤ |

---

១៦២ ប្រភព : ដកស្រង់ចេញពី ប្រកាសលេខ ៤៩៣ ប្រ.ក ស្ដីពីឈ្មោះ ចំនួន និងព្រំប្រទល់ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០១។

មេភូមិខ្លះមានការអប់រំតិចតួច។ មេភូមិទាំងអស់ដែលយើងបានទៅជួបសុទ្ធតែជាបុរស។ មានមេភូមិខ្លះឋិតនៅក្នុងមុខងារនេះរយៈពេលជាង១០ឆ្នាំមកហើយ។ អ្នកទាំងនោះភាគច្រើនទទួលតួនាទី នេះមុនពេលបង្កើតក្រុមប្រឹក្សាឃុំ-សង្កាត់មកម្ល៉េះ[១៦៣]។

មេភូមិទទួលបានប្រាក់បៀវត្សន៍ ២២.០០០ រៀលក្នុងមួយខែ (៥.៥ ដុល្លារអាមេរិក) ដែលផ្តល់ដោយក្រុមប្រឹក្សាឃុំ។ ជាធម្មតាមេភូមិប្រើប្រាស់ផ្ទះរបស់គាត់ជា "ការិយាល័យ"។ ជាទូទៅមេភូមិមិនបានទទួលលុយកាក់ សម្រាប់សម្ភារៈការិយាល័យទេ លើកលែងតែមានគម្រោងណាមួយបែបដូច្នោះ។

**តារាងស្តីពី "ប្រាក់ឧបត្ថម្ភមេភូមិ"[១៦៤]**

| តួនាទី | ប្រចាំខែ | | ប្រចាំឆ្នាំ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក |
| មេភូមិ | ២២.០០០ | ៥.៥ | ២៦៤.០០០ | ៦៦.០ |

រដ្ឋចំណាយតិចជាងមួយលានដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់ប្រាក់បៀវត្សរ៍មេភូមិ (៩០៣ ៨០៤ ដុល្លារ) ព្រោះនៅប្រទេសកម្ពុជាមានភូមិចំនួន ១៣ ៦៩៤ ភូមិ ហើយប្រាក់ចំណូលរបស់មេភូមិម្នាក់ទទួលបាន ប្រហែលជា ៦៦ ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។

ទំហំរឿងក្តី

មិនមានតួលេខរឿងក្តីណាមួយច្បាស់លាស់ អំពីចំនួនរឿងក្តីដែលសម្រុះសម្រួលដោយមេភូមិ នៅក្នុងភូមិនីមួយៗឡើយ។ តែទោះជាយ៉ាងណាក្តី បញ្ហានិងវិវាទនៅក្នុងភូមិនីមួយៗ មានកម្រិតធ្ងន់ធ្ងរខុសៗគ្នា។ រឿងខ្លះអាចជា រឿងធម្មតាសាមញ្ញ ឯខ្លះទៀតអាចតម្រូវឱ្យមានការប្រជុំសម្រុះសម្រួល ហើយរឿងខ្លះទៀតអាចត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាឃុំ ឬទៅនគរបាល។

ក្នុងបទសម្ភាសន៍ខ្លះមេភូមិបានឱ្យដឹងថា ពួកគេមានរឿងក្តីពី ៣ ទៅ ៥ ករណីក្នុងមួយឆ្នាំ។

| ចំនួនភូមិ | ចំនួនរឿងក្តីជាមធ្យមក្នុងមួយឆ្នាំ | ចំនួនសរុបទូទាំងប្រទេស |
|---|---|---|
| ១៣.៦៩៤ | ៤ | ៥៤.៧៧៦ |

បញ្ហារឿងក្តី

មេភូមិគឺជាអាជ្ញាធរ ដែលនៅជិតប្រជាពលរដ្ឋជាងគេបំផុតនៅថ្នាក់មូលដ្ឋាន ដូចនេះពួកគេទទួលរឿងក្តីនៅមូលដ្ឋានភាគច្រើនដើម្បីសម្រុះសម្រួល ហើយរឿងខ្លះទទួលហើយបញ្ជូនទៅថ្នាក់ឃុំឬនគរបាល។ រឿងវិវាទដែលមេភូមិបានទទួលមានទាក់ទងនឹងបញ្ហាផ្សេងៗ ដូចជាៈ ក-វិវាទកើតមាននៅមូលដ្ឋាន និងបទល្មើសព្រហ្មទណ្ឌ ខ-អំពើហិង្សាខាងយេនឌ័រ និងការលែងលះ និង គ-វិវាទដីធ្លី និងវិវាទផ្សេងៗទៀតរវាងភាគី ដែលមិនមានតុល្យភាពរវាងគ្នា ដូចជា រវាងម្ខាងជាអ្នកភូមិ និងម្ខាងទៀតជាភាគីអ្នកមានអំណាចជាដើម។ មេភូមិមួយចំនួនបញ្ជូនរឿងក្តី ដែលមានភាគច្រើនទៅក្រុមប្រឹក្សាឃុំ ជាពិសេសពេលដែលរឿងក្តីណា ដែលមានសភាពធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ មេភូមិផ្សេងទៀតដោះស្រាយរឿងទាំងអស់រួមទាំងវិវាទទាក់ទិន

[១៦៣] តាមការសម្ភាសនិងការស្ទង់មតិរបស់ IRL

[១៦៤] ប្រភពៈ កម្មវិធីសិលា : ព័ត៌មានស្តីពីមូលនិធិ និងថវិការបស់ក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ ២០០៥ ។

នឹងការផ្តាច់សង្វាស និងការលែងលះ[១៦៥]ផង។ នេះជាករណីដែលខុសពីធម្មតា។ ខាងក្រោមនេះជាឧទាហរណ៍នៃរឿងក្តី "លែងលះ" មួយ ដែលធ្វើឡើងដោយមេភូមិ តែក្រោយមកត្រូវបានចាត់ទុកជាមោឃៈវិញ ដោយក្រុមប្រឹក្សាឃុំ។

រឿងក្តីលែងលះដែលត្រូវបានធ្វើឡើងដោយមេភូមិ ហើយក្រោយមកត្រូវបានចាត់ទុកជា មោឃៈដោយថ្នាក់ឃុំ

*ឃុំមហាឬស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ*

- *កំណត់ហេតុនៃការសម្រុះសម្រួលនិងកិច្ចសន្យា (ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៣)*

*នៅថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៣ គូភាគីបានប្តឹងមកមេភូមិសុំលែងលះ និងបែងចែកទ្រព្យសម្បត្តិ។ កិច្ចសន្យាស្តីពីការលែងលះ និងការបែងចែកទ្រព្យសម្បត្តិ ត្រូវបានធ្វើឡើងនៅចំពោះមុខមេភូមិ និងឪពុកម្តាយទាំងសងខាង។ ក្រោយមកភាគីបានដាក់ពាក្យប្តឹងទៅក្រុមប្រឹក្សាឃុំដើម្បីសុំ មោឃភាព កិច្ចសន្យាដែលមានពីមុន ពីព្រោះវាបានធ្វើឡើងដោយមានការគាបសង្កត់ពីឪពុកម្តាយ។ នៅ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៣ គូភាគីបានធ្វើកិច្ចសន្យាថ្មី ដើម្បីទុកជាមោឃៈនូវកិច្ចសន្យាលែងលះដែលបាន ធ្វើនៅមុខមេភូមិ ហើយបានសន្យាថារស់នៅជាមួយគ្នាជារៀងរហូត [១៦៦]។*

នីតិវិធី

- ស្ទើរតែគ្រប់រឿងក្តីនៅមូលដ្ឋានទាំងអស់ មិនថាជារឿងក្តីរដ្ឋប្បវេណីឬព្រហ្មទណ្ឌទេ ប្រជាពលរដ្ឋដំបូងនាំគ្នាទៅរកមេភូមិ។ មានន័យថាមេភូមិជាអ្នកដើរតួនាទីសំខាន់នៅក្នុងការដោះស្រាយវិវាទនៅក្នុងមូលដ្ឋាន [១៦៧]។
- មេភូមិតែម្នាក់ឯង ឬដោយមានការជួយជ្រោមជ្រែងពីចាស់ទុំ ឬអ្នកមានកិត្តិនាមនៅក្នុងសហគមន៍ (គ្រូបង្រៀន ឬអ្នកចេះដឹង) បានដោះស្រាយរឿងក្តីតាមរយៈដំណើរការសម្រុះសម្រួល។
- មេភូមិរៀបចំការប្រជុំសម្រុះសម្រួលមួយរវាងគូវិវាទ និងសុំពួកគេឱ្យពន្យល់ប្រាប់ពីរឿងវិវាទ និងឱ្យភាគីលើកពីតម្រូវការរបស់ពួកគេ។ បន្ទាប់មក មេភូមិនាំគូភាគីឱ្យសុំទោសគ្នាទៅវិញទៅមក និងចរចារកលក្ខខណ្ឌនានា និងធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក។
- នៅក្នុងករណីខ្លះ មានកំណត់ហេតុជាកិច្ចសន្យាផងដែរ។
- ប្រសិនបើការសម្រុះសម្រួលទទួលបរាជ័យនៅថ្នាក់ភូមិ ឬក៏មេភូមិយល់ថាគាត់មិនមានសមត្ថកិច្ចដោះស្រាយរឿងនេះ មេភូមិនឹងបញ្ជូនគូភាគីឱ្យទៅអាជ្ញាធរឃុំ។
- ក្នុងករណីខ្លះ មេភូមិធ្វើដំណើរទៅជាមួយគូភាគីទៅរកក្រុមប្រឹក្សាឃុំ ឬប៉ុស្តិ៍នគរបាលនៅថ្នាក់ឃុំ។ ក្នុងករណីខ្លះទៀត មេភូមិគ្រាន់តែសរសេរកំណត់សំគាល់លើពាក្យបណ្តឹង ឬលិខិតមួយបញ្ជូនរឿងក្តីទៅកាន់អាជ្ញាធរឃុំប៉ុណ្ណោះ។ ឯកសារនេះបើកផ្លូវឱ្យមានរឿងក្តីនៅថ្នាក់ឃុំ។
- ជាធម្មតា អាជ្ញាធរឃុំសួរនាំព័ត៌មានពីមេភូមិអំពីរឿងក្តីដែលទាក់ទងនឹងយុត្តាធិការរបស់ខ្លួន។

១៦៥ ដូចដែលបានរៀបរាប់ និងពន្យល់ក្នុងជំពូកទី ២ លោកអ្នកគួរកត់សំគាល់ថា ប្រជាពលរដ្ឋនៅមូលដ្ឋាន ប្រើពាក្យ "លែងលះ" គ្រប់ករណីទាំងអស់សម្រាប់ការសម្រេចចិត្តរស់នៅដោយបែកគ្នា ទោះបីជាការរៀបការរបស់ពួកគេបានចុះបញ្ជី ឬមិនចុះបញ្ជី ដែលច្បាប់កំណត់ថា ភាគីមិនបានរៀបការស្របច្បាប់ក្តី។

១៦៦ សូមមើលរឿងក្តីលេខ E6 នៅក្នុងឧបសម្ព័ន្ធទី២

១៦៧ មានការស្ទង់មតិមួយផ្សេងទៀតដែលបានធ្វើសេចក្តីសន្និដ្ឋានដូចគ្នានេះដែរ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលសម្រាប់ការសិក្សា ស្រាវជ្រាវជាន់ខ្ពស់សម្រាប់មូលនិធិអាស៊ី "*Public Opinion Poll on the role and performance of commune councils, especially regarding local conflicts*" ភ្នំពេញ ឆ្នាំ២០០៥។ (ចាប់ពីពេលនេះ ទៅត្រូវសរសេរ : *CAS-AF Survey*)។ ការសិក្សាស្រាវជ្រាវនេះមានប្រយោជន៍ណាស់ដើម្បីវាយតម្លៃតួនាទីរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការដោះស្រាយវិវាទ ជូនប្រជាពលរដ្ឋ។

រឿងក្តីដែលត្រូវបានដោះស្រាយនៅថ្នាក់ភូមិ

តួនាទីនៅក្នុងការដោះស្រាយវិវាទ :

មិនមានចំនួនរឿងក្តីច្បាស់លាស់ ដែលមេភូមិបានទទួលទេ ពីព្រោះមេភូមិអន្តរាគមរឿងក្តី ចាប់តាំងពីដំណាក់កាលដំបូងនៃវិវាទមុនពេលវាក្លាយជារឿងធ្ងន់ធ្ងរ។ ដូចដែលបានរៀបរាប់ប្រាប់មកខាងលើនេះរួចហើយថា នៅក្នុងភូមិខ្លះមានរឿងក្តីជាមធ្យម ៤ ករណីក្នុងមួយឆ្នាំ ដែលសរុបទៅមាន ៥៤.៧៧៦ ករណី ដែលបានដោះស្រាយដោយមេភូមិក្នុងមួយឆ្នាំៗ នៅក្នុងទូទាំងប្រទេស។ រឿងក្តីមួយចំនួនត្រូវបានបញ្ជូនឱ្យទៅក្រុមប្រឹក្សាឃុំ [១៦៨] ។

មេភូមិមានការពាក់ព័ន្ធដោយផ្ទាល់ស្ទើរតែគ្រប់រឿងក្តី ដែលបានកើតឡើងនៅក្នុងភូមិរបស់ខ្លួន។ ប្រសិនបើមេភូមិមិនបានទទួលរឿងក្តីផ្ទាល់ទេ ក្រុមប្រឹក្សាឃុំអាចហៅមេភូមិមកសាកសួរព័ត៌មានបន្ថែម អំពីវិវាទដែលកើតមាននៅក្នុងភូមិរបស់ខ្លួន ឧទាហរណ៍ រឿងក្តីដែលបានទទួលនៅឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ នៅក្នុងឆ្នាំ២០០៣ និង ២០០៤ គឺមានស្ទើរតែគ្រប់រឿងក្តីទាំងអស់ មេភូមិដែលនៅទីនោះមានចូលរួមពាក់ព័ន្ធ : ១៦ ករណី លើ ១៧ករណី ក្នុងឆ្នាំ២០០៣ និង ៣៣ លើ ៣៣ករណី ក្នុងឆ្នាំ ២០០៤ [១៦៩] ។

មេភូមិទទួលខុសត្រូវកាន់តែច្រើន ក្នុងវិវាទដែលមានកើតឡើងនៅមូលដ្ឋាន នៅពេលដែលគូភាគីវិវាទ ឋិតនៅក្នុងស្ថានភាពដូចគ្នា ហើយកម្មវត្ថុនៃរឿងក្តីជារឿងតូចតាច។ នៅក្នុងករណីអំពើហិង្សាខាងយេនឌ័រ ដូចជាអំពើហិង្សាក្នុងគ្រួសារ ឬការបំពានខាងផ្លូវភេទ ក៏ដូចជាការទាមទារលែងលះគ្នា មេភូមិតែងព្យាយាមសម្រុះសម្រួលគូភាគី ប៉ុន្តែប្រសិនបើការសម្រុះសម្រួលបរាជ័យ មេភូមិបញ្ជូនរឿងក្តីនេះ ទៅឱ្យនគរបាល ឬក្រុមប្រឹក្សាឃុំ។ ទាក់ទិននឹងរឿងក្តីព្រហ្មទណ្ឌ មេភូមិព្យាយាមបញ្ជូនរឿងក្តីទាំងនោះទៅនគរបាល រីឯករណីទាក់ទងនឹងវិវាទដីធ្លីធំៗ ឬវិវាទផ្សេងទៀតកើតឡើង រវាងអ្នកភូមិ និងភាគីអ្នកមានអំណាច មេភូមិបានបញ្ជូនរឿងវិវាទនេះឱ្យទៅអាជ្ញាធរឃុំ។

តម្លៃ/ការចំណាយ

ក្នុងការដោះស្រាយវិវាទ មេភូមិមិនបានទទួលប្រាក់ខែ ឬការបណ្តុះបណ្តាលពិសេសណាមួយពីរដ្ឋនោះទេ។ គាត់គ្រាន់តែទទួលបានប្រាក់ឧបត្ថម្ភ ២២.០០០រៀល (៥.៥ ដុល្លារអាមេរិក) ពីក្រសួងមហាផ្ទៃតាមរយៈក្រុមប្រឹក្សាឃុំ ដូចបានរៀបរាប់មកខាងលើរួចមកហើយ។ នៅក្នុងករណីខ្លះ គាត់ធ្វើការប្រជុំសម្រុះសម្រួលនៅក្នុងផ្ទះរបស់គាត់ ហើយចំណាយពេលរបស់គាត់ជាមួយគូភាគីទៅរកក្រុមប្រឹក្សាឃុំ នគរបាល ឬនាំយកដីកាកោះពីឃុំមកឱ្យភាគីនៅក្នុងភូមិថែមទៀត។ ក្នុងករណីខ្លះ ភាគីវិវាទបានជូនសរគុណទៅមេភូមិ សម្រាប់ការជួយដោះស្រាយវិវាទរបស់គាត់។ ជាទូទៅមេភូមិមិនបានទទួលប្រាក់ពីគូភាគីនោះទេ តែគាត់បានទទួលកិត្តិនាមផ្ទាល់ខ្លួនក្នុងសហគមន៍ច្រើនជាង។

មេភូមិមួយចំនួន បានប្រើប្រាស់តួនាទីជាមេភូមិរបស់ខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់ជាប្រយោជន៍ដល់សម្ព័ន្ធភាពនយោបាយរបស់ខ្លួន ដើម្បីឱ្យខ្លួនអាចបន្តនៅកាន់អំណាចតទៅទៀត។

---

១៦៨ មិនទាន់ មានព័ត៌មានច្បាស់លាស់មួយអំពីចំនួនរឿងក្តីដែលមេភូមិបានបញ្ជូនទៅក្រុមប្រឹក្សាឃុំឡើយ។ យោងតាមការសិក្សារបស់ *CAS-AF Survey* គឺមានរឿងក្តីប្រហែលជា ៦០% ទទួលដោយប្រធានភូមិ ត្រូវបានដោះស្រាយចប់នៅថ្នាក់ភូមិ។ យោងតាមការសម្ភាស របស់ក្រុមការងារសិក្សាស្រាវជ្រាវយើងខ្ញុំឃើញថាប្រធានភូមិបញ្ជូនរឿងក្តីភាគច្រើនទៅក្រុមប្រឹក្សាឃុំ ក្នុងចំណោមរឿងក្តីដែលគាត់ទទួល។ ទោះជាយ៉ាងនេះក្តី យើងមិនអាចកំណត់ពីបរិមាណ ឬទិន្នន័យអំពីចំនួននេះបានឡើយ។

១៦៩ សូមមើលតារាងស្តីពីរឿងក្តីនៅថ្នាក់ឃុំ ក្នុងឧបសម្ព័ន្ធ ១-៣។

ការវាយតម្លៃ

ប្រជាពលរដ្ឋយល់ថា មេភូមិគឺជាអាជ្ញាធរដំបូង ដែលពួកគេត្រូវទៅរកក្នុងការដោះស្រាយវិវាទ ឬជាអ្នកដែលមានតួនាទីសម្រាប់ណែនាំដល់ពួកគេ ក្នុងការដោះស្រាយវិវាទ ក្នុងករណីដែលមេភូមិមិនអាចជួយដោះស្រាយបាន។ ដោយសារមេភូមិរស់នៅក្នុងភូមិស្រាប់នោះ អ្នកភូមិអាចមករកដោយងាយស្រួល។ ដូចនេះមិនមានការចំណាយលើការធ្វើដំណើរនោះទេ។ ជាធម្មតាមេភូមិអាចឆ្លើយតបចំពោះសំណូមពរណាមួយ របស់ពលរដ្ឋបានឆាប់រហ័ស ដូចនេះជាលទ្ធផល បញ្ហានានាអាចត្រូវបានដោះស្រាយក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ។ មេភូមិក៏ស្គាល់ប្រជាពលរដ្ឋក្នុងភូមិច្បាស់លាស់ ព្រមទាំងយល់ច្បាស់អំពីវប្បធម៌នៅមូលដ្ឋាន និងប្រវត្តិនៃវិវាទទៀតផង។ ដោយសារគាត់គ្មានអំណាចនឹងសម្រេចដោះស្រាយរឿងក្តី ដូចនេះតួនាទីសំខាន់របស់គាត់ គឺលើកទឹកចិត្តឱ្យមានការសម្រុះសម្រួលរវាងគូភាគី។ នេះគឺជាចំណុចខ្លាំង ហើយក៏ជាចំណុចខ្សោយរបស់គាត់ផងដែរ។ ប្រសិនបើភាគីមួយមិនយល់ព្រម ឬមិនអនុវត្តកិច្ចសន្យា នោះមេភូមិមិនមានសិទ្ធិធ្វើអ្វីទេ។ ក្នុងន័យនេះនៅពេលដែលមានអតុល្យភាពរវាងគូភាគីវិវាទ វាគឺជាការលំបាកដល់ភាគីដែលទន់ខ្សោយ ជាងក្នុងការទទួលបាននូវដំណោះស្រាយមួយ ដែលខ្លួនអាចទទួលយកបាន[១៧០]។ រឿងបែបនេះ អាចកើតមានរវាងភាគីអ្នកក្រីក្រ និងភាគីម្ខាងទៀតជាអ្នកមានទ្រព្យសម្បត្តិ ឬករណីវិវាទរវាងស្ត្រី និងបុរស ក្នុងករណី ទាក់ទងនឹង អំពើហិង្សាខាងយេនឌ័រ។

អ្នកចូលរួមក្នុងសិក្ខាសាលាមួយចំនួន បានរិះគន់ចំពោះការដែលមេភូមិ មិនត្រូវបានគេបោះឆ្នោតជ្រើសរើសនៅពេលដែលក្រុមប្រឹក្សាឃុំត្រូវបានគេបោះឆ្នោតជ្រើសរើសនោះ។ រីឯអ្នកខ្លះទៀតក៏បានទិតៀនថា មេភូមិទទួលតួនាទីនោះយូរពេកដោយគ្មានការផ្លាស់ប្តូរជំនួសសោះ។

## ២.២. អាជ្ញាធរមូលដ្ឋាននៅថ្នាក់ឃុំ

នៅថ្នាក់ឃុំ មានអាជ្ញាធរពីរគឺក្រុមប្រឹក្សាឃុំ និងនគរបាល។ ដូចនេះប្រជាពលរដ្ឋ ទៅរកអាជ្ញាធរទាំងពីរនេះ ដើម្បីឱ្យជួយដោះស្រាយវិវាទ យោងតាមប្រភេទនៃវិវាទ និងយោងទៅតាមកាលៈទេសៈផ្សេងៗទៀត។

### ២.២.១. ក្រុមប្រឹក្សាឃុំៈ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

**ក្របខ័ណ្ឌច្បាប់ៈ** ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ឆ្នាំ២០០១ បានបង្កើតក្រុមប្រឹក្សាឃុំ ឱ្យទៅជាអង្គភាពមួយស្វយ័តនៅក្នុងឃុំនីមួយៗ។ សមាជិករបស់ក្រុមប្រឹក្សានេះត្រូវបានបោះឆ្នោត ក្នុង ៥ឆ្នាំម្តង តាមការបោះឆ្នោតទូទៅ យោងតាមបញ្ជីឈ្មោះបេក្ខជនរបស់គណបក្សនយោបាយ។ ច្បាប់បានផ្តល់ឱ្យក្រុមប្រឹក្សាឃុំ នូវមុខងារក្នុងការ "លើកស្ទួយដល់ការអត់ឱន និងការយោគយល់គ្នា" តែមិនបានរៀបរាប់ពីមុខងារណាមួយ ទាក់ទងនឹងការដោះស្រាយវិវាទទេ។ ទោះជាយ៉ាងនេះក្តី អនុក្រឹត្យស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុម ប្រឹក្សាឃុំ-សង្កាត់ (ឆ្នាំ២០០២) បានផ្តល់សិទ្ធិដល់ក្រុមប្រឹក្សាឃុំក្នុងការ "ផ្សះផ្សាការខ្វែងមតិយោបល់គ្នា ហើយជម្រុញឱ្យមានការយោគយល់ និងការអត់អោនទៅវិញទៅមករវាងប្រជាពលរដ្ឋ"។ ច្បាប់ព្រហ្មទណ្ឌក៏បានផ្តល់មុខងារដល់មេឃុំ ធ្វើជាមន្ត្រីនគរបាលយុត្តិធម៌ដែរ។ ដូចនេះ ក្រុមប្រឹក្សាឃុំបានប្រមូលផ្តុំអំណាចផ្សេងៗ ដូចជា : ក-រដ្ឋបាលមូលដ្ឋាន ការរៀបចំសេវាសាធារណៈនិងការអភិវឌ្ឍ ខ-ត្រួតពិនិត្យសន្តិសុខនិងរបៀបរៀបរយសាធារណៈ យាមល្បាត និង គ-មុខងារលើកស្ទួយដល់ការអត់ឱន និងការសម្រុះសម្រួលរវាងប្រជាពលរដ្ឋ។

[១៧០] តាមការស្ទង់មតិធ្វើឡើងដោយ CAS-AF ក្នុងឆ្នាំ ២០០៥ បានរកឃើញថា (ក្នុងតារាងទី ៧៩ ) "ប្រមាណច្រើនជាង ៤០% នៃវិវាទនៅមូលដ្ឋាន ភាគីទន់ខ្សោយសុខចិត្តចុះចាញ់ភាគីមានអំណាច ឬខ្លាំងជាង"

តារាងស្ដីពីមុខងារខាងផ្លូវច្បាប់របស់ក្រុមប្រឹក្សាឃុំ

| សង្ខេប | ឯកសារ |
|---|---|
| ច្បាប់: លើកតម្កើងការអធ្យាស្រ័យ | **ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ (២០០១)**<br>មាត្រា ៤៣ : ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាល ឃុំ សង្កាត់មានភារកិច្ច :<br>- ធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ<br>- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះ ដំណើរការបានល្អ<br>- លើកទឹកចិត្តឱ្យមានការបង្កើតផាសុខភាព និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ<br>- ការពារ ថែរក្សា បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភ័ណ្ឌជាតិ<br>- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់ អធ្យាស្រ័យគ្នាទៅវិញទៅមក<br>- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ។<br>មាត្រា ២៧ : មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មការនានា ដើម្បីផ្ដល់យោបល់ និងជួយកិច្ចការនានា តាមការចាំបាច់ ។ |
| អនុក្រឹត្យ : ការសម្រុះសម្រួលវិវាទ | **អនុក្រឹត្យស្ដីពី ការធ្វើវិមជ្ឈការអំណាច តួនាទីនិងភារកិច្ច ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ (ឆ្នាំ ២០០២)**<br>មាត្រា ៦១ : ឃុំ សង្កាត់ មានតួនាទី និងមុខងារយ៉ាងទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលក្នុងនោះមានមុខងារ និងតួនាទីជាមូលដ្ឋានគឺ : រក្សាសន្តិសុខនិងសណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ<br>(...)<br>- ផ្សះផ្សាការខ្វែងមតិយោបល់គ្នា ហើយជម្រុញឱ្យមានការយោគយល់ និងការអត់អោនទៅវិញទៅមករវាងប្រជាពលរដ្ឋ<br>- ទទួលរ៉ាប់រងលើកិច្ចការទូទៅបន្ថែមទៀត ដើម្បីបំពេញទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ |
| សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើសំណើ ឬពាក្យបណ្ដឹង | មាត្រា ៣១ : ប្រជាពលរដ្ឋមានសិទ្ធិលើកសំណើ ឬធ្វើការប្ដឹងតវ៉ា ជាលាយល័ក្ខណ៍អក្សរ ឬផ្ទាល់មាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវឆ្លើយតបនឹងសំណើ ឬការប្ដឹងតវ៉ានោះជាកំហិត ។ |

មុខងារធ្វើឱ្យមានការស្រុះស្រួលគ្នារបស់ក្រុមប្រឹក្សាឃុំ ស្របគ្នាជាមួយនឹងប្រពៃណីរបស់ប្រទេសកម្ពុជា ពីយូរណាស់មកហើយ ដែលមេឃុំបានដើរតួនាទីជាអ្នកសម្រុះសម្រួល[១៧១] ។

[១៧១] សូមមើល : Luco (2002) and Hughes (2001).

| | |
|---|---|
| ក្រមព្រហ្មទណ្ឌ ឆស្សវត្សរ៍ ១៩៦០ | មាត្រា ២៣ : ទោសលហុមានពីរយ៉ាងគឺ :<br>- ទោសគុកពី ១ ថ្ងៃ ដល់ ៧ ថ្ងៃ និង/ឬ<br>- ទោសពិន័យពី ១៥ ដល់ ១៥០ រៀល ។<br><br>មាត្រា ៣៨០ : មេឃុំធ្វើជាប្រធានក្រុមប្រឹក្សាញាតិ<br>សន្និបាតដែលមានមេឃុំជាប្រធាន និងមានញាតិមិត្តរបស់មាតាបិតា នៃអនីតិជនមានខាន់ស្លាប្រាំមួយនាក់ជាសមាជិក ដែលតាំងឡើងដើម្បីជ្រើសរើសជនណាម្នាក់ឱ្យធ្វើជាអាណាព្យាបាលលើអនីតិជននោះ ដើម្បីដកហូតអំណាចមេបាពីជនអ្នកព្យាបាល លែងឱ្យព្យាបាលតទៅទៀត ដើម្បីត្រួតពិនិត្យកិច្ចការរបស់អ្នកព្យាបាល ឬដើម្បីអនុញ្ញាតឱ្យអ្នកព្យាបាលធ្វើកិច្ចការអ្វីមួយជាប្រយោជន៍ដល់ព្យាបាលិក |
| រាជក្រិត្យ ឆ្នាំ១៩៦២ | មាត្រា ២ : ចៅក្រមនៃសាលាលហុ កាលបានទទួលកំណត់ហេតុ ដែលបានពិនិត្យបទល្មើសលហុហើយ ត្រូវឱ្យដំណឹងទៅអ្នកល្មើសជាលហុនោះ តាមសំបុត្រអនុសិដ្ឋថា ឱ្យអ្នកមកបង់តាមស្ម័គ្រចិត្តនូវពិន័យសមាសភាពជាប្រាក់មានចំនួន ដូចដែលចៅក្រមនេះបានកំណត់ក្នុងព្រំដែន ដែលមានសំដែងក្នុងមាត្រា ៤៤ នៃក្រមព្រហ្មទណ្ឌ ។<br><br>មាត្រា ៧ : នៅគ្រប់បទទាំងអស់ អំពើល្មើសជាលហុអាចនាំឱ្យបង់ភ្លាមៗនូវពិន័យសរុប នឹងភ្ជាក់ងារធ្វើកំណត់ហេតុនោះបាន ។<br><br>មាត្រា ១១ : ច្បាប់ទាំងឡាយជាធរមាន ដែលជូនអំណាចដល់អ្នករាជការរដ្ឋបាល ឱ្យសម្រុះសម្រួលលើបណ្ដឹងអាជ្ញានោះមិនមានកែប្រែទេ ។ |
| ក្រមនីតិវិធី រដ្ឋប្បវេណីឆ្នាំ ១៩៦៣ | មាត្រា ៤២៤ : ចំពោះអាណាព្យាបាលដែលមិនស្មោះត្រង់ គ្មានសមត្ថភាព ឬក៏មានគំនិតមាយាទអាក្រក់ ឬប្រាសចាកលោកចរិយា នោះក្រុមប្រឹក្សាញាតិអាចនឹងដកពីទីអាណាព្យាបាលចេញ ក្រោយពីបានសេចក្ដីយល់ព្រមពីចាងហ្វាងសាលាដំបូងក៏បាន ឬតុលាការអាចនឹងដកចេញដោយចិត្តឯងក៏បាន ។<br><br>មាត្រា ៤៣៨ : បើក្រុមប្រឹក្សាញាតិដែលមានមេឃុំជាអធិបតី ជំនុំព្រមបើកឱ្យកូនអនីតិភាពបានអគ្គាធិនភាព ហើយកំណត់ហេតុនៃការជំនុំដែលមេឃុំចុះហត្ថលេខាដែរនោះមានតម្លៃ ដូចជាសំបុត្របញ្ជាក់ដែរ ។<br>អាស្រ័យហេតុនេះ មេឃុំត្រូវចំលងសេចក្ដីជំនុំនេះដាក់ក្នុងសៀវភៅនៃសំបុត្របញ្ជាក់ ហើយត្រូវចំលងជាបីច្បាប់ដូចគ្នា គឺឱ្យអាណាព្យាបាលមួយច្បាប់ ឱ្យកូនអនីតិភាពមួយច្បាប់ជូនទៅសមុហបញ្ជីសាលាដំបូងមួយច្បាប់ ។ ចំណែកឯកំណត់ហេតុដើម ត្រូវទុកនៅបណ្ណសារដ្ឋាន នៃសាលាឃុំ ។<br><br>មាត្រា ៤៦៩ : ទណ្ឌិតអាចរើសបានជនណាម្នាក់ ដែលខ្លួនចង់ឱ្យធ្វើជាអាណាព្យាបាល លើទ្រព្យរបស់ខ្លួនក្នុងវេលាដែលខ្លួនជាប់ទោសបាន ។<br><br>មាត្រា ៤៧០ : បើទណ្ឌិតមិនបានរើសអ្នកព្យាបាលទេ អាជ្ញាធរឃុំត្រូវចាត់តាំងអាណាព្យាបាលឱ្យ ។ |

បន្ទាប់ពីរបប ប៉ុល ពត នៅក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក៏ដូចជាក្នុងសម័យនៃរបបរដ្ឋកម្ពុជា មុខងារសម្រុះសម្រួលវិវាទនៅថ្នាក់ឃុំ ត្រូវបានដាក់អនុវត្តឡើងវិញ ស្របតាមសេចក្តីណែនាំ ឆ្នាំ ១៩៨៣ ស្តីពីមុខងារយុត្តិធម៌នៅថ្នាក់ស្រុក ឃុំ និងថ្នាក់ប្រហាក់ប្រហែល ។

មូលដ្ឋានច្បាប់:

**សារាចរណ៍ណែនាំ ស្តីពីការងារយុត្តិធម៌ស្រុក ឃុំ និងថ្នាក់ប្រហាក់ប្រហែល (២៤ កញ្ញា ១៩៨៣)**

យោងតាមច្បាប់ព្រមជាមួយនឹងការងាររដ្ឋបាល គណៈកម្មាធិការប្រជាពលរដ្ឋបដិវត្តឃុំ ឬ ថ្នាក់ប្រហាក់ប្រហែល មានភារកិច្ចនិងសិទ្ធិក្នុងការងារយុត្តិធម៌ដូចខាងក្រោមនេះ :

១- ផ្សះផ្សារឿងទំនាស់រវាងប្រជាជន និងប្រជាជន ឬបណ្តារឿងទំនាស់មានលក្ខណៈរដ្ឋប្បវេណីរវាងប្រជាជន និងបណ្តាអង្គការនានា ដើម្បីឱ្យគូភាគីស្រុះស្រួលនឹងគ្នារាប់អានគ្នាដូចដើមឡើងវិញ រក្សាសាមគ្គីភាព ឯកភាពក្នុងជួរប្រជាជនបានល្អប្រពៃ។

- ការបើផ្សះផ្សាច្រើន ដងនិងអស់សមត្ថភាពហើយ ប៉ុន្តែនៅតែមិនបានសម្រេចនោះ គណៈកម្មាធិការប្រជាជនឃុំ ត្រូវធ្វើរបាយការណ៍វាយតម្លៃអំពីមូលហេតុនៃការមិនបានសម្រេច រួចបញ្ជូនសំណុំរឿងទៅគណៈកម្មាធិការប្រជាជនបដិវត្តថ្នាក់លើ។
- ចំពោះការផ្សះផ្សាសុំលែងប្តី ឬ ប្រពន្ធ គណៈកម្មាធិការប្រជាជនបដិវត្តឃុំ ឬ ថ្នាក់ប្រហាក់ប្រហែលត្រូវសហការជាមួយបណ្តាអង្គការមហាជនបដិវត្ត ខិតខំបញ្ចុះបញ្ចូលសម្រុះសម្រួលឱ្យប្តីប្រពន្ធសុខចិត្តរួមរស់ជាមួយគ្នាដូចដើមវិញ ហើយគ្មានសិទ្ធិសម្រេចឱ្យលែងលះគ្នាទេ ទោះបីគូភាគីស្ម័គ្រចិត្តលែងលះគ្នាយ៉ាងណាក៏ដោយ ។
- ចំពោះបទល្មើសមួយចំនួនមានលក្ខណៈតូចតាច ហើយជាអំពើល្មើសលើកដំបូង ដូចជា លួចបេះបន្លែ ផ្លែឈើបន្តិចបន្តួច លួចមាន់មួយក្បាល ឬ បំពារបំពានលើរូបរាងកាយមិនបណ្តាលឱ្យមានរបួសធ្ងន់ធ្ងរ ។ល។ គណៈកម្មាធិការប្រជាជនបដិវត្តឃុំ ឬ សង្កាត់ ត្រូវអប់រំប្រៀនប្រដៅឱ្យជនល្មើសមានការភ្ញាក់រលឹក ទទួលសងការខូចខាតឱ្យអ្នកដែលត្រូវរងគ្រោះ។ បើគូភាគីនៅតែមិនសុខចិត្តត្រូវធ្វើរបាយការណ៍បញ្ជូនសំណុំរឿងទៅថ្នាក់លើ ដូចបានអធិប្បាយរួចហើយ ។

២- ឃោសនា អប់រំបំផុសមហាជន ឱ្យយល់អំពីគោលនយោបាយរបស់បក្ស និងច្បាប់របស់រដ្ឋ។ បើប្រជាជនបានយល់ហើយ អនុវត្តបានល្អនូវគោលនយោបាយរបស់បក្ស និងច្បាប់របស់រដ្ឋ នោះរឿងវិវាទក្នុងជួរប្រជាជនប្រាកដជាថយចុះជាលំដាប់ ហើយប្រជាជនក៏មានពេលវេលាបំពេញភារកិច្ចកសាង និងការពារមាតុភូមិបានល្អប្រសើរដែល។ ដូច្នេះអនុវត្តបានដូចពាក្យស្លោកថា: "ការពារប្រសើរជាងព្យាបាល" ។

៣- អនុវត្ត និងផ្សព្វផ្សាយក្នុងមូលដ្ឋានរបស់ខ្លួន នូវបណ្តាអត្ថបទច្បាប់អត្ថបទក្រោមច្បាប់សារាចរ ។ល។ របស់ស្ថាប័នយុត្តិធម៌ថ្នាក់លើ ។

៤- យកលិខិតអញ្ជើញ និងលិខិតផ្សេងៗរបស់អង្គការតុលាការ និងអយ្យការ ឬគណៈកម្មាធិការប្រជាជនបដិវត្តស្រុកទៅប្រគល់ឱ្យសាមីខ្លួនឱ្យទាន់ពេលវេលា។

៥- អនុវត្តក្រើនរំលឹកការអនុវត្តបណ្តាសេចក្តីសម្រេចរបស់បណ្តាសាលក្រមស្ថាពរ ដែលស្តីពីសំណងជម្ងឺចិត្ត និងប្រាក់ពិន័យ ឬសហការ ជាមួយកម្មាភិបាលតុលាការប្រជាជនក្នុងការបំពេញភារកិច្ចនេះ។ ប្រាក់ដែលប្រមូលបានទាំងនោះត្រូវបញ្ជូនទៅតុលាការប្រជាជនដែលចេញសាលក្រម ។

៦- នៅពេលដែលមានបញ្ជារបស់ថ្នាក់លើ ស្តីពីការឆែកឆេរលំនៅស្ថាន ឬចាប់ខ្លួនជនល្មើសត្រូវគោរពតាមបញ្ជានោះយ៉ាងម៉ឺងម៉ាត់។

ក្របខ័ណ្ឌស្ថាប័ន

មានក្រុមប្រឹក្សាឃុំនៅគ្រប់ឃុំទាំងអស់ ដែលសរុបទៅមាន ១.៦២១ ក្រុមប្រឹក្សា។ ក្រុមប្រឹក្សានីមួយៗមានប្រធានក្រុមប្រឹក្សា និងមានសមាជិកក្រុមប្រឹក្សាពី ៥ ទៅ ១១ នាក់ អាស្រ័យតាមទំហំនៃឃុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសតាំងនៅក្នុងឆ្នាំ ២០០២ ចេញមកពីគណបក្សនយោបាយចំនួនបី។ ភាគច្រើនគឺជា បុរស មានតែ ៩%ប៉ុណ្ណោះជាស្ត្រី [១៧២]។ សមាជិកក្រុមប្រឹក្សាទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែប្រហែល ពី ១៧.៥ ទៅ ២៥ ដុល្លារអាមេរិក។ ក្រុមប្រឹក្សាឃុំទទួលបានថវិកាសម្រាប់គម្រោងអភិវឌ្ឍន៍ និងសម្រាប់ការចំណាយរដ្ឋបាល។ ពួកគេមិនមានថវិកាពិសេសណាមួយសម្រាប់បញ្ហាដោះស្រាយវិវាទនោះទេ។

តារាងស្តីពី "ប្រាក់បៀវត្សន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រាក់ឧបត្ថម្ភមេភូមិ" [១៧៣]

| តួនាទី | ប្រចាំខែ | | ប្រចាំឆ្នាំ | |
|---|---|---|---|---|
| | រៀល | ដុល្លារអាមេរិក | រៀល | ដុល្លារអាមេរិក |
| ប្រធានក្រុមប្រឹក្សាឃុំ | ១០០.០០០ | ២៥.០ | ១.២០០.០០០ | ៣០០.០ |
| អនុប្រធានក្រុមប្រឹក្សាឃុំ (២នាក់) | ៨០.០០០ | ២០.០ | ៩៦០.០០០ | ២៤០.០ |
| សមាជិកក្រុមប្រឹក្សាឃុំ | ៧០.០០០ | ១៧.៥ | ៨៤០.០០០ | ២១០.០ |
| មេភូមិ | ២២.០០០ | ៥.៥ | ២៦៤.០០០ | ៦៦.០ |

ចំពោះកម្រិតវប្បធម៌របស់សមាជិកក្រុមប្រឹក្សាវិញ គឺភាគច្រើនជាអ្នកដែលចេះអាននិងសរសេរ។ តែសមាជិកក្រុមប្រឹក្សាទាំងនេះពុំមានបទពិសោធន៍ ឬទទួលការបណ្តុះបណ្តាលស្តីពីជំនាញក្នុងការដោះស្រាយវិវាទឡើយ លើកលែងតែអ្នកដែលធ្លាប់ជាមេឃុំ ឬអនុប្រធានឃុំ ឬជាមេភូមិ នៅក្នុងសម័យមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំឆ្នាំ ២០០២។ ឆ្នាំកន្លងមកថ្មីៗនេះ មានអង្គការជាច្រើនដែលធ្វើការជាមួយក្រុមប្រឹក្សាឃុំ ដើម្បីកសាងសមត្ថភាពដើម្បីជួយដល់ការដោះស្រាយវិវាទនានានៅមូលដ្ឋាន។

## ២.២.២. តម្រូវការយុត្តិធម៌ដែលបានប្តឹងទៅអាជ្ញាធរមូលដ្ឋាន

សម្រាប់ប្រជាពលរដ្ឋដែលនៅតាមជនបទដាច់ស្រយាល អាជ្ញាធរទីមួយដែលជួយដល់ពួកគេក្នុងការដោះស្រាយវិវាទគឺមេភូមិ និងបន្ទាប់មកគឺក្រុមប្រឹក្សាឃុំ។

បញ្ហារឿងក្តី:

ដោយយោលទៅលើរឿងក្តីដែលបានសង្កេត តម្រូវការយុត្តិធម៌ជាក់ស្តែងនៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធទៅនឹងរឿងរ៉ាវដែលមានដូចខាងក្រោមនេះ។

---

១៧២ ក្រសួងកិច្ចការនារី

១៧៣ ប្រភព : កម្មវិធីសីលា (SEILA): ព័ត៌មានស្តីពីមូលនិធិនិងថវិកាឃុំ សង្កាត់ សម្រាប់ឆ្នាំ ២០០៥។

| បញ្ហារឿងក្តី |
|---|
| ១. អំពើហិង្សាក្នុងគ្រួសារ និងការលែងលះ |
| ២. វិវាទដីធ្លី |
| ៣. ជម្លោះក្នុងគ្រួសារ និងរវាងអ្នកជិតខាង និងការបរិហាកេរ្តិ៍ |
| ៤. វិវាទតូចតាចទាក់ទិននឹងសត្វស៊ីដំណាំអ្នកដទៃ ការខូចខាតផ្សេងៗ ការប្រើប្រាស់អណ្តូងឬស្រះសាធារណៈ |
| ៥. បំណុល និងរឿងក្តីរដ្ឋប្បវេណីផ្សេងទៀត |
| ៦. រំលោភសេពសន្ថវៈ បង្ករបួសស្នាម ប្លន់ បងតូចបងធំ និងរឿងក្តីព្រហ្មទណ្ឌផ្សេងទៀត |

ទំហំការងារ:

- ឃុំនីមួយៗដែលយើងបានទៅដល់ ទទួលបាន ២០ ទៅ ៣០ រឿងក្តីក្នុងមួយឆ្នាំ។ នេះបើគិតជាមធ្យមគឺមានប្រហែល ២៥រឿងក្តី សម្រាប់ឃុំមួយៗក្នុងមួយឆ្នាំ។ ការនេះបង្ហាញពីចំនួននៃរឿងក្តីប្រមាណ ៤០.៥២៥ រឿងក្តីក្នុងមួយឆ្នាំៗ ដែលត្រូវបានប្តឹងនៅថ្នាក់ឃុំ (១៦២១ គុណនឹង ២៥ = ៤០.៥២៥)។ មធ្យមភាគក្នុងខេត្តនីមួយៗគឺមាន ១៦៨៨.៥ រឿងក្តី។
- **ក្នុងមួយឆ្នាំៗចំនួនរឿងក្តីកើតឡើងជាលំដាប់:** តួលេខនេះតំណាងឱ្យរឿងក្តីទាំងឡាយ ដែលបានចុះបញ្ជីប្រហែលជាតួលេខពិតប្រាកដនៃចំនួនរឿងក្តីដែលបានទទួល និងដោះស្រាយដោយឃុំមានចំនួនខ្ពស់ជាងនេះ។
- ចំនួនរឿងក្តី ២៥ ករណីជាមធ្យមដែលបានដោះស្រាយដោយឃុំនេះ មានលក្ខណៈស៊ីគ្នាជាមួយនឹងលទ្ធផលនៃការសិក្សារបស់អង្គការមូលនិធិអាស៊ី [១៧៤] ស្តីពីការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន។

**តារាង: ស្ថិតិរឿងក្តីទទួលបានពីឃុំចំនួន ៤ នៅក្នុងខេត្ត ៤ ផ្សេងៗពីគ្នា[១៧៥]**

| ឈ្មោះ ឃុំ | ឆ្នាំ | ប្រភេទលាច់រឿងវិវាទ/ភាគរយ (%) |
|---|---|---|
| **ឃុំខ្នងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង** ២០០២ | (គំរូរឿងក្តី ចំនួន ១១) | - លែងលះ ........ ៤/១១ = ៣៦.៣៦%<br>- អំពើហិង្សាក្នុងគ្រួសារ ........ ២/១១ = ១៨.១៨%<br>- វិវាទដីធ្លី ........ ៣/១១ = ២៧.២៧%<br>- បរិហាកេរ្តិ៍ ........ ២/១១ = ១៨.១៨% |
| | ២០០៣ (គំរូរឿងក្តី ចំនួន ១១) | - រំលោភសេន្ថវៈ ........ ៤/១១ = ៣៦.៣%<br>- លែងលះ ........ ៣/១១ = ២៧.៣%<br>- បរិហាកេរ្តិ៍ និងជេរគ្នា ........ ២/១១ = ១៨.២%<br>- ជម្លោះរឿងផ្តាច់ពាក្យ ........ ១/១១ = ៩.១ %<br>- ទំនាស់រឿងប្រើប្រាស់អណ្តូងសាធារណៈ ១/១១ = ៩.១ % |
| | ២០០៤ (គំរូរឿងក្តី ចំនួន ៧) | - លែងលះ ........ ២/៧ = ២៨ %<br>- បរិហាកេរ្តិ៍ ........ ១/៧ = ១៤ %<br>- វិវាទរវាងប្តីប្រពន្ធ .... ........ ២/៧ = ២៨ %<br>- វិវាទដីធ្លី ........ ១/៧ = ១៤ %<br>- វិវាទលើផ្លូវចូលផ្ទះ ........ ១/៧ = ១៤ % |

---

[១៧៤] ការស្ទង់មតិរបស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវជាន់ខ្ពស់ (Center for Advanced Study) (2005): *Public Opinion Poll on the role and performance of commune councils, especially regarding local conflicts. Survey Report for Asia Foundation*. Phnom Penh: Asia Foundation, Table 78. (*CAS-AF Survey*). ការស្ទង់មតិនេះ មានសារៈសំខាន់ ក្នុងការវាយតម្លៃអំពីការបំពេញមុខងាររបស់ក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយវិវាទ។

[១៧៥] សូមមើលករណីវិវាទទាំងឡាយដែលបានដោះស្រាយនៅថ្នាក់ឃុំនៅខេត្តកំពង់ធំ កំពង់ឆ្នាំង និងកំពង់ស្ពឺ ដូចមានរៀបរាប់ នៅក្នុងឧបសម្ព័ន្ធទី ២។

| | | |
|---|---|---|
| **ឃុំមហាឬស្សី-<br>ស្រុកគងពិសី<br>ខេត្តកំពង់ស្ពឺ** | ២០០៣<br>(តំរូវរឿងក្តី<br>ចំនួន ១៧) | - លែងលះ ...................................... ៧/១៧ = ៤២%<br>- អំពើហិង្សាក្នុងគ្រួសារ ...................... ២/១៧ = ១១%<br>- វិវាទដីធ្លី ........................................ ៤/១៧ = ២៣%<br>- បរិហាកេរ្តិ៍ ...................................... ២/១៧ = ១១%<br>- បំណុល .......................................... ១/១៧ = ៦ %<br>- ចោទបទរំលោភសេពសន្ថវៈ .............. ១/១៧ = ៦ % |
| | ២០០៤<br>(ពេញមួយ<br>ឆ្នាំ) | - លែងលះ ...................................... ១/៣៣ = ៣%<br>- អំពើហិង្សាក្នុងគ្រួសារ ...................... ១៣/៣៣ = ៤០%<br>- បរិហាកេរ្តិ៍ ...................................... ៣/៣៣ = ១០%<br>- បំណុល .......................................... ៤/៣៣ = ១៣ %<br>- វិវាទដីធ្លី ........................................ ៥/៣៣ = ១៥%<br>- វិវាទអ្នកជិតខាង ........................... ៥/៣៣ = ១៥%<br>- បៀតបៀនកេរ្តិ៍ខ្មាស ........................ ១/៣៣ = ៣ % |
| | | |
| **ឃុំតាំងក្រសាំង<br>ស្រុកសន្ទុក<br>ខេត្តកំពង់ធំ** | ២០០៤ (ខែ<br>កក្កដា<br>សីហា កញ្ញា<br>និង វិច្ឆិកា<br>ឆ្នាំ ២០០៤) | - វិវាទដីធ្លី ........................................ ៣/៩ = ៣៤%<br>- លែងលះ ...................................... ២/៩ = ២២%<br>- វិវាទរវាងប្តីប្រពន្ធ ......................... ២/៩ = ២២%<br>- វិវាទផ្សេងទៀត (ច្រកចេញចូលសាធារណៈ ឬ<br>បំផ្លាញសម្បត្តិអ្នកដទៃ) .................. ២/៩ = ២២% |
| | | |
| **ឃុំកូនក្រៀល<br>ស្រុកសំរោង<br>ខេត្តឧត្តរមានជ័យ**<br>(CPMHRV) | ២០០៣ | សរុប : ១៣ ករណី |
| | ២០០៤ | សរុប : ២០ ករណី |
| | មករា<br>-<br>មិនា ២០០៥<br>(សរុប : ៨<br>ករណី) | - វិវាទដីស្រែ ..................................... ៣/៨ = ៣៧.៥%<br>- ហិង្សាក្នុងគ្រួសារ (ជម្លោះប្តីប្រពន្ធ ១, លែងលះ ១ ,<br>ហិង្សាក្នុងគ្រួសារ ១) ......................... ៣/៨ = ៣៧.៥%<br>- បំណុល .......................................... ១/៨ = ១២.៥%<br>- បង្ករបួសស្នាម ................................ ១/៨ = ១២.៥% |

### ២.២.៣. សមត្ថភាពការងារ

យោងតាមតារាងខាងលើនេះយើងអាចមើលឃើញថា រឿងក្តីភាគច្រើនត្រូវបានដោះស្រាយដោយអាជ្ញាធរ នៅថ្នាក់ឃុំ ។ ផ្អែកលើទិន្នន័យនេះ (ចំនួនរឿងក្តីដែលបានចុះបញ្ជី កំណត់ហេតុ នៃការសម្រុះសម្រួល និងកិច្ចព្រមព្រៀងរវាងគូភាគី) មើលទៅហាក់បីដូចជា យ៉ាងហោចណាស់មួយភាគបីនៃរឿងក្តី ត្រូវបានដោះស្រាយដោយគូភាគីទាំងសងខាងបានឯកភាពគ្នា[១៧៦] ។ ទោះជាយ៉ាងនេះក្តី កម្រិតនៃការពេញចិត្តចំពោះដំណោះស្រាយទាំងនោះ គឺវាអាស្រ័យលើកត្តាជាច្រើនផ្សេងៗទៀត ។ លទ្ធផលនេះ

[១៧៦] សូមមើលតារាងតារាងរឿងក្តីដែលបានដោះស្រាយនៅថ្នាក់ឃុំ ក្នុងឧបសម្ព័ន្ធទី ២ ។

គឺស្របទៅនឹងការរកឃើញនៃការសិក្សាផ្សេងៗទៀត [១៧៧]។

បញ្ហារឿងក្តី

យោងតាមរឿងក្តីទាំងឡាយដែលបានទទួលនៅក្នុងខេត្តទាំង ៤ ចាប់ពីឆ្នាំ ២០០២ រហូតដល់ដើមឆ្នាំ ២០០៥ វិវាទភាគច្រើនដែលត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាឃុំ មានទាក់ទងនឹងបញ្ហា :

ក- អំពើហិង្សាខាងយេនឌ័រ : ស្ទើរតែពាក់កណ្តាល (៤៨%) ដែលរួមមានអំពើហិង្សាក្នុងគ្រួសារ (២៣%) ការលែងលះ (១៩%) និងការរំលោភសេពសន្ថវៈ (៦%)។

ខ- វិវាទដីធ្លី : មួយភាគបួននៃរឿងក្តីទាំងអស់ ២៥% និង

គ- វិវាទនៅមូលដ្ឋានផ្សេងៗនិងបទល្មើសតូចតាចប្រហែលជា ២៧%។ វិវាទនៅមូលដ្ឋានរួមមាន ជម្លោះរវាងអ្នកជិតខាង ជម្លោះក្នុងគ្រួសារ និងការបរិហារកេរ្តិ៍ (១០%) បំណុល (៨%) វិវាទទាក់ទងនឹងការប្រើប្រាស់ស្រះ ប្រកចូលរួមគ្នា អណ្តូង ។ល។ និងការបង្ករបួសស្នាម (៣%)។

យោងតាមការសិក្សាលើរាល់ករណី ដែលត្រូវបានសម្រុះសម្រួលនៅថ្នាក់ឃុំ ក្នុងខេត្តទាំងបួននេះ គួរកត់សំគាល់ថា ពុំមានរឿងក្តីណាមួយដែលពាក់ព័ន្ធនិងបទល្មើសឧក្រិដ្ឋ ឬករណីមនុស្សឃាត ត្រូវបានសម្រុះសម្រួលដោះស្រាយដោយថ្នាក់ឃុំទេ។ តាមការសម្ភាសន៍ ក្រុមប្រឹក្សាឃុំក៏លើកឡើងផងដែរអំពីបទល្មើសមជ្ឈិមមួយចំនួន។

អំពើហិង្សាក្នុងគ្រួសារ ត្រូវបានគេកត់សំគាល់ថាជាបញ្ហាធំបំផុតនៃរឿងក្តី ដែលត្រូវសហគមន៍ចាត់ទុកថាជាមូលហេតុដែលអាចឈានទៅដល់ករណី "លែងលះ"។ ការដាក់ពាក្យសុំលែងលះអាចនាំឱ្យមានការសម្រុះសម្រួល។ បណ្តឹងទាក់ទិននឹងអំពើហិង្សាក្នុងគ្រួសារមួយចំនួនអាចក្លាយជាបណ្តឹងលែងលះគ្នា។ ច្បាស់ណាស់ថាបណ្តឹងច្រើនជាង ៤០% ដែលប្តឹងទៅក្រុមប្រឹក្សាឃុំ ពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ និងអាចពាក់ព័ន្ធនឹងការទាមទារសុំផ្តាច់សង្វាស ឬជាការលែងលះ។

**តារាង: សរុបរឿងក្តីដែលបានទទួលដោយក្រុមប្រឹក្សាឃុំ (គំរូ : ឃុំ ៤ នៅក្នុងខេត្តចំនួន ៤)** [១៧៨]

| កម្មវត្ថុនៃរឿងក្តី | ជាមធ្យម | សរុប |
|---|---|---|
| **អំពើហិង្សាខាងយេនឌ័រ** | | **៤៨%** |
| អំពើហិង្សាក្នុងគ្រួសារ | ២៣% | |
| ការលែងលះ | ១៩% | |
| ការរំលោភសេពសន្ថវៈ | ៦% | |
| **វិវាទដីធ្លី** | ២៥% | **២៥%** |
| **វិវាទនៅមូលដ្ឋានផ្សេងទៀត** | | **២៧%** |
| ការបរិហាកេរ្តិ៍និងជេរប្រមាថ ជម្លោះរវាងអ្នកជិតខាង វិវាទក្នុងគ្រួសារ | ១០% | |
| បំណុល | ៨% | |
| ការប្រើប្រាស់អណ្តូង ប្រកចេញចូលសាធារណៈ ។ល។ | ៦% | |
| ការបង្ករបួសស្នាម និងរឿងផ្សេងៗទៀត | ៣% | |
| សរុប | ១០០% | ១០០% |

១៧៧ សូមមើលលទ្ធផលស្ទង់មតិរបស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវជាន់ខ្ពស់: CAS-AF Survey (2005): Table 100 "*75% of all conflicts for which mediation is sought are solved.*"

១៧៨ សូមមើលតារាងរឿងវិវាទដែលសម្រុះសម្រួលនៅថ្នាក់ឃុំ នៅក្នុងឧបសម្ព័ន្ធ ២ ។

រឿងក្តីដែលបានទទួលដោយឃុំទាំងនេះ មានភាពស្របគ្នាជាមួយនឹងលទ្ធផលស្ទង់មតិរបស់ IRL ដែលបានសួរពីទស្សនាទានរបស់ប្រជាពលរដ្ឋចំពោះអាជ្ញាធរមូលដ្ឋាន និងអំពីវិវាទដែលបានដោះស្រាយដោយពួកគេ ( ហៅថា "ប្រព័ន្ធក្រៅផ្លូវការ" ) ។

**តារាង៖ រឿងក្តីច្រើនជាងគេទាំង ៥ ទទួលដោះស្រាយដោយ *ប្រព័ន្ធក្រៅផ្លូវការ* តាមការយល់ឃើញរបស់អាជ្ញាធរឃុំ**

ទស្សនៈស្តីពីការប្រើប្រាស់ *ប្រព័ន្ធក្រៅផ្លូវការ* ( អាជ្ញាធរសហគមន៍) ដោយអាជ្ញាធរឃុំ

សំណួរ : រឿងក្តីច្រើនជាងគេទាំង ៥




ការស្ទង់មតិ IRL ទំព័រទី ២៧

ការប្រៀបធៀបនៃបញ្ជីរឿងក្តី ដែលបានទទួលដោយក្រុមប្រឹក្សាឃុំ ជាមួយនឹងវិវាទដែលគេត្រូវបានរាយការណ៍នៅថ្នាក់មូលដ្ឋានក្នុង *ការស្ទង់មតិរបស់* CAS-AF បានបង្ហាញអំពីភាពស្រដៀងគ្នា ប៉ុន្តែក៏មានភាពខុសគ្នាគួរឱ្យកត់សំគាល់ផងដែរ: ក-នៅក្នុងការស្ទង់មតិរបស់ CAS-AF អ្នកត្រូវគេសម្ភាសបាននិយាយទៅដល់ការកើតមានឡើង នូវរឿងក្តីព្រហ្មទណ្ឌ ដូចជាអំពើឃាតកម្ម ការចាប់ជម្រិត និងបញ្ហាបងតូចបងធំជាដើម ។ រឿងក្តីទាំងនោះ មិនត្រូវបានដោះស្រាយដោយឃុំទាំងឡាយដែលក្រុមការស្រាវជ្រាវសម្រាប់ការសិក្សានេះ បានទៅសិក្សាឡើយ ។ ក្រុមប្រឹក្សាឃុំមិនដោះស្រាយបទល្មើសឧក្រិដ្ឋទេ ប្រហែលជាករណីទាំងនេះ ត្រូវបានបញ្ជូនឱ្យទៅនគរបាល ។ តែទោះជាយ៉ាងនេះក្តី នៅក្នុងខេត្តមណ្ឌលគីរី ក្រុមប្រឹក្សាឃុំមួយដែលយើងបានទៅដល់ (សមាជិកទាំងអស់ជាជនជាតិដើមភាគតិច) បានទទួលដោះស្រាយរឿងក្តីបងតូចបងធំផងដែរ[១៧៩] ខ-នៅក្នុងការស្ទង់មតិរបស់ CAS-AF រឿងក្តីដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារមានចំនួន ១៩% នៃរឿងក្តីទាំងអស់ដែលមាននៅថ្នាក់មូលដ្ឋាន ។ តែគេមិនបានលើកឡើងអំពីការផ្តាច់សង្វាស ឬរឿងក្តីលែងលះទេ ។ តាមការអនុវត្តជាក់ស្តែង ក្រុមប្រឹក្សាឃុំដោះស្រាយវិវាទក្នុងភាគរយ ស្រដៀងគ្នានេះដែរ ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ( ប្រហែល ២៣%) បូកនិងការទាមទារសុំលែងលះ ២០% បន្ថែមទៀត ដែលកើតចេញពីអំពើហិង្សាក្នុងគ្រួសារផងដែរ ។ ឃុំដែលយើងបានសម្ភាស យល់ថារឿងក្តីអំពើហិង្សាក្នុងគ្រួសារ និងការលែងលះ គឺជាបន្ទុកយ៉ាងធំសម្រាប់ពួកគេ ( ប្រហែល ៤៣% នៃរឿងក្តីទាំងអស់) ។

ទាក់ទងនឹងវិវាទដីធ្លី ចាំបាច់ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់ ។ យោងតាមការស្ទង់មតិរបស់ CAS-AF វិវាទដីធ្លីមានដល់ ៣១% នៃរឿងក្តីទាំងអស់ ដែលក្នុងនោះរួមមានវិវាទដីធ្លីតូចតាច (២១%) និងរឿងវិវាទដីធ្លីធំៗ (១០%) ។ នៅក្នុងឃុំដែលយើងបានសម្ភាស រឿងក្តីដីធ្លីមាន ២៥% នៃរឿងក្តីទាំងអស់ដែលបានដោះស្រាយដោយពួកគេ ។ វាជារឿងសំខាន់ក្នុងការកត់សំគាល់ឃើញថា មានតែវិវាទដីធ្លីតូចតាចប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយនៅមូលដ្ឋាន ។ វិវាទដីធ្លីធំៗត្រូវបានគេបញ្ជូនទៅគណៈកម្មការសុរិយោដី ឬអាជ្ញាធរផ្សេងទៀត ។ វាក៏ដូចគ្នានេះដែរចំពោះ វិវាទដីធ្លីតូចតាចមួយចំនួន ពេលដែលគូភាគីមិនអាចឈានដល់ការព្រមព្រៀងគ្នានោះ ។

[១៧៩] ក្រុមប្រឹក្សាឃុំបានពន្យល់ប្រាប់ក្រុមការងារយើងថា ពួកគេព្យាយាមសម្រុះសម្រួលគ្រប់រឿងក្តីទាំងអស់នៅមូលដ្ឋាន ដោយសហការជាមួយនគរបាល រួមទាំងរឿងក្តីពាក់ព័ន្ធនឹងក្រុមបងធំ "ដើម្បីបញ្ចៀសកុំឱ្យជនល្មើសជាយុវជនជាប់ក្នុងពន្ធនាគារ"

## តារាងស្តីពីវិវាទកើតមានច្រើនជាងគេនៅថ្នាក់មូលដ្ឋានដែលគេបានរៀបរាប់

*របាយការណ៍ស្ទង់មតិរបស់មូលនិធិអាស៊ី* ឆ្នាំ ២០០៥ : តារាងទី ៧២

មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ( CAS ) : *ការធ្វើស្ទង់មតិអំពីសាធារណៈ ស្តីពីតួនាទី និងលទ្ធផលអនុវត្តរបស់ក្រុមប្រឹក្សាឃុំ ជាពិសេស ទាក់ទងនឹងការដោះស្រាយវិវាទនៅតាមមូលដ្ឋាន ។*

- ២៩%នៃអ្នកបោះឆ្នោតជាអ្នកធ្លាប់មានបទពិសោធន៍ផ្ទាល់ខ្លួនជាមួយការផ្សះផ្សា
- វិវាទរវាងអ្នកជិតខាង និងវិវាទដីធ្លី ជាករណីដែលកើតមានញឹកញាប់ជាងគេ
- មេភូមិ និងក្រុមប្រឹក្សាឃុំ ជាអ្នកផ្សះផ្សាសំខាន់នៅថ្នាក់មូលដ្ឋាន

| | |
|---|---|
| បាទ | ២៩% ( ៣៥៣ ) |
| ទេ | ៧១% ( ៨៨៧ ) |
| សរុប | ១២៤០ |

| វិវាទដែលបានរៀបរាប់ភាគច្រើន | % | អ្នកឆ្លើយតប |
|---|---|---|
| វិវាទតូចតាចជាមួយអ្នកជិតខាង | ៣០% | ១ |
| វិវាទដីធ្លីតូចតាច | ២១% | ៤ |
| វិវាទអំពើហិង្សា | ១៦% | ៣ |
| វិវាទដីធ្លីធំៗ | ១០% | ៥ |
| ផ្សេងៗ | ៨% | |
| វិវាទទាក់ទងនឹងការសងប្រាក់ និងរឿងលុយកាក់ផ្សេងៗទៀត | ៥% | |
| បទល្មើសផ្សេងៗ ដូចជាចោរកម្ម ចាប់រំលោភ ឬអំពើឃាតកម្ម | ៤% | |
| បញ្ហាកើតឡើងដោយក្រុមបងធំ | ៣% | ២ |
| សរុប | ១០០% | |

| អ្នកផ្សះផ្សាដែលត្រូវបានលើកឡើង ជាច្រើនជាង | ភាគរយនៃរឿងក្តី |
|---|---|
| មេភូមិ | ៥៧% |
| ចាស់ទុំ | ២៤% |
| អ្នកផ្សះផ្សាថ្នាក់ភូមិ/ឃុំផ្សេងទៀត | ៧% |
| ក្រុមប្រឹក្សាឃុំ | ៤៥% |
| នគរបាល | ១៣% |
| អ្នកផ្សះផ្សាថ្នាក់ស្រុក | ១០% |
| អ្នកផ្សះផ្សាថ្នាក់ខេត្ត | ៦% |
| ផ្សេងៗ | ២% |
| សរុប | ៣៥៣ |

### នីតិវិធី

- ប្រសិនបើវិវាទមួយមិនអាចដោះស្រាយនៅថ្នាក់ភូមិ ប្រជាពលរដ្ឋទៅរកអាជ្ញាធរឃុំ ។
- ពេលខ្លះប្រជាពលរដ្ឋទៅរកអាជ្ញាធរឃុំដោយផ្ទាល់តែម្តង ហើយក្នុងករណីខ្លះទៀតពួកគេទៅដោយមានកំណត់ហេតុសរសេរដោយមេភូមិ ។ ប្រសិនបើគូភាគីទៅរកក្រុមប្រឹក្សាឃុំដោយផ្ទាល់ មេឃុំអាចសួរនាំព័ត៌មានពីមេភូមិផងដែរ ។

- ក្នុងករណីខ្លះ បន្ទាប់ពីមេឃុំទទួលរឿងក្តីហើយគ្រាន់តែផ្តល់ជាដំបូន្មានដល់គូភាគីប៉ុណ្ណោះ។
- ក្នុងករណីធ្ងន់ធ្ងរ ជាធម្មតាមេឃុំកំណត់ថ្ងៃ ដើម្បីពិភាក្សារឿងក្តីជាមួយសមាជិកក្រុមប្រឹក្សាទាំងអស់ ឬយ៉ាងហោចណាស់ពិភាក្សាជាមួយសមាជិកខ្លះនៃក្រុមប្រឹក្សា។
- ជាធម្មតាឃុំមានសៀវភៅ ដែលពួកគេប្រើសម្រាប់ចុះបញ្ជីរឿងក្តីដែលបានទទួល ហើយស្មៀនជាអ្នករក្សាទុកឯកសារដែលបានទទួល។
- ករណីខ្លះ មានឯកសារបីក្នុងរឿងក្តីមួយ : ១-ពាក្យបណ្តឹងរបស់ភាគី ២-កំណត់ហេតុនៃការសម្រុះសម្រួល និង ៣-កិច្ចសន្យាដែលបានចុះហត្ថលេខាដោយគូភាគីនៅចំពោះមុខអាជ្ញាធរ។
- ក្រោយពេលដាក់បណ្តឹង(ជាធម្មតាបានចុះហត្ថលេខាដោយមេភូមិ) គូភាគីត្រូវបានគេកោះហៅឱ្យមកជួបប្រជុំសម្រុះសម្រួលក្នុងពេលដ៏ខ្លី ជាធម្មតាក្នុងកំឡុងពេលមួយសប្តាហ៍។ ជូនកាលគូភាគីព្រមព្រៀងគ្នា ក្នុងពេលជួបប្រជុំសម្រុះសម្រួលតែមួយលើក ករណីខ្លះទៀតតម្រូវឱ្យមានការសម្រុះសម្រួលជាច្រើនលើក។
- មេឃុំ និងសមាជិកនានាជួយសម្របសម្រួលដល់ការប្រជុំសម្រុះសម្រួលនេះ។ ក្រុមប្រឹក្សាអាចសួរ ពន្យល់ និងសុំឱ្យគូភាគី : ក-ពន្យល់ប្រាប់ពីវិវាទកើតឡើង ខ- សុំទោសគ្នាទៅវិញទៅមកចំពោះការប្រព្រឹត្តិខុសរបស់ខ្លួន គ-ស្រុះស្រួលគ្នាដើម្បីបញ្ចប់វិវាទ និង ឃ-ឈានដល់ការការព្រមព្រៀងគ្នា។ អាជ្ញាធរឃុំលើកទឹកចិត្តដល់គូភាគីឱ្យឈានដល់ការព្រមព្រៀងគ្នា ដោយចរចារគ្នានូវអ្វីដែលពួកគេចង់បាន និងទាមទារពីដំបូង (ដោយសូមឱ្យគូភាគីបញ្ចុះការទាមទារ និងតម្លើងសំណងរបស់ខ្លួន) ដើម្បីចុងក្រោយចេញទៅជាសំណងជាក់លាក់មួយ អាចគិតជាទឹកប្រាក់ ឬការសងជារបស់ទ្រព្យ ឬការសងសំណងខូចខាតលើវត្ថុ និងដាក់ជាវិធាននៃអាកប្បកិរិយាសម្រាប់គូភាគី ដើម្បីចៀសវាងវិវាទកើតឡើងថ្មីទៀតនៅពេលអនាគត។ ប្រសិនបើសមាជិកក្រុមប្រឹក្សាយល់ឃើញថាគូភាគី មិនអាចឈានទៅរកការព្រមព្រៀងគ្នាទេនោះ ពួកគេនឹងឱ្យពេលគូភាគីដើម្បីគិតមួយរយៈសិន រួចទើបកោះអញ្ជើញមកប្រជុំម្តងទៀត ឬបញ្ជូនរឿងក្តីទៅលើទៀត។
- ប្រសិនបើការសម្រុះសម្រួលបរាជ័យ ក្រុមប្រឹក្សាឃុំអាចបញ្ជូនរឿងក្តីទៅថ្នាក់ផ្សេងទៀត ដូចជាគណៈកម្មការសុរិយោដី (សម្រាប់វិវាទលើដីធ្លីមិនបានចុះបញ្ជី) អភិបាលស្រុក នគរបាល ឬតុលាការ។

អាជ្ញាធរមូលដ្ឋានភាគច្រើនព្យាយាមដោះស្រាយវិវាទ និងបញ្ហានានាដោយការសម្រុះសម្រួលរវាងគូភាគី ទោះបីវាជាករណីទំនាស់ផលប្រយោជន៍ បទល្មើសព្រហ្មទណ្ឌ(ដូចជារំលោភសេពសន្ថវៈ និងបង្ករបួសស្នាម) ឬជាការរំលោភលើសិទ្ធិកុមារ (នៅពេលដែលឪពុកម្តាយខកខាន មិនបានផ្តល់ប្រាក់អាហារកិច្ចសម្រាប់ចិញ្ចឹមកូន) ក៏ដោយ។ ដោយសារតែវិវាទ ក៏អាចជាការគំរាមកំហែងចំពោះសន្តិភាពសង្គម នៅក្នុងសហគមន៍របស់ខ្លួនដែរ នោះអាជ្ញាធរបានដាក់សម្ពាធកម្រិតណាមួយ ចំពោះភាគីនៅពេលដែលពួកគេយល់ឃើញថា គូភាគីវិវាទមានការលំបាកដើម្បីឈានដល់ការស្រុះស្រួលគ្នា។ ចំពោះករណីដែលបានប្តឹងទៅឃុំ និងចុះបញ្ជីនៅក្រុមប្រឹក្សាឃុំ តែងមានពាក្យបណ្តឹង កំណត់ហេតុ សម្រុះសម្រួល និងកិច្ចព្រមព្រៀងដោយមានហត្ថលេខា។ ប្រហែលជាមានករណីវិវាទច្រើនជាងចំនួនដែលបាន សម្រុះសម្រួលដោយក្រុមប្រឹក្សាឃុំ តែករណីទាំងនោះមិនត្រូវបានចុះបញ្ជីឡើយ[១៨០]។

[១៨០] នៅពេលមានបណ្តឹងធ្វើឡើងដោយផ្ទាល់មាត់ ហើយអាចដោះស្រាយដោយងាយស្រួលនោះ នាំឱ្យករណីបែបនេះជាទូទៅ មិនត្រូវបានចុះបញ្ជីឡើយ។ លើសពីនេះទៀត សម្រាប់ករណីមួយចំនួនដែលប្តឹងមកក្រុមប្រឹក្សាឃុំ ហើយក្រុមប្រឹក្សាឃុំដឹងថា ករណីនោះមិនមែនជាសមត្ថកិច្ចរបស់ខ្លួននោះ ក្រុមប្រឹក្សាឃុំអាចមិនចុះបញ្ជីផងដែរ។

ដំណោះស្រាយអាចប្រែប្រួលទៅតាមប្រភេទនៃបញ្ហានីមួយៗ។ ចំពោះវិវាទនៅមូលដ្ឋាន រួមទាំងវិវាទលើព្រំប្រទល់ដី ការប្រើប្រាស់អណ្តូងសាធារណៈ សត្វស៊ីដំណាំអ្នកជិតខាង ការបង់ប្រាក់សម្រាប់ការកាប់ឆ្ការព្រៃដីស្រែ ការបរិហារកេរ្តិ៍ និងជម្លោះផ្សេងៗទៀត អាជ្ញាធរឃុំព្យាយាមលើកទឹកចិត្តឱ្យគូភាគីស្រុះស្រួលគ្នា ដើម្បីចៀសវាង និងទប់ស្កាត់កុំឱ្យវិវាទរីករាលដាលកាន់តែខ្លាំង។ ករណីខ្លះនៃករណីទាំងនេះគឺជាវិវាទ ដែលពាក់ព័ន្ធនឹងលុយកាក់តែបន្តិចបន្តួចប៉ុណ្ណោះ (អាចត្រឹមតែ ពី ២ ទៅ ៥ ដុល្លារ)។ តែចំនួននេះគឺជាចំនួនយ៉ាងច្រើនសម្រាប់ប្រជាពលរដ្ឋអ្នកភូមិដែលមានប្រាក់ចំណូលត្រឹមតែមួយដុល្លារក្នុងមួយថ្ងៃ។ វិវាទតូចតាចបែបនេះនឹងមិនទៅដល់តុលាការទេ តែដំណោះស្រាយសមរម្យសម្រាប់វិវាទតូចតាចនេះ មានលក្ខណៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋនៅតាមភូមិ និងសម្រាប់សន្តិភាពសង្គម។

សម្រាប់វិវាទដីធ្លីទាំងឡាយណា ដែលក្រុមប្រឹក្សាឃុំមិនអាចដោះស្រាយបាន ឬពាក់ព័ន្ធនឹងភាគីមានអំណាច នឹងត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដី អភិបាលស្រុក ឬអភិបាលខេត្ត។

អាជ្ញាធរក្រុមប្រឹក្សាឃុំត្រូវបានគេសុំឱ្យដោះស្រាយរឿងក្តីមួយចំនួន ដែលហួសពីសមត្ថកិច្ចផ្លូវច្បាប់របស់ខ្លួន ដូចជាការលែងលះ និងរឿងក្តីព្រហ្មទណ្ឌជាដើម។

ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងការប្តឹងសុំលែងលះ សមាជិកក្រុមប្រឹក្សាតែងព្យាយាមបញ្ចុះបញ្ចូលគូភាគីឱ្យស្រុះស្រួលនៅជាមួយគ្នាបន្តទៀត ទោះបីជាអំពើហិង្សានៅតែកើតមានក៏ដោយ។ ប្រសិនបើគូភាគីទាំងពីរព្រមព្រៀងគ្នា ពួកគេចុះហត្ថលេខាលើកិច្ចសន្យាថាស្រុះស្រួលគ្នា និងឈប់ប្រព្រឹត្តអំពើហិង្សាតទៅទៀត ឬសុំផ្តាច់សង្វាស។ មានតែក្នុងករណីបង្ករបួសស្នាមមានសភាពធ្ងន់ធ្ងរប៉ុណ្ណោះ ដែលត្រូវបញ្ជូនទៅឱ្យនគរបាល ឬឱ្យគូភាគីទៅរកនគរបាលខ្លួនឯង។

**ឧទាហរណ៍នៃករណីវិវាទទាក់ទិននឹងអំពើហិង្សាក្នុងគ្រួសារ និងការសុំលែងលះនៅចំពោះមុខអាជ្ញាធរឃុំ :**

- *ការដោះស្រាយវិវាទដោយក្រុមប្រឹក្សាឃុំ នៅឃុំខ្ទុងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*
- *ថ្ងៃដោះស្រាយ : ១១ ឧសភា ២០០៤*
- *រឿងហេតុ : ការទាមទារសុំលែងលះ (បង្កឡើងដោយមានអំពើហិង្សា)*
- *លទ្ធផល : ប្តីប្រពន្ធរស់ជាមួយគ្នាវិញ*

*នេះគឺជារឿងវិវាទប្តីប្រពន្ធរវាងលោកស្រី CR ដែលជាប្រពន្ធ និងលោក EC ដែលជាប្តី។ នៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៤ ក្រុមប្រឹក្សាឃុំបានធ្វើការផ្សះផ្សាលើរឿងក្តីសុំលែងលះ ដែលបានដាក់ពាក្យប្តឹងដោយលោកស្រី CR ដែលជាប្រពន្ធ ដោយបានបញ្ជាក់ថានាងមិនអាចម្រាំរស់នៅជាមួយប្តីរបស់នាង គឺលោក EC បានតទៅទៀតទេ ដោយសារគាត់បានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារច្រើនលើកច្រើនសារ ហើយនាងចង់សុំលែងលះ។ ក្រោយពីដំណើរការផ្សះផ្សារួចមក ប្តីមិនចង់លែងលះទេ ហើយប្រពន្ធបាននិយាយថានាងអាចយល់ព្រមទទួលលោក EC ប្រសិនបើគាត់ព្រមសន្យាថានឹង កសាងទំនាក់ទំនងល្អជាមួយឪពុកម្តាយរបស់នាងវិញ ហើយប្តីក៏បានយល់ព្រម។ ចុងក្រោយភាគីទាំងពីរយល់ព្រមថានឹង ថែរក្សាគ្នាទៅវិញទៅមក និងទទួលស្គាល់កំហុសរបស់ខ្លួន ព្រមទាំងព្រមព្រៀងថា ឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ។ បន្ទាប់មកគូភាគីបានផ្តិតមេដៃរបស់ខ្លួនលើកិច្ចសន្យាទៅចំពោះវត្តមានរបស់សមាជិកក្រុមប្រឹក្សាឃុំ។*

យោងតាមការសិក្សាស្រាវជ្រាវ យើងបានរកឃើញថា ភាគច្រើននៃអំពើហិង្សាក្នុងគ្រួសារ មានការទាក់ទងនឹងភាពខ្វះការទទួលខុសត្រូវរបស់ឪពុក ដូច្នេះស្ត្រីស្នើសុំអាហារកិច្ចនៅចំពោះមុខអាជ្ញាធរឃុំដើម្បីចិញ្ចឹមកូន។ អាជ្ញាធរអាចកោះហៅប្តី ហើយព្យាយាមធ្វើការសម្រុះសម្រួល ជាលទ្ធផលករណីខ្លះប្តីសន្យាថាគាត់នឹងផ្លាស់ប្តូរ ហើយគូភាគីចុះហត្ថលេខាលើកិច្ចសន្យារស់នៅជាមួយគ្នាវិញ។

ក្រុមប្រឹក្សាឃុំមិនមានអំណាចតាមផ្លូវច្បាប់ ក្នុងការសម្រេចឱ្យលែងលះទេ មានតែតុលាការទេដែលមានអំណាចនេះ។ ក្រុមប្រឹក្សាឃុំមានសិទ្ធត្រឹមជួយសម្រុះសម្រួលគូភាគី ដែលបានដាក់ពាក្យបណ្តឹងសុំលែងលះប៉ុណ្ណោះ[១៨១]។ អាជ្ញាធរឃុំអាចផ្តល់ដំបូន្មានឱ្យប្រជាពលរដ្ឋទៅរកតុលាការ ដើម្បីសុំលែងលះដោយស្របច្បាប់។ តែទោះជាយ៉ាងនេះក្តី អាជ្ញាធរឃុំទទួលនូវសំពាធយ៉ាងខ្លាំង សុំឱ្យដោះស្រាយរឿងបែបនេះ ដោយសារថាចម្ងាយនិងតម្លៃចំណាយ ក្នុងការធ្វើដំណើរទៅតុលាការ អស់ច្រើនសម្រាប់អ្នកភូមិ ជាពិសេសសម្រាប់ស្ត្រី។ ភាគច្រើនប្តីប្រពន្ធមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ ដូច្នេះក្នុងន័យចង្អៀត ពួកគេមិនចាំបាច់ទៅតុលាការដើម្បីសុំលែងលះទេ ដោយសារពួកគេមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ តែទោះយ៉ាងនេះក្តី យោងតាមការយល់ពីសង្គម និងជាវប្បធម៌ ពួកគេយល់ថាពួកគេបានរៀបការស្របច្បាប់។ ប៉ុន្តែប្រសិនបើពួកគេមានកូនឬទ្រព្យសម្បត្តិរួម វាជាការចាំបាច់ត្រូវតែគោរពតាមនីតិវិធីច្បាប់ ក្នុងការទាមទារអាហារកិច្ច និងការបែងចែកទ្រព្យសម្បត្តិ។ ក្នុងករណីភាគច្រើន ស្ត្រីទៅរកអាជ្ញាធរដើម្បីសុំអាហារកិច្ច និងសុំបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ដែលពោរពេញដោយអំពើហិង្សា (អាចជាហិង្សាដែលកើតឡើងម្តងហើយម្តងទៀត ភាពមិនទទួលខុសត្រូវជាឪពុក ការបោះបង់ចោលគ្រួសារ ឬករណីមានប្រពន្ធច្រើន)។ ស្ត្រីនៅតាមជនបទ ជាពិសេសអ្នកដែលត្រូវបានប្តីបោះបង់ចោលជាមួយនឹងកូន មិនមានធនធាន ឬចំណេះដឹងផ្លូវច្បាប់ដើម្បីទៅរកតុលាការ ដើម្បីទាមទារអាហារកិច្ចនោះទេ។ មានតែក្រុមប្រឹក្សាឃុំប៉ុណ្ណោះ ដែលពួកគេអាចមករកបាន។

ប្រសិនបើគូភាគីបានឈានដល់ការព្រមព្រៀងក្នុងការផ្តាច់សង្វាស/ការលែងលះ អាជ្ញាធរឃុំសរសេរកំណត់ហេតុនៃការប្រជុំសម្រុះសម្រួល និងចុះហត្ថលេខាលើ "កិច្ចសន្យាលែងលះ" ក្នុងនាមជាសាក្សី។ អាជ្ញាធរនិងគូភាគីយល់ថា កិច្ចសន្យាដែលបានចុះហត្ថលេខានោះ មានប្រសិទ្ធិភាពពេញទីក្នុងការលែងលះហើយ និងអាចអនុញ្ញាតឱ្យភាគីរៀបការម្តងទៀតបាន។ តែប្រសិនបើភាគីមួយមិនព្រមលែងលះទេនោះ ភាគីម្ខាងទៀតត្រូវតែប្តឹងទៅតុលាការ។ ដូចគ្នានេះដែរ ប្រសិនបើគូភាគីមិនយល់ព្រមលើលក្ខខណ្ឌក្នុងកិច្ចសន្យាលែងលះ ដូចជាការបែងចែកទ្រព្យសម្បត្តិរួម អាហារកិច្ច ការគ្រប់គ្រងកូន និងសំណងជម្ងឺចិត្ត ។ល។ នោះគឺត្រូវតែប្តឹងទៅតុលាការ។

ក្នុងរឿងរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈ អ្នកសម្រុះសម្រួលព្យាយាមលើកទឹកចិត្ត ឱ្យធ្វើការសម្រុះសម្រួលរវាងជនល្មើស និងគ្រួសារជនរងគ្រោះ។ ជាធម្មតា ជនល្មើសគឺជាមនុស្សដែលស្គាល់គ្នាជាមួយជនរងគ្រោះជាសាច់ញាតិ ឬអ្នកជិតខាង។ ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួន ឬក៏ជនរងគ្រោះអាចកំណត់អត្តសញ្ញាណជនល្មើសបាន ហើយជនល្មើសទទួលស្គាល់ការប្រព្រឹត្តិរបស់ខ្លួន នោះអាជ្ញាធរឃុំនឹងសុំឱ្យជននោះធ្វើការសុំទោស។ បន្ទាប់មកពួកគេសួរគ្រួសារជនរងគ្រោះថាតើគ្រួសារជនរងគ្រោះចង់បានអ្វី ឬទាមទារសំណងប៉ុន្មាន។ បន្ទាប់មកការចរចាពីសំណង ការខូចខាតត្រូវបានចាប់ផ្តើម។ ជាធម្មតារឿងក្តីត្រូវបានដោះស្រាយតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម : ក-ការសុំទោសពីជនល្មើស ខ-ការផ្តល់ជាសំណងខូចខាត

[១៨១] ប្រជាពលរដ្ឋរៀបចំពិធីមង្គលការតាមប្រពៃណីរបស់ខ្លួន។ ចាប់តាំងពីឆ្នាំ ១៩៨៩ មក ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ តម្រូវឱ្យប្តីប្រពន្ធថ្មីគោរពតាមនីតិវិធីមួយចំនួន ដើម្បីឱ្យអាពាហ៍ពិពាហ៍ស្របច្បាប់ (ដូចជា ដាក់ពាក្យសុំរៀបការ ដោយមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ការផ្សាយជាសាធារណៈ និងការចុះបញ្ជីអាពាហ៍ពិពាហ៍) នៅចំពោះមុខគណៈកម្មការឃុំ (សព្វថ្ងៃហៅក្រុមប្រឹក្សាឃុំ-សង្កាត់)។ ប្តីប្រពន្ធភាគច្រើនមិនបានទៅចុះបញ្ជីឡើយ។ ទោះជាយ៉ាងនេះក្តី ប្រជាពលរដ្ឋទូទៅយល់ថាពួកគេបានរៀបការស្របច្បាប់ហើយ។ ដូចនេះបើសិនជាពួកគេចង់លែងលះ ពួកគេអាចទៅប្តឹងសុំលែងលះនៅថ្នាក់ឃុំបាន (សូមមើលជំពូកទី ២ ទាក់ទងនឹងក្របខណ្ឌច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ)។ ដោយសារច្បាប់បានតម្រូវឱ្យគោរពតាមនីតិវិធីដែលច្បាប់ចែង ដើម្បីឱ្យអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយអាពាហ៍ពិពាហ៍ដែលមិនបានចុះបញ្ជី អាចចាត់ទុកថាជាមិនជាប់កាតព្វកិច្ចប្តីប្រពន្ធ ដូចនេះជាលទ្ធផល គួរតែមិនចាំបាច់តម្រូវឱ្យពួកគេត្រូវប្តឹងមកតុលាការ ដើម្បីបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ដែលមិនទាន់បានចងជាប់តាមច្បាប់នៅឡើយនោះទេ ។ ទោះជាយ៉ាងនេះក៏ដោយក្តី មានការបកស្រាយមួយផ្សេងទៀត ចៅក្រមមួយចំនួនចាត់ទុកគូអាពាហ៍ពិពាហ៍ទាំងឡាយដែលបានរៀបការតាមប្រពៃណី និងមានកូន រួមទាំងទ្រព្យសម្បត្តិរួម ហើយបើក្រោយមកពួកគេចង់លែងលះគ្នា ពួកគេគួរតែគោរពតាមនីតិវិធីច្បាប់ដោយប្តឹងទៅតុលាការ ព្រោះអាពាហ៍ពិពាហ៍ទាំងនោះ ត្រូវបានគេចាត់ទុកថាមានសុពលភាព (តាមវប្បធម៌ និងសង្គម) គ្រប់គ្រាន់ហើយ។

គ-ការស្រុះស្រួលគ្នាពីជនល្មើសថានឹងមិនធ្វើបែបនេះម្តងទៀត បើមិនដូច្នោះគាត់ "នឹងទទួលខុសត្រូវចំពោះមុខច្បាប់" (មានន័យថាគាត់នឹងប្រឈមនឹងការចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌ) និង ឃ-ភាគីស្រុះស្រួលគ្នាថាបញ្ចប់វិវាទត្រឹមនេះ។ ចំនួនទឹកប្រាក់សំណងខុសគ្នាពីរឿងក្តីមួយទៅរឿងក្តីមួយ។ នៅក្នុងសហគមន៍ដែលយើងបានទៅដល់ រឿងក្តីខ្លះត្រូវបាន "ធ្វើការសម្រុះសម្រួល" ដោយសំណងទឹកប្រាក់ ចំនួនពី ៤០០.០០០ រៀល ទៅ ១.០០០.០០០ រៀល (១០០-២៥០ដុល្លារអាមេរិក)។ ប្រសិនបើជនរងគ្រោះមានផ្ទៃពោះ គូភាគីអាចជជែកគ្នាពីរឿងរៀបអាពាហ៍ពិពាហ៍ឱ្យបានឆាប់ ដើម្បីបញ្ចប់រឿងក្តី។ ទាំងជនរងគ្រោះ ទាំងអាជ្ញាធរព្យាយាមដាក់វិធានការនានាតាមផ្លូវសាសនា ឬវប្បធម៌ ដើម្បីទប់ស្កាត់កុំឱ្យមានបទល្មើសបែបនេះកើតមានម្តងទៀត។ ក្នុងករណីខ្លះទៀត ជាផ្នែកមួយនៃការគាំទ្រដល់ការសម្រុះសម្រួល ជនរងគ្រោះស្នើសុំឱ្យជនល្មើសប្តេជ្ញាចិត្តថា នឹងមិនប្រព្រឹត្តម្តងទៀតទេ។ ក្នុងករណីរឿងក្តីមួយ ឪពុកម្តាយជនរងគ្រោះបានសុំឱ្យឪពុកម្តាយរបស់ជនល្មើស ដែលមានអាយុនៅក្មេង ធ្វើការអប់រំកូនរបស់ខ្លួន ហើយឪពុកម្តាយរបស់ជនល្មើសបានយល់ព្រមអប់រំកូនប្រុសរបស់ខ្លួន។ ក្នុងករណីមួយទៀត ជនល្មើសត្រូវបានគេបង្ខំឱ្យធ្វើការស្បថស្បែនៅក្នុងវត្តអារាមថា ខ្លួននឹងមិនប្រព្រឹត្តបទល្មើសបែបនេះទៀតទេ ព្រមទាំងធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរផង។

### ករណីប៉ុនប៉ងរំលោភដែលត្រូវបានសម្រុះសម្រួលនៅក្នុងក្រុមប្រឹក្សាឃុំ

*ការដោះស្រាយវិវាទដោយក្រុមប្រឹក្សាឃុំ នៅឃុំខ្លុងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

- *ថ្ងៃដាក់ពាក្យបណ្តឹង : ១៩ តុលា ២០០៣*
- *ថ្ងៃជួបប្រជុំសម្រុះសម្រួល និង "កំណត់ហេតុនៃការសម្រុះសម្រួល" : ២៥ តុលា ២០០៣*
- *រឿងហេតុ : ការប៉ុនប៉ងរំលោភសេពសន្ថវៈ*
- *លទ្ធផល : បានដោះស្រាយដោយសំណងការខូចខាត និងទៅស្បថនៅក្នុងវត្ត*

*លោក AA ដែលរស់នៅភូមិក្រោយវត្ត ឃុំខ្លុងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានដាក់ពាក្យបណ្តឹងប្តឹងឈ្មោះ BB អាយុ ១៥ឆ្នាំ ចោទប្រកាន់ឈ្មោះ BB ដែលប៉ុនប៉ងរំលោភកូនស្រីគាត់ ឈ្មោះ CC អាយុ ១១ឆ្នាំ ដោយបញ្ចុះបញ្ចូលនាង ឱ្យចូលក្នុងព្រៃប្រហែល ៣០០ម៉ែត្រឆ្ងាយពីផ្លូវ។ បន្ទាប់មកជននេះព្យាយាមចាប់រំលោភនាង ប៉ុន្តែនាងរត់រួច ហើយស្រែកហៅមិត្តភ័ក្ត្រនាងឱ្យជួយ។ មិត្តនាងបាននាំនាងមកផ្ទះ។ ឪពុកនាង លោក AA បានប្តឹងទាមទារលុយចំនួន ២.០០០.០០០ រៀល (៥០០ ដុល្លារអាមេរិក) ជាសំណងការខូចខាត និងសំណូមពរឱ្យអាជ្ញាធរដាក់ទណ្ឌកម្មដល់ជនល្មើសតាមច្បាប់។ នៅថ្ងៃទី២៥ តុលា ឆ្នាំ២០០៣ ក្រុមប្រឹក្សាឃុំបានធ្វើការសម្រុះសម្រួល។ ដោយការសម្រុះសម្រួល គូភាគីបានផ្តិតមេដៃពួកគេនៅក្នុង "កំណត់ហេតុនៃការសម្រុះសម្រួល"។ កិច្ចសន្យាមានដូចតទៅ: គូភាគីបានពិភាក្សា និងលើកពីការទាមទាររបស់ពួកគេ ហើយភាគីទាំងពីរបានព្រមព្រៀងឈប់ចោទប្រកាន់គ្នាទៅវិញទៅមក។ ជនជាប់ចោទយល់ព្រមបង់ ៨៥០.០០០ រៀល (២១៥ ដុល្លារអាមេរិក) សម្រាប់ការខូចខាតដល់ដើមបណ្តឹង។ ភាគីទាំងពីរយល់ព្រមស្បថក្នុងព្រះវិហារនៅវត្តអារាម ដោយមានវត្តមានព្រះសង្ឃ ៤អង្គ ដើម្បីបង្ហាញពីការតាំងចិត្តរបស់ពួកគេ[១៨២]។*

ពេលខ្លះអាជ្ញាធរក្រុមប្រឹក្សាឃុំមួយចំនួន ក៏បានដោះស្រាយរឿងក្តីព្រហ្មទណ្ឌផ្សេងទៀតផងដែរ ដូចជា ករណីបង្ករបួសស្នាម ការបរិហារកេរ្តិ៍ និងបទល្មើសដទៃទៀត។ ជាធម្មតា ជនរងគ្រោះចង់បានសំណងការខូចខាត។ ការបង់សំណងខូចខាតធ្វើនៅឱ្យចប់រឿងក្តីតែម្តង ហើយករណីនោះមិនត្រូវបានគេរាយការណ៍ទៅអាជ្ញាធរ ឬតុលាការទេ។ នៅពេលដែលពួកគេមិនអាចឈានទៅដល់ការព្រមព្រៀងគ្នា ឬក្នុងករណីរឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ អាជ្ញាធរឃុំបញ្ជូនរឿងក្តីទាំងនោះទៅនគរបាល។

[១៨២] សូមមើលរឿងក្តីលេខ ៩១០ ក្នុងឧបសម្ព័ន្ធទី២ ។

ជាគោលការណ៍ អាជ្ញាធរឃុំសម្របសម្រួលការសន្ទនាចរចារ ការសម្រុះសម្រួលអត្ថប្រយោជន៍ និងការប្តេជ្ញាចិត្តរបស់ភាគីដើម្បីឱ្យឈានដល់កិច្ចព្រមព្រៀងមួយ ។ ប្រសិទ្ធិភាពនៃប្រព័ន្ធនេះគឺវាអាស្រ័យយ៉ាងខ្លាំង ទៅលើការប្តេជ្ញាចិត្តដែលត្រូវបានធ្វើឡើងដោយគូភាគី[១៨៣] ។ ផ្ទុយទៅវិញប្រព័ន្ធនេះបង្ហាញពីចំណុចខ្សោយនៅពេលៈ ក-ភាគីមួយមានអំណាចខ្លាំងជាង ឬមានសមត្ថភាពក្នុងការចរចារជាងភាគីម្ខាងទៀត ដូចនេះលទ្ធផលអាចមិនធានាបាននូវភាពយុត្តិធម៌ឡើយ ខ- ភាគីមិនព្រមព្រៀងគ្នាក្នុងការដោះស្រាយ គ-ក្រោយពេលព្រមព្រៀងហើយ តែភាគីម្ខាងមិនព្រមអនុវត្តកិច្ចព្រមព្រៀងនោះ និង ឃ-នៅពេលដែលមានការរំលោភលើសិទ្ធិ។ ក្នុងករណីអំពើហិង្សាខាងយេនឌ័រ ដែលកើតឡើងជាប្រចាំ ឬក្នុងករណីមិនមានការទទួលខុសត្រូវរបស់ឪពុកម្តាយ អាជ្ញាធរឃុំអាចជួយប្តីប្រពន្ធក្នុងការសម្រុះសម្រួល ប៉ុន្តែពួកគេមិនមានសមត្ថភាពក្នុងការការពារសិទ្ធិរបស់កុមារ និងសិទ្ធិស្ត្រីឡើយ ។ ក្រុមប្រឹក្សាឃុំមិនមានមធ្យោបាយ ក្នុងការបង្ខំឱ្យឪពុកម្តាយដែលធ្វេសប្រហែស ឬមិនទទួលខុសត្រូវចំពោះកូនឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនជាឪពុកម្តាយឡើយ ។ ការផ្តោតសំខាន់របស់អ្នកសម្រុះសម្រួល គឺការឈានដល់ការព្រមព្រៀងគ្នាដើម្បីបញ្ចប់បញ្ហាវិវាទ ជាជាងផ្តោតសំខាន់លើការការពារសិទ្ធ។ ជាសរុបមក នេះគឺជាចំណុចខ្សោយនៃប្រព័ន្ធ ដែលផ្អែកជាចម្បងតែទៅលើការសម្រុះសម្រួលអត្ថប្រយោជន៍ ។

តម្លៃ

អ្នកចូលរួមក្នុងសិក្ខាសាលាអះអាងថា ពួកគេត្រូវបង់លុយមួយចំនួនទៅក្រុមប្រឹក្សាឃុំ ដើម្បីឱ្យធ្វើការដោះស្រាយវិវាទ។ ចំនួននេះអាចមានការប្រែប្រួលតាមឃុំនីមួយៗ ។

គម្រោងបណ្តុះបណ្តាលអ្នកផ្សះផ្សា និងអ្នកសម្រុះសម្រួល

មានគម្រោងមួយចំនួនធ្វើឡើង ដោយអង្គការក្រៅរដ្ឋាភិបាល ដែលបានបង្កើតជាគណៈកម្មការនៅក្នុងក្រុមប្រឹក្សាឃុំមួយចំនួន សម្រាប់ជាប្រយោជន៍ដល់ការដោះស្រាយវិវាទ។ គណៈកម្មាធិការ ឬគណៈកម្មការទាំងនេះ ត្រូវបានបង្កើតឡើងក្នុងនាមជាយន្តការដោះស្រាយវិវាទក្រៅតុលាការ (ADR) យោងតាមមាត្រា ២៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលបានចែងថាៈ "មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មការនានា ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់របស់ខ្លួន" និងយោងតាមអនុក្រឹត្យលេខ ២២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានចែងថា : "ប្រជាពលរដ្ឋអាចប្តឹងមកកាន់ឃុំ/សង្កាត់ ដើម្បីធ្វើការដោះស្រាយវិវាទណាមួយបាន" ។

ក្នុងចំណោមគម្រោងផ្សេងៗ មានគម្រោងពីរដែលបានបណ្តុះបណ្តាលអ្នកផ្សះផ្សានៅថ្នាក់ឃុំ ។ គម្រោងមួយត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) និងគម្រោងមួយទៀតធ្វើឡើងដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) ។

**គម្រោងដែលធ្វើឡើងដោយមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍** (CLEC)

**មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍** (CLEC)ៈ

គម្រោងយុត្តិធម៌សហគមន៍ (ដំណោះស្រាយវិវាទមូលដ្ឋានតាមបែបវិមជ្ឈការ)

CLEC បានជ្រើសរើសឃុំសង្កាត់ចំនួន ៣ (មួយនៅក្នុងខេត្តកំពង់ធំ មួយនៅក្រុងភ្នំពេញ និងមួយទៀតនៅខេត្តកណ្តាល) ធ្វើជាដៃគូសម្រាប់ការសាកល្បងគម្រោងយុត្តិធម៌សហគមន៍របស់អង្គការខ្លួន។ គម្រោងនេះត្រូវបានធ្វើឡើងដោយមានការសម្របសម្រួលជាមួយ ក្រុមប្រឹក្សាឃុំដែលបានជាប់ឆ្នោត ក្នុងការបង្កើតនូវគណៈកម្មការថ្នាក់ភូមិ និងថ្នាក់ឃុំសម្រាប់ដោះស្រាយវិវាទ។

[១៨៣] ជាធម្មតា ភាគីសុខចិត្តបង់នូវសំណងដែលពួកគេបានឯកភាពរវាងគ្នានិងគ្នា ជាជាងសំណងដែលតម្រូវឱ្យបង់ដោយភាគីទី៣ រួមទាំងចៅក្រមផង ។

ការជ្រើសរើសសមាជិកគណៈកម្មការដោះស្រាយវិវាទថ្នាក់ភូមិ និងឃុំ មិនបានធ្វើឡើងតាមការបោះឆ្នោតទេ ប៉ុន្តែជ្រើសរើសដោយក្រុមប្រឹក្សាឃុំខ្លួនឯង។ នៅថ្នាក់ឃុំ សមាជិកគឺជាសមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីនគរបាលឃុំ និងអ្នកដែលត្រូវបានគេគោរពនៅក្នុងឃុំ ដូចជាគណៈកម្មការវត្ត និងសកម្មជនអភិវឌ្ឍន៍ឃុំ។ នៅថ្នាក់ភូមិមានសមាជិក ៥រូប ដែលរួមមានមេភូមិ អនុប្រធានភូមិ និងអ្នកដែលគេគោរពក្នុងភូមិ។ នៅពេលប្រជាពលរដ្ឋមានវិវាទ ពួកគេដំបូងដាក់ពាក្យប្តឹងទៅគណៈកម្មការថ្នាក់ភូមិ ហើយប្រសិនបើការសម្រុះសម្រួលបរាជ័យនៅថ្នាក់នោះ ពួកគេនឹងឡើងមករកគណៈកម្មការនៅថ្នាក់ឃុំ។ ក្នុងការដោះស្រាយវិវាទមួយ ទោះនៅថ្នាក់ភូមិ ឬថ្នាក់ឃុំត្រូវមានអ្នកសម្រុះសម្រួលចំនួនបីនាក់។ ភាគីនីមួយៗអាចជ្រើសរើសអ្នកសម្រុះសម្រួលម្នាក់ ហើយអ្នកសម្រុះសម្រួលទាំងពីរ ដែលបានរើសដោយគូភាគី ត្រូវរើសអ្នកសម្របសម្រួលម្នាក់ទៀត ដើម្បីធ្វើជាលេខាក្នុងពេលធ្វើការសម្រុះសម្រួល។

ការដាក់ពាក្យបណ្តឹង និងការដោះស្រាយវិវាទនៅគណៈកម្មការភូមិឬឃុំ ឥតមានបង់ថ្លៃទេ។ តែទោះជាយ៉ាងណាក្តី CLEC ផ្តល់ការគាំទ្រដល់អ្នកសម្រុះសម្រួលវិវាទ ក្នុងម្នាក់មួយដុល្លារអាមេរិក សម្រាប់ការដោះស្រាយវិវាទមួយ និងសម្ភារៈការិយាល័យមួយចំនួនដល់គណៈកម្មការ។

ការសម្រុះសម្រួលដោយគណៈកម្មការសម្រុះសម្រួលនេះ គឺយោងតាមការស្រុះស្រួលគ្នារវាងគូភាគីទាំងពីរ ជាជាងផ្អែកលើច្បាប់។ ធ្វើបែបនេះដោយសារមានមូលហេតុ២: ក-គណៈកម្មការមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេច និង ខ- ចំណេះដឹងផ្នែកច្បាប់របស់សមាជិកគណៈកម្មការមានកម្រិត។ នៅក្នុងពេលធ្វើការសម្រុះសម្រួល អ្នកសម្រុះសម្រួលព្យាយាមឱ្យគូភាគីឈានដល់ការព្រមព្រៀង និងបញ្ចប់វិវាទជាជាងស្វែងរកយុត្តិធម៌សម្រាប់គូភាគី។ ការដាក់សំពាធលើគូភាគីឱ្យឈានដល់ការស្រុះស្រួលគ្នានេះមានប្រសិទ្ធភាពខ្ពស់ ពិសេសសម្រាប់ភាគីដែលទន់ខ្សោយ ក្រីក្រ និងអ្នកគ្មានអំណាច ដែលពួកគេមិនមានមធ្យោបាយទៅរកតុលាការ ហើយគេមានគំនិតជាស្រេចថាតុលាការមានភាពលម្អៀងទៅអ្នកមានលុយច្រើន និងអ្នកមានអំណាច។ ដោយសារហេតុផលនេះ ទើបធ្វើឱ្យភាគីមានអំណាច ទាញយកអត្ថប្រយោជន៍លើភាគីទន់ខ្សោយ ដូចជានៅក្នុងរឿងក្តីវិវាទដីធ្លី ដែលក្រុមការងារសិក្សាស្រាវជ្រាវយើងខ្ញុំបានសង្កេតជាដើម។

គម្រោងធ្វើឡើងដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD)

**គម្រោងរបស់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) លើការដោះស្រាយវិវាទ**

អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) កំពុងអនុវត្តគម្រោងមួយស្តីពីកម្មវិធីសិទ្ធិមនុស្សនៅមូលដ្ឋាន នៅក្នុងស្រុកដែលបានជ្រើសរើសមួយចំនួនក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ។ BFD បានធ្វើគម្រោងនេះ ដោយមានកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ ដែលបានជាប់ឆ្នោត។

នៅក្នុងគម្រោងនេះ BFD ជួយក្រុមប្រឹក្សាឃុំ ក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្តដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDV) ក្រុមឃ្លាំមើលសិទ្ធិមនុស្ស (HRW) និងគណៈកម្មាធិការដើម្បីការពារនិងត្រួតពិនិត្យការរំលោភសិទ្ធិមនុស្ស (CPMHRV).

PDV ជ្រើសរើសសម្រាប់គ្រប់ភូមិ ដែលការទទួលខុសត្រូវរបស់ខ្លួនគឺអប់រំដល់អ្នកភូមិស្តីពីការអភិវឌ្ឍ និងបញ្ហាសិទ្ធិមនុស្ស ដើម្បីធ្វើជាអ្នកទាក់ទងនៅក្នុងភូមិ និងសម្របសម្រួលការងារជាមួយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងភូមិ និងដើម្បីជួយដល់មេភូមិក្នុងការដោះស្រាយវិវាទនៅក្នុងមូលដ្ឋានតូចតាច ព្រមទាំងតាមដានលទ្ធផលនៃការដោះស្រាយវិវាទ ដូចជាវិវាទដីធ្លីតូចតាច អំពើហិង្សាក្នុងគ្រួសារ វិវាទគ្រួសារ( ការសុំលែងលះ) បញ្ហាបងធំ ការបរិហាកេរ្តិ៍ ជម្លោះអ្នកជិតខាងតូចតាច ចោរកម្មតូចតាច សត្វពាហនៈស៊ីដំណាំ។ល។PDV ត្រូវបានជ្រើសរើសដោយអ្នកភូមិតាម វិធីបោះឆ្នោតសម្ងាត់ឬការលើកដៃ ហើយដំណើរការនៃការជ្រើសរើស ត្រូវបានសម្របសម្រួលដោយ BFD។ នៅក្នុងភូមិនីមួយៗ មេភូមិតែងតាំងមនុស្ស ៣នាក់ ដែលជាមនុស្សមានប្រជាប្រិយ និងមានឥទ្ធិពលដើម្បីឱ្យអ្នកភូមិជ្រើសរើស។

CPMHRV ត្រូវបានបង្កើតឡើងដោយដីការបស់មេឃុំ។ CPMHRV អាចមានមនុស្សពី ៥ ទៅ ៨នាក់ អាស្រ័យលើទំហំភូមិសាស្ត្រ និងលក្ខណៈនយោបាយរបស់ឃុំ។ ពួកគេត្រូវបានតែងតាំងឡើងដោយមេឃុំដោយមាន ការពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាឃុំ។ សមាជិករបស់ CPMHRV អាចជាសមាជិកក្រុមប្រឹក្សា នគរបាលក្នុងឃុំ ឬអ្នកដែលគេគោរព។ ប្រធានគណៈកម្មាធិការ ត្រូវបានគេចាត់តាំង។ តួនាទីរបស់ CPMHRV គឺដោះស្រាយវិវាទរវាង អ្នកភូមិដែលមិនអាចដោះស្រាយបានដោយ PDV។ សម្រាប់រឿងក្តីធ្ងន់ធ្ងរ (បទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ) ឬករណីវដ្តប្បវេណីមួយចំនួនដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មាធិការ។ សមត្ថកិច្ចនគរបាលគឺត្រូវធ្វើតាមនីតិវិធីផ្លូវច្បាប់ ប៉ុន្តែ ពេលខ្លះរឿងក្តីត្រូវបានដោះស្រាយដោយនគរបាលដោយមិនបានបញ្ជូនទៅតុលាការទេ។ សមាជិកគណៈកម្មាធិការបានបង្ហើបឱ្យដឹងថា ពួកគេពេលខ្លះក៏ធ្វើការដោះស្រាយរឿងក្តីរំលោភសេពសន្ថវៈដែរ ដែលជាធម្មតាគូភាគីយល់ព្រមរៀបការនឹងគ្នា។ ជាទូទៅនៅពេលដោះស្រាយវិវាទសមាជិកគណៈកម្មាធិការទាំងអស់ត្រូវចូលរួម ប៉ុន្តែក្នុងឃុំមួយចំនួន ពួកគេតម្រូវឱ្យមានត្រឹម ៥០% នៃសមាជិកទាំងអស់ក៏បានដែរ។ នៅក្នុងពេលដោះស្រាយវិវាទ គណៈកម្មាធិការពន្យល់ដល់គូភាគីពីបញ្ហាច្បាប់ ទ្រឹស្តីពុទ្ធសាសនា និងបទដ្ឋានប្រពៃណីផ្សេងៗទៀត។

HRW ត្រូវបានបង្កើតឡើងនៅក្នុងឃុំនីមួយៗ និងមានសមាជិក ៥ រូបដែលជ្រើសរើសតាមវិធីដូចគ្នានឹងការរើសសមាជិករបស់ PDVEដែរ។ សមាជិករបស់ HRW អាចជាប្រជាពលរដ្ឋ ព្រះសង្ឃ គ្រូបង្រៀនដែលគេគោរព និងមានប្រជាប្រិយភាព។ តួនាទីរបស់ HRW មានភាពស្រដៀងគ្នានឹង PDV ដែលរួមមានការផ្សព្វផ្សាយអំពីការអភិវឌ្ឍ និងបញ្ហាសិទ្ធិមនុស្ស ធ្វើការសង្កេតលើការរំលោភសិទ្ធិមនុស្សណាមួយ ដែលកើតឡើងនៅក្នុងឃុំ និងរាយការណ៍ជូនទៅអាជ្ញាធរឃុំ ព្រមទាំងតាមដានដំណើរការដោះស្រាយវិវាទ ដែលធ្វើឡើងដោយគណៈកម្មាធិការ និងតាមដានគូភាគីវិវាទ ដែលត្រូវបានដោះស្រាយរួចហើយថាតើពួកគេបានផ្លាស់ប្តូរឥរិយាបទរបស់ខ្លួន និងបំពេញតាមកាតព្វកិច្ចរបស់ខ្លួនដែរឬទេ។ ឃុំខ្លះមានទាំង PDV និង HRW ឃុំខ្លះទៀតមានតែ PDV រីឯឃុំផ្សេងទៀតមានតែ HRW។

វាជាការសំខាន់ក្នុងការកត់សំគាល់ថា ខេត្តឧត្តរមានជ័យពុំមានតុលាការទេ។ រាល់វិវាទ ឬបទល្មើសនានា ត្រូវតែបញ្ជូនមកតុលាការខេត្តសៀមរាប។ ហេតុដូចនេះ ការយល់ដឹងរបស់ប្រជាពលរដ្ឋពីច្បាប់ និងយុត្តិធម៌ គឺនៅមានកម្រិតទាបណាស់ ហើយយុត្តិធម៌សហគមន៍ គឺជាយន្តការតែមួយគត់សម្រាប់ដោះស្រាយវិវាទ និងបទល្មើសមជ្ឈិមមួយចំនួន។ គម្រោងរបស់ BFD ត្រូវបានវាយតម្លៃខ្ពស់ដោយប្រជាពលរដ្ឋ និងអាជ្ញាធរ។ គោលបំណងនៃគម្រោងនេះ គឺមិនគ្រាន់តែចង់ដោះស្រាយវិវាទប៉ុណ្ណោះទេ ថែមទាំងជួយទប់ស្កាត់និងចៀសវាងនូវវិវាទនានា តាមរយៈការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មាន ព្រមទាំងតាមដានវិវាទក្រោយដំណើរការដោះស្រាយទៀតផង។

BFD មិនបានផ្តល់ការគាំទ្រខាងរដ្ឋបាល ឬហិរញ្ញវត្ថុដល់ HRW និង CPMHRV ទេ ប៉ុន្តែបានផ្តល់កង់មួយដល់ PDV សម្រាប់ការធ្វើដំណើរនៅក្នុងមូលដ្ឋាន។ ទោះជាយ៉ាងនេះក្តី BFD បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការកសាងសមត្ថភាពដល់ PDV HRW និង CPMHRV តាមរយៈការបណ្តុះបណ្តាលពី ២ ទៅ ៣ សប្តាហ៍អំពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ច្បាប់ ទ្រឹស្តីពុទ្ធសាសនា យេនឌ័រ សុខភាព និងការអភិវឌ្ឍ។ អ្នកសម្រុះសម្រួលមិនត្រូវបានបង់ថ្លៃដោយគម្រោងរបស់ BFD ទេ។ នៅក្នុងឃុំកូនក្រៀល អ្នកសម្រុះសម្រួលបានទារថ្លៃ ១០០បាត (១០.០០០រៀល = ២.៥ ដុល្លារអាមេរិក) ពីភាគីនីមួយៗ ដែលជាតម្លៃមួយខ្ពស់សម្រាប់អ្នកនៅក្នុងមូលដ្ឋាន។ រឿងនេះអាចបំបាក់ទឹកចិត្តគ្រួសារក្រីក្រ មិនឱ្យដាក់ពាក្យប្តឹងមកគណៈកម្មាធិការនេះ។

រឿងក្តីមួយដែលត្រូវបានសង្កេតដោយក្រុមស្រាវជ្រាវបានបង្ហាញថា អ្នកសម្រុះសម្រួលមានការយល់ដឹងទាបអំពីច្បាប់ និងសិទ្ធិស្ត្រី។ គូភាគីបានចេញឡោតដាក់គ្នាទៅវិញទៅមក ក្នុងពេលដំណើរការសម្រុះសម្រួល ហើយអ្នកសម្រុះសម្រួលខ្លះក៏មានអកប្បកិរិយាសង្កត់លើភាគីម្ខាងជាងភាគីម្ខាងទៀត។ នៅក្នុងការជួបប្រជុំសម្រុះសម្រួល អ្នកសម្រុះសម្រួលមិនបានព្យាយាមរកឱ្យឃើញពីមូលហេតុឬសគល់នៃវិវាទទេ ប៉ុន្តែបានសង្កត់ធ្ងន់តែទៅលើអ្វីដែលអ្នកប្តឹងទាមទារទៅវិញ។ ទោះបីជាពួកគេដឹងថា

ប្តីបានប្រព្រឹត្តអំពើហិង្សាទៅលើប្រពន្ធជាញឹកញាប់ក្តី ឬមានពេលខ្លះមានបង្ករបួសស្នាមធ្ងន់ធ្ងរថែមទៀត ក៏ពួកគេមិនបានប្រាប់ប្តីថា ទង្វើរបស់គាត់គឺជាបទល្មើសនោះទេ ហើយក៏មិនបានពន្យល់ប្រាប់ប្រពន្ធអំពីសិទ្ធិរបស់ខ្លួន ក្នុងនាមជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ ដើម្បីការស្វែងរកយុត្តិធម៌តាមផ្លូវតុលាការដែរ។ រឿងនេះបង្ហាញថា មានការងារជាច្រើនទៀតដែលត្រូវធ្វើបន្តជាមួយនឹងអ្នកសម្រុះសម្រួល ដើម្បីធានាដល់ការផ្តល់យុត្តិធម៌ ឱ្យបានកាន់តែប្រសើរឡើងជូនស្ត្រី និងភាគីទន់ខ្សោយ។

ការវាយតម្លៃលើគម្រោងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ

គម្រោងទាំងពីរ ដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់មូលដ្ឋាន មានសារៈសំខាន់ណាស់សម្រាប់កែលំអការដោះស្រាយវិវាទនៅថ្នាក់ភូមិនិងថ្នាក់ឃុំ។ តាមការសង្កេតលើរឿងក្តី ដែលបានសម្រុះសម្រួលដោយគណៈកម្មការ ដែលបានបង្កើតឡើងក្រោមគម្រោងទាំងនេះ យើងឃើញថាវាមានតម្រូវការជាបន្ទាន់ ក្នុងការផ្តល់ការបណ្តុះបណ្តាលដល់អ្នកសម្រុះសម្រួល ជាពិសេសនៅក្នុងផ្នែកពីរៈ ១-បច្ចេកទេសដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កើតឱ្យមានបរិយាកាសស្និទ្ធស្នាលក្នុងការដោះស្រាយវិវាទ និង ២-សិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី និងសិទ្ធិកុមារ ដើម្បីបង្កើនការព្រមព្រៀងគ្នា ដោយមិនមានការរំលោភបំពានលើសិទ្ធិរបស់ស្ត្រី និងកុមារតទៅទៀត។ នៅក្នុងករណីរឿងក្តីដែលបានធ្វើការសង្កេតនៅក្នុងគម្រោងទាំងពីរភាគីវិវាទទន់ខ្សោយ (ស្ត្រី ឬ/និង អ្នកក្រីក្រ) ត្រូវបាត់បង់អត្ថប្រយោជន៍ បើប្រៀបធៀបទៅនឹងភាគីអ្នកមានអំណាច។ នេះបង្ហាញពីចំណុចចំណុចខ្សោយ ឬចំណុចខ្វះខាតមួយនៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ លទ្ធផលនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ហាក់ដូចជាមានលក្ខណៈយុត្តិធម៌ ជាងចំពោះករណីដែលគូភាគីមានតុល្យភាពរវាងគ្នានិងគ្នា។ តែក្នុងករណីដែលមានអតុល្យភាពរវាងគូភាគីនោះ អ្នកមានអំណាចគំរាមកំហែងអ្នកទន់ខ្សោយថានឹងបន្តទៅតុលាការ ដូចនេះអ្នកទន់ខ្សោយ ត្រូវតែទទួលនូវអ្វីមួយដែលជាសំណើររបស់ភាគីអ្នកមានអំណាច ទោះបីខ្លួនដឹងថាមិនមានយុត្តិធម៌ក៏ដោយ។ ចំណុចខ្វះខាតទីពីរ គឺទាក់ទងនឹងសមត្ថភាពផ្លូវច្បាប់របស់យន្តការស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងការដោះស្រាយរឿងក្តីជាក់លាក់មួយចំនួន។ ប្រជាពលរដ្ឋស្វែងរកយុត្តិធម៌តាមយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ ចំពោះករណីមួយចំនួនដែលមិនមែនជាសមត្ថកិច្ចរបស់ខ្លួន ដូចជា អំពើហិង្សាក្នុងគ្រួសារ ការលែងលះ និងបទល្មើសព្រហ្មទណ្ឌមួយចំនួន[១៨៤]។ ចំណុចខ្សោយទីបី គឺភាពខ្វះខាតខាងសមត្ថភាព ក្នុងការដាក់ឱ្យអនុវត្តកិច្ចសន្យា ឬអ្វីដែលគូភាគីបានព្រមព្រៀងហើយ។ ទោះបីគូភាគីបានឈានដល់ការព្រមព្រៀងហើយក្តី អ្នកសម្រុះសម្រួលមិនអាចបង្ខំឱ្យភាគីអនុវត្តបានទេ ប្រសិនបើភាគីមួយមិនព្រមបំពេញតាមកិច្ចព្រមព្រៀងនោះ[១៨៥]។ ជាចុងក្រោយ ចំណុចខ្សោយទីបួននៃយន្តការដោះស្រាយវិវាទក្រៅតុលាការ គឺទាក់ទងនឹងនិរន្តភាពរបស់វា។ នៅក្នុងគម្រោងរបស់ CLEC អង្គការក្រៅរដ្ឋាភិបាលជាអ្នកបង់លុយមួយដុល្លារអាមេរិកទៅឱ្យអ្នកសម្រុះសម្រួលម្នាក់ ក្នុងការដោះស្រាយរឿងក្តីមួយ ដែលមានន័យថា អង្គការត្រូវបង់ប្រាក់ចំនួន៣ដុល្លារអាមេរិកក្នុងរឿងក្តីមួយ ដែលធ្វើឱ្យគម្រោងនេះ ពឹងផ្អែកទៅលើមូលនិធិរបស់អង្គការក្រៅរដ្ឋាភិបាលទាំងស្រុង។ នៅក្នុងគម្រោងរបស់ BFD អង្គការក្រៅរដ្ឋាភិបាលមិនបានបង់ថ្លៃទៅឱ្យអ្នកសម្រុះសម្រួលទេ ដោយចៀសវាងលើការពឹងផ្អែកផ្អែកលើការឧបត្ថម្ភទាំងនេះ។ តែបញ្ហាគឺថានៅក្នុងឃុំមួយ អ្នកសម្រុះសម្រួលបានយកថ្លៃ ១០.០០០ រៀល

---

១៨៤ យោងតាមអ្នកស្រុះសម្រួលនៅក្នុងឃុំសាកល្បងចំនួន ៣ ដែលបានចូលរួមក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយ CLEC នៅ ខែធ្នូ ឆ្នាំ ២០០៥ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ បានលើកឡើងថាប្រជាពលរដ្ឋដែលមកប្តឹងភាគច្រើនទាក់ទងនឹងការលែងលះ (ដែលកើតចេញពីអំពើហិង្សាក្នុងគ្រួសារ) ទោះបីក្រុមប្រឹក្សាឃុំពុំមានអំណាច ស្របច្បាប់ដើម្បីដោះស្រាយក៏ដោយក្តី។

១៨៥ ជាឧទាហរណ៍ នៅពេលដែលឪពុកម្តាយមិនបានបំពេញនាទីជាអាណាព្យាបាល ដូចជាមិនបង់ប្រាក់អាហារកិច្ច។ យន្តការដោះស្រាយវិវាទក្រៅតុលាការពុំមានសមត្ថភាពផ្លូវច្បាប់ក្នុងការបង្ខំឱ្យអនុវត្តកិច្ចព្រមព្រៀង និងសម្រេចលើសិទ្ធិណាមួយឡើយ។ ការនេះបញ្ជាក់អំពីតម្រូវការចាំបាច់ ដើម្បីឱ្យមានអង្គភាពមានសមត្ថកិច្ចស្របច្បាប់មួយនៅមូលដ្ឋានដែលមាន អំណាចក្នុងការដោះស្រាយវិវាទនៅមូលដ្ឋាន ផ្តល់សិទ្ធិ និងសម្រេចនៅក្នុងករណីដែលមានអតុល្យភាពរវាងគូភាគី និងអនុវត្តរាល់សេចក្តីសម្រេច និងកិច្ចព្រមព្រៀង។

(២.៩ដុល្លារអាមេរិក) ពីគូភាគីវិវាទម្ខាង ដែលជាតម្លៃមួយខ្ពស់សម្រាប់អ្នកភូមិ ហើយដែលមានតម្លៃថ្លៃជាងប្រាក់ប្រដាប់ក្តីដែលតម្រូវឱ្យបង់ជូនតុលាការ ចំពោះរឿងក្តីរដ្ឋប្បវេណី (៧.០០០រៀល = ១.៧៥ដុល្លារអាមេរិក) ទៅទៀត ។

គុណភាពសេវា និងកម្រិតនៃការពេញចិត្តចំពោះការផ្តល់សេវា:

ជាទូទៅប្រជាពលរដ្ឋគ្រប់រូបចូលចិត្ត ប្តឹងទៅអាជ្ញាធរមូលដ្ឋានជាជាងប្តឹងទៅតុលាការ ។ យោងតាមការស្ទង់មតិរបស់ IRL បានរកឃើញថាកម្រិតនៃការពេញចិត្តរបស់ស្ត្រីចំពោះការផ្តល់សេវាយុត្តិធម៌ មានទាបជាងក្រុមគោលដៅដទៃៗទៀត ។ រីឯការស្ទង់មតិរបស់មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់វិញ បានរកឃើញថាប្រហែលជា ៤០% នៃវិវាទភាគីទន់ខ្សោយសុខចិត្តចុះចាញ់ភាគីអ្នកមានអំណាច ក្នុងដំណើរការសម្រុះសម្រួលទាំងឡាយ ។ ចំពោះមូលហេតុនានា ដែលលើកឡើងដោយអ្នកដែលចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលក្រុមការងារបានសម្ភាស មានដូចខាងក្រោម ។

## ២.២.៤. វាយតម្លៃលើតួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងការដោះស្រាយវិវាទ

ក្រុមប្រឹក្សាឃុំមានតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ ។ នេះជាស្ថាប័នតែមួយគត់ដែលអាចផ្តល់ដំណោះស្រាយនូវវិវាទនានាដែលកើតមាននៅថ្នាក់ឃុំ ក្រៅពីនគរបាល ។ អ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលក្រុមការងារបានសម្ភាសបានលើកឡើងនូវចំណុចខ្លាំង និងអត្ថប្រយោជន៍របស់ក្រុមប្រឹក្សាឃុំជាច្រើន ។

**ការវាយតម្លៃលើយុត្តិធម៌មូលដ្ឋានដោយអ្នកចូលរួមក្នុងសិក្ខាសាលា:**

| | ចំណុចល្អ | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|---|
| **ក្រុមប្រឹក្សាឃុំ** | - ចំណាយ និងប្រើពេលវេលាតិចជាងតុលាការ<br>- ឆ្លើយតបទាន់ពេល និងឆាប់<br>- ងាយរកដោយប្រជាពលរដ្ឋ<br>- ភាគីចូលរួមពេញលេញក្នុងដំណើរការសម្រុះសម្រួល<br>- ប្រជាពលរដ្ឋយល់ច្បាស់ ពីនីតិវិធី និងភាសាដែលប្រើ<br>- អាជ្ញាធរមូលដ្ឋាន យល់ច្បាស់ពីស្ថានភាពនៃគូភាគី និងវិវាទ<br>- រក្សាបាននូវទំនាក់ទំនងល្អឡើងវិញ រវាងគូភាគី<br>- ពេញចិត្តនឹងដំណោះស្រាយដែលបានធ្វើ<br>- មិនលម្អៀង<br>- មានការសម្របសម្រួលល្អ | - បក្សពួកនិយម/ប្រកាន់បកនយោបាយ និងអំពើពុករលួយ ព្រមទាំងខ្វះកិច្ចសហការក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ<br>- សមត្ថភាពនៅមានកម្រិត និងមិនមានសមត្ថកិច្ចផ្លូវច្បាប់សម្រាប់ដោះស្រាយវិវាទមួយចំនួន ដូចជាករណីលែងលះ និងបទឧក្រិដ្ឋនានា<br>- មិនអាចចេញសេចក្តីសម្រេចលើរឿងក្តីបាន ។ នៅពេលដែលភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមប្រឹក្សាឃុំមិនអាចកាត់សេចក្តីបានឡើយ ។<br>- ពុំមាននីតិវិធីសមស្រប និង ច្បាស់លាស់សម្រាប់ដោះស្រាយវិវាទ ដូចជាពុំមានពេលកម្រិតក្នុងការដោះស្រាយជាដើម ។ | - សមាជិកក្រុមប្រឹក្សាគួរតែចៀសវាងការប្រកាន់បក្សពួកនិយម/ប្រកាន់គណបក្សនយោបាយ ហើយធ្វើការរួមគ្នាឱ្យមានភាពរលូន<br>- បង្កើតគណៈកម្មការដោះស្រាយវិវាទនៅក្នុងសហគមន៍ ដោយមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយវិវាទ<br>- ការបណ្តុះបណ្តាលច្បាប់ និងការដោះស្រាយវិវាទដល់អាជ្ញាធរមូលដ្ឋាន និងថ្នាក់ដឹកនាំសហគមន៍<br>- ក្របខ័ណ្ឌច្បាប់សម្រាប់ យន្តការដោះស្រាយនៅមូលដ្ឋាន និងកំណត់ដែនសមត្ថកិច្ចដែលពួកគេអាចសម្រេចបាន<br>- ថ្លៃផ្សេងៗគួរតែត្រូវបានកំណត់ឱ្យបានច្បាស់លាស់ |

| | | | |
|---|---|---|---|
| | | - ធ្វើការស្របតាមទំនៀមទម្លាប់<br>- លទ្ធផលនៃការសម្រុះសម្រួលមិនអាចដាក់ឱ្យអនុវត្តបាន<br>- ខ្វះខាតធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ<br>- មិនគោរពពេលវេលាម៉ោងធ្វើការ<br>- មិនមានប្រព័ន្ធសម្រាប់ទទួលពាក្យបណ្ដឹងសមស្រប<br>- គ្មានមូលដ្ឋានច្បាប់សម្រាប់ការសម្រុះសម្រួល<br>- មិនមានអំណាចក្នុងការកាត់សេចក្ដី សម្រាប់ករណីមានអតុល្យភាព រវាងគូភាគី<br>- ខ្វះតម្លាភាពក្នុងការទាមទារថ្លៃឈ្នួល | - កាលកំណត់ពេលវេលាសម្រាប់រឿងក្ដីមួយត្រូវតែបានកំណត់<br>- គោរពម៉ោងពេលធ្វើការ<br>- គួរតែបែងចែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ |

២.២.៤.(១). ចំណុចខ្លាំង និងអត្ថប្រយោជន៍របស់យុត្តិធម៌មូលដ្ឋានៈ

បើសិនជាពុំមានអាជ្ញាធរឃុំនៅថ្នាក់មូលដ្ឋាន (នៅតាមតំបន់ជនបទ) ទេ នោះប្រហែលជាស្ត្រីគ្មានកន្លែងសម្រាប់ខ្លួនអាចប្ដឹងដើម្បីទាមទារប្រាក់អាហារកិច្ច ឬអ្នកភូមិនៅជនបទមិនមានយន្តការដោះស្រាយវិវាទ ដែលកើតមាននៅមូលដ្ឋានទេ ហើយជនរងគ្រោះប្រហែលជាមិនអាចទទួលបាននូវសំណងខូចខាតណាមួយឡើយ។

ចំពោះគុណប្រយោជន៍ទាំងនោះមានដូចជាៈ

ក. **មានទីតាំងនៅជិតប្រជាពលរដ្ឋៈ** អាជ្ញាធរមូលដ្ឋាននៅជិតប្រជាពលរដ្ឋដែលរស់នៅតាមភូមិ និងឃុំនៅជនបទ។ ដូចនេះ ភាគីវិវាទមិនចាំបាច់ចំណាយពេល និងធនធានច្រើនដើម្បីធ្វើដំណើរទៅកាន់ទីរួមខេត្តទេ។ នេះជាមូលហេតុដ៏សំខាន់ក្នុងការដាក់ឱ្យមានយន្តការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន។

ខ. **តម្លៃចំណាយទាបៈ** ដំណើរការដោះស្រាយនៅមូលដ្ឋាន ចំណាយលុយកាក់តិចជាងទៅរកតុលាការ ទោះបីជាប្រជាពលរដ្ឋត្រូវបង់លុយខ្លះ ទៅឱ្យអាជ្ញាធរមូលដ្ឋានក្នុងការជួយដោះស្រាយរឿងក្ដីក៏ដោយ។ អ្នកចូលរួមសិក្ខាសាលាបានត្អូញត្អែរប្រាប់ថា ការដែលប្ដឹងទៅតុលាការ ពួកគេត្រូវចំណាយលុយយ៉ាងច្រើនសម្រាប់រឿងក្ដីរដ្ឋប្បវេណី និងថ្លៃកោសល្យវិច័យសម្រាប់រឿងក្ដីព្រហ្មទណ្ឌ ការធ្វើដំណើរទៅទីរួមខេត្ត(ជាច្រើនលើក) និងការចំណាយក្រៅច្បាប់ផ្សេងទៀតឱ្យទៅបុគ្គលិកតុលាការដូចជាក្រឡាបញ្ជីជាដើម។ ហេតុដូច្នេះហើយការទៅរកអាជ្ញាធរមូលដ្ឋាន ហាក់ដូចជាធូរស្រាលជាង។ ការចំណាយទាបគឺជារឿងមួយសំខាន់ទាក់ទងនឹងរឿងក្ដីនៅមូលដ្ឋាន។

រឿងក្តីមួយចំនួនដែលមិនដែលទៅដល់តុលាការៈ កម្មវត្ថុនៃវិវាទនៅមូលដ្ឋានមួយចំនួនមានតម្លៃជាទឹកប្រាក់តិចតួចណាស់ (អាចត្រឹមតែ២ទៅ៥ដុល្លារអាមេរិក) ប៉ុន្តែវាមានចំនួនច្រើនសម្រាប់អ្នកភូមិ ដែលមានប្រាក់ចំណូលប្រហែលមួយដុល្លារក្នុងមួយថ្ងៃ។ វិវាទប្រភេទនេះកើតមានញឹកញាប់ ហើយមិនដែលបានទៅដល់តុលាការនោះទេ ព្រោះគ្រាន់តែការចំណាយក្នុងការដាក់ពាក្យបណ្តឹងរឿងក្តីមួយនៅតុលាការ មានតម្លៃប្រហែល២ដុល្លារទៅហើយ។ អត្ថិភាពនៃយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ធ្វើឱ្យអ្នកក្រីក្រមានដំណោះស្រាយសម្រាប់វិវាទ កើតមានក្នុងជីវិតប្រចាំថ្ងៃទាំងនេះ។ ហេតុដូច្នេះនេះជាមូលហេតុ ដ៏សំខាន់ក្នុងការដាក់ឱ្យមានយន្តការដោះស្រាយវិវាទនៅថ្នាក់មូលដ្ឋាន។

តម្លៃក៏ជារាំងស្ទះដល់ស្ត្រី និងជនរងគ្រោះក្នុងការប្តឹងទៅតុលាការដែរៈ ប្រសិនបើស្ត្រីត្រូវចិញ្ចឹមកូននោះ ពួកគេមិនមានធនធានសម្រាប់ទៅប្តឹងតុលាការ ដើម្បីស្នើសុំអាហារកិច្ច ឬការលែងលះទេ ដូចនេះស្ត្រីទៅរកអាជ្ញាធរមូលដ្ឋាន ទោះបីពួកគេមិនមានសមត្ថកិច្ចផ្លូវច្បាប់ ក្នុងការដោះស្រាយការលែងលះ ឬអាហារកិច្ចក៏ដោយ។ តម្លៃក៏ជាឧបសគ្គដល់ជនរងគ្រោះក្នុងការទៅប្តឹងតុលាការដែរ (ដោយសារពួកគេត្រូវបង់ថ្លៃធ្វើកោសល្យវិច្ច័យ ហើយពួកគេប្រហែលជាមិនបានទទួលសំណងការខូចខាត) ហេតុនេះពួកគេចូលចិត្តដោះស្រាយនៅចំពោះមុខអាជ្ញាធរមូលដ្ឋាន ឬនគរបាលវិញ។ ក្នុងករណីទាំងនេះប្រហែលជាវាទាមទារឱ្យមានយន្តការដោះស្រាយវិវាទផ្សេងៗទៀតជំនួសវិញ។

ប្រសិនបើមុខងារសម្រុះសម្រួលត្រូវបានគេពង្រីងទៅថ្នាក់មូលដ្ឋាន នោះដំណោះស្រាយវិវាទទាំងនេះអាចត្រូវធ្វើឡើងដោយអាជ្ញាធរឯករាជ្យ ហើយរដ្ឋគួរតែពិចារណាលើការផ្តល់មូលនិធិ បើមិនដូច្នោះទេ ជាបន្ទុកនេះនឹងធ្លាក់មកលើអ្នកក្រីក្រ។ អាជ្ញាធរមូលដ្ឋាន (មេភូមិ និងក្រុមប្រឹក្សាឃុំ) ទទួលបានប្រាក់បៀវត្សរ៍តិចណាស់បើប្រៀបធៀបទៅនឹងអ្នកផ្តល់សេវាយុត្តិធម៌ដទៃទៀត ដូចជាចៅក្រម ឬអាជ្ញាកណ្តាល តែពួកគេដើរតួយ៉ាងសំខាន់ក្នុងការចូលរួម ក្នុងវិស័យសន្តិភាពសង្គម។

**៣. ការយល់ដឹងផ្នែកវប្បធម៌ :** អាជ្ញាធរមូលដ្ឋានរស់នៅក្នុងតំបន់នោះស្រាប់ ពួកគេមានភាពស៊ាំជាមួយនឹងរឿងរ៉ាវនៅមូលដ្ឋាន និងដឹងច្បាស់ពីបរិបទនៃវិវាទដែលពួកគេទទួល។ អាជ្ញាធរមូលដ្ឋាន និងអ្នកភូមិប្រើប្រាស់ភាសាដូចគ្នា ហើយការដោះស្រាយវិវាទគឺយោងទៅលើតម្លៃរួម (ទម្លាប់)។ ពួកគេមិនត្រូវការរកមើលក្រមឬច្បាប់ ដែលគេមិនស្គាល់ណាមួយដើម្បីដោះស្រាយរឿងក្តីនោះទេ។ រឿងនេះបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ដែលប្រព័ន្ធយុត្តិធម៌ នៅមូលដ្ឋានប្រើភាសា និងនីតិវិធីដែលងាយយល់សម្រាប់អតិថិជន (ភាគីវិវាទ) ដោយគិតទៅដល់ក្របខ័ណ្ឌវប្បធម៌ ទំនៀមទម្លាប់ និងតម្លៃរួម។ តែទំនៀមទម្លាប់ ឬតម្លៃជាប្រពៃណីមួយចំនួន បានក្លាយជាបញ្ហាចំពោះអ្វីដែលជាតម្លៃថ្មីៗ ដូចជាករណីទាក់ទិននឹងអំពើហិង្សាក្នុងគ្រួសារ។ ប្រជាពលរដ្ឋមួយចំនួន នៅតែមានជំនឿតាមប្រពៃណីថា "បុរសនៅក្នុងគ្រួសារមានសិទ្ធិដាក់វិន័យលើស្ត្រី និងកូនដោយប្រើកម្លាំង"។ តែឥឡូវនេះ ស្ត្រីភាគច្រើនយល់ដឹងពីសិទ្ធិរបស់ពួកគេ ហើយពួកគេប្រឈមនឹងទស្សនៈនេះ។ ឧទាហរណ៍នេះបង្ហាញពីតម្រូវការឱ្យមានយន្តការផ្តល់យុត្តិធម៌នៅមូលដ្ឋាន ដែលយន្តការត្រូវរកឱ្យឃើញនូវតុល្យភាព ចំពោះការយកចិត្តទុកដាក់ដល់ភាសា វប្បធម៌ និងតម្លៃរបស់មូលដ្ឋាន ជាមួយនឹងភាពចាំបាច់ក្នុងការបើកចំហដល់តម្លៃ និងសិទ្ធិថ្មីៗ ដូចជាសិទ្ធិស្ត្រី និងសិទ្ធិកុមារជាដើម។ ក្នុងន័យនេះ ចាំបាច់ត្រូវមានការផ្សព្វផ្សាយ និងបណ្តុះបណ្តាលពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ។ ប្រធានបទនេះក៏ប្រឈមមុខនឹងសមាសភាពបច្ចុប្បន្ន នៃអ្នកផ្តល់សេវាយុត្តិធម៌ដែលមានតែបុរសភាគច្រើន។ ចុងក្រោយគឺការខ្វះខាតនូវយន្តការសម្រាប់ប្តឹងតវ៉ាជាក់លាក់ ដើម្បីការពារសិទ្ធិនៅពេលដែលវិវាទមិនទាក់ទងនឹងអត្ថប្រយោជន៍ ប៉ុន្តែទាក់ទងនឹងសិទ្ធិ (ដូចជាសិទ្ធិកុមារ)។

ឃ. **វិធីសាស្ត្រក្នុងការសម្រុះសម្រួលដើម្បីដោះស្រាយវិវាទៈ** វិធីសាស្ត្រក្នុងការសម្រុះសម្រួល ដែលបានអនុវត្តដោយអាជ្ញាធរមូលដ្ឋាន មានការទាក់ទងនឹងវប្បធម៌នៃការសម្រុះសម្រួល ដែលមានរយៈពេលវែង និងទូលំទូលាយ។ អ្នកចូលរួមសិក្ខាសាលា និងអ្នកដែលត្រូវបានគេសម្ភាសបានសង្កត់ធ្ងន់ថា គុណធម៌មួយនៃការដោះស្រាយវិវាទនៅមូលដ្ឋាន គឺលទ្ធភាពក្នុងការចូលរួមរបស់ភាគីក្នុងដំណើរការដោះស្រាយ ដោយផ្អែកលើការចរចារ និងការសម្រុះសម្រួលរវាងពួកគេ។ នេះក៏គឺជាគន្លឹះមួយសម្រាប់ប្រសិទ្ធិភាពនៃប្រព័ន្ធនេះ ដោយវាមានភាពងាយស្រួលជាង នៅពេលដែលគូភាគីបង់សំណង ឬធ្វើអ្វីដែលគេមានការស្រុះស្រួលគ្នា ជាជាងអ្វីមួយដែលភាគីទីបីដោះស្រាយឱ្យពួកគេ។ ឥទ្ធិពលល្អមួយទៀត ដែលបានលើកឡើងដោយអ្នកចូលរួមសិក្ខាសាលាគឺ ទំនាក់ទំនងល្អរវាងគូភាគីអាចបង្កើតឡើងវិញបាន ដោយសារមិនមានអ្នកចាញ់ ឬអ្នកឈ្នះ។

**រឿងក្តីដែលអាចធ្វើការសម្រុះសម្រួលបានជោគជ័យៈ** នៅក្នុងរឿងក្តីភាគច្រើនដែលបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមូលដ្ឋាន ពួកគេបានសម្របសម្រួលដោយផ្តល់បរិយាកាសក្នុងការចរចាសម្រុះសម្រួល និងការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគី។ ពេលខ្លះពួកគេក៏ដាក់សំពាធទៅលើគូភាគី ដើម្បីឈានដល់ការព្រមព្រៀងគ្នាដែរ នៅពេលដែលគូភាគីចំណាយពេលយូរ ហើយមិនទាន់ស្រុះស្រួលគ្នាទៀត។ នៅពេលដែលពួកគេឈានដល់ការព្រមព្រៀងគ្នា ពួកគេចុះហត្ថលេខានៅចំពោះមុខអាជ្ញាធរមូលដ្ឋាន។ យន្តការនេះហាក់ដូចជាមានប្រសិទ្ធិភាព និងមានយុត្តិធម៌សម្រាប់វិវាទក្នុងជីវភាពប្រចាំថ្ងៃ ជាពិសេសនៅពេលគូភាគីវិវាទមានស្ថានភាពប្រហាក់ប្រហែលគ្នា (មានតុល្យភាពអំណាច)។ វិវាទនៅក្នុងមូលដ្ឋាន និងបទល្មើសតូចតាចមានប្រហែល ២៥% នៃរឿងក្តីដែលបានទទួលដោះស្រាយដោយឃុំ។ ២៥%ទៀត គឺជាវិវាទលើដីធ្លីតូចតាច។ ការដោះស្រាយវិវាទនៅមូលដ្ឋាន អាចត្រូវបានពង្រឹងសម្រាប់វិវាទនៅមូលដ្ឋានប្រភេទបែបទាំងនេះ ជាពិសេសនៅពេលដែលកម្មវត្ថុរឿងក្តីមិនមែនជារឿងធំដុំហើយគូភាគីមានភាពស្មើគ្នា ដែលជាទំនាស់ផលប្រយោជន៍ និងមិនមានការរំលោភសិទ្ធិធ្ងន់ធ្ងរនោះ។

ង. **ប្រសិទ្ធិភាពរបស់យុត្តិធម៌មូលដ្ឋានៈ** តារាងខាងក្រោមនេះ ឆ្លុះបង្ហាញអំពីកម្រិតនៃប្រសិទ្ធិភាពការងារក្នុងការដោះស្រាយវិវាទនៅថ្នាក់ឃុំ ដោយឈរឧទាហរណ៍ពីឃុំចំនួន៣ នៅខេត្ត៣ផ្សេងៗពីគ្នា រួមមានខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ធំ។

លទ្ធផល ឬរបកគំហើញនៃការសិក្សាលើដំណោះស្រាយ នូវរាល់ករណីវិវាទទាំងនេះមានដូចខាងក្រោមៈ

- **(ភាគរយ) ក្នុងចំណោមរឿងក្តីដែលទទួលដោយក្រុមប្រឹក្សាឃុំ រយៈពេលគិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងរហូតដល់កាលបរិច្ឆេទនៃការសម្រុះសម្រួលគឺៈ**
  - i- ចន្លោះពី ៧៣% ទៅ ៩២% នៃរឿងក្តីដែលបានទទួលត្រូវបានសម្រុះសម្រួលក្នុងរយៈពេល ១សប្តាហ៍ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងមក។
  - ii- ចន្លោះពី ៩% ទៅ ២៣% នៃរឿងក្តីដែលបានទទួលត្រូវបានសម្រុះសម្រួលក្នុងរយៈពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងមក។
  - iii- ចន្លោះពី ៤% ទៅ ៩% នៃរឿងក្តីដែលបានទទួលត្រូវបានសម្រុះសម្រួលក្នុងរយៈពេល ១ខែ ឬលើស គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹងមក។

- **ភាគរយនៃរឿងក្តីដែលឈានដល់កិច្ចព្រមព្រៀង ក្នុងចំណោមរឿងក្តីទាំងអស់ដែលបានសម្រុះសម្រួលៈ**
  - i- ចន្លោះពី ៦០% ទៅ ៩០% នៃរឿងក្តីដែលបានទទួលត្រូវបានសម្រុះសម្រួលដោយក្រុមប្រឹក្សាឃុំ ហើយបានឈានដល់កិច្ចព្រមព្រៀង (ភាគីបញ្ចប់វិវាទ)។

- **ចំនួនដងនៃការសម្រុះសម្រួលក្នុងរឿងក្តីមួយៗ:**
  - i- ប្រហែល ៦៦% នៃករណីដែលបានទទួលទាំងអស់ ត្រូវបានភាគីស្រុះស្រួលគ្នា ដោយមានការសម្រុះសម្រួលតែចំនួន ១ ដង ប៉ុណ្ណោះ។
  - ii- ប្រហែល ២៨% នៃករណីដែលបានទទួលទាំងអស់ ត្រូវបានភាគីស្រុះស្រួលគ្នា ដោយមានការសម្រុះសម្រួលតែចំនួន ២ ដង ប៉ុណ្ណោះ។
  - iii- ប្រហែល ៦% នៃករណីដែលបានទទួលទាំងអស់ ត្រូវបានភាគីស្រុះស្រួលគ្នា ដោយមានការសម្រុះសម្រួលចំនួន ៣ ដង ឬច្រើនជាង។

- **ភាគរយនៃរឿងក្តីភាគីបានស្រុះស្រួលគ្នាបញ្ចប់វិវាទបន្ទាប់ពីការសម្រុះសម្រួល ក្នុងចំណោមរឿងក្តីទាំងអស់ដែលក្រុមប្រឹក្សាឃុំបានទទួល:** ក្នុងចំណោមរឿងក្តីទាំងអស់ដែលក្រុមប្រឹក្សាឃុំបានទទួល គឺមានប្រមាណពី ៦០% ទៅ ៧០% នៃរឿងក្តីទាំងអស់ ភាគីបានឯកភាពគ្នាបញ្ចប់វិវាទបន្ទាប់ពីការសម្រុះសម្រួល។ ក្នុងចំណោមករណីដែលគូភាគីស្រុះស្រួលគ្នាទាំងនេះ:
  - i- មានប្រមាណពី ៦៣% ទៅ ៨៩% ត្រូវបានស្រុះស្រួលគ្នាក្នុងរយៈពេល ១ សប្តាហ៍
  - ii- មានប្រមាណពី ១១% ទៅ ៤៥% ត្រូវបានស្រុះស្រួលគ្នាក្នុងរយៈពេល ២ សប្តាហ៍
  - iii- ហើយក្រៅពីនេះត្រូវបានស្រុះស្រួលគ្នាក្នុងរយៈពេល ១ ខែឬលើស

**តារាងស្តីពីប្រសិទ្ធិភាពនៃការដោះស្រាយវិវាទនៅថ្នាក់ឃុំ:**

| ភាគរយ | ខេត្តកំពង់ឆ្នាំង | ខេត្តកំពង់ស្ពឺ | ខេត្តកំពង់ធំ [១៨៦] |
|---|---|---|---|
| ចំនួនរឿងក្តីដែលបានទទួលសរុប | ២៩ | ៤៨ | ១៥ |
| ភាគរយនៃរឿងក្តីដែលបានសម្រុះសម្រួលក្នុងចំណោមរឿងក្តីទាំងអស់ដែលបានទទួល : | ៧៦% (២២/២៩) | មានឯកសារតែ១១ | ១០០% (១៥/១៥) |
| i. សម្រុះសម្រួលក្នុង១សប្តាហ៍គិតពីថ្ងៃទទួលបណ្តឹង | ៧៣ % (១៦/២២) | ៨២ % (៩/១១) | ៩២ % (១៤/១៥) |
| ii. សម្រុះសម្រួលក្នុង២សប្តាហ៍គិតពីថ្ងៃទទួលបណ្តឹង | ២៣ % (៥/២២) | ៩ % (១/១១) | ១០ % (១/១៥) |
| iii. សម្រុះសម្រួលក្នុង១ខែ ឬលើសគិតពីថ្ងៃទទួលបណ្តឹង | ៤ % (១/២២) | ៩ % (១/១១) | ០ % (០/១៥) |
| ភាគរយករណីដែលភាគីស្រុះស្រួលគ្នា និងករណីដែលភាគី មិនចុះសម្រុងគ្នាបន្ទាប់ពីមានការសម្រុះសម្រួលដោយ ក្រុមប្រឹក្សាឃុំ : | | | |
| i. សម្រុះសម្រួលហើយ **ស្រុះស្រួលគ្នា** | ៩០ % (២០/២២) | ខ្វះឯកសារ | ៦០% (៩/១៥) |
| ii. សម្រុះសម្រួលហើយ **មិនស្រុះស្រួលគ្នា** | ១០ % (២/២២) | ខ្វះឯកសារ | ៤០% (៦/១៥) |
| ចំនួននៃការសម្រុះសម្រួលគ្នាក្នុងករណីនីមួយៗ : | | | |
| i. សម្រុះសម្រួលតែម្តង (១ ដង) | ៦៦ % (១២/១៨) | ខ្វះឯកសារ | ខ្វះឯកសារ |
| ii. សម្រុះសម្រួលពីរដង (២ ដង) | ២៨% (៥/១៨) | ខ្វះឯកសារ | ខ្វះឯកសារ |
| iii. សម្រុះសម្រួលបីដង ឬលើស (៣ ដងឡើង) | ៦ % (១/១៨) | ខ្វះឯកសារ | ខ្វះឯកសារ |

[១៨៦] យោងតាមបទសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាឃុំតាំងក្រសាំង បានឱ្យដឹងថា មានរឿងក្តីប្រមាណជា ៨០% ត្រូវបានដោះស្រាយចប់សព្វគ្រប់នៅថ្នាក់ភូមិតាមរយៈអនុគណៈកម្មការដោះស្រាយវិវាទថ្នាក់ភូមិ។ ហើយក្នុងចំណោមរឿងក្តី ដែលបានបញ្ជូនមកគណៈកម្មការដោះស្រាយវិវាទថ្នាក់ឃុំ គណៈកម្មការនេះបានដោះស្រាយបានប្រមាណជា ៦៧ % ។ សូមមើលបទសម្ភាសលេខ KT2 នៅក្នុងតារាងអ្នកដែលក្រុមការងារស្រាវជ្រាវ បានសម្ភាសក្នុងឧបសម្ព័ន្ធទី ៣។

| | | | |
|---|---|---|---|
| ភាគរយនៃរឿងក្តីដែលភាគីស្រុះស្រួលគ្នា ធៀបនឹងចំនួនរឿងក្តីដែលប្តឹងមកក្រុមប្រឹក្សាឃុំទាំងអស់ : | ៦៩% (២០/២៩) ខ្វះឯកសារ១ករណី | ៦៧ % (៣២/៤៨) ខ្វះឯកសារ១៤ករណី | ៦០ % (៩/១៥) |
| i. ព្រមព្រៀងក្នុងរយៈពេល១សប្តាហ៍ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង | ៦៣ % (១២/១៩) | ៥០% (៩/១៨) | ៨៩% (៨/៩) |
| ii. ព្រមព្រៀងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង | ៣១ % (៦/១៩) | ៤៥ % (៨/១៨) | ១១% (១/៩) |
| iii. ព្រមព្រៀងក្នុងរយៈពេល១ខែឡើង បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង | ៦ % (១/១៩) | ៥ % (១/១៨) | 0 % (0/៩) |
| ភាគរយនៃរឿងក្តី ដែលមិនមានកំណត់ហេតុសម្រុះសម្រួល | ១៨ % (៥/២៩) វិវាទដីធ្លី២ បរិហារកេរ្តិ៍១ ហិង្សាក្នុងគ្រួសារ១ អណ្តូងសាធារណៈ១ | ២៥ % (១២/៤៨) វិវាទដីធ្លី៣ បំណុល១ ហិង្សាយេនឌ័រ៥ បំផ្លាញទ្រព្យអ្នកដទៃ១ វិវាទអ្នកជិតខាង ២ | 0 % (0/១៥) |

២.២.៤.(២). ចំណុចខ្សោយ និងការរិះគន់បំពោះក្រុមប្រឹក្សាឃុំរួមមាន :

ទោះបីជាទូទៅ មានការទទួលស្គាល់អំពីអត្ថប្រយោជន៍ នៃការដោះស្រាយវិវាទនៅមូលដ្ឋានក៏ដោយក្តី តែអ្នកចូលរួមក្នុងសិក្ខាសាលា និងអ្នកដែលក្រុមការងារសិក្សាស្រាវជ្រាវបានសម្ភាសមួយចំនួន បានលើកឡើងផងដែរ នូវបញ្ហាឬការមិនពេញចិត្តមួយចំនួន ដែលជាចំណុចខ្សោយរបស់យុត្តិធម៌មូលដ្ឋាននេះ ។ យោងតាមការសិក្សា និងការសង្កេតមើលដំណើរការដោះស្រាយវិវាទ ក្រុមការងារបានរកឃើញដូចអ្វីដែលប្រជាពលរដ្ឋមួយចំនួនបារម្ភ ឬមិនពេញចិត្តមែន។ ចំពោះចំណុចខ្សោយនៃការសម្រុះសម្រួលនៅថ្នាក់មូលដ្ឋានមានដូចជា :

**ក. ការចរចាដោយគ្មានតុល្យភាពអាចឈានទៅដល់ដំណោះស្រាយដោយអយុត្តិធម៌:** នៅពេលមានអតុល្យភាពទំនាក់ទំនងរវាងគូភាគី វាជាការលំបាកដែលថាលទ្ធផលនៃការសម្រុះសម្រួលនឹងមានភាពយុត្តិធម៌ ពីព្រោះភាគីអ្នកមានអំណាចប្រហែលជាព្យាយាមប្រើអំណាចរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍ពីភាគីទន់ខ្សោយ។ ការសម្រុះសម្រួលយោងទៅលើសមត្ថភាពរបស់គូភាគីជាចម្បង ដើម្បីបង្ហាញការការពារ និងចរចារអត្ថប្រយោជន៍របស់គេ។ អ្នកសម្រុះសម្រួលមិនផ្តោតសំខាន់ទៅលើរឿងសិទ្ធិ ឬការពិតទេ ប៉ុន្តែផ្តោតសំខាន់ទៅលើការឈានទៅដល់ការព្រមព្រៀងគ្នា ហើយដោយសាររឿងនេះ អ្នកសម្រុះសម្រួលលើកទឹកចិត្តគូភាគី ឱ្យកាត់បន្ថយការទាមទាររបស់ខ្លួន ដោយមិនគិតថាការទាមទារមួយចំនួនគឺជាសិទ្ធិរបស់ភាគី (ដូចជាសិទ្ធិខាងអាហារកិច្ច) ឬយ៉ាងណានោះទេ។ ក្នុងស្ថានភាពបែបនេះ ភាគីទន់ខ្សោយជាងច្រើនតែចុះចាញ់ ឬត្រូវកាត់បន្ថយការទាមទាររបស់ខ្លួន ទោះបីជាអ្វីដែលខ្លួនទាមទារជាសិទ្ធិក៏ដោយ។ ស្ថានភាពនេះអាចកើតឡើង ជាពិសេសនៅពេលភាគីម្ខាងមានការគាំទ្រផ្នែកនយោបាយ ហើយភាគីម្ខាងទៀតគ្មាន ឬក្នុងករណីដែលភាគីម្ខាង មានទ្រព្យសម្បត្តិធនធានច្រើនជាងភាគីម្ខាងទៀត ហេតុនេះអ្នកដែលទន់ខ្សោយមិនអាចទៅប្តឹងតុលាការបានទេ ឬករណីស្ត្រីត្រូវបានគេបោះបង់ចោលជាមួយកូន ដូចនេះពួកគេសុខចិត្តទទួលយក "អ្វីមួយជាជាងការដែលអត់អ្វីសោះ។

ករណីដែលមានអតុល្យភាពរវាងគូភាគី ជាសញ្ញាមួយនៃភាពទន់ខ្សោយរបស់ប្រព័ន្ធដោះស្រាយវិវាទ នៅមូលដ្ឋាន។ ទោះជាយ៉ាងនេះក្តី នេះក៏ជាបញ្ហាមួយដែលកើតមាននៅក្នុងប្រព័ន្ធតុលាការដែរ ដែលតុលាការហាក់ដូចជា ដោះស្រាយលម្អៀងទៅរកភាគីមានអំណាច ព្រោះភាគីនោះមានធនធានផ្នែកច្បាប់ (ឬមិនស្របច្បាប់) ច្រើនជាង ដើម្បីការពារជំហររបស់ខ្លួន។ នៅក្នុងស្ថានភាពបែបនេះ វាហាក់ដូចជាចាំបាច់ដែលត្រូវ: ក-ផ្តល់សិទ្ធិអំណាចឱ្យភាគីទន់ខ្សោយ(ជាពិសេសស្ត្រី) ដើម្បីចូលរួមដោយមានសមត្ថភាពល្អជាងនេះ នៅក្នុងដំណើរការចរចា ក៏ដូចជាក្នុងដំណើរការក្តីតាមផ្លូវច្បាប់។ ការយល់ដឹងពីសិទ្ធិ និងច្បាប់ជាឧបករណ៍មួយសំខាន់សម្រាប់គោលបំណងនេះ ខ-បង្កើនការយល់ដឹងសិទ្ធិស្ត្រី និងកុមារក្នុងចំណោមអាជ្ញាធរមូលដ្ឋាន ដើម្បីការពារកុំឱ្យមានការសម្រុះសម្រួលក្រៅផ្លូវការ ដោយរំលោភលើសិទ្ធិទាំងនោះ ហើយ គ-បង្កើតអាជ្ញាធរដែលមានអំណាចយុត្តាធិការឱ្យទៅជិតប្រជាពលរដ្ឋ ដែលអាជ្ញាធរនេះមានសមត្ថភាពក្នុងការកាត់សេចក្តី ដោយយោងលើសិទ្ធិ និងអាចបង្ខំឱ្យភាគីណាមួយ ដែលបដិសេធមិនព្រមបំពេញការទទួលខុសត្រូវរបស់ខ្លួន ឱ្យគោរពខាងតែបាន (ដូចជាការផ្តល់អាហារកិច្ច)។

យោងតាមការស្ទង់មតិរបស់ IRL:
ស្ត្រីយល់ថាអាជ្ញាធរឃុំមានភាពលម្អៀងទៅរកភាគីដែលជាអ្នកមាន និងអ្នកមានអំណាច[១៨៧]។




*ការស្ទង់មតិរបស់* IRL *(ទំព័រ ៦៣)*

**ខ. មិនមានសមត្ថភាពក្នុងការកាត់សេចក្តី:** នៅពេលដែលភាគីមួយមិនព្រម អ្នកសម្រុះសម្រួលមិនមានសមត្ថភាពផ្លូវច្បាប់ ដើម្បីដោះស្រាយដោយចេញសេចក្តីសម្រេចចុងក្រោយឡើយ។ ដើម្បីទទួលបានសេចក្តីសម្រេចចុងក្រោយ ចាំបាច់ភាគីត្រូវប្តឹងទៅតុលាការ។ ប៉ុន្តែតុលាការនៅឆ្ងាយពីប្រជាពលរដ្ឋ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ត្រូវចំណាយខ្ពស់ ប្រើពេលវេលាយូរ និងពួកគេមិនស្គាល់ពីនីតិវិធីតុលាការច្បាស់ឡើយ។ គំនិតដែលថាប្តឹងទៅតុលាការ ដើម្បីឱ្យមានសេចក្តីសម្រេចចុងក្រោយនោះ មិនបានលើកទឹកចិត្តដល់ភាគីទន់ខ្សោយទេ តែបែរជាហេតុផលដែលនាំឱ្យពួកគេ អាចបោះបង់នូវសិទ្ធិនេះ ឬសុខចិត្តទទួលយកការព្រមព្រៀងមួយ ដែលមិនយុត្តិធម៌សម្រាប់ខ្លួន ជាជាងទៅតុលាការ។ នៅក្នុងកាលៈទេសៈនេះ ចាំបាច់ក្នុងការបង្កើតអាជ្ញាធរយុត្តាធិការ ដែលមានសមត្ថកិច្ចផ្លូវច្បាប់ឱ្យនៅជិតប្រជាពលរដ្ឋ ដោយមានសមត្ថភាពក្នុងការសម្រុះសម្រួល ប៉ុន្តែនៅពេលចុងក្រោយមានសមត្ថកិច្ចផ្លូវច្បាប់ក្នុងការសម្រេចសេចក្តីផងដែរ។ អង្គភាពដែលមានយុត្តាធិការមួយនេះ គួរតែមានតម្លៃថោកសមរម្យ យកចិត្តទុកដាក់ចំពោះបញ្ហាភាសា ហើយគួរតែបត់បែនបាន និងឆ្លើយតបចំពោះតម្លៃរួមរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃអាជ្ញាធរនេះ។

[១៨៧] គួរកត់សំគាល់ថា តាមការស្ទង់មតិ ស្ត្រីបានលើកឡើងថាក្រុមប្រឹក្សាឃុំពុំមានភាពលម្អៀងទៅបុរសទេ។ ទោះបីយើងបានសង្កេតមើលការសម្រុះសម្រួលរឿងក្តីនៅមូលដ្ឋាន យើងឃើញថាអាជ្ញាធរមូលដ្ឋានមិនអើពើអំពីអំពើហិង្សាក្នុងគ្រួសារដែលកើតមានកន្លងមក ។ នេះប្រហែលជាមកពីស្ត្រីមិនមានការយល់អំពីសិទ្ធិរបស់ពួកគេ។

គ. **មិនអាចអនុវត្តកិច្ចព្រមព្រៀង ឬសេចក្ដីសម្រេចបានៈ** ជាគោលការណ៍ កិច្ចព្រមព្រៀងដែលធ្វើនៅមូលដ្ឋានត្រូវបានគេអនុវត្តភ្លាមៗ (ដូចជា ការសុំទោស បង់ប្រាក់ចំនួនណាមួយ ឬការឱ្យរបស់ណាមួយទៅម្ចាស់ដើមវិញ)។ ទោះជាយ៉ាងនេះក្ដី ក៏មានកិច្ចព្រមព្រៀងមួយចំនួន ដែលតម្រូវឱ្យភាគីត្រូវបំពេញនៅពេលក្រោយជាបន្តបន្ទាប់ ដែលករណីនេះភាគីខ្លះមិនបំពេញតាមអ្វីដែលខ្លួនបានសន្យាទេ ដូចជា ការខកខានក្នុងការផ្ដល់អាហារកិច្ច ឬនៅតែបន្តអំពើហិង្សាជាដើម។ នេះគឺជាចំណុចខ្វះខាតរបស់អាជ្ញាធរមូលដ្ឋានមួយផ្សេងទៀត ដោយពួកគេមិនមានសមត្ថកិច្ច ផ្លូវច្បាប់ ឬមធ្យោបាយដើម្បីអនុវត្តកិច្ចព្រមព្រៀង ឬសេចក្ដីសម្រេចឡើយ។ នៅក្នុងករណីខ្លះទៀត គូភាគីបានធ្វើកិច្ចព្រមព្រៀងក្រៅផ្លូវការ ឬភាគីមានអំណាចចាត់វិធានការណាមួយដោយខ្លួនឯង (De facto measures taken by the powerful party) ។ ទោះជាយ៉ាងនេះក្ដី គួរកត់សំគាល់ថាការអនុវត្តសេចក្ដីសម្រេចនេះ អាចជាបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀតសម្រាប់តុលាការ ដោយហេតុថាចាំបាច់ត្រូវមានការប្ដឹងសុំអនុវត្តសាលក្រម ហើយតុលាការមានតែនៅក្នុងទីរួមខេត្តឆ្ងាយពីភូមិ ឃុំ ដូច្នេះហើយពួកគេត្រូវតែបញ្ជូននគរបាលពីទីរួមខេត្តដើម្បីអនុវត្តសេចក្ដីសម្រេច។ បើគិតដល់អង្គហេតុទាំងអស់នេះ វាជាការមួយចាំបាច់ណាស់ ក្នុងការបង្កើតអាជ្ញាធរមានយុត្តាធិការមួយនៅមូលដ្ឋាន (អាចនៅថ្នាក់ស្រុក) ដែលមានសមត្ថកិច្ចផ្លូវច្បាប់ ក្នុងការអនុវត្តកិច្ចព្រមព្រៀង និងសេចក្ដីសម្រេចទាំងនេះ។

ឃ. **មិនអាចផ្ដល់សិទ្ធិៈ** ប្រព័ន្ធសម្រុះសម្រួល អាចសម្របសម្រួលការសម្រុះសម្រួល រវាងគូភាគីវិវាទ ប៉ុន្តែវាមិនមានសមត្ថកិច្ចផ្លូវច្បាប់ដើម្បីផ្ដល់សិទ្ធិ នៅពេលភាគីម្ខាងមិនចង់បំពេញកាតព្វកិច្ចរបស់ខ្លួន ដោយបានរំលោភលើសិទ្ធិរបស់អ្នកដទៃទេ (ដូចជាការផ្ដល់អាហារកិច្ច ឬសិទ្ធិកុមារ ទ្រព្យសម្បត្តិ ។ល។)។ នៅក្នុងការអនុវត្តជាក់ស្តែង អាជ្ញាធរមូលដ្ឋានបញ្ចុះបញ្ចូល ឬរកវិធីបង្ខំឱ្យភាគីម្ខាងដែលរំលោភសិទ្ធិសងទៅភាគីម្ខាងទៀត ប៉ុន្តែអ្នកសម្រុះសម្រួល មិនអាចទៅលើសពីនេះបានទេ នៅពេលដែលភាគីនោះនៅតែមិនចង់ធ្វើដូច្នោះ។

ង. **ខ្វះសមត្ថកិច្ចផ្លូវច្បាប់ក្នុងរឿងក្ដីមួយចំនួន ដែលបំរុងទុកសម្រាប់សេចក្ដីសម្រេចរបស់តុលាការៈ** អាជ្ញាធរមូលដ្ឋានគ្មានសមត្ថកិច្ចផ្លូវច្បាប់ ក្នុងការដោះស្រាយរឿងក្ដីលែងលះ ក៏ដូចជាលើអាហារកិច្ច ការគ្រប់គ្រងកូន និងការបែងចែកទ្រព្យរួម បន្ទាប់ពីមានការលែងលះទេ។ ហើយក៏ដូចគ្នានេះដែរសម្រាប់ករណីរឿងព្រហ្មទណ្ឌ។ ដូច្នេះរាល់ការសម្រុះសម្រួលដោះស្រាយរឿងទាំងនេះ គឺត្រូវបានទុកជាមោឃៈតាមច្បាប់បាន។ នៅពេលបច្ចុប្បន្នការរៀបអាពាហ៍ពិពាហ៍នៅជនបទភាគច្រើនមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ នាំឱ្យមានមេធាវីមួយចំនួនអាចលើកអំណះអំណាងថា នៅពេលប្ដីប្រពន្ធទាំងនោះចង់ផ្ដាច់សង្វាស ពួកគេមិនចាំបាច់សុំការលែងលះពីតុលាការទេ ដោយហេតុថាពួកគេមិនបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ អាពាហ៍ពិពាហ៍ និងគ្រួសារឡើយ មានន័យថា ពួកគេអាចព្រមព្រៀងគ្នាលើការផ្ដាច់សង្វាស ដោយឯកជនបាន។ ទោះជាយ៉ាងនេះក្ដី ករណីលែងលះសម្រាប់ប្ដីប្រពន្ធបែបនេះ នៅតែជាចំណុចពិភាក្សានៅឡើយ ដោយការផ្ដាច់សង្វាសនេះជាប់ពាក់ព័ន្ធច្រើនជាមួយករណីផ្សេងៗទៀត ដូចជាការទាមទារអាហារកិច្ច សម្រាប់កូន ការបែងចែកទ្រព្យរួមជាដើម។

តម្រូវការយុត្តិធម៌នៅតាមមូលដ្ឋានរួមមានករណីមួយចំនួន ដែលតម្រូវឱ្យមានការការពារសិទ្ធិ និងការសម្រេចតាមផ្លូវតុលាការ ដូចជារឿងទាក់ទងនឹងអំពើហិង្សាខាងយេនឌ័រ និងសិទ្ធិរបស់កុមារ។ យោងតាមការសង្កេតលើឃុំនានា ដោយក្រុមការងារសិក្សាស្រាវជ្រាវនេះ អំពើហិង្សានិងការទាមទារផ្ដាច់សង្វាស/ការលែងលះ និងផលវិបាកនៃរឿងនេះ ដូចជាការផ្ដល់អាហារកិច្ច និងការបែងចែកទ្រព្យរួមមានរហូតដល់ទៅជាង ៤០% នៃរឿងក្ដីដែលបានទទួលដោយក្រុមប្រឹក្សាឃុំ។ ក្នុងរឿងក្ដីទាំងនេះ ស្ត្រីបានទៅរកអាជ្ញាធរមូលដ្ឋាន ដោយសារតែតម្លៃនិងការលំបាកផ្សេងៗ ទៀតក្នុងការប្ដឹងទៅតុលាការ។ នៅក្នុងដំណើរការសម្រុះសម្រួល ស្ត្រីត្រូវធ្វើការចរចារទាមទារចំនួនទឹកប្រាក់ ដែលនាងគួរទទួលបានជាអាហារកិច្ចសម្រាប់ចិញ្ចឹមកូន និងពេលខ្លះលទ្ធផល គឺមានភាពអយុត្តិធម៌សម្រាប់កូនៗ ដោយសារតែជំហរទន់ខ្សោយរបស់គាត់ជាស្ត្រី។ អាជ្ញាធរឃុំមិនអាចផ្ដល់ដល់គាត់ ឬដល់កូនៗរបស់គាត់ នូវអ្វីដែលពួកគេសមតែទទួលបាន ដែលជាសិទ្ធិរបស់ពួកគេនោះឡើយ។ គាត់ត្រូវធ្វើការចរចារ

ដើម្បីទាមទារអ្វីដែលគាត់អាចទទួលយកបាន។ ក្នុងរឿងក្តីដែលបានយើងបានសង្កេត អាហារកិច្ចត្រូវបានបង់ទៅតែមួយលើកប៉ុណ្ណោះ ក្រោយពីមានការព្រមព្រៀងផ្តាច់សង្វាស/ការលែងលះ ដោយឪពុកដូចជាមិនមានការទទួលខុសត្រូវបន្តផ្តល់ការគាំទ្រដល់កូនរបស់គាត់ទេ ជាពិសេសប្រសិនបើគាត់បានកសាងគ្រួសារថ្មីមួយទៀត។ រឿងដូចគ្នានេះកើតឡើងនៅក្នុងការចរចារលើសំណងការខូចខាត សម្រាប់បទល្មើសព្រហ្មទណ្ឌ និងការប្រព្រឹត្តិខុសផ្សេងៗទៀតផងដែរ។

នៅពេលសិទ្ធិត្រូវបានរំលោភបំពាន ការសម្រុះសម្រួលហាក់ដូចជាមិនសូវមានប្រសិទ្ធិភាព ក្នុងការផ្តល់សិទ្ធិទាំងនោះទេ។ អ្នកសម្រុះសម្រួលមិនអាចផ្តល់សិទ្ធិ ហើយជនរងគ្រោះអាចឋិតនៅក្នុងស្ថានភាពទន់ខ្សោយ ក្នុងការចរចារទាមទារនូវអ្វីដែលគាត់គួរទទួលបាន។ ក្នុងករណីនេះ តម្រូវការយុត្តិធម៌ក្នុងសង្គម មិនត្រូវបានផ្តល់តាមរយៈការចរចារឡើយ។ ទោះជាយ៉ាងនេះក្តី ជនរងគ្រោះនិងស្ត្រី ដែលត្រូវគេបោះបង់នៅក្នុងភូមិ មិនមានថវិកាប្តឹងទៅតុលាការទេ។ ដូច្នេះចាំបាច់ត្រូវមានអាជ្ញាធរមានយុត្តាធិការនៅជិតប្រជាពលរដ្ឋមួយ ដែលមានតម្លៃថោក នីតិវិធីមិនស្មុំគ្មាញ់ ហើយប្រកបដោយសមត្ថភាព ដើម្បីធានាសិទ្ធិដល់ស្ត្រីនិងកុមារនៅក្នុងស្ថានភាពរងគ្រោះ។

ច. **ភាពលម្អៀងផ្នែកនយោបាយៈ** ដោយសារអាជ្ញាធរមូលដ្ឋានត្រូវបានគេតែងតាំង (មេភូមិ) ឬត្រូវបានគេបោះឆ្នោត (សមាជិកក្រុមប្រឹក្សា) យោងតាមគណបក្សនយោបាយ ពេលខ្លះពួកគេមានភាពលម្អៀងផ្នែកនយោបាយ។ អ្នកចូលរួមក្នុងសិក្ខាសាលាបានលើកឡើងថា សមាជិកក្រុមប្រឹក្សាឃុំមួយចំនួន បានដោះស្រាយវិវាទដោយលម្អៀង ទៅលើសម្ព័ន្ធនយោបាយរបស់ខ្លួន ហើយខ្លះក៏មិនមានភាពលម្អៀងដែរ។ សមាជិកសិក្ខាសាលាបានសំណូមពរថា អាជ្ញាធរដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទ គួរតែត្រូវបានបោះឆ្នោតជ្រើសរើស តែមិនមែនតាមរយៈគណបក្សនយោបាយនោះទេ។ ធ្វើដូច្នេះគឺដើម្បីការពារកុំឱ្យមានការប្រកាន់គណបក្សនយោបាយ បក្សពួកនិយម និងលម្អៀង។

ឆ. **ខ្វះគណនេយ្យភាព និងការរៀបចំៈ** មិនមានប្រព័ន្ធច្បាស់លាស់ក្នុងការត្រួតពិនិត្យ ដើម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋានទទួលខុសត្រូវ លើការដោះស្រាយវិវាទឡើយ ហេតុនេះពួកគេអាចទាញយកអត្ថប្រយោជន៍ តាមកាលៈទេសៈ (ក្នុងនាមជាអាជ្ញាធរ) ក្នុងការស្នើសុំលុយកាក់ពីប្រជាពលរដ្ឋ ដែលត្រូវការសេវារបស់ខ្លួន។ ពេលខ្លះទៀតពួកគេក៏អាចផ្តល់ព័ត៌មានខុស ឬជម្រុញឱ្យគូវិវាទទទួលព្រមលើកិច្ចព្រមព្រៀង ដែលគ្មានភាពយុត្តិធម៌ផងដែរ។ អ្នកចូលរួមក្នុងសិក្ខាសាលាបានកត់សំគាល់ផងដែរថា អាជ្ញាធរឃុំមួយចំនួនពុំបានរក្សាឯកសារ ឬចុះបញ្ជីនូវរឿងក្តីឱ្យបានត្រឹមត្រូវនោះទេ។ លើសពីនេះទៅទៀត ពុំមានពេលកំណត់ណាមួយសម្រាប់ការដោះស្រាយវិវាទ ពុំមានការចែងច្បាស់ពីការបង់ប្រាក់ ហើយក៏គ្មានតម្លាភាពផងដែរ។ វាជាការមួយចាំបាច់ណាស់ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាំងនេះ ជាប្រយោជន៍ក្នុងការពង្រឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន។

## ២.៣. ជនជាតិដើមភាគតិច

ជនជាតិដើមភាគតិចនៅកម្ពុជាអនុវត្តវិធានប្រពៃណី និងយន្តការដោះស្រាយវិវាទរបស់គេ នៅក្នុងសហគមន៍របស់ពួកគេ តាមរយៈអាជ្ញាធរប្រពៃណី ឬអ្នកចាស់ទុំរបស់ខ្លួន។ វិធាន និងនីតិវិធីរបស់ពួកគេមានទាក់ទងទៅនឹងក្របខ័ណ្ឌវប្បធម៌ និងសេចក្តីត្រូវការសង្គមរបស់ពួកគេ និងធ្វើឡើងជាភាសារបស់គេ។ ថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់សំខាន់ៗចំនួនពីរ ដែលបានធ្វើឱ្យស្របច្បាប់ និងការពារសិទ្ធិរបស់ពួកគេ។ ច្បាប់ទាំងនេះបានការពារសិទ្ធិជនជាតិដើមភាគតិច ក្នុងការប្រើប្រាស់វិធានប្រពៃណី អាជ្ញាធរ និងដំណើរការធ្វើសេចក្តីសម្រេចរបស់ពួកគេ ក្នុងការដោះស្រាយលើដីធ្លីរួម និងសហគមន៍របស់ខ្លួន។ តែមិនទាន់មានការផ្សព្វផ្សាយច្បាប់ទាំងនេះ ក្នុងចំណោមជនជាតិដើមភាគតិចនិងអាជ្ញាធរឱ្យបានទូលាយនៅឡើយទេ។

### ៣.៣.១. ក្របខ័ណ្ឌច្បាប់

ច្បាប់ប្រពៃណីជនជាតិដើមភាគតិច មាននៅក្នុងច្បាប់ភូមិបាល (កម្ពុជា ឆ្នាំ ២០០១)

ច្បាប់ភូមិបាល បានចែងពីសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចទាក់ទងនឹងអចលនវត្ថុរួម ប៉ុន្តែក៏បានបញ្ចូលផងដែរនូវនិយមន័យនៃពាក្យសហគមន៍ជនជាតិដើមភាគតិច សមាជិកភាព និងការគ្រប់គ្រងរួមនៃសហគមន៍[១៨៨]។

> ច្បាប់ភូមិបាល (ឆ្នាំ ២០០១)
>
> មាត្រា ២៣ : (និយមន័យនៃសហគមន៍ជនជាតិដើមភាគតិច)[១៨៩]
>
> - សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។
> - ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។
>
> មាត្រា ២៤ :(និយមន័យនៃសមាជិកសហគមន៍ជនជាតិដើមភាគតិច)
>
> ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុ អំពីវប្បធម៌និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដទៃទៀត និងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឱ្យមានការចូលក្នុងសហគមន៍។
>
> មាត្រា ២៦ : (កម្មសិទ្ធិសមូហភាព និងការការពារច្បាប់ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច)
>
> - កម្មសិទ្ធិនៃអចលនវត្ថុដែលបានចែងនៅក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយ នៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋឱ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ។
> - ការអនុវត្តនូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឱ្យនៅក្រោមច្បាប់នៃការអនុវត្តទូទៅទាក់ទងនឹងអចលនវត្ថុដូចជា ច្បាប់ការពារបរិស្ថានជាដើម។
> - បញ្ញត្តិនៃមាត្រានេះមិនមែនជាឧបសគ្គដល់សកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការនៃប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិឡើយ។

---

[១៨៨] មានផ្នែកមួយនៃច្បាប់ភូមិបាលដែលបានអនុម័តក្នុងឆ្នាំ ២០០១ ដែលពាក់ព័ន្ធនឹង "អចលនវត្ថុរបស់សហគមន៍ជនជាតិ ដើមភាគតិច" (ផ្នែកទី២ នៃជំពូកទី៣ -កម្មសិទ្ធិរួម)។ ផ្នែកនេះរួមមាន ៦មាត្រា។ ច្បាប់បានចែងពីសិទ្ធិរបស់សហគមន៍ ជនជាតិដើមភាគតិចទាក់ទងនឹងទ្រព្យរួម ដែលរួមមានៈ ក-និយមន័យនៃសហគមន៍ជនជាតិដើមភាគតិច (មាត្រា ២៣) ខ-និយមន័យនៃសមាជិកជនជាតិដើមភាគតិច (មាត្រា ២៤) គ-និយមន័យដីរបស់សហគមន៍ជនជាតិដើមភាគតិច (មាត្រា ២៥) ឃ-កម្មសិទ្ធិរួមរបស់ជនជាតិដើមភាគតិច និងការការពារច្បាប់ប្រពៃណី (មាត្រា ២៦) ង-សិទ្ធិជាម្ចាស់របស់បុគ្គលម្នាក់ៗ ក្រៅពីក្រុម (មាត្រា ២៧) និង ច-បទបញ្ញត្តិស្តីពីការលើកលែងរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការទទួលបានអចលនវត្ថុជនជាតិដើមភាគតិច (មាត្រា ២៨)។

[១៨៩] ក្នុងច្បាប់មិនមានសរសេរជាអក្សរខ្មែរ ឬជិតដូច្នេះទេ

ច្បាប់ភូមិបាលបានធានាដល់ការចាត់ចែងកម្មសិទ្ធិសមូហភាព ដោយសហគមន៍ជនជាតិដើមភាគតិច តាមរយៈអាជ្ញាធរ វិធានប្រពៃណី និងយន្តការសម្រាប់ធ្វើសេចក្ដីសម្រេចរបស់ពួកគេ។ ច្បាប់ភូមិបាលបានថែមទាំងទទួលស្គាល់វិធានប្រពៃណី ជនជាតិដើមភាគតិច សម្រាប់គ្រប់គ្រងសហគមន៍របស់ខ្លួន។ ក្រុមដែលមានជាក់ស្ដែងមកទល់បច្ចុប្បន្ននេះ នឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ (មាត្រា ២៣)។

ច្បាប់ភូមិបាលបានទទួលស្គាល់ធាតុបីរបស់ **ច្បាប់ប្រពៃណី**

| ធាតុផ្សំនៃច្បាប់ប្រពៃណី | ច្បាប់ភូមិបាល (ឆ្នាំ ២០០១) |
|---|---|
| ១-អាជ្ញាធរជនជាតិដើមភាគតិច ឬអាជ្ញាធរប្រពៃណី | មាត្រា ២៦ : *អាជ្ញាធរប្រពៃណី* |
| ២-ប្រពៃណីជនជាតិដើមភាគតិច ឬវិធានប្រពៃណី | មាត្រា ២៣ : *តាម វិធានប្រពៃណី នៃការប្រើប្រាស់រួម*<br>មាត្រា ២៣ : *តាម ប្រពៃណីទំនៀមទម្លាប់ របស់ពួកគេ*<br>មាត្រា ២៤ : (ការទទួលយកក្នុងការរស់នៅក្រោមវិធានរបស់សហគមន៍) *"អ្នកដែលព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះ ដែលនាំឱ្យមានការចូលក្នុងសហគមន៍"*។<br>មាត្រា ២៦ : *ស្របតាម ប្រពៃណី របស់ពួកគេ* |
| ៣-យន្តការធ្វើសេចក្ដីសម្រេច | មាត្រា ២៦ : *យន្តការធ្វើសេចក្ដីសម្រេចរបស់សហគមន៍ ស្របតាមប្រពៃណីរបស់ពួកគេ* |

**ក. អាជ្ញាធរជនជាតិដើមភាគតិចខ្លួនឯង ឬអាជ្ញាធរប្រពៃណី:** អាជ្ញាធរគឺជាមនុស្សម្នាក់ ឬអង្គភាពរួមមួយ (ដូចជាក្រុមប្រឹក្សាចាស់ទុំ) ដែលមានសមត្ថភាព និងមានសមត្ថកិច្ចធ្វើសេចក្ដីសម្រេច។ អាជ្ញាធរត្រូវតែអនុវត្តតាមនីតិវិធីមួយចំនួនជាក់លាក់ ក្នុងការធ្វើសេចក្ដីសម្រេច។ អាជ្ញាធរទាំងនេះត្រូវបានកំណត់ និងតែងតាំងយោងតាមវិធានបទដ្ឋាន និងនីតិវិធីរបស់ជនជាតិដើមភាគតិចខ្លួនឯង។ ច្បាប់ព្យាយាមចៀសវាងការបង្ខំពីអាជ្ញាធរខាងក្រៅ ដែលមិនបានទទួលស្គាល់ដោយសហគមន៍ជនជាតិដើមភាគតិច។

**ខ. វិធាន និងប្រពៃណីរបស់ជនជាតិដើមភាគតិចខ្លួនឯង:** ច្បាប់ភូមិបាលបានប្រើពាក្យ *វិធានប្រពៃណី ប្រពៃណីទំនៀមទម្លាប់* ឬ *ប្រពៃណី* ជាពាក្យសទិសន័យ។ ក្នុងន័យទូទៅ វិធានប្រពៃណីសំដៅលើបទដ្ឋាន និងគោលការណ៍ផ្សេងៗផ្អែកលើតម្លៃវប្បធម៌របស់ជនជាតិដើមភាគតិច ដែលប្រើដើម្បីគ្រប់គ្រងជីវិតក្នុងសង្គមរបស់ខ្លួន គ្រប់គ្រងសហគមន៍របស់ខ្លួន បង្កើតករណីយកិច្ចនិងសិទ្ធិដល់សមាជិក និងកំណត់ពីអាកប្បកិរិយាសមរម្យ និងការអ្វីៗដែលជាការប្រព្រឹត្តិខុស។ ក្នុងករណីដែលស្ថានភាពថ្មី តម្រូវឱ្យសហគមន៍អនុម័តយកតាម នោះចាំបាច់ត្រូវតែសម្រេចដោយសហគមន៍ស្របតាមតម្លៃវប្បធម៌ និងអត្ថប្រយោជន៍របស់ពួកគេ។ បទបញ្ញត្តិនៃជីវិតក្នុងសង្គមទាំងនោះគឺសំដៅលើប្រពៃណី តម្លៃ វិធាននានា និងការអនុវត្តទាំងឡាយរបស់ជនជាតិដើម ភាគតិចដែលទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ និងភាពជាឪពុកម្ដាយ និងទំនាក់ទំនងគ្រួសារ ការបន្តមរតក ការទទួលបាន និងការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិ ទ្រព្យសម្បត្តិ ករណីយកិច្ចនិងសិទ្ធិនៅចំពោះសហគមន៍ និងការកំណត់ពីទង្វើដែលខុសឆ្គងនានា។

គ. យន្តការសម្រាប់ធ្វើសេចក្ដីសម្រេច៖ ច្បាប់ភូមិបាលបានទទួលស្គាល់យន្តការ ធ្វើសេចក្ដីសម្រេចរបស់សហគមន៍ស្របតាមប្រពៃណីរបស់ពួកគេ។ ការនេះនាំឱ្យជនជាតិដើមភាគតិចអាចធ្វើសេចក្ដីសម្រេច និងការដាក់ឱ្យអនុវត្តសេចក្ដីសម្រេចទាំងអស់នោះ ដោយគោរព និងអនុវត្តនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់មួយចំនួនក្នុងការប្រើប្រាស់ដីរបស់ពួកគេ។ សេចក្ដីសម្រេចទាំងនេះ គឺនៅតែតម្រូវឱ្យមានច្បាប់សម្រាប់អនុវត្តន៍។ សេចក្ដីសម្រេចលើអចលនវត្ថុអាចជះឥទ្ធិពល ដល់សណ្ដាប់ធ្នាប់សង្គម របស់សហគមន៍ជនជាតិដើមភាគតិចជាក់លាក់មួយចំនួន[១៩០]។ យន្តការធ្វើសេចក្ដីសម្រេចដែលបានទទួលស្គាល់ដោយច្បាប់ គឺជាយន្តការដែលធ្វើឡើងស្របតាមប្រពៃណី ឬវិធានរបស់ជនជាតិដើមភាគតិច។ ច្បាប់មិនអនុញ្ញាតមានការសម្រេច ដែលធ្វើឡើងដោយបុគ្គលតែម្នាក់នៅក្នុងសហគមន៍ជនជាតិដើមភាគតិចឡើយ។

សរុបមក យោងតាមច្បាប់ភូមិបាល សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា ត្រូវបានទទួលស្គាល់តាមច្បាប់ឱ្យមានអាជ្ញាធរផ្ទាល់ខ្លួនគេ (កំណត់ និងតែងតាំងឡើងស្របតាមបទដ្ឋានរបស់ពួកគេ) គោរពទៅតាមវិធាន និងប្រពៃណីទំនៀមទំលាប់របស់ពួកគេ និងប្រើយន្តការរបស់ពួកគេសម្រាប់ធ្វើសេចក្ដីសម្រេច ស្របតាមវិធាននិងប្រពៃណីទាំងនោះក្នុងការប្រើប្រាស់ដីធ្លីសមូហភាព។ ករណីនេះយើងអាចបកស្រាយបានថា ពួកគេមានសិទ្ធិដោះស្រាយវិវាទ និងដាក់ឱ្យអនុវត្តសេចក្ដីសម្រេចទាក់ទិននឹងដីធ្លី ដែលអនុម័តដោយសហគមន៍ផងដែរ។

ឃ. បញ្ហាដីធ្លី និងតួនាទីរបស់គណៈកម្មការសុរិយោដី៖ បញ្ហាធ្ងន់ធ្ងរបំផុតដែលជនជាតិដើមភាគតិចជួបប្រទះប៉ុន្មានឆ្នាំចុងក្រោយនេះ គឺការទន្ទ្រានយកដីសហគមន៍ដោយអ្នកខាងក្រៅ និងអ្នករកស៊ីរកកម្រៃជើងសារនៅក្នុងមូលដ្ឋាន និងអ្នកមកពីខាងក្រៅ។ ការទន្ទ្រានយកដីសហគមន៍ដោយអ្នកខាងក្រៅ ត្រូវបានហាមឃាត់ដោយច្បាប់ភូមិបាល ប៉ុន្តែអ្នករកស៊ីរកកម្រៃជើងសារ បានទាញយកអត្ថប្រយោជន៍ពីកង្វះការយល់ដឹងពីសិទ្ធិ និងចំណេះដឹងផ្លូវច្បាប់របស់ជនជាតិដើមភាគតិចដើម្បីធ្វើការទន្ទ្រានយកដីតែម្ដង។ យោងតាមចម្លើយរបស់បងប្អូនជនជាតិដើមភាគតិច អ្នករកស៊ីរកកម្រៃជើងសាមួយចំនួនបានគំរាមដល់ជនជាតិដើមភាគតិចថា ពួកគេមិនមែនជាជនជាតិខ្មែរទេ ដូច្នេះពួកគេគ្មានសិទ្ធិជាម្ចាស់លើដីធ្លីទេ ហើយរដ្ឋាភិបាលនឹងយកដីទាំងនេះពីពួកគេដើម្បីធ្វើផ្លូវ ឬលក់ឱ្យទៅអ្នកផ្សេងទៀត។ ពួកគេបានប្រើល្បិចដើម្បីឱ្យបងប្អូនជនជាតិដើមភាគតិចចុះហត្ថលេខា ឬផ្ដិតមេដៃលក់ដីក្នុងតម្លៃទាប លើកិច្ចសន្យាដែលពួកគេមិនចេះអាននិងមិនយល់។ សកម្មភាពខុសច្បាប់ទាំងនេះបានកំពុងបំផ្លាញដីរបស់ជនជាតិដើមភាគតិច ដែលជាលទ្ធផលពួកគេនឹងបាត់បង់នូវមធ្យោបាយក្នុងការចិញ្ចឹមជីវិត និងបំផ្លាញបរិស្ថាន។

គណៈកម្មការសុរិយោដីដែលមាននៅក្នុងខេត្តទាំងនេះ មិនទាន់បានបង្កើតឡើងពេញលេញនៅឡើយទេ។ នៅក្នុងខេត្តមណ្ឌលគិរី គណៈកម្មការសុរិយោដីមានការិយាល័យថ្នាក់ស្រុកតែមួយប៉ុណ្ណោះ ដែលបានបង្កើត និងកំពុងរង់ចាំការបង្កើតនៅក្នុងស្រុកចំនួន ៤ ផ្សេងទៀត។ នៅក្នុងខេត្តរតនៈគីរី មានស្រុក៣ទៀត ដែលមិនទាន់បានបង្កើតគណៈកម្មការសុរិយោដីនៅក្នុងស្រុកទាំង៩នៅក្នុងខេត្តនេះ។ នៅក្នុងខេត្តទាំងពីរនេះ គណៈកម្មការសុរិយោដីទទួលរឿងក្ដីតិចតួចបំផុត បើធៀបទៅនឹងមធ្យមភាគនៅក្នុងខេត្តនីមួយៗទូទាំងប្រទេស (៨៨)។ ក្នុងខេត្តមណ្ឌលគិរី គណៈកម្មការសុរិយោដីទទួលរឿងក្ដីបានតែចំនួន ១០ ករណីប៉ុណ្ណោះ នៅពេលដែលខេត្តរតនៈគីរីទទួលបានច្រើនជាង ៨ដង (៨៦ករណី)។ ទោះយ៉ាងនេះក្ដី គណៈកម្មការសុរិយោដីក្នុងខេត្តទាំងពីរ បានដោះស្រាយតែមួយករណីប៉ុណ្ណោះ។ ភាពយឺតយ៉ាវក្នុងការដោះស្រាយបញ្ហាទន្ទ្រានយកដី

[១៩០] ដោយសារច្បាប់ភូមិបាលចែងថា សហគមន៍ជនជាតិដើមភាគតិចត្រូវគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់គេ ស្របតាមប្រពៃណីរបស់ខ្លួន ពេលមានរឿងវិវាទកើតឡើង អាជ្ញាធរជនជាតិដើមភាគតិចត្រូវដោះស្រាយវិវាទតាមយន្តការធ្វើ សេចក្ដីសម្រេចរបស់សហគមន៍ និងប្រពៃណី ឬវិធានផ្ទាល់ខ្លួនរបស់គេ។

ជនជាតិដើមភាគតិចនេះ គឺជាសញ្ញាមួយដែលគួរឱ្យកត់សំគាល់ (និងតម្រូវឱ្យមានការដោះស្រាយជាបន្ទាន់) នៃការគំរាមកំហែងដល់អត្តិភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ការដែលគ្មានក្របខ័ណ្ឌពេលវេលាកំណត់ច្បាស់លាស់សម្រាប់គណៈកម្មការសុរិយោដី ក្នុងការដោះស្រាយវិវាទដីធ្លីបែបនេះ អាចធ្វើឱ្យស្ថានភាពនេះកាន់តែអាក្រក់ថែមទៀត។

ង. តួនាទីតុលាការៈ តុលាការទទួលរឿងក្តីតិចបំផុតពីសហគមន៍ជនជាតិដើមភាគតិច។ ជាក់ស្តែង ក្នុងខេត្តមណ្ឌលគិរី និងរតនៈគិរី ចំនួនរឿងក្តីដែលបានទទួលដោយចៅក្រមមានកម្រិតទាប បើប្រៀបធៀបទៅនឹងខេត្តដទៃៗទៀត។ នេះមានន័យថា វិវាទភាគច្រើនត្រូវបានដោះស្រាយនៅក្នុងសហគមន៍ជនជាតិដើមរបស់ខ្លួន ដែលករណីនេះក៏បានបញ្ជាក់ថាដូច្នេះមែនផងដែរពីចៅក្រមនិងព្រះរាជអាជ្ញា។ ភាគច្រើននៃរឿងក្តីកើតមាននៅទីប្រជុំជន។ នៅក្នុងខេត្តមណ្ឌលគិរី នៅក្នុងឆ្នាំ២០០៣ មានរឿងក្តីព្រហ្មទណ្ឌថ្មី ២៥ករណី ដែលបានដោះស្រាយដោយព្រះរាជអាជ្ញា ហើយមានរឿងក្តីរដ្ឋប្បវេណីថ្មី ៨ករណី។ នៅក្នុងខេត្តរតនៈគិរី ព្រះរាជអាជ្ញាទទួលបានរឿងក្តីថ្មី ៥៨ករណី ហើយមានរឿងក្តីរដ្ឋប្បវេណីថ្មី ៣២ករណី។

ការដែលមានសំណុំរឿងព្រហ្មទណ្ឌច្រើន ត្រូវបានដោះស្រាយដោយប្រព័ន្ធផ្លូវការនៅក្នុងខេត្តរតនៈគិរី នោះវាអាចបង្កឱ្យមានបញ្ហាផ្សេងទៀត ដោយហេតុថាពុំមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធានាដល់ការជំនុំជំរះប្រកបដោយយុត្តិធម៌។ នៅខេត្តនេះពុំមានមេធាវី និងអ្នកបកប្រែសម្រាប់ជនជាតិដើមភាគតិចឡើយ។ ពន្ធនាគារមានលក្ខណៈតូចចង្អៀតយ៉ាងខ្លាំង។ ព្រះរាជអាជ្ញា និងចៅក្រមមានការបារម្ភពីស្ថានភាពនេះ ដោយហេតុថាពិរុទ្ធជនប្រឈមមុខនឹងការជំនុំជម្រះដោយគ្មានមេធាវី។ សាលាឧទ្ធរណ៍នៅឆ្ងាយពីខេត្តរតនៈគិរី (១៥ម៉ោងដោយរថយន្តឈ្នួល) ហើយពុំមានធនធានគ្រប់គ្រាន់ ដើម្បីបញ្ជូនជនជាប់ចោទមកសាលាឧទ្ធរណ៍នៅភ្នំពេញឡើយ។ ដោយសារតែពន្ធនាគារពុំមានរបងសុវត្ថិភាពរឹងមាំ ពិរុទ្ធជនមិនត្រូវបានអនុញ្ញាតឱ្យនៅខាងក្រៅបន្ទប់ឃុំឃាំងឡើយ។ ដូច្នេះពួកគេចំណាយពេលពេញមួយថ្ងៃ នៅក្នុងបន្ទប់ឃុំឃាំងដ៏តូចមួយ ដែលមានមនុស្ស ១៥នាក់ផ្សេងទៀត។ ការនេះអាចជះឥទ្ធិពលដល់ផ្លូវចិត្ត ក៏ដូចជា សុខភាពរបស់ពួកគេផងដែរ។ ពួកគេក៏ពុំមានឱកាសធ្វើពលកម្ម និងសិក្សាឡើយ។ ពួកគេនៅឆ្ងាយពីសហគមន៍របស់ខ្លួន និងឋិតនៅក្នុងស្ថានភាពពន្ធនាគារដ៏អាក្រក់។ ក្នុងនាមជាជនជាតិដើមភាគតិច ដែលពុំបានដឹងច្បាស់ពីនីតិវិធី និងមិនអាចនិយាយភាសាខ្មែរបានល្អ អាចជាឱកាសឱ្យបុគ្គលមួយចំនួនឆ្លៀតយកផលចំណេញពីស្ថានភាពនេះ។

## ២.៣.២. សហគមន៍ជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី

ច្បាប់ប្រពៃណីរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរីៈ

ជនជាតិភ្នង គឺជាជនជាតិដើមភាគតិចមួយនៅកម្ពុជា។ សហគមន៍ជនជាតិភ្នងមួយចំនួនរស់នៅក្នុងខេត្តមណ្ឌលគិរី[១៨១]។ ពួកគេក៏ត្រូវបានគេហៅថា *អ្នកតំបន់ខ្ពង់រាប* ឬ *កុលសម្ព័ន្ធភ្នំ* ដោយសារពួកគេរស់នៅក្នុងតំបន់ខ្ពង់រាបនៃប្រទេស។ ពួកគេនិយាយភាសារបស់គេដែលខុសពីភាសាខ្មែរ។ ពួកគេមានវប្បធម៌ ទម្រង់នៃការរៀបចំសង្គមដោយឡែក ដូចជាបទដ្ឋាន តម្លៃ អាជ្ញាធរ និងយន្តការដោះស្រាយវិវាទរបស់គេជាដើម។ ព័ត៌មានដែលយើងផ្តល់ជូននៅទីនេះ គឺទទួលបានតាមរយៈបទសម្ភាសន៍ជាមួយអាជ្ញាធរជនជាតិភ្នង និងអ្នកភូមិផ្សេងៗទៀត។

[១៨១] ច្បាប់ភូមិបាល (ឆ្នាំ ២០០១) បានប្រើពាក្យ "សហគមន៍ជនជាតិដើមភាគតិច" (មាត្រា ២៣ ដល់ ២៨)។ ធនាគារអភិវឌ្ឍន៍អាស៊ី ចូលចិត្តប្រើពាក្យ "ជនជាតិដើមភាគតិច" ជាង "ជនជាតិភាគតិច" សូមមើល ADB (2002): *Indigenous peoples/Ethnic minorities and poverty reduction Cambodia.* របស់ ADB, Environment and Social Safeguard Division Regional and Sustainable Development Department. ទោះជាយ៉ាងនេះក្តី ស្ថាប័នផ្សេងទៀតច្រើនតែប្រើពាក្យ "ជនជាតិភាគតិច" ប៉ុណ្ណោះ។

- នៅពេលមានបញ្ហា ឬវិវាទក្នុងចំណោមជនជាតិភ្នង ភាគីម្ខាង ឬទាំងពីរដំបូងទៅរកចាស់ទុំ។ ចាស់ទុំចុះទៅជួបគូភាគីក្នុងវិវាទនិងព្យាយាមរកដំណោះស្រាយ។ នៅក្នុងដំណើរការសម្រុះសម្រួល សាច់ញាតិនិងអ្នកជិតខាងអាចចូលរួមផងដែរ។
- ប្រសិនបើមានបទល្មើសប្រឆាំងនឹងវិធាននៃសហគមន៍ (រំលោភលើប្រពៃណី) សហគមន៍អាចអន្តរាគមន៍ ទោះបីគ្មានជនរងគ្រោះដោយផ្ទាល់ក្តី។ ក្នុងករណីនេះជនគ្រប់គ្នាអាចដាក់ពាក្យប្តឹងទៅចាស់ទុំបាន។ ករណីមួយក្នុងរឿងក្តីបែបនេះគឺទំនាក់ទំនងផ្លូវភេទរវាងមីងនិងក្មួយប្រុស។ ទាំងពីរនាក់ មីង និងក្មួយប្រុសត្រូវបានចាត់ទុកថាជាជនល្មើស។
- ជនល្មើសត្រូវតែបង់ការខូចខាតដល់ជនរងគ្រោះដោយផ្ទាល់ ប្រសិនបើមាន ឬទៅសហគមន៍ប្រសិនបើជនល្មើសបានរំលោភលើវិធានរបស់សហគមន៍ ដោយគ្មានជនរងគ្រោះណាមួយនោះ។
- ជនល្មើសត្រូវតែធ្វើ "លៀសលៀង"។ វាជាពិធីបែបប្រពៃណីមួយ ដែលជនល្មើសត្រូវតែសែនម្ហូប និងគ្រឿងផឹកទៅដល់ចាស់ទុំ និងសាក្សីដែលបានចូលរួមក្នុងការដោះស្រាយវិវាទ ក៏ដូចជាសាច់ញាតិនិងសមាជិកសហគមន៍ដទៃទៀតដែរ។ ជនរងគ្រោះក៏អាចចូលរួម និងអាចនាំយករបស់មួយចំនួនមករួមចំណែកជាមួយ និងអ្នកដទៃទៀតបានដែរ។
- គោលបំណងនៃពិធីលៀសលៀង គឺដើម្បីសងដល់ជនរងគ្រោះ សម្រុះសម្រួលរវាងគូភាគីក្នុងបញ្ហាវិវាទ និងដើម្បីពង្រឹងវិធានសហគមន៍។
- ប្រសិនបើគូភាគីមិនអាចឈានដល់ការដោះស្រាយនៅមូលដ្ឋាននេះទេ ពួកគេទៅរកមេភូមិ និងបន្ទាប់មកក្រុមប្រឹក្សាឃុំ។ ជាធម្មតា អាជ្ញាធរទាំងនេះក៏ព្យាយាមរកដំណោះស្រាយដោយមានការជួយពីចាស់ទុំ និងការអនុវត្តពិធីលៀសលៀងដែរ។
- នៅឃុំដាក់ដាំដែលយើងបានទៅដល់ សមាជិកក្រុមប្រឹក្សាឃុំទាំងអស់ជាជនជាតិភ្នង ដូចនេះពួកគេក៏អនុវត្ត ពិធីលៀសលៀងនេះដែរ។ ពួកគេព្យាយាមដោះស្រាយរាល់បញ្ហាគ្រប់ប្រភេទ រួមទាំងបទល្មើសព្រហ្មទណ្ឌ (ចោរកម្ម ការបរិហារកេរ្តិ៍ អំពើហិង្សាក្នុងគ្រួសារ ការបង្ករបួសស្នាម និងបញ្ហាក្រុមបងធំ) នៅក្នុងឃុំ។ ពួកគាត់បានប្រាប់យើងថា: "យើងមិនចង់ឱ្យកូនចៅរបស់យើងជាប់គុកទេ"។ នគរបាលឃុំធ្វើការងារស្របជាមួយនឹងក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋានដែរ ហើយថែមទាំងព្យាយាមរក្សាដោះស្រាយនៅថ្នាក់មូលដ្ឋានថែមទៀត។ តាមការសម្ភាសន៍សមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយនេះ អាជ្ញាធរជនជាតិភ្នងនៅឃុំដាក់ដាំ បានរាយការណ៍ទៅអាជ្ញាធរតុលាការទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌតែមួយករណីគត់ ដែលជាករណីឃាតកម្មក្នុងឆ្នាំ ១៩៩៣។ ក្នុងករណីរឿងក្តីនេះពួកគេមិនបានដឹងថាអ្នកណាជាជនល្មើសទេ។

ទោះបីស្ថាប័នរបស់រដ្ឋមានការកើនឡើង នៅក្នុងខេត្តដែលមានជនជាតិដើមភាគតិច ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះយ៉ាងច្រើនក៏ដោយ ក៏ជនជាតិភ្នងនៅតែរក្សាទុកនូវតម្លៃ បទដ្ឋាន និងយន្តការដោះស្រាយវិវាទរបស់ពួកគេដដែល។ ពួកគេចង់ដោះស្រាយរឿងក្តីទាំងនេះនៅថ្នាក់មូលដ្ឋានតាមដែលអាចធ្វើទៅបានដើម្បីរារាំងអន្តរាគមន៍ពីខាងក្រៅ។

អ្នកចូលរួមក្នុងសិក្ខាសាលាខ្លះបាននិយាយថា ពិធីលៀសលៀងគឺជាអបិយជំនឿមួយប្រភេទ។ អ្នកផ្សេងៗ ទៀតយល់ថា ពិធីលៀសលៀង គឺជាបន្ទុកដ៏ធ្ងន់សម្រាប់អ្នកក្រីក្រ ដូចនេះវាគួរតែត្រូវបានលុបបំបាត់ចោល ឬត្រូវបានកាត់បន្ថយ។ វាហាក់ដូចជាមានការមិនយល់ច្បាស់ ពីសំណាក់ក្រុមអ្នកមិនមែនជាជនជាតិដើមភាគតិច ពីមុខងារនៃពិធីលៀសលៀង ក្នុងការបង្កើតឡើងនូវវិធានបទដ្ឋាន តម្លៃ និងអត្តសញ្ញាណ វប្បធម៌ និងជួយរក្សានូវសណ្តាប់ធ្នាប់ និងសន្តិភាពសម្រាប់ប្រជាពលរដ្ឋជនជាតិភ្នង។

ច្បាប់ប្រពៃណី និងការដោះស្រាយវិវាទរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនៈគិរី:

សមាជិកនៅក្នុងសហគមន៍ជនជាតិដើមភាគតិច អនុវត្តតាមច្បាប់ប្រពៃណី ហើយពួកគេដោះស្រាយវិវាទរបស់គេស្ទើរតែទាំងអស់ស្របតាមវិធាន តម្លៃ នីតិវិធី និងជំនឿរបស់ខ្លួន។

សហគមន៍មួយនៅខេត្តរតនៈគីរី ដែលយើងបានទៅដល់មានឈ្មោះ **អូយ៉ាដាវ** ដែលមានជនជាតិដើមភាគតិច ប្រមាណ ៤៦គ្រួសារ នៅក្នុងសហគមន៍នេះ។ ពួកគេជាជនជាតិ**ចារ៉ាយ**។ ទាំងអស់គ្នានិយាយភាសាចារ៉ាយ។ មានតែសមាជិកមួយចំនួនតូច ប៉ុណ្ណោះ ដែលអាចនិយាយភាសាខ្មែរបាន និងមានក្មេងប្រុសម្នាក់គត់ ដែលបានប្រាប់យើងថាចេះអានអក្សរខ្មែរ។

វិវាទដែលកើតឡើងជារឿយៗនៅក្នុងសហគមន៍មាន ជម្លោះអ្នកជិតខាង និងរវាងប្តីប្រពន្ធ។ វិវាទខ្លះទៀតទាក់ទងនឹង ដីធ្វើកសិកម្មពនេចរ។ ស្ត្រីក៏បានប្រាប់ផងដែរថា ជម្លោះប្តីប្រពន្ធច្រើនដោយសារប្តីផឹកស្រា។ ពួកគេនិយាយថា រឿងក្តីអំពើហិង្សាក្នុងគ្រួសារកើតឡើងចុងក្រោយបង្អស់គឺនៅឆ្នាំ ២០០៣ ហើយវាហាក់ដូចជាមិនកើតឡើងញឹកញាប់ទេ[១៥២]។ ការបោះបង់ចោលគ្រួសារដោយឪពុក ហាក់ដូចជាមិនសូវមានញឹកញាប់ ដូចក្នុងចំណោមប្រជាពលរដ្ឋខ្មែរទេ ដោយសារសំពាធសង្គមនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។ នៅក្នុងសហគមន៍ដែលយើងទៅដល់វិវាទផ្ទៃក្នុងទាំងអស់ ត្រូវបានដោះស្រាយនៅក្នុងសហគមន៍ដោយចាស់ទុំ។ ចាស់ទុំបានប្រាប់ថារឿងក្តីចុងក្រោយ ដែលពួកគាត់បានដោះស្រាយទាក់ទងនឹងៈ ក-ការបំផ្លាញទ្រព្យសម្បត្តិ ខ-ជម្លោះប្តីប្រពន្ធ និង គ-ការជេរប្រទេច។ ចាស់ទុំបានជម្រុញឱ្យគូភាគីយល់ពីគ្នា និងគោរពតាមវិធានរួមរបស់សហគមន៍។ ជាធម្មតា ដំណោះស្រាយពាក់ព័ន្ធនឹងការសងការខូចខាតដល់ជនរងគ្រោះដោយផ្ទាល់ និងតម្រូវឱ្យជនល្មើសប្រកាសទទួលស្គាល់ជាសាធារណៈនូវវិធានរបស់សហគមន៍ ដោយការរៀបចំពិធីផ្សេងៗសម្រាប់សហគមន៍ ដែលបន្ទុកចំណាយគឺឋិតលើជនល្មើស។

សហគមន៍នេះមានចាស់ទុំ ៥នាក់ ដែល២នាក់ជាស្ត្រី។ ពួកគេត្រូវបានចាត់ទុកថាជាចាស់ទុំ ដោយសារបទពិសោធន៍ប្រាជ្ញា និងសមត្ថភាពរបស់ពួកគេក្នុងការបំរើឱ្យសហគមន៍។ ចាស់ទុំត្រូវបានគោរពដោយសហគមន៍។ ពួកគេដឹងពីវិធានធ្វើកសិកម្មពនេចរ និងរបៀបដាក់វិធានការសមស្រប ឬទណ្ឌកម្មចំពោះជនល្មើសនៃការធ្វើឱ្យខូចទ្រព្យសម្បត្តិ ជេរប្រមាថ ជម្លោះនានា និងវិវាទផ្សេងៗទៀត។

សហគមន៍ដែលយើងទៅដល់ បានសំណូមពរឱ្យរក្សាទុកការដោះស្រាយវិវាទរបស់ពួកគេដោយខ្លួនគេ។ ពួកគេបានទិតៀនមេភូមិ និងក្រុមប្រឹក្សាឃុំយ៉ាងខ្លាំង ដោយអាជ្ញាធរមូលដ្ឋានទាំងនេះជាអ្នកចូលរួម និងយកផលចំណេញពីការទន្ទ្រានយកដីរបស់ពួកគេដោយអ្នកខាងក្រៅ។

## ២.៤. នគរបាល

### ២.៤.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័នៈ

ស្ថាប័ននេះមាននៅថ្នាក់ឃុំ ស្រុក និងខេត្ត។

ក្របខ័ណ្ឌច្បាប់ៈ

ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ ១៩៩៣ ដោយមានការកែប្រែនៅក្នុងឆ្នាំ ២០០១) បានកំណត់អំពីអ្នកណាដែលត្រូវគេចាត់ទុកថាជាមន្ត្រីនគរបាលយុត្តិធម៌ រួមទាំងអ្នកដែលអាចអនុវត្តមុខងារនេះថែមទៀត។ ច្បាប់បានរាប់បញ្ចូលទាំងអភិបាល អភិបាលរងខេត្ត-ក្រុង ស្រុក-ខណ្ឌ និងមេឃុំ-ចៅសង្កាត់ផងដែរ។ អង្គភាពទាំងនេះធ្វើសកម្មភាពនៅក្រោមការសម្របសម្រួល និងការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចជាច្រើន ទាក់ទងនឹងការ

[១៥២] ទោះបីជាយ៉ាងនេះក្តី ការដែលលើកឡើងនេះគ្រាន់តែផ្អែកលើសក្ខីកម្ម ប៉ុន្តែមិនមែនដោយការសង្កេតរឿងក្តីទេ។ លើសពីនេះមិនមានការកត់ត្រាជាលាយលក្ខណ៍អក្សរណាមួយ ដែលបានទៅដល់សហគមន៍ដែលយើងទៅនោះទេ។ យើងមិនអាចប្រាប់បានថាតើអំពើហិង្សា មិនត្រូវបានគេរាយការណ៍ប្រាប់ថាមានញឹកញាប់ ដោយសារតែការអត់អោនដ៏ខ្លាំង ឬការកើតឡើងមានតិចនោះទេ។

ទប់ស្កាត់កុំឱ្យមានបទល្មើសកើតឡើង ការស៊ើបអង្កេត និងការដាក់ទណ្ឌកម្ម។ ពួកគេមានសិទ្ធិ ឃុំខ្លួនជនល្មើសរហូតដល់ ៤៨ ម៉ោង ហើយអាចស្នើសុំបន្តរយៈពេលនេះក្នុងកាលៈទេសៈមួយចំនួន។

| សរុប | ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ ១៩៩៣) ដោយមានធ្វើវិសោធនកម្ម (ឆ្នាំ ២០០២) |
|---|---|
| អ្នកណាដែលត្រូវបានចាត់ទុកថាជាមន្ត្រីនគរបាលយុត្តិធម៌? | មាត្រា ៣៦ថ្មី : ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រី នគរបាលយុត្តិធម៌ រួមមាន:<br>១. ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត "ក្នុងភារកិច្ចតែប៉ុណ្ណោះ"<br>២. អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់<br>៣. ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធាន ផ្នែកនៃ:<br>• នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ<br>• នាយកដ្ឋាននគរបាលសេដ្ឋកិច្ច<br>• នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ<br>• នាយកដ្ឋានប្រឆាំងភេរវកម្ម<br>• នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"<br>• នាយកដ្ឋានជនបរទេស<br>• មន្ទីរប្រឆាំងគ្រឿងញៀន<br>៤. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង<br>៥. ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែកដែលទទួលបន្ទុក ការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា :<br>• ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់<br>• ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល<br>• ការិយាល័យនគរបាលសេដ្ឋកិច្ច<br>• ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ<br>• ការិយាល័យប្រឆាំងគ្រឿងញៀន<br>• ការិយាល័យប្រឆាំងភេរវកម្ម<br>• ការិយាល័យជនបរទេស<br>៦. អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាន នគរបាលស្រុក ខណ្ឌ<br>៧. ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ និងប្រធាន អនុប្រធានផ្នែក នគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"<br>៨. ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"<br>៩. មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រីចាប់ពីអនុប្រធានផ្នែកឡើង នៃ កងរាជអាវុធហត្ថដែលទទួលការងារព្រហ្មទណ្ឌ "ចំពោះបទល្មើសដែលពាក់ព័ន្ធនឹង កិច្ចការយោធា" |

| | |
|---|---|
| | ១០.មន្ត្រីនៃក្រសួង ឬ ស្ថាប័នណាដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើស ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការដឹកនាំ និងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធី និងវិធានស៊ើបអង្កេត ដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិប្រគល់ទៅមន្ត្រីនគរបាលយុត្តិធម៌ នូវសមត្ថកិច្ចណាមួយដែលមានវិសាលភាពលើដែនដីទាំងមូល។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចេញប្រកាសណែនាំអំពីរបៀបរបបធ្វើការ និងនីតិវិធីខាងផ្លូវរដ្ឋបាល ដល់មន្ត្រីនគរបាលយុត្តិធម៌។ |
| សមត្ថកិច្ច និងភារកិច្ច | អភិបាល អភិបាលរងខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចបញ្ជាណែនាំមន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតក្នុងរង្វង់ដែនដីរបស់ខ្លួនគ្រប់គ្រងឱ្យធ្វើប្រតិបត្តិការលើបទល្មើសបាន ហើយប្រតិបត្តិការទាំងឡាយត្រូវមានសហការពីព្រះរាជអាជ្ញា។<br>មាត្រា ៣៨ថ្មី : មន្ត្រីនគរបាលយុត្តិធម៌ :<br>- ទទួលពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ ទាក់ទង បទឧក្រិដ្ឋ បទមជ្ឈិមនិងបទលហុនានា<br>- ចាត់ចែងប្រមូលភស្តុតាងនានា<br>- អាចស្នើសុំជំនួយពីកម្លាំងសាធារណៈ<br>- ធ្វើកំណត់<br>- អាចទទួលលិខិតបង្គាប់ឱ្យសួរជំនួស<br>- អាចសម្រេចឃាត់ខ្លួនបានរយៈពេល ៤៨ ម៉ោងយ៉ាងយូរ<br>- ក្នុងករណីរឿងឧក្រិដ្ឋនិងមជ្ឈិមជាក់ស្តែង អាចសួរយកចម្លើយសាក្សីធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសម្រេចឃាត់ខ្លួនជនល្មើស "៤៨ម៉ោងយ៉ាងយូរ" ឃាត់ខ្លួនបុគ្គលណាប្រសិនបើមានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់សមស្របធ្វើការចោទប្រកាន់បាន<br>- មន្ត្រីនគរបាលយុត្តិធម៌ អាចសុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបាន ក្នុងរយៈពេលមិនលើសពី ៤៨ម៉ោង ដោយមិនគិតពីថេរវេលាចាំបាច់នៃការដឹកជញ្ជូនក្នុងលក្ខខណ្ឌទាំងប្រាំដូចខាងក្រោម :<br>១- បទឧក្រិដ្ឋធ្ងន់ធ្ងរ<br>២- មានតំរុយចង្អុលបង្ហាញច្បាស់ថា បានប្រព្រឹត្តបទល្មើស<br>៣- ជាវិធានការចាំបាច់ ដើម្បីធ្វើឱ្យការស៊ើបអង្កេតប្រព្រឹត្តិទៅបានល្អ<br>៤- ពាក្យសុំត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល<br>៥- មានចំណារយល់ព្រមពីព្រះរាជអាជ្ញា។<br>ការអនុញ្ញាតឱ្យពន្យារត្រូវដាក់បញ្ចូលក្នុងសំណុំរឿង<br>- ការពន្យា មិនអាចត្រូវយល់ព្រមបានទេ ចំពោះបុគ្គលដែលត្រូវហាមឃាត់នោះមានអាយុតិចជាង ១៨ ឆ្នាំ។<br>- អនីតិជនដែលមានអាយុតិចជាង ១៣ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនដល់ ៣៦ម៉ោងឡើយ។<br>មាត្រា ៤៨ : ក្នុងករណីណាក៏ដោយមន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតម្កល់ទុកឥតចាត់ការនូវរឿងអាជ្ញាដែលខ្លួនបានទទួល ទោះមានការសម្រុះសម្រួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុ បញ្ជូនទៅរដ្ឋអាជ្ញាមានសមត្ថកិច្ចជាដរាប។<br>ក្នុងករណីមិនគោរពវិធានខាងលើនេះទេ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលការផ្តន្ទាទោសដែលមានចែងក្នុងមាត្រា ២២ និង ៩៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ |

តាមឋានានុក្រមៈ

យោងតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ១១ (ឆ្នាំ ២០០២) អធិការដ្ឋាននគរបាលស្រុក-ខណ្ឌ មិនមានសិទ្ធិកសាងសំណុំរឿងក្តី និងបញ្ជូនវាដោយផ្ទាល់មកតុលាការខេត្ត-ក្រុងនោះទេ។ សំណុំរឿងក្តីទាំងអស់ត្រូវតែធ្វើឡើងមកការិយាល័យកណ្តាលរបស់នគរបាលយុត្តិធម៌ នៅស្នងការដ្ឋាននគរបាលខេត្ត-ក្រុង ឬតាមរយៈស្នងការនគរបាល ដើម្បីចុះហត្ថលេខារួចទើបបញ្ជូនទៅកាន់តុលាការខេត្ត-ក្រុង។ ច្បាប់នេះចែងកំណត់អំពីឋានានុក្រម ក្នុងការកសាងសំណុំរឿងក្តីព្រហ្មទណ្ឌ។ នគរបាលនៅតាមមូលដ្ឋាន មិនអាចកសាងសំណុំរឿងព្រហ្មទណ្ឌ បញ្ជូនទៅកាន់ព្រះរាជអាជ្ញាដោយផ្ទាល់បានទេ។

| | សេចក្តីណែនាំក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ<br>លេខ ០១១ សណន ភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០២ |
|---|---|
| នគរបាលស្រុកមិនមានសិទ្ធិក្នុងការបញ្ជូនរឿងក្តីទៅតុលាការ រឿងនេះត្រូវតែបានធ្វើឡើងតាមរយៈការិយាល័យកណ្តាលនៅការិយាល័យថ្នាក់ខេត្ត-ក្រុង | កន្លងទៅនេះអគ្គស្នងការដ្ឋាននគរបាលជាតិ បានពិនិត្យឃើញនគរបាលនៅថ្នាក់ប៉ុស្តិ៍រដ្ឋបាល និងថ្នាក់អធិការដ្ឋាន នគរបាលស្រុក ខណ្ឌ មួយចំនួនធំបានបំពេញភារកិច្ច ដោយការទទួលខុសត្រូវខ្ពស់ជាពិសេសក្នុងការប្រតិបត្តិច្បាប់។ ប៉ុន្តែត្រូវបានពិនិត្យឃើញថាមានថ្នាក់នគរបាលប៉ុស្តិ៍រដ្ឋបាល និងថ្នាក់អធិការនគរបាល ខណ្ឌ ស្រុកមួយចំនួន បានប្រើប្រាស់សិទ្ធិអំណាចជានគរបាលយុត្តិធម៌ រៀបចំកសាងបញ្ជូនសំណុំរឿង ត្រង់ទៅតុលាការទៅលើរឿងហេតុព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដោយរំលោភទៅលើប្រជាពលរដ្ឋ ស្លូតត្រង់មួយចំនួន។<br><br>ដើម្បីកែលំអនៅកង្វះខាតខាងលើនេះអគ្គស្នងការនគរបាលជាតិសូមធ្វើការណែនាំដូចខាងក្រោមៈ<br>១- ចាប់ពីនេះតទៅ ថ្នាក់នគរបាលប៉ុស្តិ៍រដ្ឋបាល និងថ្នាក់អធិការដ្ឋាននគរបាលខណ្ឌ ស្រុកគ្មានសិទ្ធិកសាងសំណុំរឿងបញ្ជូនត្រង់ទៅតុលាការខេត្តក្រុងឡើយ។ សំណុំរឿងទាំងអស់ត្រូវឆ្លងកាត់តាមរយៈការិយាល័យកណ្តាលនគរបាលយុត្តិធម៌ នៃស្នងការដ្ឋាននគរបាល ខេត្ត ក្រុង ឬឆ្លងកាត់ស្នងការនគរបាល ដើម្បីចុះហត្ថលេខាបញ្ជូនសំណុំរឿងទៅតុលាការខេត្តក្រុង ។<br>២- រាល់រឿងហេតុទំនាស់វិវាទផ្សេងៗ (លើកលែងរឿងហេតុព្រហ្មទណ្ឌ) គ្រប់ស្នងការដ្ឋាននគរបាលខេត្តក្រុង មុននឹងកសាងសំណុំរឿងជូនទៅតុលាការ ត្រូវស្នើសុំយោបល់សម្រេចពីអគ្គស្នងការនគរបាលជាតិ។<br><br>ទទួលការណែនាំនេះ ស្នងការដ្ឋាននគរបាលខេត្តក្រុង ត្រូវធ្វើការណែនាំដល់នគរបាលប៉ុស្តិ៍រដ្ឋបាល អធិការដ្ឋាននគរបាលស្រុក ខណ្ឌ និងការិយាល័យកណ្តាលនគរបាលយុត្តិធម៌ ចាត់តាំងឱ្យមានប្រសិទ្ធិភាព។ |

ការព្រមព្រៀងក្រៅប្រព័ន្ធតុលាការត្រូវបានហាមឃាត់ៈ

ដោយគិតទៅដល់ការអនុវត្តជាក់ស្តែងកន្លងមក ក្រសួងយុត្តិធម៌បានចេញប្រកាស ស្តីពីនីតិវិធីការងាររបស់នគរបាលយុត្តិធម៌ (ឆ្នាំ២០០៤)។ ប្រកាសនេះចែងថា នគរបាលមិនអាចទទួលរឿងក្តី ដែលមិនមែនជារឿងព្រហ្មទណ្ឌនោះទេ (មាត្រា ៩) ហើយមិនត្រូវរក្សាទុកសំណុំរឿងក្តី ឬបដិសេធក្នុងការបញ្ជូនរឿងក្តីទៅឱ្យព្រះរាជអាជ្ញា ដោយសារមានកិច្ចព្រមព្រៀងរវាងគូភាគីរួចហើយទេ។ ប្រសិនបើដូច្នោះមែន ព្រះរាជអាជ្ញានឹងអាចធ្វើការចោទប្រកាន់ពីបទរាំង ដល់នីតិវិធីរបស់តុលាការ (មាត្រា ១៥)។

| | |
|---|---|
| | **ប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពីរបៀបរបបធ្វើការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ (១១ មិថុនា ២០០៤)** |
| មិនទទួលរឿងក្តីដែលមិនមែនជារឿងព្រហ្មទណ្ឌនោះទេ | ប្រការ ៩ : ក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមមិនជាក់ស្តែង ហើយដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបណ្តឹង ឬបានដឹងអំពីព្រឹត្តិហេតុនៃបទល្មើសនោះដែលកើតមានឡើងនៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាប្រញាប់ទៅព្រះរាជអាជ្ញាសាម៉ី ទៅថ្នាក់លើរបស់ខ្លួនជាខ្សែបណ្តោយតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន រួចចុះទៅពិនិត្យស្រាវជ្រាវស្វែងរកបទល្មើស និងកសាងសំណុំរឿងព្រហ្មទណ្ឌជូនទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងក្នុងពេលដ៏ខ្លី ហើយរាយការណ៍ជូនទៅថ្នាក់លើរបស់ខ្លួន អំពីសកម្មភាពការងារដែលខ្លួនបានបំពេញដោយភ្ជាប់នូវសេចក្តីចម្លងសំណុំឯកសារផ្សេងៗនៃសំណុំរឿងទៅជាមួយផង ។<br><br>ក្នុងករណីដែលទទួលបណ្តឹងទាំងឡាយ ដែលមិនចូលជាបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកោះអញ្ជើញម្ចាស់បណ្តឹង ឱ្យមកទទួលយកសំណុំរឿងវិញ ដោយពន្យល់គេឱ្យយកទៅដាក់ជូនចំស្ថាប័នមានសមត្ថកិច្ច ឬជួយបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើមានសំណូមពរពីម្ចាស់បណ្តឹង ដោយមិនត្រូវតម្កល់ទុកសំណុំរឿងមិនចាត់ការឡើយ ពីព្រោះមន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់រដ្ឋ និង របស់ប្រជាពលរដ្ឋ។ |
| ការរំខានដល់តុលាការ : បដិសេធក្នុងការបញ្ជូនរឿងក្តីមកព្រះរាជអាជ្ញាដោយសារមានការព្រមព្រៀងរវាងគូភាគី | ប្រការ ១៥ : ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ដែលជាម្ចាស់បណ្តឹងអាជ្ញា និងជាអ្នកដឹកនាំប្រតិបត្តិការនៃមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបង្ក្រាបបទល្មើស កាលបើបានទទួលព័ត៌មាន ឬសេចក្តីរាយការណ៍ថា មន្ត្រីនគរបាលយុត្តិធម៌បានផ្អិបសំណុំរឿងចោលឬតម្កល់រឿងទុកមិនចាត់ការ ឬមិនព្រមបញ្ជូនមកព្រះរាជអាជ្ញា ក្រោមមូលហេតុគូភាគីបានព្រមព្រៀងគ្នាក៏ដោយនោះ ព្រះរាជអាជ្ញាត្រូវចេញបង្គាប់ឱ្យមន្ត្រីនគរបាលដែលមានសមត្ថកិច្ចនោះចាត់ការជាបន្ទាន់តាមនីតិវិធី មន្ត្រីនគរបាលយុត្តិធម៌ជាគោលការណ៍ត្រូវតែអនុវត្តតាមបញ្ជានេះជាដរាប។ ក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌ មិនព្រមអនុវត្តតាមដីកាបង្គាប់ ឬលិខិតបញ្ជារបស់ព្រះរាជអាជ្ញាទេ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់ពីបទរារាំងនីតិវិធីរបស់តុលាការ ដែលមានចែងក្នុងមាត្រា ៤៥ នៃក្រឹត្យច្បាប់លេខ ២៧ ក្រ.ច ចុះថ្ងៃទី ១២-០៣-៨៦ ឬតាមច្បាប់ផ្សេងទៀត ដែលចែងពីបទល្មើសប្រភេទនេះ ។ |
| | **ក្រឹត្យច្បាប់លេខ ២៧ ស្តីពីការចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនជាបណ្តោះអាសន្ន ការដោះលែង ការរឹបអូសរបស់ឆែកឆេរលំនៅដ្ឋាន សំភារៈវត្ថុ និងលើខ្លួនបុគ្គល -១២ មិនា ១៩៨៦** |
| ការរារាំងដល់នីតិវិធីតុលាការ | មាត្រា ៤៥ : ជនណាបង្កឧបសគ្គដល់ការអនុវត្តអាជ្ញាចាប់ ឃាត់ ឬ ឃុំខ្លួន ក្នុងគោលបំណងបិទបាំងជនប្រព្រឹត្តបទល្មើស ក្នុងគោលបំណងចង់បានផលប្រយោជន៍ផ្ទាល់ខ្លួន បង្កអន្តរាយដល់ការស៊ើបអង្កេត ឬមិនព្រមដោះលែងតាមលិខិត ឬដីការបស់អង្គការមានសមត្ថកិច្ច ឬកំណត់នៃសាលក្រមរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ខែ ដល់ ២ ឆ្នាំ។ |

ក្របខណ្ឌស្ថាប័ន:

មានប៉ុស្តិ៍នគរបាលនៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ។ នគរបាលគឺជាស្ថាប័នមួយដ៏ធំទូលំទូលាយជាងគេ ដែលទាក់ទងក្នុងរឿងសន្តិសុខ និងការងារយុត្តិធម៌។ នៅប៉ុស្តិ៍ក្នុងឃុំ មានមន្ត្រីនគរបាលប្រហែលជា ៥ ទៅ ៧នាក់ ទោះបីជាមានអត្រាបទល្មើសតិចក៏ដោយ។ នគរបាលទទួលបន្ទុកលើការងារអត្រានុកូលដ្ឋាន និងការគ្រប់គ្រងរដ្ឋបាលមួយចំនួនលើប្រជាពលរដ្ឋ។ កម្រិតនៃការអប់រំរបស់នគរបាលឃុំ មានកម្រិតទាបណាស់។ នៅតាមតំបន់ជនបទ ក្នុងករណីខ្លះមន្ត្រីនគរបាលប៉ុស្តិ៍ជាច្រើនជាអ្នកមិនចេះអក្សរ[១៩៣] ។

ប្រាក់ខែរបស់នគរបាលឃុំទាប។ ជាផ្លូវការនគរបាលម្នាក់ទទួលប្រាក់បៀវត្សរ៍ពី ២០ ទៅ ៤៥ ដុល្លារអាមេរិក។ ប្រាក់បៀវត្សរ៍នេះ មិនអាចដោះស្រាយចំពោះសេចក្តីត្រូវការជាមូលដ្ឋានរបស់ពួកគេបានឡើយ។

**តារាងនៃប្រាក់ចំណូលរបស់នគរបាល**

| ល.រ | តួនាទី | ប្រាក់បៀវត្សរ៍សុទ្ធ | សរុប | សរុបជាលុយដុល្លារ |
|---|---|---|---|---|
| ១ | ស្នងការ ( ឧត្តមសេនីយ៍ត្រី ឬ វរសេនីយ៍ឯក) | ៦៤.៥០០ - ៦៨.៥០០ | ១៦០.០០០-១៨០.០០០ | ៤០-៥០ |
| ២ | អធិការ | ៥៤.៥០០ | ១៤០.០០០ | ៣៥ |
| ៣ | នាយប៉ុស្តិ៍រដ្ឋបាល | ២៦.៤០០- | ប្រហែល ១០០.០០០ | ២៥ |
| | ឧត្តមសេនីយ៍ត្រី | ៦៨.៥០០ រៀល | | ១៧.១២ |
| | វរសេនីយ៍ឯក | ៦៤.៥០០ រៀល | | ១៦.១២ |
| | វរសេនីយ៍ទោ | ៥៨.៥០០ រៀល | | ១៤.៦២ |
| | វរសេនីយ៍ត្រី | ៥៤.៥០០ រៀល | ១៤០.០០០ រៀល | ៣៥ |
| | អនុសេនីយ៍ឯក | ២៨.៤០០ រៀល | | |
| | អនុសេនីយ៍ទោ | ២៧.៤០០ រៀល | | |
| | អនុសេនីយ៍ត្រី | ២៦.៤០០ រៀល | | |
| | ព្រិន្ទបាល | ២៥.៤០០ រៀល | ប្រហែល ៩០.០០០រៀល | ២២.៥ |
| | នគរបាល | ២៤.៥០០ រៀល | ប្រហែល ៨០.០០០រៀល | ២០ |

នគរបាលក៏ខ្វះខាតមធ្យោបាយចាំបាច់ ក្នុងការបំពេញបេសកកម្មរបស់ខ្លួនឱ្យបានល្អប្រសើរផងដែរ ដូចជា ខ្វះខាតមធ្យោបាយធ្វើដំណើរ វិទ្យុទាក់ទង និងសម្ភារៈការិយាល័យដទៃទៀត។

> ***នគរបាលស្រុក នៅខេត្តសៀមរាប :***
> *"យើងមានម៉ូតូ តែ៤គ្រឿងសម្រាប់ថ្នាក់ស្រុក និងមានវិទ្យុទាក់ទងមួយចំនួន គ្រាន់តែសម្រាប់មន្ត្រីខ្លះប៉ុណ្ណោះ ប៉ុន្តែយើងត្រូវការម៉ូតូមួយចំនួនទៀតសម្រាប់ថ្នាក់ឃុំ ទូរស័ព្ទ ទូរសារ សម្ភារៈ និងវិទ្យុទាក់ទងថែមទៀត"* ។

[១៩៣] ដូចជានៅឃុំ រំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

## ២.៤.២. តម្រូវការយុត្តិធម៌នៅចំពោះមុខនគរបាល

បញ្ហា:

យោងតាមការស្ទង់មតិរបស់ IRL បានបង្ហាញថា នគរបាលបានទទួលរឿងក្តីជាច្រើនទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសដែលកើតឡើង។ តែទោះជាយ៉ាងនេះក្តី ស្ថាប័ននេះក៏បានទទួលរឿងក្តីរដ្ឋប្បវេណី និងរឿងវិវាទដីធ្លីផងដែរ។

តាមរយៈបទសម្ភាសន៍ និងឯកសារដែលប្រមូលបានរបស់យើង នគរបាលក៏ជួយដោះស្រាយរឿងក្តីរដ្ឋប្បវេណីផងដែរ ដូចជាករណីបំណុល ក្នុងការដាក់ឱ្យអនុវត្តកិច្ចសន្យា នៅពេលម្ចាស់បំណុលស្នើសុំឱ្យអនុវត្តជាដើម។ ក្នុងរឿងក្តីអំពើហិង្សាក្នុងគ្រួសារភាគច្រើន នគរបាលធ្វើការ "សម្រុះសម្រួល"។ សូម្បីតែក្នុងរឿងក្តីបទល្មើសព្រហ្មទណ្ឌ ដូចជា ការបង្ករបួសស្នាម ឬបទរំលោភសេពសន្ថវៈ នគរបាលជម្រុញឱ្យភាគីធ្វើការសម្រុះសម្រួល តាមរយៈការសងសំណងខូចខាតជាលុយកាក់ជូនដល់ជនរងគ្រោះ។ វាគឺជាការពិបាកក្នុងការកំណត់ចំនួនរឿងក្តី ដែលបានទទួលដោយនគរបាល ដោយសារពួកគេមិនមានកត់ត្រាគ្រប់រឿងក្តី ដែលគេបានទទួលនោះឡើយ។

ករណី១ : **វិវាទរវាងអ្នកជិតខាងដែលបានប្តឹងទៅនគរបាលថ្នាក់ឃុំ** ១៥៤

*លោកស្រី ជជ បានដាក់ពាក្យបណ្តឹងលោកស្រី ផផ ដោយបានរៀបរាប់ថា លោកស្រី ផផ យកមែកល្ហុងវាយគាត់ ៦-៧ ដង ធ្វើឱ្យលោកស្រី ជជ រងរបួសនិងស្នាមនៅលើខ្លួនប្រាណ។ លោកស្រី ជជ បានទៅផ្ទះលោកស្រី ផផ ដើម្បីហៅប្តីខ្លួនមកព្យាបាល។ លោកស្រី ជជ និយាយថា "ខ្ញុំបានហៅប្តីខ្ញុំឱ្យចេញពីផ្ទះប្រពន្ធចុងរបស់គាត់។ ភ្លាមនោះ លោកស្រី ផផ ចេញមកពីផ្ទះហើយវាយខ្ញុំ"។*

*(ពាក្យប្តឹងចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០០៤)*

ករណី២ : **ការបរិហារកេរ្តិ៍ ដែលបានប្តឹងទៅនគរបាលថ្នាក់ឃុំ និងស្រុក** ១៥៥

*លោក កក និងលោក ខខ រស់នៅឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ នៅថ្ងៃទី ១៥ ខែតុលា ២០០៤ លោក កក បានប្តឹងលោក ខខ ពីបទបរិហាកេរ្តិ៍។ អំពើបរិហាកេរ្តិ៍នេះបានកើតនៅថ្ងៃទី ១២ តុលា ២០០៤ នៅប៉ុស្តិ៍នគបាលឃុំព្រះដាក់។ លោក កក ប្តឹងទាមទារប្រាក់សំណងចំនួន ៥០០ ដុល្លារអាមេរិក។ នៅថ្ងៃទី ១៩ តុលា ២០០៤ កិច្ចប្រជុំសម្រុះសម្រួល ត្រូវបានធ្វើឡើងនៅប៉ុស្តិ៍នគរបាលឃុំព្រះដាក់ ដឹកនាំដោយអនុសេនីទោ... ជាអធិការរងស្រុកបន្ទាយស្រី។ នៅពេលសម្រុះសម្រួល នគរបាលបានអានពាក្យបណ្តឹង ចម្លើយរបស់សាក្សី និងកំណត់ហេតុសួរចម្លើយចំពោះលោក ខខ។ នៅពេលសម្រុះសម្រួលនេះដែល នគរបាលបានអានមាត្រា ៦៣ (ច្បាប់អ៊ុនតាក់) ដែលបានចែងថា ជនណាប្រព្រឹត្តបទបរិហារកេរ្តិ៍ នឹងត្រូវដាក់ទោសពន្ធនាគារពី ៨ ថ្ងៃ ដល់ មួយឆ្នាំ និងពិន័យជាប្រាក់ពី មួយលាន ដល់ ដប់លានរៀល។ ចុងចម្លើយ លោក ខខ បានសារភាពថា រឿងហេតុគឺមកពីគាត់ស្រវឹងនៅពេលនោះ ហើយបានសុខចិត្តសងសំណង ២៥០ដុល្លារ និងសន្យាថាឈប់ធ្វើដូច្នោះទៀតហើយ។ ដើមបណ្តឹង លោក កក បានយល់ព្រម ហើយគូភាគី និងសាក្សីបានផ្តិតមេដៃលើកិច្ចសន្យា។*

---

១៥៤ សូមមើលរឿងក្តីលេខ L4 ក្នុងឧបសម្ព័ន្ធទី ២

១៥៥ សូមមើលរឿងក្តីលេខ L2 ក្នុងឧបសម្ព័ន្ធទី ២

ករណីទី៣ : **ការបង្ករបួសស្នាម និងការរំលោភលំនៅដ្ឋានដែលបានប្ដឹងទៅនគរបាលឃុំ និងស្រុក** [១៥៦]

*លោក កក និងលោក ខខ រស់នៅក្នុងភូមិជាមួយគ្នា នៅឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៤ លោក កក បានប្ដឹងលោក ខខ ពីបទបង្ករបួសស្នាម ដោយចេតនា និងការរំលោភលំនៅដ្ឋានរបស់គាត់។ ពាក្យបណ្ដឹងត្រូវបានដាក់នៅអធិការដ្ឋាននគរបាលស្រុកបន្ទាយស្រី ។ លោក កក ទាមទារសំណងចំនួន ៥០០ ដុល្លារអាមេរិក។ នៅថ្ងៃទី ៣១ ខែ តុលា ២០០៥។ ការសម្រុះសម្រួលត្រូវ ធ្វើឡើងនៅអធិការដ្ឋាននគរបាលស្រុក ដឹកនាំដោយអធិការរងស្រុកបន្ទាយស្រី។ នៅពេលសម្រុះសម្រួល នគរបាលបានអានកំណត់ហេតុបណ្ដឹង ចម្លើយសាក្សី និងកំណត់ហេតុសាកសួរ ព្រមទាំងមាត្រា ៤១ (ច្បាប់អ៊ិនតាក់) ដែលចែងថាជនដែលរំលោភលើមាត្រានេះ នឹងត្រូវជាប់ពន្ធនាគារ និងត្រូវពិន័យជាប្រាក់ចំពោះជនរងគ្រោះ។ ចុងចម្លើយបានទទួលយកការពិត។ ពួកគេព្រមសង ២០០ដុល្លារ ហើយសន្យា ថាមិនមានគំនុំគុំគួននឹងក្រុមគ្រួសារដើមបណ្ដឹងទេ តែនឹងរក្សាទំនាក់ទំនងអ្នកជិតខាងឡើងវិញ ដើមបណ្ដឹងយល់ព្រម។ គូភាគី និងសាក្សីបានផ្ដិតមេដៃនៅលើកិច្ចសន្យា។*

នៅក្នុងករណីព្រហ្មទណ្ឌទាំងនេះ នគរបាលនៅថ្នាក់ឃុំ និងថ្នាក់ស្រុក បានធ្វើការសម្រុះសម្រួលហួសពីដែនសមត្ថកិច្ចរបស់ខ្លួន។ នៅពេលសម្រុះសម្រួល នគរបាលប្រើប្រាស់សំពាធដោយខុសច្បាប់ទៅលើជនល្មើស ដើម្បីឱ្យជនល្មើសយល់ព្រមលើដំណោះស្រាយណាមួយ ដោយអានមាត្រាច្បាប់នានាដើម្បីឱ្យជនល្មើសយល់ ឬដឹងថាខ្លួននឹងទទួលការដាក់ទោសកាន់តែធ្ងន់ធ្ងរថែមទៀតបើសិនជាត្រូវប្ដឹងទៅតុលាការ។ នៅករណីទី២ នគរបាលបានអានមាត្រា ៤១ នៃច្បាប់អ៊ុនតាក់ដែលចែងអំពីទោសទណ្ឌ សម្រាប់ការរំលោភលើលំនៅដ្ឋាន ទោះជាមាត្រានេះគ្រាន់តែនិយាយអំពីការបង្ករបួសស្នាមក្ដី។

ករណីទី៤ : **រឿងក្ដីបំណុលដែលត្រូវបានសម្រុះសម្រួលដោយនគរបាលថ្នាក់ស្រុក**

*លោកស្រី កក និងលោកស្រី ខខ រស់នៅក្នុងភូមិស្ដុក ឃុំស្ដុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺជាមួយគ្នា។ នៅខែ កញ្ញា ឆ្នាំ ២០០៣ ប្អូនស្រីរបស់លោកស្រី ខខ បានទៅរកខ្ចីលុយពីលោកស្រី ខខ ចំនួន ៥០.០០០ រៀល។ លោកស្រី ខខ ពុំមានលុយ ហើយលោកស្រីខខ ក៏ទៅពឹងលោកស្រី កក ឱ្យជួយទៅនិយាយខ្ចីលុយពី អ្នករកស៊ីម្នាក់ដែលលោកស្រី កក ស្គាល់។ ពេលនោះ លោកស្រី កក បានយកប្រាក់ឱ្យលោកស្រី ខខ ខ្ចីចំនួន ៥០០.០០០ រៀល ដោយមានការប្រាក់ចំនួន ២០% ក្នុងមួយខែ១ ស្មើនឹង ១០០.០០០ រៀល។ លោកស្រីកក និងលោកស្រី ខខ បានធ្វើកិច្ចសន្យាមួយ ដោយមានលោកមេភូមិជាសាក្សី ហើយលោកស្រី ខខ យល់ព្រមបង់ប្រាក់ការប្រចាំខែ រៀងរាល់ខែ។*

*ពីរខែក្រោយមក លោកស្រី ខខ ខកខានមិនបានបង់ការប្រាក់ ។ ជាលទ្ធផល លោកស្រី កក ត្រូវបង់ការប្រាក់ជំនួសលោកស្រី ខខ ជូនទៅអ្នករកស៊ីដែលជាម្ចាស់លុយ។ លោកស្រី កក បានទៅពឹងពាក់នគរបាលនៅថ្នាក់ឃុំជួយបង្ខំឱ្យលោកស្រី ខខ សងប្រាក់ដែលខ្លួនបានបង់ការប្រាក់ឱ្យគេ។ នគរបាលឃុំបាន តម្រូវឱ្យលោកស្រី កក បង់ប្រាក់ចំនួន ១០.០០០ រៀល ជាឈ្នួលសម្រាប់ ការដោះស្រាយករណីនេះ ។ នគរបាលឃុំបានហៅលោកស្រី ខខ មកដើម្បីសម្រុះសម្រួល។ នៅពេលសម្រុះសម្រួល លោកស្រី ខខ សន្យាថាគាត់ជាអ្នករ៉ាប់រងនូវការសងប្រាក់ និងការប្រាក់ទាំងអស់ ព្រមទាំងសងប្រាក់ទៅលោកស្រី កក វិញដែរ។ ភាគីទាំងពីរបានធ្វើកិច្ចសន្យានៅចំពោះមុខនគរបាល។ មួយខែក្រោយមកលោកស្រី ខខ មិនបានបង់ប្រាក់ការទៀត។ លោកស្រី កក បានប្ដឹងទៅនគរបាលថ្នាក់ស្រុក។ លោកស្រី កក ត្រូវបង់ប្រាក់ថ្លៃបណ្ដឹងចំនួន ១៥.០០០ រៀលទៅនគរបាលស្រុក។ នគរបាលថ្នាក់ស្រុកបានហៅលោកស្រី ខខ មកសម្រុះសម្រួលទៀត។*

---

[១៥៦] សូមមើលរឿងក្ដីលេខ ៤ ក្នុងឧបសម្ព័ន្ធទី ២

*ជាថ្មីម្តងទៀត លោកស្រី ខខ សន្យាថាជាអ្នករ៉ាប់រងនូវសំណងទាំងអស់ ។ តែទោះ ជាយ៉ាងនេះក្តី លោកស្រី ខខ មិនបានបង់ទៀត ។ ជាចុងក្រោយ លោកស្រី កក បង្ខំឱ្យលោកស្រី ខខ ឱ្យឱ្យស្រែរបស់គាត់ទៅម្ចាស់លុយដែលជាអ្នករកស៊ីកាត់ជាមួយនឹងប្រាក់ចំនួន ៥០០.០០០ រៀលដែលគាត់ជំពាក់ ព្រោះគាត់មិនអាចមានប្រាក់បង់ការមួយខែ ១០០.០០០ ឡើយ ។*

*នៅខែមករា ឆ្នាំ ២០០៤ លោកស្រី កក បានដាក់ពាក្យប្តឹងទៅតុលាការ ដោយចោទលោកស្រី ខខ ថា លោកស្រី ខខ បានរំលោភកិច្ចសន្យា ។ តម្លៃនៃការដាក់ពាក្យប្តឹងនេះគឺ ១០០.០០០ រៀល ។ មួយខែក្រោយមក តុលាការបានហៅគូភាគីមកសម្រុះសម្រួល ។ ជាថ្មីម្តងទៀត លោកស្រី ខខ សុខចិត្តទទួលរ៉ាប់រងក្នុងការសងប្រាក់ដែលគាត់ខ្ចី តែគាត់មិនបានបង់ទៀតលើកនេះ ។ រហូតមកដល់ខែ វិច្ឆិកា ឆ្នាំ ២០០៤ តុលាការមិនទាន់បានជំនុំជំរះរឿងក្តីនេះនៅឡើយទេ ។ លោកស្រី កក ត្រូវបានតុលាការកោះហៅចំនួន ៧ ដងហើយដើម្បីសាកសួរ ។ ដើម្បីធ្វើដំណើរឡើងទៅតុលាការមួយដង គាត់ត្រូវចាយលុយអស់ប្រមាណ ៤០០.០០០ រៀល ។ លោកស្រី កក និយាយថា គាត់ចង់ឱ្យតុលាការសម្រេចករណីនេះឱ្យបានឆាប់ បើពុំដូចនោះទេ គាត់មិនដឹងថាគាត់អាចមាន លទ្ធភាពបន្តរឿងក្តីនេះឬយ៉ាងណាទេ ។*

ករណីនេះ ប្រាប់យើងឱ្យដឹងថា នគរបាលទទួលសម្រុះសម្រួលទាំងករណីព្រហ្មទណ្ឌ ទាំងករណីរដ្ឋប្បវេណី ។ លើសពីនេះទៀត តាមរយៈករណីមួយនេះផងដែរ យើងមើលឃើញថា នគរបាលមានឥទ្ធិពលនៅក្នុងរឿងរដ្ឋប្បវេណី តិចជាងនៅក្នុងរឿងព្រហ្មទណ្ឌ ។ ក្នុងករណីរដ្ឋប្បវេណីនេះផងដែរ ទោះបីជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅចំពោះមុខនគរបាលក៏ដោយក៏នគរបាលពុំមានអំណាច ក្នុងការបង្ខំឱ្យគូភាគីអនុវត្តកិច្ចព្រមព្រៀងនោះដែរ ។ មិនដូចករណីព្រហ្មទណ្ឌទេ ដែលជនល្មើសត្រូវតែបំពេញនូវអ្វីដែលខ្លួនបានព្រមព្រៀងនៅចំពោះមុខនគរបាល បើពុំដូចនោះទេ ជនល្មើសនឹងត្រូវទទួលការដាក់ទោសទណ្ឌកាន់តែធ្ងន់តាមផ្លូវច្បាប់ ។



ក្នុងរឿងក្តីព្រហ្មទណ្ឌ ដូចជាការរំលោភសេពសន្ថវៈ ការបង្ករបួសស្នាមនិងករណីផ្សេងៗទៀត ប្រជាពលរដ្ឋអាចទៅរកនគរបាលឃុំដោយផ្ទាល់ ដោយសារនគរបាលគឺជាភ្នាក់ងារ ដែលនៅជិតជាងគេហើយមានអំណាចដោះស្រាយរឿងព្រហ្មទណ្ឌ។ ក្នុងករណីខ្លះទៀត អ្នកភូមិទៅរកនគរបាលក្រោយពីទទួលបានការជូនដំណឹង ឬពន្យល់ពីលោកមេភូមិ ឬក្រុមប្រឹក្សាឃុំ។ ក្នុងសិក្ខាសាលានានា អ្នកចូលរួមមួយចំនួនបានពន្យល់ប្រាប់ថា សូម្បីតែក្នុងរឿងក្តីរដ្ឋប្បវេណី ដូចជា ការខ្ចីប្រាក់ប្រជាពលរដ្ឋចូលចិត្តទៅចុះកិច្ចសន្យានៅចំពោះមុខនគរបាល។ ធ្វើដូចនេះ នៅពេលដែលកូនបំណុលខកខានមិនបានសងម្ចាស់បំណុល ទៅរកការិយាល័យនគរបាល ដើម្បីអនុវត្តកិច្ចសន្យាជំពាក់ប្រាក់ ដោយឱ្យនគរបាលបញ្ជាទៅកូនបំណុលឱ្យសង។ ក្នុងករណីនេះ អ្នកចូលរួមទាំងនោះបាននិយាយថា ម្ចាស់បំណុលបានជូនលុយកាក់មួយចំនួនដល់នគរបាលសម្រាប់ជា "ថ្លៃសេវា"។

នេះគឺជាការអនុវត្តដែលមិនមានច្បាប់អនុញ្ញាតឡើយ។ តែទោះជាយ៉ាងនេះក្តី អ្នកភូមិមិនអាចរកអាជ្ញាធរណាផ្សេងទៀត ដែលមានសមត្ថភាពក្នុងការដាក់ឱ្យអនុវត្តកិច្ចសន្យា ឬសេចក្តីសម្រេចនានានៅថ្នាក់មូលដ្ឋាននោះទេ។

ការសម្រុះសម្រួលក្រៅផ្លូវការនានា:

ដោយហេតុថា នគរបាលពុំមានសមត្ថកិច្ចផ្លូវច្បាប់ដើម្បីបញ្ជូនរឿងក្តីពីថ្នាក់ឃុំ ឬថ្នាក់ស្រុកដោយផ្ទាល់ទៅ ព្រះរាជអាជ្ញា នាំឱ្យឱកាសក្នុងការសម្រុះសម្រួលក្រៅផ្លូវការ រហូតដល់ទៅបីដំណាក់កាល (គឺនៅថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត) សម្រាប់ការព្រមព្រៀងគ្នារវាងជនល្មើស និងជនរងគ្រោះ ដូចនេះជនល្មើសអាចរួចផុតពីការចោទប្រកាន់ បទព្រហ្មទណ្ឌ ហើយជនរងគ្រោះអាចទទួលបាននូវសំណងខូចខាតកម្រិតណាមួយ។ "ការសម្រុះសម្រួលក្រៅផ្លូវការ" ទាំងនេះត្រូវបានហាមឃាត់ដោយច្បាប់ និងអាចត្រូវបានចាត់ទុកថាជា "ការរារាំងដល់យុត្តិធម៌"។ តែទោះជាយ៉ាងនេះក្តី វាហាក់ដូចជាត្រូវបានគេទទួលយក ក្នុងការអនុវត្តន៍ជាធម្មតាទៅហើយ។

ប្រសិនបើជនរងគ្រោះត្រូវធ្វើតាមនីតិវិធីព្រហ្មទណ្ឌ ដូចដែលបានចែងនោះ ជនរងគ្រោះត្រូវប្រើពេលយ៉ាងយូរ និងចំណាយយ៉ាងច្រើន។ ជាដំបូងជនរងគ្រោះត្រូវបង់ថ្លៃធ្វើកោសល្យវិច្ច័យ។ បន្ទាប់មកត្រូវធ្វើដំណើរជាច្រើនលើកមកខេត្ត ដើម្បីតាមដានរឿងក្តី និងបង់ថ្លៃធ្វើដំណើរ និងអាហារក្នុងការនាំសាក្សីមកកាន់តុលាការ។ លើសពីនេះទៅទៀត ជាចុងក្រោយប្រហែលជាជនរងគ្រោះ អាចនឹងមិនបានទទួលសំណងការខូចខាតអ្វីនោះទេ[១៩៧]។ អ្នកចូលរួមក្នុងសិក្ខាសាលាបានប្រាប់ថា ករណីមួយចំនួនជនរងគ្រោះត្រូវចេញលុយធ្វើដំណើរឱ្យនគរបាល។

- ជាធម្មតា ជនរងគ្រោះចង់ឱ្យមានការសងសំណងនៅថ្នាក់ឃុំ ដោយសារវាមាក់មងនឹងការចំណាយលុយ និងពេលវេលាតិចជាងទៅរកតុលាការ។
- ក្នុងករណីខ្លះ (ដូចជាការបង្ករបួសស្នាម ការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ បំណុល និងគ្រោះថ្នាក់ចរាចរ) នគរបាលលើកទឹកចិត្តឱ្យគូភាគីព្រមព្រៀងគ្នាទទួលយកសំណងការខូចខាតពីជនល្មើស។
- ជនល្មើសត្រូវបានបង្ខំឱ្យបង់ការខូចខាតភ្លាមៗដល់ជនរងគ្រោះ។
- គូភាគីត្រូវបង់លុយមួយចំនួនដល់នគរបាលពេលខ្លះ ។
- ប្រសិនបើជនល្មើសមិនព្រមបង់ទេ នគរបាលឃុំបញ្ជូនរឿងក្តីទៅកាន់នគរបាលស្រុក ហើយបន្ទាប់មកនគរបាលខេត្ត ដែលជាអ្នកចុងក្រោយបញ្ជូនរឿងក្តីទៅកាន់ព្រះរាជអាជ្ញា។

---

១៩៧ នៅប្រទេសដទៃៗទៀត មានចែងនូវវិធានការក្រៅតុលាការនានា សម្រាប់បទល្មើសព្រហ្មទណ្ឌតូចតាច ដោយមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ដើម្បីចៀសវាងនូវដំណើរការក្តីតាមផ្លូវច្បាប់សម្រាប់បទល្មើសតូចតាចទាំងនេះ។ ការអនុញ្ញាតឱ្យមានវិធានការបែបនេះ ជាទូទៅធ្វើទៅបានដោយមានការឯកភាពពីជនរងគ្រោះ អ្នកប្រព្រឹត្តបទល្មើស និងនគរបាល ដោយមានការគាំទ្រដោយច្បាប់។

- ក្នុងករណីខ្លះ ជនរងគ្រោះត្រូវបង់ថ្លៃការធ្វើដំណើររបស់នគរបាល ក៏ដូចជាការចំណាយផ្សេងៗទៀតផងដែរ។

> **នគរបាលស្រុក នៅក្នុងខេត្តសៀមរាប:**
>
> *"ឧទាហរណ៍ មានការសម្រុះសម្រួលក្នុងរឿងក្ដីពីបទបរិហារកេរ្តិ៍។ ជនរងគ្រោះបានស្នើសុំ ៥០០ដុល្លារ។ ជនជាប់ចោទព្រមបង់ ២០០ដុល្លារ។ ក្រោយគូភាគីបានព្រមព្រៀងគ្នា ពួកគេចុះកិច្ចសន្យាសម្រុះសម្រួលគ្នា បញ្ចប់រឿងក្ដី ដោយការសងសំណងខូចខាត។ រឿងក្ដីនេះកើតឡើងថ្មីៗ នៅក្នុងខែសីហា ឆ្នាំ២០០៤។*
>
> (បទសម្ភាសន៍ : ក្នុងខែធ្នូ ឆ្នាំ ២០០៤)

## ២.៤.៣. ការវាយតម្លៃលើនគរបាល

អ្នកចូលរួមក្នុងសិក្ខាសាលាបានបង្ហាញនូវការវាយតម្លៃដល់នគរបាលដូចខាងក្រោមនេះ។

| ចំណុចល្អ | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|
| - ទទួលបណ្ដឹងពីប្រជាពលរដ្ឋ<br>- ចុះដល់កន្លែងកើតហេតុបទល្មើស និងធ្វើការស៊ើបអង្កេត<br>- បញ្ជូនរឿងក្ដីទៅអាជ្ញាធរដែលមានសមត្ថកិច្ច<br>- បង្ការ និងបង្ក្រាបបទល្មើស | - ទាមទារឱ្យមានការបង់ថ្លៃការស៊ើបអង្កេតពីភាគី<br>- យឺតយ៉ាវក្នុងការបង្ក្រាបបទល្មើស និងប្រើពេលយូរក្នុងការបញ្ជូនរឿងក្ដី ទៅថ្នាក់លើ<br>- ជួមកាលដោះស្រាយរឿងក្ដី ដែលឋិតនៅក្រៅសមត្ថកិច្ចរបស់ខ្លួន<br>- គំរោះគំរើយ និងមិនគួរសមដាក់ប្រជាពលរដ្ឋ<br>- ជម្រិតទារប្រាក់ពីប្រជាពលរដ្ឋ | - គួរតែគោរពសិទ្ធិប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្ដឹង<br>- ការស៊ើបអង្កេតគួរតែធ្វើឱ្យបានទាន់ពេលវេលា<br>- ចៀសវាងដោះស្រាយរឿងក្ដីដែលមិនឋិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន<br>- ចៀសវាងដាក់សំពាធ និងគំរាមកំហែងប្រជាពលរដ្ឋ<br>- គួរតែអនុវត្តតាមច្បាប់<br>- គួរតែឈប់ជម្រិតទារប្រាក់ពីប្រជាពលរដ្ឋ |

យោងតាមអ្នកដែលត្រូវបានសម្ភាសន៍ និងអ្នកដែលចូលរួមក្នុងសិក្ខាសាលា បានឱ្យដឹងថា "ការសម្រុះសម្រួល" និងសំណងខូចខាតនៅចំពោះមុខនគរបាល កើតឡើងចំពោះរឿងក្ដីព្រហ្មទណ្ឌជាច្រើនប្រភេទ ដូចជា ការបរិហារកេរ្តិ៍ ការបង្ករបួសស្នាម អំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែក៏មានបទរំលោភសេពសន្ថវៈ និងរឿងក្ដីធ្ងន់ធ្ងរមួយចំនួនផ្សេងទៀតផងដែរ[១៩៨]។ តាមប្រភពដដែលនេះផងដែរ ភាគីវិវាទជាទូទៅមានទម្លាប់បង់លុយជាសគុណចំពោះនគរបាល នេះបានក្លាយជារឿងធម្មតាទៅហើយ។

នៅប្រទេសផ្សេងៗទៀត ច្បាប់ព្រហ្មទណ្ឌអនុញ្ញាតឱ្យមានវិធានការណ៍ជំនួស ឬក្រៅតុលាការផ្សេងៗ ក្នុងការដោះស្រាយបញ្ហាព្រហ្មទណ្ឌ ដែលរួមទាំងឱកាសដោះស្រាយដោយការចរចាររបស់ភាគី (plea-bargainning) វិធានការជំនួសពន្ធនាគារ និងគោលការណ៍ផ្ដល់ឱកាសផ្សេងៗទៀត ដើម្បីបំពេញគោលដៅព្រហ្មទណ្ឌ ដោយចៀសវាងការជំនុំជំរះតាមផ្លូវ

---

[១៩៨] អង្គការ ADHOC បានរាយការណ៍អំពីការសម្រុះសម្រួលក្រៅផ្លូវការ នៃបទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសផ្សេងៗទៀត។ សូមមើលរបាយការណ៍របស់អង្គការនេះនៅឆ្នាំ ២០០៤។

តុលាការតាមដែលអាចធ្វើទៅបាន។ គោលដៅនៃដំណើរការក្តីព្រហ្មទណ្ឌគឺៈ ក-ដើម្បីទប់ស្កាត់ជាទូទៅនៃបទល្មើស ខ-ទប់ស្កាត់ជាពិសេសនូវបទល្មើស និង គ-ការផ្តល់សំណងខូចខាតចំពោះជនរងគ្រោះ។ បើសិនជាគោលដៅទាំងនេះ អាចសម្រេចបានដោយមិនចាំបាច់មានការជំនុំជំរះ ដែលត្រូវចំណាយថវិការច្រើន ហើយរដ្ឋអាចសន្សំនូវធនធានដ៏កម្ររបស់ខ្លួន ដើម្បីផ្តន្ទាទោសបទល្មើសធ្ងន់ធ្ងរផ្សេងៗ ហើយនិងជួយសំរួលដល់យន្តការដទៃ សម្រាប់ផ្តល់សំណងជូនជនរងគ្រោះ ឬទប់ស្កាត់បទល្មើសផងដែរ។ ប៉ុន្តែប្រព័ន្ធជំនួសឱ្យតុលាការ មិនគួរជាប្រព័ន្ធ "ក្រៅផ្លូវការ" ឡើយ គឺយន្តការទាំងនេះត្រូវតែផ្តល់ការធានា និងការពារដល់ជនរងគ្រោះ និងជនជាប់ចោទ។ ដូចនេះច្បាប់ត្រូវតែចែងឱ្យច្បាស់ថាតើរឿងក្តីប្រភេទណា និងធ្ងន់ឬស្រាលកម្រិតណា ហើយមានលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះដែលអាចអនុវត្តនូវវិធានការទាំងនេះបាន។

ជាសង្ខេប ដោយនៅថ្នាក់មូលដ្ឋានពុំមានអាជ្ញាធរមានអំណាចយុត្តាធិការ នាំឱ្យប្រជាពលរដ្ឋទៅរកនគរបាល ដើម្បីអាចឱ្យខ្លួនបានទទួលនូវសំណងខូចខាត ពីជនល្មើសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ក៏ដូចជាដើម្បីដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ទោះបីជានគរបាលមិនមានសមត្ថកិច្ចស្របច្បាប់ ក្នុងការសម្រុះសម្រួល និងដោះស្រាយករណីព្រហ្មទណ្ឌក៏ដោយ។ ដោយសារនៅថ្នាក់ឃុំ និងថ្នាក់ស្រុកពុំមានអាជ្ញាធរណាមួយ ដែលមានសមត្ថកិច្ចក្នុងការអនុវត្តកិច្ចសន្យានោះ នគរបាលក៏ជាអាជ្ញាធរដែលដើរតួជាអ្នកអនុវត្តកិច្ចសន្យាពាក់ព័ន្ធនឹងបំណុល និងករណីរដ្ឋប្បវេណីផ្សេងៗទៀតដែរ។ ការដែលពុំមានអាជ្ញាធរមានយុត្តាធិការនៅថ្នាក់មូលដ្ឋាននេះ គឺជាបន្ទុកមួយដ៏ធំរបស់ប្រជាពលរដ្ឋ រស់នៅតំបន់ជនបទដាច់ស្រយាល។ ក្នុងការអនុវត្តជាក់ស្តែង នគរបាលបំពេញមុខងារជាអាជ្ញាធរមានយុត្តាធិការ (ទោះបីជាខ្លួនមិនមែនជាអាជ្ញាធរមានយុត្តាធិការក្តី) ដោយពុំមានការត្រួតពិនិត្យ ឬគណនេយ្យភាពឡើយ។ ការអនុវត្តរបស់នគរបាល និងអាជ្ញាធរមូលដ្ឋានយ៉ាងទូលំទូលាយក្នុងការ "សម្រុះសម្រួល" ករណីព្រហ្មទណ្ឌទាំងនេះ គឺជាភស្តុតាងយ៉ាងជាក់ច្បាស់ថា ជនរងគ្រោះដោយបទល្មើសព្រហ្មទណ្ឌ ត្រូវការសំណងជួសជុលការខូចខាត។ នៅក្នុងរឿងក្តីភាគច្រើន ជនរងគ្រោះក្លាយជាជនរងគ្រោះទ្វេរដង ដោយសារគំនាបនៃប្រព័ន្ធព្រហ្មទណ្ឌនាពេលបច្ចុប្បន្ននេះ ហើយជនរងគ្រោះទាំងនោះ មិនបានទទួលសំណងការខូចខាតឡើយ។ ការនេះបានឆ្លុះបញ្ចាំងអំពីភាពគ្មានប្រសិទ្ធិភាពរបស់ប្រព័ន្ធច្បាប់ ដែលមិនមានវិធានការជំនួសឱ្យការដោះស្រាយដោយជំនុំជំរះ ក៏ដូចជាមិនអនុញ្ញាតឱ្យមានគោលការណ៍ផ្តល់ឱកាសដោះស្រាយដោយការចរចាររបស់ភាគី (plea-bargainning) គោលការណ៍ស្តីពីការផ្តល់ប្រាក់សំណងការខូចខាត[១៩៩] និងវិធានការជំនួសពន្ធនាគារដែរ។

## ២.៥. អាជ្ញាធរនយោបាយ (អភិបាលស្រុក និងអភិបាលខេត្ត)

### ២.៥.១. ក្របខ័ណ្ឌផ្លូវច្បាប់ និងស្ថាប័ន

អភិបាលស្រុកៈ

អភិបាលស្រុក គឺជាមន្ត្រីរាជការដែលបានតែងតាំងដោយក្រសួងមហាផ្ទៃ និងមានមុខងារជាច្រើន។ យោងតាមបទបញ្ញត្តិច្បាប់នានាដែលមានពេលបច្ចុប្បន្ននេះ អភិបាលស្រុកមានមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ទទួលខុសត្រូវក្នុងការសម្រុះសម្រួលរឿងក្តីរដ្ឋប្បវេណី និងដាក់ពិន័យលើអ្នកដែលបានប្រព្រឹត្តិបទល្មើសលហុ ត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈ និងសម្រប

---

[១៩៩] ស្ថាប័ននេះ ឬវិធានការក្រៅតុលាការទាំងនេះ ត្រូវបានគេអនុញ្ញាតឱ្យមាននៅក្នុងនីតិវិធីព្រហ្មទណ្ឌនានា នៅប្រទេសមួយចំនួននៅអាមេរិកឡាទីន (ដូចជាប្រទេសកូឡុំប៊ី ឬនៅប្រទេសប៉េរូជាដើម)។ វាមានលក្ខណៈប្រហាក់ប្រហែលជាមួយនឹងគោលការណ៍ plea-bargaining តែមានច្បាប់ចែងច្រើនជាង។ សម្រាប់ករណីបទល្មើសព្រហ្មទណ្ឌ ដែលមិនសូវធ្ងន់ធ្ងរ (ដែលអាចទទួលទោសជាប់ពន្ធនាគារតិចជាង ៤ឆ្នាំ) គូភាគីប្រហែលជាអាចស្រុះស្រួលគ្នាដោយបង់សំណងជួសជុល នៅចំពោះមុខព្រះរាជអាជ្ញា។ ការដែលធ្វើដូចនេះ ព្រះរាជអាជ្ញាមិនចាំបាច់បញ្ជូនរឿងក្តីទៅតុលាការឡើយ ហើយជនរងគ្រោះបានទទួលប្រាក់សំណង។ ករណីនេះ អាចមានចែងជាច្បាប់ផងដែរ នូវក្រមសីលធម៌មួយចំនួនស្តីពីការធ្វើដូច្នេះដោយព្រះរាជអាជ្ញា។ សំណងជួសជុល អាចធ្វើឡើងតាមរូបភាពផ្សេងៗ ដូចជា ការសុំទោស ទំនិញ លុយកាក់ ធ្វើការងារ ឬផ្តល់ជាសេវាផ្សេងៗពីសំណាក់ជនប្រព្រឹត្តល្មើសចំពោះជនរងគ្រោះ។

សម្រួលការអនុវត្តដីការបស់តុលាការ។ ក្នុង "មុខងារសម្រុះសម្រួល" អភិបាលស្រុកមានការិយាល័យយុត្តិធម៌មួយ ទទួលបន្ទុកផ្តល់សេវាយុត្តិធម៌នៅថ្នាក់ស្រុក។ "មុខងារសម្រុះសម្រួល" ទាំងនេះមិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់រៀបចំអង្គការណាមួយទេ ប៉ុន្តែមាននៅក្នុងប្រកាសដែលបានចេញក្នុងឆ្នាំ ១៩៩៤ (ប្រកាសលេខ ០៣១ ស្តីពីតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្តនិងក្រុង)។ ក្នុងន័យនេះ អភិបាលស្រុកគឺជាមន្ត្រីខាងអំណាចប្រតិបត្តិផង ជាមន្ត្រីនគរបាលយុត្តិធម៌ផង និងជាអ្នកសម្រុះសម្រួលផង។ ទោះបីរដ្ឋធម្មនុញ្ញបានកំណត់ពីការបែងចែកអំណាចក្តី តែនៅថ្នាក់ស្រុកអាជ្ញាធរតែមួយ ដែលឋិតនៅក្រោមក្រសួងមហាផ្ទៃ បានប្រមូលផ្តុំអំណាចដែលបានរៀបរាប់ខាងលើនេះ។

អភិបាលខេត្ត:

អភិបាលខេត្តត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ តែអភិបាលខេត្តមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ក្នុងការសម្រុះសម្រួលវិវាទទេ។ អភិបាលខេត្ត ឬអភិបាលរងខេត្តគឺជាប្រធាននៃគណៈកម្មការសុរិយោដីខេត្ត។ ដូចនេះអាជ្ញាធរនេះដើរតួនាទីយ៉ាងសំខាន់ក្នុងខេត្ត នៅក្នុងវិវាទដីធ្លីដែលពាក់ព័ន្ធជាមួយភាគីច្រើន។ ក្រៅពីនេះអភិបាលខេត្តទទួលរឿងក្តីមួយចំនួនដែលបានបញ្ជូនមកពីអភិបាលស្រុក ឬបានដាក់ពាក្យប្តឹងដោយផ្ទាល់ពីប្រជាពលរដ្ឋ។ ក្នុងករណីខ្លះ ប្រជាពលរដ្ឋព្យាយាមដោះស្រាយរឿងក្តី ដោយប្រើសម្ព័ន្ធភាពខាងនយោបាយ ដោយពួកគេដាក់ពាក្យទៅអាជ្ញាធរនយោបាយ ដូចជាអភិបាលខេត្តជាដើម។

មូលដ្ឋានច្បាប់នានា:

| មុខងារ | ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣ និងវិសោធនកម្ម ឆ្នាំ ២០០១) |
|---|---|
| អ្នកណាដែលត្រូវបានចាត់ទុកថាជាមន្ត្រីនគរបាលយុត្តិធម៌ | មាត្រា ៣៦ថ្មី : ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ រួមមាន:<br>២- អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរង ស្រុក ខណ្ឌ (...) |
| | ឧបសម្ព័ន្ធប្រកាសលេខ ០៣១ ស្តីពីមុខការអភិបាល អភិបាលរងខេត្ត/ក្រុង និងអង្គភាព ក្រោមឱវាទ (១៥ កុម្ភៈ ១៩៩៤) |
| មុខងារធ្វើការសម្រុះសម្រួល | ៥. អភិបាលស្រុក : ...<br>- បញ្ជាអធិការ និងមន្ត្រីនគរបាលក្នុងឋានៈជាអាជ្ញាធរ នគរបាលយុត្តិធម៌ និងនគរបាលរដ្ឋបាល។<br>- សម្របសម្រួល និងជម្រុញអនុវត្តរាល់ដីការបស់តុលាការ។<br>- ទទួលបន្ទុកសម្រុះសម្រួល ផ្សះផ្សាបទរដ្ឋប្បវេណី និងផាកពិន័យបទលហុ។ |
| | អនុក្រឹត្យស្តីពីការរក្សាសណ្តាប់ធ្នាប់សាធារណៈនៅក្នុងរាជធានីភ្នំពេញ និងខេត្ត-ក្រុង (១៩៩៤) |
| ត្រួតពិនិត្យសណ្តាប់ធ្នាប់សាធារណៈ:<br>ផាកពិន័យបទល្មើសលហុ | មាត្រា ២ : បទល្មើសដែលធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់សង្គម របៀបរៀបរយ អនាម័យសាធារណៈ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបានចាត់ទុកជាបទល្មើសលហុ។<br>បទល្មើសលហុប្រឆាំងបទបញ្ជារបស់អាជ្ញាធរដែនដី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម:<br>- ព្រមាន<br>- ពិន័យជាប្រាក់<br>- សំណងជួសជុលការខូចខាត |

| | | |
|---|---|---|
| | មាត្រា៣ : | នីតិវិធីសម្រាប់ការព្រមាន ការផាកពិន័យពី ២.០០០ រៀល ដល់ ៥០.០០០ រៀល និងសំណងជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសលហុ ដូចមានចែងក្នុងមាត្រា ៤ ដល់ ១៦ នៃអនុក្រឹត្យនេះ នឹងត្រូវកំណត់ដោយអាជ្ញាធរខេត្ត/ក្រុង ដោយមានការឯកភាពពី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ៤០ % នៃប្រាក់ពិន័យត្រូវបញ្ជូនទៅឱ្យស្ថាប័នមានសមត្ថកិច្ចប្រមូល ដោយមានតុល្យភាពជាមួយនិងការដាក់ប្រាក់នៅរតនាគារជាតិ ។ |

អត្ថិភាពនៃអាជ្ញាធរនៅថ្នាក់ស្រុក ជាមួយនឹងសមត្ថភាពក្នុងការដោះស្រាយវិវាទ គឺស្របទៅនឹងប្រពៃណីរបស់ប្រទេសកម្ពុជា[២០០]។ នៅក្នុងសម័យអាណានិគម មានតុលាការជាន់ទាបដែលគេហៅថា "សាលាលហុ"[២០១] ទទួលបន្ទុកក្នុងការសម្រុះសម្រួលក្នុងរឿងរដ្ឋប្បវេណី និងបទល្មើសព្រហ្មទណ្ឌតូចតាច ដែលជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ ។ តុលាការមាន ៤ ថ្នាក់។ ប្រព័ន្ធនោះត្រូវបានរក្សាទុកនៅក្រោយទទួលបានឯករាជ្យ[២០២]។ នៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា មិនមានតុលាការនៅ ថ្នាក់ស្រុកទេ ដូចនេះ មុខងារយុត្តិធម៌ ត្រូវបានផ្ទេរផ្ទេរទៅឱ្យមនុស្សម្នាក់ នៅក្នុងគណៈកម្មាធិការប្រជាពលរដ្ឋបដិវត្តនៅថ្នាក់ស្រុក។ មនុស្សនោះគឺជាអ្នកទទួលបន្ទុក ខាងការសម្រុះសម្រួលរឿងក្តីរដ្ឋប្បវេណីនិងរឿងគ្រួសារ ដែលមិនអាចសម្រុះសម្រួលបាននៅថ្នាក់ឃុំ។ ប្រសិនបើការសម្រុះសម្រួលបរាជ័យនៅថ្នាក់ស្រុកទៀត រឿងនោះនឹងត្រូវបានបញ្ជូនទៅតុលាការនៅថ្នាក់ខេត្ត។

**ប្រវត្តិក្របខ័ណ្ឌច្បាប់នៃមុខងារផ្នែកតុលាការនៅថ្នាក់ស្រុក**

| **សម័យអាណានិគម** | *ការបង្កើត សាលាលហុ* |
|---|---|
| **រាជក្រឹត្យ**<br>**១១ ធ្នូ ១៩២១**<br>L'Ordonnance Royale (1921) | - សាលាលហុ (justice of the peace) មានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌតូចតាច និងសម្រុះសម្រួលរឿងរដ្ឋប្បវេណី។ សេចក្តីសម្រេចរបស់សាលាលហុ អាចប្តឹងឧទ្ធរណ៍នៅសាលាដំបូងបាន ។<br>- នៅភ្នំពេញ មានសាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យ។ |
| **ក្រោយឯករាជ្យ** | **មានអង្គភាពដោះស្រាយវិវាទរដ្ឋប្បវេណី និងព្រហ្មទណ្ឌជាអចិន្ត្រៃយ៍** |
| **ច្បាប់ស្តីពីសោធនកម្មច្បាប់ស្តីពីរចនាសម្ព័ន្ធតុលាការ ឆ្នាំ ១៩៥៩** | មាត្រា ៧ : ការរៀបចំសាលាលហុ ត្រូវរក្សាឱ្យនៅដដែលសម្រាប់ទាំងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។<br><br>មាត្រា ៨ : បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើបទលហុ មិនត្រូវបានអនុញ្ញាតឡើយបើសិនជាការសម្រេចនោះ មិនដល់ជាប់ពន្ធនាគារ។ តែបើសិនជាសម្រេចដល់ជាប់ពន្ធនាគារ នោះរាល់បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងនៅសាលាដំបូង (ខេត្ត-ក្រុង)។<br><br>មាត្រា ៩ : ដែនសមត្ថកិច្ចរបស់សាលាលហុ ត្រូវបានកែប្រែដូចតទៅ :<br>- សម្រេច មិនអាចឧទ្ធរណ៍បានសម្រាប់ករណីទាក់ទងនឹងចលនវត្ថុ និងរាល់ការសម្រេចលើបុគ្គល តែមិនមានតម្លៃលើសពី ២.០០០ រៀល។<br>- សម្រេច អាចប្តឹងឧទ្ធរណ៍បានសម្រាប់ករណីអចលនវត្ថុ និងរាល់ការសម្រេចលើបុគ្គល តែមិនមានតម្លៃ ចាប់ពី ២.០០១ ដល់ ៥.០០០ រៀល ។ |

[២០០] សូមមើល : Luco (2001) and Hughes (2000).
[២០១] សាលាលហុ
[២០២] សូមមើល : ឧបសម្ព័ន្ធ ១ ស្តីពីមូលដ្ឋានច្បាប់

| | |
|---|---|
| **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៦០** | មាត្រា ២៣ : បុគ្គលទាំងឡាយដែលប្រព្រឹត្តបទលហុត្រូវ :<br>- ជាប់ពន្ធនាគារចាប់ពី ១ ថ្ងៃ ដល់ ៧ ថ្ងៃ និង/ឬ<br>- ពិន័យជាប្រាក់ចាប់ពី ១៥ ដល់ ១៥០ រៀល ។ |
| **រាជក្រឹត្យ ឆ្នាំ ១៩៦២** | មាត្រា ២ : នៅពេលទទួលបានកំណត់ហេតុ ឬបទលហុ ចៅក្រមសាលាលហុ ត្រូវផ្តល់ដំណឹងដល់ជនល្មើស ឱ្យបង់ប្រាក់ពិន័យដូចដែលបានកំណត់ដោយចៅក្រម ស្របតាមមាត្រា ៤៤ នៃក្រមព្រហ្មទណ្ឌ។<br>មាត្រា ៧ : រាល់បទលហុទាំងអស់ អ្នកប្រព្រឹត្តត្រូវបង់ប្រាក់ពិន័យភ្លាម១ជូនដល់មន្ត្រី ដែលទទួលបន្ទុកសរសេរកំណត់ហេតុ។<br>មាត្រា ១១ : រាល់ច្បាប់ជាធរមានស្តីពីការផ្ទេរអំណាចជូនមន្ត្រីរដ្ឋបាល នូវតួនាទីសម្រុះសម្រួលជាសាធារណៈ ត្រូវរក្សានៅមានសុពលភាពដដែល។ |
| **ក្រមរដ្ឋប្បវេណី ឆ្នាំ ១៩៦៣** | មាត្រា ៣៨ : អង្គការតុលាការមាន ៤ថ្នាក់គឺ :<br>១-សាលាលហុ (tribunal d'instance)<br>២-សាលាដំបូង (Tribunal de grande instance)<br>៣-សាលាឧទ្ធរណ៍ (cour d'appel)<br>៤-សាលាវិនិច្ឆ័យ (cour de cassation)<br>មាត្រា ៣៨ : សាលាលហុ និងសាលាដំបូង ជាតុលាការជាន់ទាប។ សាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យជាតុលាការជាន់ខ្ពស់។ |
| **សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា** | **តួនាទីសម្រុះសម្រួលវិវាទនៅថ្នាក់ស្រុក** |
| **សារាចរណ៍ណែនាំស្តីពីការងារយុត្តិធម៌ ស្រុក ឃុំ និងថ្នាក់ប្រហាក់ប្រហែល ២៤ កញ្ញា ១៩៨៣** | ក្នុងពេលដែលប្រទេសយើងពុំទាន់មានតុលាការប្រជាពលរដ្ឋ នៅថ្នាក់ស្រុកការងារយុត្តិធម៌ ត្រូវបានប្រគល់ឱ្យសមាជិកម្នាក់នៃគណៈកម្មាធិការប្រជាពលរដ្ឋបដិវត្តស្រុក ជាអ្នកមានសិទ្ធិ និងភារកិច្ចដូចតទៅ:<br>១. ផ្សះផ្សារឿងវិវាទរដ្ឋប្បវេណី និងរឿងគ្រួសារដែលគណៈកម្មាធិការប្រជាពលជនបដិវត្តឃុំបញ្ជូនមក។ ការផ្សះផ្សានេះត្រូវធ្វើឱ្យអស់លទ្ធភាព ហើយបើនៅតែមិនបានសម្រេច គប្បីបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនខេត្ត ដោយមានធ្វើរបាយការណ៍មានតម្លៃជូនជាប់ជាមួយផង ចៀសវាងគ្រាន់តែសម្រុះសម្រួលតែបន្តិចបន្តួច ឬគ្រាន់តែពិនិត្យលើរបាយការណ៍របស់ថ្នាក់ឃុំ រួចបញ្ជូនទៅតុលាការហាក់បីដូចជាថ្នាក់ស្រុកគ្រាន់ជាស្ពានសម្រាប់ចំលងតែប៉ុណ្ណោះ។ |

ក្របខ័ណ្ឌស្ថាប័នៈ

មានអភិបាលស្រុកនៅគ្រប់ស្រុក-ខណ្ឌទាំង ១៨៥ នៅទូទាំងប្រទេស ដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ ប្រាក់បៀវត្សរ៍របស់អភិបាលស្រុករួមទាំងប្រាក់ឧបត្ថម្ភទៀតមានប្រហែលជា ១៩៥ដុល្លារអាមេរិកក្នុងមួយខែ។

និងមានអភិបាលខេត្តនៅក្នុងខេត្ត-ក្រុងទាំង ២៤ នៅក្នុងប្រទេស។ ប្រាក់បៀវត្សរ៍របស់ពួកគេ រួមទាំងប្រាក់ឧបត្ថម្ភទៀតមានប្រហែលជា ២១៧ដុល្លារអាមេរិកក្នុងមួយខែ។

តារាង ៖ ប្រាក់បៀវត្សរ៍របស់អភិបាលស្រុក និងអភិបាលខេត្ត[២០៣]

| ល.រ | តួនាទី | ប្រាក់ខែសុទ្ធ | ប្រាក់ឧបត្ថម្ភ | សរុប | ជាលុយដុល្លារ |
|---|---|---|---|---|---|
| ១ | អភិបាលខេត្ត | ១២០.០០០ -១៣០.០០០ | ៧៤០.០០០ * | ៨៧០ | ២១៧ |
| ២ | អភិបាលរងខេត្ត | ១២០.០០០ -១៣០.០០០ | ៦១៥.០០០ * | ៧៤៥ | ១៨៦.២៥ |
| ៣ | អភិបាលស្រុក | ១១០.០០០ - ១២០.០០០ | ៥០០.០០០ * | ៦២០ | ១៥៥ |
| ៤ | អភិបាលរងស្រុក | ១០០.០០០-១១០.០០០ | ៤០.០០០-៥០.០០០ * | ១៦០ | ៤០ |

## ២.៥.២. តម្រូវការយុត្តិធម៌ពីអភិបាលស្រុក និងខេត្ត

អភិបាលស្រុក និងអភិបាលខេត្ត ដើរតួយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ។ ភាគច្រើននៃវិវាទត្រូវបានទទួលដោយគណៈកម្មការសុរិយោដី ឬទទួលមកពីក្រុមប្រឹក្សាឃុំដោយផ្ទាល់នូវរាល់ករណី ដែលក្រុមប្រឹក្សាឃុំមិនអាចសម្រុះសម្រួលបាន។ អាជ្ញាធរនេះ ក៏ដើរតួខាងនយោបាយផងដែរ ក្នុងការដោះស្រាយវិវាទមួយចំនួនដូចជាករណីវិវាទដីធ្លី និងករណីផ្សេងៗទៀត។

តួនាទីក្នុងការដោះស្រាយវិវាទ និងនីតិវិធី:

- នៅពេលក្រុមប្រឹក្សាឃុំមិនអាចដោះស្រាយវិវាទបាន ភាគីខ្លះបានប្តឹងរឿងនេះមកកាន់អភិបាលស្រុក។
- អភិបាលស្រុកទទួលបានរឿងក្តីប្រភេទផ្សេងៗគ្នា ដូចជាវិវាទនៅតាមមូលដ្ឋាន វិវាទដីធ្លី អំពើហិង្សាក្នុងគ្រួសារ ការទាមទារលែងលះ ។ល។ និង ។ល។
- ករណីខ្លះអភិបាលស្រុកអន្តរាគមន៍ដោយផ្ទាល់ ហើយមិនមានការកត់ត្រាជាឯកសារណាមួយទេ។ ក្នុងករណីខ្លះទៀត អភិបាលស្រុកដោះស្រាយរឿងក្តី ដោយមានជំនួយពីមន្ត្រីយុត្តិធម៌ស្រុក។ មន្ត្រីនេះអាចកសាងឯកសារនានាពេលដំណើរការក្តី។
- ចាប់តាំងពីក្រុមប្រឹក្សាឃុំត្រូវបានបោះឆ្នោតជ្រើសតាំងមក មានរឿងក្តីតិចជាងមុនដែលត្រូវបានបញ្ជូនមកអភិបាលស្រុក។ ក្រុមប្រឹក្សាឃុំដោះស្រាយរឿងក្តីច្រើនជាងមុន ឬប្រសិនបើចាំបាច់សមាជិកក្រុមប្រឹក្សាឃុំ សុំឱ្យគូភាគីទៅរកគណៈកម្មការសុរិយោដី តុលាការ ឬនគរបាល។
- តាំងពីគណៈកម្មការសុរិយោដី ត្រូវបានបង្កើតឡើងនៅថ្នាក់ស្រុកមក អភិបាលស្រុកក៏បានបញ្ជូនរឿងក្តីពាក់ព័ន្ធនឹងដីមិនបានចុះបញ្ជីទៅគណៈកម្មការនេះដែរ។
- ប្រសិនបើរឿងក្តីត្រូវបានប្តឹងមកអភិបាលស្រុកដោយផ្ទាល់តែម្តង នោះអភិបាលស្រុក ឬមន្ត្រីយុត្តិធម៌ស្រុក អាចបញ្ជូនរឿងក្តីមកក្រុមប្រឹក្សាឃុំ ឱ្យសាកសួរគូភាគីនៃរឿងក្តីជាដើម។
- អភិបាលស្រុកអាចប្រើឋានានុក្រមនយោបាយក្នុងរឿងក្តីស្មុគ្រស្មាញមួយចំនួន។
- ទាក់ទងនឹងរឿងដីធ្លីធំៗ បញ្ហាបរិស្ថាន វិវាទរវាងអ្នកភូមិនិងក្រុមហ៊ុនយោធា ឬអ្នកមានអំណាចអភិបាលស្រុកអាចបញ្ជូនរឿងក្តីទៅអភិបាលខេត្តផ្ទាល់។

[២០៣] ព័ត៌មាននេះទទួលបានពីលោក ហ៊ាង ម៉េង នាយរងខុទ្ទកាល័យខេត្តឧត្តរមានជ័យ។

- មិនមានក្របខ័ណ្ឌពេលវេលា នីតិវិធីច្បាស់លាស់ ហើយក៏គ្មានយន្តការត្រួតពិនិត្យដើម្បីគ្រប់គ្រងលើការងារ របស់អភិបាលស្រុកក្នុងមុខងារធ្វើការសម្រុះសម្រួលនេះដែរ។ ដូចនេះ អ្នកចូលរួមក្នុងសិក្ខាសាលាមួយចំនួនបាននិយាយថា ពួកគេត្រូវត្រលប់ទៅមក១ជាច្រើនលើកច្រើនសារ ហើយពេលខ្លះពួកគេមិនបានទទួលការឆ្លើយតបសមស្របទេ។
- អភិបាលខេត្ត ទទួលរឿងក្តីដោយផ្ទាល់ពីប្រជាពលរដ្ឋ ឬបញ្ជូនមកពីអភិបាលស្រុក។ ពេលខ្លះគូភាគីព្យាយាមប្រើប្រាស់ឥទ្ធិពលខាងនយោបាយរបស់ពួកគេ ដូចនេះពួកគេប្តឹងដោយផ្ទាល់ទៅអាជ្ញាធរ ឬ អភិបាលខេត្ត។

រឿងក្តីដែលត្រូវបានដោះស្រាយដោយមន្ត្រីយុត្តិធម៌ស្រុករបស់អភិបាលស្រុក

**ករណី ១ : ការដោះស្រាយវិវាទដោយមន្ត្រីយុត្តិធម៌ស្រុក របស់មន្ត្រីយុត្តិធម៌ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង**[២០៤]

- *ថ្ងៃធ្វើកិច្ចព្រមព្រៀងគ្នា : ៥ មិថុនា ២០០៤។*
- *រឿងហេតុ : វិវាទលើទ្រព្យសម្បត្តិ។*
- *លទ្ធផល : ត្រូវបានដោះស្រាយរួច*
- *ដើមបណ្តឹង លោកស្រី YM បានទាមទារឱ្យប្រគល់ក្របីរបស់គាត់មកវិញ ព្រោះឪពុកក្មេក បានយកពីគាត់។ គាត់បានប្រាប់ថា: ៉ទៅពេលខ្ញុំបានរៀបការនឹងកូនប្រុសគាត់ ឪពុកក្មេកខ្ញុំបានប្រគល់ក្របីឈ្មោលមួយក្បាលដល់យើងទាំងពីរ។ បន្ទាប់មកយើងបានដោះដូរក្របីនោះជាមួយក្របីញីមួយ។ ក្របីញីក្រោយមកមានកូន ២ ក្បាល។ បន្ទាប់មក ខ្ញុំក៏បានលក់ក្របីមួយហើយទិញរទេះមួយ។ ខ្ញុំបានយកក្របីខ្ញុំទៅទឹមជាមួយក្របី ដែលឪពុកក្មេកខ្ញុំឱ្យ។ ច្រើនខែក្រោយមក ម្តាយក្មេកខ្ញុំបានចោទប្រកាន់ប្តីខ្ញុំថា បានលួចដួងគាត់។ ខ្ញុំបានខឹងយ៉ាងខ្លាំង និងបានជេរគាត់។ ភ្លាមនោះ គាត់ក៏បានទាមទារយកក្របីរបស់ខ្ញុំទាំងអស់។ ខ្ញុំបានឱ្យប្តីខ្ញុំទៅសុំឱ្យគាត់ប្រគល់ក្របីមកវិញដើម្បីធ្វើស្រែ ប៉ុន្តែឪពុកក្មេកខ្ញុំមិនព្រម។ ហេតុនេះហើយ ខ្ញុំសូមឱ្យប្រគល់ក្របី និងរទេះរបស់ខ្ញុំមកវិញទុកធ្វើស្រែ។ ចុងចម្លើយ លោក CN ជាឪពុកក្មេករបស់ដើមបណ្តឹង បាននិយាយថា: ៉ប្រសិនបើច្បាប់ចែងថា ខ្ញុំត្រូវប្រគល់ក្របីទៅឱ្យកូនខ្ញុំវិញ ខ្ញុំនឹងធ្វើតាម៉។ ដើមបណ្តឹងមានលោកស្រី YM និងលោក CB បានសន្យាថា ពួកគេឈប់ជេរប្រមាថឪពុកម្តាយរបស់ខ្លួនទៀតហើយ។ ប្រសិនបើពួកគេធ្វើខុសការសន្យា ពួកគេនឹងត្រូវទទួលទោសចំពោះមុខច្បាប់។ ចុងចម្លើយ លោក CN បានសន្យាថា គាត់នឹងប្រគល់ក្របីទាំងអស់ និងគោទៅឱ្យកូនប្រុសគាត់វិញ ប៉ុន្តែគាត់បានស្នើសុំឱ្យកូនប្រុសគាត់ ឈប់មើលងាយគាត់តទៅទៀត។*

*ចុងក្រោយគូភាគីបានព្រមព្រៀងគ្នាបញ្ចប់រឿងក្តី ដោយបានផ្តិតមេដៃរបស់គេទៅលើកិច្ចសន្យា នៅចំពោះមុខមន្ត្រីយុត្តិធម៌ស្រុក។*

**ករណី ២ : វិវាទដីធ្លី - ករណីដីសម្បទាន**[២០៥]

*នៅខែ កញ្ញា ឆ្នាំ ២០០៤ បណ្តឹងដែលបានផ្តិតមេដៃ ធ្វើឡើងដោយក្រុមជនជាតិភាគតិច ៧៥ នាក់ រស់នៅក្នុង ឃុំសែនមនោរម្យ ស្រុកអូរាំង ខេត្តមណ្ឌលគីរី ប្តឹងក្រុមហ៊ុនចិនមួយ ដែលបានដាំ ដើមស្រល់នៅលើភ្នំ ដែលប្រជាពលរដ្ឋធ្លាប់តែចិញ្ចឹមសត្វ រាប់សតវត្សរ៍មកហើយនោះ។ បណ្តឹងនេះគឺប្រជាពលរដ្ឋទាមទារឱ្យប្រគល់ដី ព្រោះជាដីដែលប្រជាពលរដ្ឋបានប្រើប្រាស់រាប់សតវត្សរ៍មកហើយ។ ពួកគេបានប្តឹងទៅមេឃុំ បន្ទាប់មកអភិបាលស្រុក រួចឡើងទៅអភិបាលខេត្ត។*

---

២០៤ សូមមើលរឿងក្តីលេខ H1 ក្នុងឧបសម្ព័ន្ធទី ២

២០៥ សូមមើលរឿងក្តីលេខ G2 ក្នុងឧបសម្ព័ន្ធទី ២

**ករណី ៣ : វិវាទ " លែងលះ "** [២០៦]

ប្រពន្ធបានដាក់ពាក្យសុំលែងលះនៅមុខមន្ត្រីយុត្តិធម៌ស្រុក។ រឿងហេតុគឺ ប្ដីបានប្រព្រឹត្តអំពើហិង្សាជាញឹកញយ។ គាត់បានចេញពីផ្ទះ ប៉ុន្តែនៅពេលគាត់ត្រលប់មកវិញ គាត់បំផ្លាញទ្រព្យសម្បត្តិ រួមទាំងទ្រព្យសម្បត្តិរបស់បងស្រីប្រពន្ធថែមទៀត។ ប្រពន្ធក៏បានសំណូមពរឱ្យប្ដីនាងសងសំណងទៅបងស្រីនាងផងដែរ។ នៅពេលសម្រុះសម្រួល គូភាគីទាំងពីរព្រមព្រៀងលែងលះ។ ប្រពន្ធចង់បានទ្រព្យសម្បត្តិពាក់កណ្ដាល។ ប្ដីយល់ព្រមឱ្យតូបក្នុងផ្សារ និងទ្រព្យដែលនៅសេសសល់។

- ករណីនេះកើតនៅខេត្តកំពង់ឆ្នាំង នៅឆ្នាំ ១៩៩៤

**ករណី ៤ : វិវាទរឿងប្រាក់បំណុល និងឈានដល់ហិង្សា** [២០៧]

អ្នកប្ដឹងគឺ លោកស្រី យយ បានខ្ចីលុយពីចុងចម្លើយ លោក គគ ដើម្បីទិញម៉ាស៊ីនកិនស្រូវ ចំនួន ១២០ដុល្លារ និង ៧០.០០០ ៛ (១៨ដុល្លារ) ព្រមទាំងមាស ០.៥ ជី (១២ដុល្លារ)។ ដើមបណ្ដឹងជួបការលំបាក ហើយនាងគ្មានលុយសងវិញ។ ចុងចម្លើយបានឱ្យនាងសងលុយម្ដងជាពីរដង ប៉ុន្តែនាងនិយាយថា នាងត្រូវចាំរហូតដល់នាងជួសជុលម៉ាស៊ីនកិនស្រូវរួចសិន។ អ្នកប្ដឹងបាននិយាយថា ចុងចម្លើយក៏បានដាក់អាស៊ីតក្នុងទឹកកករបស់នាង និងបាញ់នាង។ នៅពេលសម្រុះសម្រួល ចុងចម្លើយយល់ព្រមមិនបង្ករឿង ឬការខូចខាតដល់ដើមបណ្ដឹង ឬក្រុមគ្រួសារនាងទៀតទេ។

- កំណត់ហេតុសម្រុះសម្រួល និងការស្រុះស្រួលគ្នានៅ ថ្ងៃទី ១៨ ខែ ឧសភា ១៩៩៤

**ករណី ៥ : វិវាទដីធ្លី** [២០៨]

លោកស្រី សក ដើមបណ្ដឹងបានដាក់ពាក្យទៅការិយាល័យយុត្តិធម៌ស្រុក ដើម្បីដោះស្រាយវិវាទដីធ្លីប្រឆាំងនឹងលោក សម។ ចុងចម្លើយបានដាំដុះ លើដីស្រែពីរតាំងពីឆ្នាំ១៩៨៥ តែដីស្រែនោះត្រូវបានដើមបណ្ដឹងបានបញ្ជាក់ថាជាដីរបស់គាត់ ហើយខ្លួនចង់បានដីទាំងនោះត្រលប់មកវិញ។ នៅពេលសម្រុះសម្រួល ចុងចម្លើយសារភាពថាគាត់បានដាំដុះលើដីនោះ និងថាដីនោះជាដីរបស់ដើមបណ្ដឹងមែន។ គាត់ព្រមប្រគល់ដី និងមិនរំលោភលើដីនោះទៀតទេ។

- កំណត់ហេតុសម្រុះសម្រួល : ថ្ងៃទី ២១ ឧសភា ១៩៩៧។

**ករណី ៦ : វិវាទដីធ្លី** [២០៩]

ដើមបណ្ដឹងបានដាក់ពាក្យបណ្ដឹងដើម្បីទាមទារ និងសុំឱ្យមន្ត្រីយុត្តិធម៌ស្រុកជួយដោះស្រាយ និងប្រគល់ដីរបស់គាត់វិញ។ នៅពេលសម្រុះសម្រួល ចុងចម្លើយបានយល់ព្រមប្រគល់ដីឱ្យដើមបណ្ដឹង។

- សម្រុះសម្រួល : ថ្ងៃទី ១៥ ខែ សីហា ១៩៩៥។

---

[២០៦] សូមមើលរឿងក្ដីលេខ H2ក្នុងឧបសម្ព័ន្ធទី ២

[២០៧] សូមមើលរឿងក្ដីលេខ H3ក្នុងឧបសម្ព័ន្ធទី ២

[២០៨] សូមមើលរឿងក្ដីលេខ H4ក្នុងឧបសម្ព័ន្ធទី ២

[២០៩] សូមមើលរឿងក្ដីលេខ H5ក្នុងឧបសម្ព័ន្ធទី ២

## ២.៦. គណៈកម្មការសុរិយោដី

### ២.៦.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

ក្របខ័ណ្ឌច្បាប់:

ច្បាប់ភូមិបាលឆ្នាំ ២០០១ បានបង្កើតគណៈកម្មការសុរិយោដី ដើម្បីដោះស្រាយវិវាទដីធ្លី ដែលមិនទាន់បានចុះបញ្ជីនៅឡើយ ដោយលើកទឹកចិត្តឱ្យមានការសម្រុះសម្រួលនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត ហើយអាចកាត់សេចក្តីបាននៅថ្នាក់ជាតិ។ នៅថ្នាក់ស្រុក ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក គឺប្រធានការិយាល័យសុរិយោដីថ្នាក់ស្រុក ដែលជាខ្សែបណ្តោយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅថ្នាក់ខេត្ត អភិបាលខេត្តជាប្រធានគណៈកម្មការសុរិយោដី ហើយនៅថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាប្រធាន។ យោងតាមច្បាប់ ការដោះស្រាយវិវាទនៅគណៈកម្មការសុរិយោដីគឺឥតបង់ថ្លៃអ្វីទាំងអស់។ បន្ទាប់ពីទទួលរឿងក្តីហើយ គណៈកម្មការសុរិយោដីត្រូវចុះធ្វើការស៊ើបអង្កេត និងលើកស្ទួយឱ្យមានការសម្រុះសម្រួលរវាងគូភាគី ដោយអញ្ជើញអាជ្ញាធរមូលដ្ឋាន ឱ្យធ្វើជាសមាជិកអាដហុករបស់គណៈកម្មការសុរិយោដី។ គណៈកម្មការនេះ អាចបដិសេធរឿងក្តីបាន ដោយផ្អែកលើគោលការណ៍ច្បាប់ និងមិនត្រូវបដិសេធដោយអយុត្តិធម៌សម្រាប់ភាគីទេ។ មិនមានខចែងច្បាស់លាស់ អំពីអំណាចរបស់តុលាការក្នុងការពិនិត្យ ឬសម្រេចលើរឿងក្តីទាំងឡាយណា ដែលត្រូវបានបដិសេធដោយគណៈកម្មការសុរិយោដីនៅថ្នាក់ជាតិឡើយ។ បន្ទាប់ពីការសម្រុះសម្រួលនៅថ្នាក់ស្រុកនិងថ្នាក់ខេត្ត បរាជ័យនោះ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែកាត់សេចក្តីលើករណីវិវាទ។ បន្ទាប់ពីមានការសម្រេចសេចក្តី ដោយគណៈកម្មការថ្នាក់ជាតិនេះហើយ តុលាការមានសិទ្ធិពិនិត្យមើលការសម្រេចនេះឡើងវិញ បើសិនជាមានភាគីប្តឹង។ គណៈកម្មការនេះ ពុំមានការកំណត់ពេលវេលាច្បាស់លាស់ សម្រាប់ដោះស្រាយវិវាទដែលបានទទួលឡើយ ជាហេតុនាំឱ្យគូភាគីត្រូវតែរង់ចាំដោយគ្មានពេលកំណត់ជាក់លាក់ សម្រាប់ការដោះស្រាយដោយគណៈកម្មការនេះ។ លើសពីនេះទៅទៀត ក្នុងពេលរង់ចាំនេះភាគីមិនអាចប្តឹងទៅតុលាការបានទេ ព្រោះពុំទាន់មានសេចក្តីសម្រេចរបស់គណៈកម្មការ ដើម្បីធ្វើជាមូលដ្ឋានក្នុងការប្តឹង។ កត្តានេះអាចជាសក្តានុពល ដល់ការរំលោភនូវសិទ្ធិរបស់ភាគីវិវាទ។ បញ្ហាដែលមិនទាន់មានដំណោះស្រាយមួយទៀត គឺទាក់ទងនឹងការពិនិត្យឡើងវិញ របស់តុលាការលើសុពលភាពរបស់សេចក្តីសម្រេចរបស់គណៈកម្មកានេះ។ ដោយហេតុថា នៅពេលនេះពុំទាន់មានច្បាប់រៀបចំអង្គការ ស្តីពីយន្តការដោះស្រាយវិវាទក្រៅតុលាការនៅឡើយនោះ សព្វថ្ងៃមានការយល់និងបកស្រាយខុសៗគ្នាជាច្រើន ស្តីពីលទ្ធផលដែលបានដោះស្រាយដោយ យន្តការដោះស្រាយវិវាទក្រៅតុលាការនេះ ដូចជាសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដី។

គណៈកម្មការសុរិយោដីគឺជាប្រភេទមួយ នៃយន្តការដោះស្រាយវិវាទក្រៅតុលាការ ដែលមានអាណត្តិស្របច្បាប់ដោះស្រាយវិវាទដីធ្លីមិនទាន់ចុះបញ្ជី មុនពេលរឿងក្តីនេះអាចប្តឹងទៅតុលាការ ( *mandatory pre-judicial ADR* ) ដោយសារ :

- ក- គណៈកម្មការសុរិយោដី ត្រូវបានគេចាត់ទុកថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ពីព្រោះគឺជាការដោះស្រាយមួយនៅក្រៅតុលាការសម្រាប់រឿងវិវាទលើដីធ្លីមិនបានចុះបញ្ជី។
- ខ- គណៈកម្មការសុរិយោដីមិនមែនជាតុលាការទេ។ គណៈកម្មការនេះ ឋិតនៅក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះក៏មិនមែនមានអំណាចឯករាជ្យពីអំណាចនីតិប្រតិបត្តិទេ។
- គ- ក្រោយពីបានធ្វើការសម្រុះសម្រួលហើយ គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចសម្រេចសេចក្តីលើរឿងវិវាទ ប៉ុន្តែសេចក្តីសម្រេចនេះគឺស្ថិតនៅក្រោមច្បាប់។ អាស្រ័យហេតុនេះ ក្នុងករណីដែលមិនមានការពេញចិត្តជាមួយនឹងលទ្ធផលនោះទេ គូវិវាទអាចប្តឹងទៅតុលាការបាន ( ច្បាប់ភូមិបាល មាត្រា ៤៧ ) ។
- ឃ- សម្រាប់វិវាទទាក់ទងនឹងដីធ្លីមិនបានចុះបញ្ជី គូភាគីមានកាតព្វកិច្ចប្តឹងទៅគណៈកម្មការសុរិយោដី មុនពេលប្តឹងទៅតុលាការ។

ង- គណៈកម្មការសុរិយោដីមិនមែនជាប្រព័ន្ធយុត្តិធម៌ក្រៅផ្លូវការនោះទេ។ វាត្រូវបានបង្កើតឡើង និងចែងនៅក្នុងច្បាប់ តែគ្រប់គ្រងចាត់ចែងដោយមន្ត្រីរាជការនៅក្រោមអំណាចនីតិប្រតិបត្តិ។

តារាងក្របខ័ណ្ឌច្បាប់

| មូលដ្ឋានច្បាប់ | ខ្លឹមសារ |
|---|---|
| ច្បាប់ភូមិបាល ឆ្នាំ២០០១ | មាត្រា ៤៧ : វិវាទរវាងភោគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធីដែលបានកំណត់។ លទ្ធផលនៃការស៊ើបអង្កេត ត្រូវដាក់ជូនគណៈកម្មការសុរិយោដីដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្តគូវិវាទ អាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។ |

រចនាសម្ព័ន្ធ និងការរៀបចំ

អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មការសុរិយោដី បានបង្កើតឱ្យមានគណៈកម្មការសុរិយោដី ៣ ថ្នាក់: ថ្នាក់ស្រុក-ខណ្ឌ ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ជាតិ :

១- គណៈកម្មការថ្នាក់ស្រុក-ខណ្ឌ ត្រូវបានដឹកនាំដោយប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្រុក-ខណ្ឌ និងមន្ត្រីរបស់ការិយាល័យនេះជាសមាជិកនៃគណៈកម្មការ ហើយគណៈកម្មការត្រូវអញ្ជើញតំណាងដែលពាក់ព័ន្ធនៅស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងអាជ្ញាធរភូមិ និង/ឬចាស់ទុំនៅមូលដ្ឋានឱ្យចូលរួមជាសមាជិក អាដហុក ( មាត្រា ៥)។ គណៈកម្មការធ្វើការសម្រុះសម្រួលវិវាទដោយប្រើវិធានទំនៀមទម្លាប់ និងបច្ចេកទេស សុរិយោដី ( មាត្រា ៦)។

២- គណៈកម្មការថ្នាក់ខេត្ត-ក្រុង ត្រូវបានដឹកនាំដោយអភិបាលខេត្ត-ក្រុង ហើយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងជាសមាជិក។ គណៈកម្មការអាចអញ្ជើញតំណាងរបស់ឃុំ-សង្កាត់ ស្រុក-ខណ្ឌ និង/ឬមន្ទីរនៅខេត្ត-ក្រុងដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិក*អាដហុក* ( មាត្រា ១២)។

៣- គណៈកម្មការថ្នាក់ជាតិត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋលេខាធិការមកពីក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រីគឺជាសមាជិក។ គណៈកម្មការអាចអញ្ជើញក្រសួង និងស្ថាប័នពាក់ព័ន្ធឱ្យមកចូលរួមក្នុងនាមជាសមាជិកអាដហុក។

មុខងារ:

គណៈកម្មការថ្នាក់ ស្រុក-ខណ្ឌ និងខេត្ត-ក្រុងមានសិទ្ធិត្រឹមធ្វើការសម្រុះសម្រួលរឿងក្តីប៉ុណ្ណោះ ហើយមិនមានអំណាចចេញសេចក្តីសម្រេចបានទេ ( មាត្រា ៩ និង ១៥)។ ចំពោះគណៈកម្មការថ្នាក់ជាតិវិញ មានអំណាចចេញសេចក្តីសម្រេចលើរឿងក្តី ( មាត្រា ២០) ប៉ុន្តែសេចក្តីសម្រេចនេះ ភាគីអាចប្តឹងទៅតុលាការឱ្យពិនិត្យមើលឡើងវិញដោយភាគីណាមួយ ( មាត្រា ២៣)។ តែបើសិនជាមានការព្រមព្រៀងគ្នា ឬពុំមានការប្តឹងទៅតុលាការប្រឆាំងនឹង សេចក្តីសម្រេចរបស់គណៈកម្មការទេ ភាគីអាចចុះបញ្ជីដីធ្លីដែលបានដោះស្រាយហើយបាន។

តារាង រចនាសម្ព័ន្ធគណៈកម្មការសុរិយោដី

| ថ្នាក់ | ស្រុក-ខណ្ឌ | ខេត្ត-ក្រុង | ថ្នាក់ជាតិ |
|---|---|---|---|
| **ដឹកនាំដោយ** | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្រុក-ខណ្ឌ | អភិបាលខេត្ត-ក្រុង/ អភិបាលរង | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **សមាជិក** | មន្ត្រីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធានមន្ទីររៀបចំដែនដី នគរូប-នីយកម្ម និងសំណង់ ខេត្ត-ក្រុង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី |
| **គណៈកម្មការអាដហុក** | តំណាងពាក់ព័ន្ធនៅស្រុក-ខណ្ឌ អាជ្ញាធរឃុំ-សង្កាត់ និងអាជ្ញាធរភូមិ និង/ឬ ចាស់ទុំនៅក្នុងមូលដ្ឋាន ដែលគេទុកចិត្តឱ្យចូលរួមជាសមាជិកអាដហុក ( មាត្រា ៥) ។ | តំណាងឃុំ-សង្កាត់ ស្រុក-ខណ្ឌ និង/ឬមន្ទីរនៅខេត្ត-ក្រុង ដែលពាក់ព័ន្ធ ចូលរួមជាសមាជិកអាដហុក ( មាត្រា ១២) ។ | ក្រសួង និងស្ថាប័នពាក់ព័ន្ធ |
| **មុខងារ** | សម្រុះសម្រួលវិវាទ ដោយប្រើវិធានទំនៀមទម្លាប់ និងបច្ចេកទេសសុរិយោដី ( មាត្រា ៦) ។ | អាចត្រឹមធ្វើការសម្រុះសម្រួល វិវាទ ហើយមិនមានអំណាច ចេញសេចក្ដីសម្រេចទេ ( មាត្រា ៩ និង ១៥) ។ | អំណាចចេញសេចក្ដីសម្រេច នៅលើរឿងក្ដី ( មាត្រា ២០) ប៉ុន្តែសេចក្ដីសម្រេចនេះ គូភាគីណាមួយមានសិទ្ធិប្ដឹងទៅតុលាការបើខ្លួនមិនពេញចិត្ត ( មាត្រា ២៣) |

ក្របខ័ណ្ឌស្ថាប័ន:

គណៈកម្មការសុរិយោដីមាននៅថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។

**ការិយាល័យ:** ប្រកាសក្រសួង ស្ដីពីការបង្កើតការិយាល័យនៅថ្នាក់ខេត្តបានចេញនៅក្នុងឆ្នាំ ២០០២ ឯការអនុវត្តគណៈកម្មការសុរិយោដីបានចាប់ផ្ដើមក្នុងឆ្នាំ ២០០៣ ហើយវាឋិតនៅក្នុងដំណើរការកសាងស្ថាប័ននៅឡើយ ។ ក្រសួងរៀបចំដែនដីបានតែងតាំងមន្ត្រីទទួលបន្ទុកគណៈកម្មការសុរិយោដីនៅគ្រប់ខេត្ត-ក្រុង ទូទាំងប្រទេសរួចរាល់ហើយ ប៉ុន្តែមិនទាន់បានតែងតាំងនៅគ្រប់ស្រុកនៅឡើយទេ ។ ដោយមានស្រុកចំនួន ១៨៥ នៅក្នុងប្រទេស វាតម្រូវឱ្យមានធនធានមនុស្ស សម្ភារៈ និងហិរញ្ញវត្ថុច្រើន ។ មកដល់ចុងឆ្នាំ ២០០៤ គណៈកម្មការសុរិយោដីបាន បង្កើតឱ្យមានការិយាល័យក្នុងស្រុកបាន ១៦៥ ហើយដែលនៅសល់ ១៩ស្រុកទៀតឋិតក្នុងខេត្តចំនួន ៨ ។ នៅក្នុងខេត្ត ចំនួន ៦ ដែលមិនទាន់បង្កើតគ្រប់ស្រុកនោះ គឺនៅសល់ប្រហែលពី ១ ទៅ ២ ការិយាល័យស្រុកប៉ុណ្ណោះ ។ ហើយនៅក្នុងខេត្ត ២ ទៀត គឺខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី នៅមិនទាន់មានការបង្កើតការិយាល័យស្រុករហូតដល់ទៅ ៤ ដែលមិនទាន់បានបង្កើតនៅឡើយ[២១០] ។ ខេត្តមណ្ឌលគិរី គឺជាខេត្តតែមួយគត់នៅក្នុងប្រទេសដែលមានការិយាល័យថ្នាក់ស្រុកតែមួយ គ្របដណ្ដប់ត្រឹម២០%នៃស្រុកទាំងអស់ (១/៥) ។ ជនជាតិដើមភាគតិចរស់នៅក្នុងខេត្តទាំងពីរនេះ ហើយការទន្ទ្រានយកដីសហគមន៍ដោយអ្នកខាងក្រៅ គឺជាបញ្ហាមួយធ្ងន់ធ្ងរបំផុត ដែលពួកគេកំពុងជួបប្រទះ ។ ហេតុដូច្នេះ នៅក្នុងខេត្តដែលមានជនជាតិដើមភាគតិច ការដាក់ឱ្យអនុវត្តរបស់ស្ថាប័ន គណៈកម្មការសុរិយោដីមានភាពទន់ខ្សោយជាងនៅក្នុងខេត្តដទៃៗទៀត ។

---

២១០ នៅខែឧសភា ឆ្នាំ ២០០៥ ប្រធានគណៈកម្មការសុរិយោដីខេត្តរតនៈគិរី បានប្រាប់ក្រុមការងារយើងថា នៅខេត្តនេះមានការិយាល័យនៅស្រុកចំនួន ៦ និងស្រុក ៣ ទៀតពុំទាន់មាននៅឡើយទេ ។ រតនៈគិរីជាខេត្តមួយក្នុងចំណោមខេត្ត៣ ដែល ការអនុវត្តការងារនៅថ្នាក់ស្រុកគ្មានប្រសិទ្ធិភាព ។

តារាង : បញ្ជីការិយាល័យ និងមន្ត្រីក្នុងគណៈកម្មការសុរិយោដី

| លេខាធិការដ្ឋាន | | គណៈកម្មការថ្នាក់ស្រុក-ខណ្ឌ | | | ថ្ងៃចេញប្រកាស |
|---|---|---|---|---|---|
| ខេត្ត-ក្រុង | ចំនួនមន្ត្រី | អត្ថិភាពនៃគណៈកម្មការ | មិនមែនគណៈកម្មការ | ចំនួនមន្ត្រី | |
| ១. កំពត | ០៦ | ០៨ | ០០ | ១៩ | ០៨៦-០១/០៨/០២ |
| ២ .តាកែវ | ០៦ | ១០ | ០០ | ១៩ | ០៨៧-០១/០៨/០២ |
| ៣.កំពង់ធំ | ០៧ | ០៨ | ០០ | ២១ | ០៨៨-០១/០៨/០២ |
| ៤.ភ្នំពេញ | ០៩ | ០៧ | ០០ | ២៨ | ០៩៨-១៥/០៨/០២ |
| ៥.ក្រុងព្រះសីហនុ | ០៥ | ០៣ | ០០ | ០៩ | ០៩៩-១៥/០៨/០២ |
| ៦.កណ្តាល | ០៥ | ១១ | ០០ | ៤១ | ១០០-១៥/០៨/០២ |
| ៧.កំពង់ស្ពឺ | ០៦ | ០៨ | ០០ | ២៤ | ១០១-១៩/០៨/០២ |
| ៨.កោះកុង | ០៥ | ០៨ | ០០ | ២២ | ០១២-១៩/០៨/០២ |
| ៩.ពោធិសាត់ | ០៤ | ០៦ | ០០ | ២១ | ១០៣-១៩/០៨/០២ |
| ១០.បន្ទាយមានជ័យ | ០៧ | ០៧ | ០១ | ២១ | ១០៤-១៩/០៨/០២ |
| ១១.បាត់ដំបង | ០៥ | ១៣ | ០០ | ២៦ | ១០៥-១៩/០៨/០២ |
| ១២.ក្រចេះ | ០៤ | ០៥ | ០០ | ១៥ | ១០៦-១៩/០៨/០២ |
| ១៣.ក្រុងកែប | ០៦ | ២ | ០០ | ០៦ | ១០៧-១៩/០៨/០២ |
| ១៤.កំពង់ចាម | ០៥ | ១៦ | ០០ | ៣៨ | ១១៥-២៦/០៨/០២ |
| ១៥.ព្រៃវែង | ០៥ | ១២ | ០០ | ៣៤ | ១១៣-២៦/០៨/០២ |
| ១៦.ស្វាយរៀង | ០៧ | ០៧ | ០០ | ១៥ | ១៦០-២២/០៨/០២ |
| ១៧.សៀមរាប | ០៦ | ១១ | ០១ | ២០ | ១១៤-២៦/០៨/០២ |
| ១៨.កំពង់ឆ្នាំង | ០៤ | ០៧ | ០១ | ២១ | ១១៧-២៦/០៨/០២ |
| ១៩.ឧត្តរមានជ័យ | ០៥ | ០៤ | ០១ | ០៨ | ១៥៩-២២/០៨/០២ |
| ២០.ស្ទឹងត្រែង | ០៣ | ០៣ | ០២ | ០៣ | ១១៨-២៦/០៨/០២ |
| ២១.ប៉ៃលិន | ០៤ | ០២ | ០២ | ០៦ | ១៦៣-២២/០៨/០២ |
| ២២.រតនៈគិរី | ០៤ | ០៥ | ០៤ | ០៥ | ១៦១-២២/០៨/០២ |
| ២៣.មណ្ឌលគិរី | ០២ | ០១ | ០៤ | ០១ | ១៦២-២២/០៨/០២ |
| ២៤.ព្រះវិហារ | ០២ | ០២ | ០០ | ០២ | ១១៦-២៦/០៨/០២ |
| ថ្នាក់ជាតិ | ០៦ | | | | |
| គណៈកម្មការ ថ្នាក់ជាតិ | ០៣ | | | | |
| គណៈកម្មការ ថ្នាក់ខេត្ត | ៤៨ | ១៦៦ | ១៩ | | |
| | ១៧៩ | | | ៤២៥ | ៦០៤ |

ប្រភព: របាយការណ៍របស់លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីជាតិ ភ្នំពេញ ២០០៤

ខេត្តដែលខ្វះការិយាល័យថ្នាក់ស្រុក

ខេត្តដែលមានជនជាតិភាគតិចរស់នៅច្រើន

ធនធានសម្ភារៈ និងហិរញ្ញវត្ថុៈ ថវិកាសម្រាប់គណៈកម្មការសុរិយោដីនៅមានកម្រិតទាប ។ ធនធានមនុស្ស និងសម្ភារៈក្នុងការចូលរួមដោះស្រាយវិវាទដីធ្លីយ៉ាងច្រើន ដែលមាននៅពេលបច្ចុប្បន្នក៏នៅមានកម្រិតដែរ។ មន្ត្រីគណៈកម្មការសុរិយោដីត្រូវចុះត្រួតពិនិត្យដីនៅកន្លែងវិវាទក្នុងភូមិ ឃុំ និងត្រូវរៀបចំសំណុំរឿង។ ការិយាល័យមានការខ្វះខាតធនធានសម្រាប់ធ្វើការងារទាំងនេះ (ដូចជាយានយន្តធ្វើដំណើរ ម៉ាស៊ីនថតចម្លង សម្ភារៈការិយាល័យ...ល។)។ មន្ត្រីគណៈកម្មការដែលយើងបានទៅដល់បានពន្យល់ប្រាប់ថា កង្វះខាតសម្ភារៈ ការផ្គត់ផ្គង់ការធ្វើដំណើរ និងសម្ភារៈការិយាល័យ បានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការបំពេញការងារ។ អតិថិជនខ្លះរបស់គណៈកម្មការសុរិយោដី បានប្រាប់ឱ្យយើងដឹងថា ពួកគេត្រូវបានគេឱ្យបង់ការចំណាយទាំងនេះ (ការធ្វើដំណើរ ថតចម្លងឯកសារ...ល។) ទោះបីច្បាប់ចែងថាដំណើរការក្នុងរឿងនេះឥតមានបង់ថ្លៃក៏ដោយ។

ធនធានមនុស្សៈ គណៈកម្មការសុរិយោដីមានមន្ត្រីចំនួន ១៧៩នាក់នៅថ្នាក់ខេត្ត-ក្រុង រួមទាំងថ្នាក់ជាតិ។ មានមន្ត្រីថ្នាក់ស្រុកចំនួន ៤២៥នាក់ ដែលជាមធ្យមមានមន្ត្រីថ្នាក់ស្រុកចំនួន ១៧ ក្នុងខេត្តនីមួយៗ។ ខេត្តកណ្តាលតែមួយ មានមន្ត្រីថ្នាក់ស្រុករហូតដល់ទៅ ៤១នាក់ ដែលស្មើនឹង ១០%នៃមន្ត្រី ដែលមានទាំងអស់។ ក្នុងខេត្ត៦ (២៥%នៃ ខេត្តទាំងអស់) មានមន្ត្រីថ្នាក់ស្រុកចន្លោះពី ២៤ ទៅ ៤១នាក់។ មួយភាគបីនៃខេត្តទាំងអស់ (ត្រូវជា ៨ខេត្ត) មានមន្ត្រីថ្នាក់ស្រុកចន្លោះពី ១៩ ទៅ ២២នាក់ និងខេត្ត ១០ទៀតដែលមានចំនួនមន្ត្រីនៅក្រោមមធ្យមភាគ គឺមានបុគ្គលិកថ្នាក់ស្រុកពីម្នាក់ទៅ១៥នាក់។ ចំពោះខេត្តមណ្ឌលគិរី ដែលមានមន្ត្រីថ្នាក់ស្រុកតែម្នាក់នៅក្នុងខេត្តទាំងខេត្ត។

មន្ត្រីធម្មតា និងប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ទទួលបានប្រាក់ចំណូលប្រចាំខែសរុប ប្រមាណពី ២០ ទៅ ៣០ ដុល្លារអាមេរិក។ ប្រធានការិយាល័យថ្នាក់ខេត្តមិនធ្វើការឱ្យក្រសួងរៀបចំដែនដីទេ ប៉ុន្តែគឺធ្វើការក្រោមក្រសួងមហាផ្ទៃ។ ប្រាក់ចំណូលរបស់គាត់ទទួលបានច្រើនជាងមន្ត្រីធម្មតា នៅក្រសួងរៀបចំដែនដី។ មិនមានមន្ត្រីណាម្នាក់ដែលបានរៀបរាប់ខាងលើនេះ ធ្វើការងារពេញម៉ោងសម្រាប់គណៈកម្មការសុរិយោដីនោះទេ។ ពួកគេរំលែកពេលវេលារបស់ខ្លួន ជាមួយនឹងការងារប្រចាំថ្ងៃរបស់ក្រសួងរៀបចំដែនដី ឬក្រសួងមហាផ្ទៃប៉ុណ្ណោះ។ បញ្ហាមួយទៀតគឺការខ្វះខាតការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីទាំងអស់នេះក្នុងការដោះស្រាយវិវាទ។ អ្នកចូលរួមក្នុងសិក្ខាសាលាបានរិះគន់ ដល់កង្វះខាតជំនាញរបស់មន្ត្រីគណៈកម្មការសុរិយោដី ក៏ដូចជាអំពើពុករលួយ និងភាពលម្អៀង។

**តារាងៈ ប្រាក់បៀវត្សរ៍មន្ត្រីគណៈកម្មការសុរិយោដី** [២១១]

| តួនាទី | ប្រាក់បៀវត្សន៍សុទ្ធ | ប្រាក់ឧបត្ថម្ភ | សរុបជារៀល | សរុបជាដុល្លារ |
|---|---|---|---|---|
| ប្រធានគណៈកម្មការសុរិយោដីខេត្ត (អភិបាល ឬអភិបាលរងខេត្ត ក្រោមក្រសួងមហាផ្ទៃ) | ១២០.០០០ -១៣០.០០០ | ៦១៥.០០០ - ៧៤០.០០០ | ៧៣៥.០០០- ៨៧០.០០០ | ១៨៣- ២១៧ |
| ប្រធានគណៈកម្មការសុរិយោដីស្រុក (ក្រសួងរៀបចំដែនដី) | ១២០.០០០ - ១៣០.០០០ជាសរុប | | | ៣០-៣២.៥ |
| មន្ត្រី (ក្រសួងរៀបចំដែនដី) | ៩០.០០០ ជាសរុប (ប្រហែល) | | | ២២.៥ |

[២១១] ប្រភព : សម្ភាសន៍ជាមួយលោក ម៉េង ហាក់ ជាប្រធានគណៈកម្មការសុរិយោដីស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង (ខែមិថុនា ឆ្នាំ ២០០៥)។

ចំណេះដឹងផ្នែកច្បាប់៖ មុខងាររបស់ស្ថាប័នគណៈកម្មការសុរិយោដី គឺកសាងសមត្ថភាពក្នុងចំណោមបុគ្គលិកទាំងអស់ និងការផ្សព្វផ្សាយច្បាប់ក្នុងចំណោមប្រជាពលរដ្ឋ។ ជាការឆ្លើយតបក្រសួងរៀបចំដែនដី បានខិតខំប្រឹងប្រែងធ្វើការងារលើផ្នែកទាំងពីរនេះ ដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិដូចជា GTZ ជាដើម[២១២] ។ មន្ត្រីថ្នាក់ស្រុក-ខេត្តមួយចំនួន ក៏បានធ្វើការងារផ្សព្វផ្សាយយ៉ាងខ្លាំងក្លាដែរ ទោះបីជាមានភាពខ្វះខាតខាងធនធានក្តី[២១៣] ។ តែទោះជាយ៉ាងនេះក្តី វានឹងត្រូវប្រើពេលជាយូរថែមទៀត ដើម្បីដាក់ឱ្យស្ថាប័នគណៈកម្មការសុរិយោដីនេះ ប្រតិបត្តិបានពេញលេញ។ ប្រជាពលរដ្ឋកម្រនឹងបានដឹងពីគណៈកម្មការសុរិយោដីណាស់ ទោះបីជានៅក្នុងស្រុកដែលមានរឿងវិវាទដីធ្លីច្រើនក្តី។

សម្រាប់នៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ជនជាតិដើមភាគតិចទាំងនោះត្រូវបានគេជូនព័ត៌មានបានតិចតួចជាងគេអំពីគណៈកម្មការសុរិយោដី ទោះបីជាពួកគេប្រឈមមុខ ជាមួយនឹងបញ្ហាទន្ទ្រានយកដីសមូហភាព ដោយអ្នកមកពីខាងក្រៅធ្ងន់ធ្ងរក៏ដោយ។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងធ្វើការផ្សព្វផ្សាយពីច្បាប់ភូមិបាល ជាពិសេសនៅក្នុងខេត្តរតនគិរី ដែលជាកន្លែងមានរឿងក្តីដីធ្លីកើនឡើងនៅគណៈកម្មការសុរិយោដី។ ក្នុងខេត្តមណ្ឌលគិរី ចំណេះដឹងច្បាប់ភូមិបាល និងសិទ្ធិរបស់ជនជាតិដើមភាគតិចនៅមានកម្រិតទាប។ ចាំបាច់ត្រូវខិតខំប្រឹងប្រែងខ្លាំងជាងមុនបន្ថែមទៀត ដើម្បីផ្តល់ការយល់ដឹងផ្នែកច្បាប់ រួមទាំងការបកប្រែច្បាប់ភូមិបាល និងឯកសារផ្សេងៗទៀតទៅជាភាសារបស់ជនជាតិដើមភាគតិច។

**តារាង៖ តើអាជ្ញាធរឃុំនៅក្នុងខេត្តមណ្ឌលគិរី កំពង់ឆ្នាំង សៀមរាប និងកំពង់ស្ពឺ ដឹងពីគណៈកម្មការសុរិយោដីទេ ?**



ការស្ទង់មតិរបស់ IRL (ទំព័រ ៤៧)

---

២១២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបោះពុម្ពឯកសារជាច្រើនក្នុងការផ្សព្វផ្សាយច្បាប់ភូមិបាល ដូចជាសៀវភៅជាភាសាខ្មែរនិងអង់គ្លេស វីដេអូស៊ីឌី និងខិតប័ណ្ណជាដើម ។ ក្រសួងក៏បានបើកវគ្គបណ្តុះបណ្តាលទៅនឹងកន្លែងជូន ដល់មន្ត្រីទាំងនេះផងដែរ ។

២១៣ ជាឧទាហរណ៍ មន្ត្រីទទួលបន្ទុកការងារគណៈកម្មការសុរិយោដីនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង បានរៀបចំវគ្គបណ្តុះបណ្តាលនៅក្នុងស្រុករបស់ខ្លួន ដើម្បីផ្សព្វផ្សាយ និងពន្យល់ពីច្បាប់ភូមិបាល ជូនដល់ប្រជាពលរដ្ឋ (សម្ភាសនៅខែធ្នូ ឆ្នាំ ២០០៤) ។

## ២.៦.២. ការទទួលយុត្តិធម៌ពីគណៈកម្មការសុរិយោដី

តាមការវាយតម្លៃលើចំនួនរឿងក្តី ដែលបានទទួលដោយគណៈកម្មការសុរិយោដីចាប់តាំងពីការបង្កើតនៅឆ្នាំ ២០០២ បានបង្ហាញឱ្យឃើញដូចខាងក្រោមនេះ:

នៅក្នុងរយៈពេលបីឆ្នាំនេះ មានរឿងក្តីប្រមាន ២០៧៩ ករណីដែលបានប្តឹងមកគណៈកម្មការសុរិយោដី។ ករណីកើតមានច្រើននៅខេត្តមួយចំនួន ហើយនៅខេត្តខ្លះទៀតគណៈកម្មការសុរិយោដីទទួលបានតែចំនួនតិចប៉ុណ្ណោះ។ ក្នុងនោះមានខេត្តមួយទទួលរឿងក្តីរហូតដល់ទៅ ៥៧៩ ករណី = ២៧.៨៥% និងខេត្ត ៥ ផ្សេងទៀត ដែលមានតួលេខខ្ពស់ គឺទទួលរហូតដល់ ៨៤០ ករណី = ៤០ %។ ដូចនេះ ខេត្តចំនួន ២៥% នៃខេត្តទាំងអស់ទទួលស្ទើរតែ ២/៣ នៃរឿងក្តីទាំងអស់ទៅហើយដែលបានប្តឹងទៅគណៈកម្មការសុរិយោដីនៅទូទាំងប្រទេសទៅហើយ ដែលគិតជាមធ្យមភាគវិញ គឺនៅខេត្តនីមួយៗទទួលរឿងក្តីប្រមាណជា ២៣៩.៥ ករណី។ រីឯនៅខេត្តចំនួន ៦ ផ្សេងទៀត ទទួលបានរឿងក្តីប្រមាណ ១៨ % ដែលជាមធ្យមនៅខេត្តនីមួយៗ ទទួលរឿងក្តីប្រមាណជា ៦២ ករណី។ ចំពោះនៅខេត្តចំនួន ៦ ផ្សេងទៀតទទួលបានត្រឹមតែ ៩ % ដែលគិតជាមធ្យមនៅខេត្តនីមួយៗមានរឿងក្តីប្រមាណជា ៣៣ ករណី។ នៅខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី ដែលមានជនជាតិដើមភាគតិចរស់នៅភាគច្រើន គណៈកម្មការសុរិយោដី មិនត្រូវបានគេបង្កើតឱ្យមាននៅគ្រប់ស្រុកឡើយ។ នៅខេត្តទាំងនេះ ការទន្ទ្រានយកដីជនជាតិដើមភាគតិចគឺជាបញ្ហាដ៏ចម្បង។ ទោះជាយ៉ាងនេះក្តី គណៈកម្មការសុរិយោដីនៅខេត្តមណ្ឌលគិរី ទទួលបានរឿងក្តីតែប្រមាណជា ១០ ករណីប៉ុណ្ណោះ ហើយនៅខេត្តរតនគិរីវិញ គណៈកម្មការនេះទទួលរឿងក្តីប្រមាណជា ៤៦ ករណី ដែលកត្តានេះឆ្លុះបញ្ចាំងអំពីស្ថានភាពរបស់ជនជាតិដើម ភាគតិច ដែលមិនអាចចូលទៅរកយុត្តិធម៌ពីគណៈកម្មការសុរិយោដីបាន។

**ករណីដែលទទួលដោយគណៈកម្មការសុរិយោដីតាមលំដាប់:**

| ចំនួនខេត្ត-ក្រុង | ចំនួនរឿងក្តីសរុប ២០៧៩ | ចំនួនភាគរយ % | ចំនួនរឿងក្តី | ជាមធ្យមភាគ |
|---|---|---|---|---|
| ៦ (២៥%) | ១= ៥៧៩ | ២៧.៨៥% | ៥៥៧ | ៥៧៩ |
| | ៥= ៨៤០ | ៤០% | ៩២-២៧២ | ១៦៨ |
| | សរុប ១៤៣៧ | សរុប ៦៧.៨៥% | ៩២-៥៥៧ | ២៣៩.៥ |
| ៦ (២៥%) | ៣៧៦ | ១៨% | ៤៦-៧៨ | ៦២.៦ |
| ១២ (៥០%) | ៦ (២៥%)=១៩៩ | ៩.៥៧% | ២០-៤០ | ៣៣.១៦ |
| | ៦ (២៥%)=៨៥ | ៤.០៨% | ០៨-១៩ | ១៤.១៦ |
| | សរុប= ២៨៤ | ១៣.៦៦% | ០៨-៤០ | ២៣.៦៦ |

**តារាងស្តីពីស្ថិតិវិវាទដីធ្លីដោះស្រាយដោយគណៈកម្មការសុរិយោដីខេត្ត-ក្រុង រហូតដល់ ថ្ងៃទី ៣០ ខែ ឧសភា ២០០៥**

- តាមលំដាប់នៃចំនួនរឿងក្តីដែលបានទទួល:

| ល.រ | គណៈកម្មការ | ចំនួនបណ្តឹង | បានដោះស្រាយ | | បានបដិសេធ | | បានបញ្ជូនទៅថ្នាក់ជាតិ | | កំពុងចាត់ការ | |
|---|---|---|---|---|---|---|---|---|---|---|
| ១ | កំពង់ចាម | ៦៦៨ | ១៨៧ | ២៨% | ៩៨ | ១៥% | ១ | | ៣៨២ | ៥៧% |
| ២ | ស្វាយរៀង | ៣០៥ | ១៦១ | ៥៣% | ២៣ | ៧% | ០ | | ១២១ | ៤០% |
| ៣ | បាត់ដំបង | ២៩៩ | ៥១ | ១៧% | ២០ | ៦៧% | ៩ | ៣% | ២១៩ | ៧៣% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | ព្រៃវែង | ១៩៨ | ៦៣ | ៣២% | ៧ | ៤% | ០ | | ១២៨ | ៦៤% |
| ៥ | ភ្នំពេញ | ១២១ | ១២ | ១០% | ៥៦ | ៥០% | ០ | | ៥៣ | ៤០% |
| ៦ | កំពត | ១១៥ | ២៦ | ៤០% | ៥ | ៤% | ០ | | ៨៤ | ៧៣% |
| ៧ | កណ្ដាល | ១១៤ | ១៨ | ១៦% | ៤ | ៤% | ២ | ២% | ៩០ | ៧៨% |
| ៨ | ឧត្ដរមានជ័យ | ១០៦ | ៣៨ | | ១៧ | | ០ | | ៥១ | |
| ៩ | កំពង់ធំ | ៩៤ | ១ | | ១១ | | ០ | | ៨២ | |
| ១០ | សៀមរាប | ៩២ | ១៣ | | ០ | | ០ | | ៧៩ | |
| ១១ | ក្រចេះ | ៨៩ | ២៩ | | ៤ | | ០ | | ៥៦ | |
| ១២ | តាកែវ | ៨០ | ៣០ | | ៦ | | ០ | | ៤៤ | |
| ១៣ | កំពង់ស្ពឺ | ៧៧ | ២៣ | | ១៥ | | ០ | | ៣៩ | |
| ១៤ | ក្រុងព្រះសីហនុ | ៧០ | ២ | | ៥៤ | | ០ | | ១៤ | |
| ១៥ | កំពង់ឆ្នាំង | ៥៨ | ១៩ | | ៥ | | ០ | | ៣៤ | |
| ១៦ | ប៉ៃលិន | ៥៣ | ១២ | | ១៥ | | ០ | | ២៦ | |
| ១៧ | រតនៈគិរី | ៥១ | ១ | | ០ | | ០ | | ៥០ | |
| ១៨ | កោះកុង | ៥០ | ៤ | | ១៣ | | ០ | | ៣៣ | |
| ១៩ | បន្ទាយមានជ័យ | ៤៦ | ២ | | ៩ | | ០ | | ៣៥ | |
| ២០ | កែប | ៤៥ | ៥ | | ១០ | | ០ | | ៣០ | |
| ២១ | ពោធិសាត់ | ៤០ | ៧ | | ០ | | ០ | | ៣៣ | |
| ២២ | ព្រះវិហារ | ៣១ | ១៣ | | ៤ | | ០ | | ១៤ | |
| ២៣ | ស្ទឹងត្រែង | ១៩ | ៤ | | ០ | | ០ | | ១៥ | |
| ២៤ | មណ្ឌលគិរី | ១១ | ២ | | ២ | | ០ | | ៧ | |
| | **សរុប** | ២៨៣២ | ៧២៣ | ២៥% | ៣៧៨ | ១៣% | ១២* | ០.៤% | ១៧១៩ | ៦០% |
| | ជាមធ្យម | | | | | | | | | |

* គណៈកម្មការសុរិយោដីថ្នាក់ជាតិ បានអនុវត្តមាត្រា ៤១ នៃប្រកាសស្ដីពីការណែនាំ និងនីតិវិធីនៃគណៈកម្មការសុរិយោដី ដោយបញ្ជូនអ្នកសម្រុះសម្រួល ទៅឱ្យសម្រុះសម្រួលវិវាទនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។ ក្នុងចំណោមរឿងក្ដីទាំង ១២ ដែលបានទទួលមានតែ ១ ករណីប៉ុណ្ណោះ ដែលសម្រុះសម្រួលដោយជោគជ័យនៅខេត្តឧត្ដរមានជ័យ ។

ប្រភព ៖ របាយការណ៍របស់លេខាធិការដ្ឋានរបស់គណៈកម្មការសុរិយោដីជាតិ, ភ្នំពេញ ខែមិថុនា ២០០៥

តួនាទីគណៈកម្មការសុរិយោដីក្នុងការដោះស្រាយវិវាទដីធ្លី

សមត្ថភាពការងារ៖

ចាប់តាំងពីបង្កើតនៅឆ្នាំ ២០០៣ រហូតមកដល់ចុងឆ្នាំ ២០០៥ គណៈកម្មការសុរិយោដីបានទទួលរឿងក្ដីចំនួន ២៨៣២ ករណី។ គណៈកម្មការសុរិយោដីបានដោះស្រាយបានមួយភាគបួន នៃរឿងក្ដីទាំងអស់ដែលបានទទួល (៧២៣ ករណី) និងបានបដិសេធប្រហែល ១៤%នៃរឿងក្ដីទាំងអស់ (៣៧៨ករណី) និងពីរភាគបីនៃរឿងក្ដីទាំងអស់រង់ចាំការដោះស្រាយ (១.៧១៩ ករណី) ។ បើប្រៀបធៀបទៅនឹងតុលាការ និងអាជ្ញាធរឃុំ សមត្ថភាពការងាររបស់គណៈកម្មការសុរិយោដី ហាក់ដូចជាទាបជាង ។

អាជ្ញាធរឃុំដោះស្រាយបានយ៉ាងហោចពីរភាគបីនៃរឿងក្តីទាំងអស់ ដែលគេបានទទួល[២១៤]។

តារាង: រឿងក្តីនៅចំពោះមុខគណៈកម្មការសុរិយោដីឆ្នាំ ២០០៣-២០០៥[២១៥]

| រឿងក្តី-គណៈកម្មការសុរិយោដី | ចំនួនពាក្យបណ្តឹង | រឿងក្តីដែលបានដោះស្រាយ | រឿងក្តីដែលបានបដិសេធ | រឿងក្តីកំពុងចាត់ការ |
|---|---|---|---|---|
| សរុប | ២៨៣២ | ៧២៣ | ៣៧៨ | ១៧១៩ |
| % | ១០០ % | ២៥ % | ១៤% | ៦១ % |




**ទំហំរឿងក្តីក្នុងគណៈកម្មការសុរិយោដីនីមួយៗ និងបុគ្គលិកគណៈកម្មការ**

បើសិនជាយើងយកចំនួនរឿងក្តីទាំងអស់ មកចែកនឹងចំនួនបុគ្គលិក ដែលបំរើការនៅក្នុងគណៈកម្មការសុរិយោដី ចំនួន ៦៤០នាក់ យើងឃើញថាក្នុងបុគ្គលិកម្នាក់ទទួលរឿងក្តីចំនួន៣.២។ សម្រាប់ថ្នាក់ស្រុកវិញ ក្នុងបុគ្គលិកគណៈកម្មការម្នាក់ទទួលរឿងក្តីប្រហែលជា ៤.៨៩ ករណី។ ហើយបើគិតពីរឿងក្តីដែលដោះស្រាយរួចគឺ ជាទូទៅបុគ្គលិកម្នាក់មានរឿងក្តីចំនួន ១.៣ ករណីត្រូវបានដោះស្រាយរួច ០.៥ ករណីបានបដិសេធ និង ៣ករណីទៀត កំពុងរង់ចាំដំណោះស្រាយ។ ចំនួននេះនឹងកើនឡើងនៅក្នុងខេត្តដែលមានរឿងក្តីច្រើន ឬខេត្តដែលមានរឿងក្តីមិនទាន់ដោះស្រាយច្រើន (ឧទាហរណ៍ នៅខេត្តកំពង់ចាមមាន ៣៤៦ ករណីមិនទាន់បានដោះស្រាយ ហើយមានមន្ត្រី ៣៨នាក់ នៅតាមថ្នាក់ស្រុកបូកនឹងមន្ត្រីនៅថ្នាក់ខេត្ត ៥ រូបទៀត)។ សម្រាប់ករណីខេត្តមណ្ឌលគីរីវិញ ជាខេត្តដែលមាន ចំនួនមន្ត្រីតិច (មាន ៨ ករណីមិនទាន់ដោះស្រាយ តែមានតែមន្ត្រីម្នាក់ប៉ុណ្ណោះនៅថ្នាក់ខេត្ត និងម្នាក់នៅថ្នាក់ស្រុក)។ ដូចនេះ ចំនួនជាមធ្យមនៃករណីដែលមិនទាន់បានដោះស្រាយសម្រាប់មន្ត្រីម្នាក់គឺ ១០ ករណី។ បើសិនជាគ្រប់មន្ត្រី ក្នុងគណៈកម្មការនេះមានការលះបង់ខ្ពស់ និងយកចិត្តទុកដាក់ខិតខំធ្វើការងារពេញម៉ោងធ្វើការ និងមានធនធានគ្រប់គ្រាន់ នោះប្រសិទ្ធិភាពរបស់គណៈកម្មការនេះ នឹងបានកាន់តែប្រសើរឡើងដែរ។

---

[២១៤] សូមមើលតារាងរឿងក្តីដែលបានសម្រុះសម្រួលនៅថ្នាក់ឃុំ ក្នុងឧបសម្ព័ន្ធ ២។ ដូចគ្នានេះផងដែរ ការស្ទង់មតិរបស់ CAS-AF ឆ្នាំ ២០០៥ បានរកឃើញថា "៧៥% នៃវិវាទត្រូវបានដោះស្រាយ"។

[២១៥] ប្រភព : របាយការណ៍ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ឆ្នាំ ២០០៤ និងរបាយការណ៍ចុងក្រោយថ្មីៗ។

| ចំនួនរឿងក្តី និងគណៈកម្មការ | ចំនួនពាក្យបណ្តឹង | ចំនួនរឿងក្តីដែលបានដោះស្រាយ និងបដិសេធ | កំពុងចាត់ការ |
|---|---|---|---|
| សរុប | ២០៧៥ | ៥៥៣ និង ២០៧ | ១៣១៥ |
| បន្ទុករឿងក្តីជាមធ្យមក្នុងមន្ត្រីម្នាក់ ក្នុងចំណោមមន្ត្រី ទាំង ៤២៥ នៅថ្នាក់ស្រុក | ៤.៩៨ | ១.៣ និង ០.៥= ១.៨ | ៣.១ |

ទំហំរឿងក្តីក្នុងការិយាល័យគណៈកម្មការសុរិយោដី

បើចែកចំនួនរឿងក្តីទាំងអស់ជាមួយនឹងចំនួនខេត្ត-ក្រុង មានមធ្យមភាគប្រមាណ ៨៦ រឿងក្តី ដែលក្នុងនោះ ២៣ ករណី ត្រូវបានដោះស្រាយ ៩ ករណី ត្រូវបានបដិសេធ និង ៥៥ ករណី កំពុងរង់ចាំការដោះស្រាយក្នុងខេត្តនីមួយៗ។ ទោះជាយ៉ាងនេះក្តី មធ្យមភាគមានភាពខុសគ្នានឹងភាពជាក់ស្តែង។ មានខេត្តមួយចំនួនដែលមានចំនួនរឿងក្តីខ្ពស់ ហើយក៏មានខេត្តមួយចំនួនទៀត ដែលមានចំនួនរឿងក្តីបានទទួលទាបដែរ ដូចដែលតារាងស្ថិតិនៃវិវាទដីធ្លីបង្ហាញនៅខាងក្រោមនេះ។ ក្នុងខេត្តដែលខ្ពស់បំផុតមាន ខេត្តកំពង់ចាម និងខេត្តស្វាយរៀងដែលមាន ៣៤៦ និង ១១៧ ករណី កំពុងរង់ចាំការដោះស្រាយក្នុងខេត្តនីមួយៗ។ ចំណែកខេត្តដទៃទៀត មួយភាគបីនៃខេត្តទាំងអស់ (៨ខេត្ត) មានតិចជាង ១៩ករណី កំពុងធ្វើការដោះស្រាយ។ ខេត្តកំពង់ឆ្នាំងមានតែមួយករណីប៉ុណ្ណោះដែលកំពុងធ្វើការដោះស្រាយ។

| រឿងក្តី-គណៈកម្មការសុរិយោដី | ចំនួនពាក្យបណ្តឹង | រឿងក្តីដែលបានដោះស្រាយ | រឿងក្តីដែលបានបដិសេធ | រឿងក្តីកំពុងចាត់ការ |
|---|---|---|---|---|
| សរុប | ២០៧៥ | ៥៥៣ | ២០៧ | ១៣១៥ |
| មធ្យមភាគទំហំរឿងក្តីក្នុងមួយ ស្រុក / ១៨៥ ស្រុក | ១១.២៣ | ២.៩៨ | ១.១១ | ៧.១២ |
| មធ្យមភាគទំហំរឿងក្តីក្នុងមួយ ខេត្ត / ២៤ ខេត្ត | ៨៦.៦២ | ២៣ | ៨.៦ | ៥៤.៩៥ |

ចំនួនរឿងក្តីដែលបានដោះស្រាយដោយថ្នាក់ខេត្ត

គណៈកម្មការសុរិយោដីបានដោះស្រាយរឿងក្តីតែចំនួនប្រមាណជា ១ ភាគ ៤ (២៦%) នៃរឿងក្តី ដែលបានទទួលទាំងអស់ប៉ុណ្ណោះ ។ ភាគច្រើននៃរឿងក្តីដែលបានទទួល ច្រើនកើតមាននៅតែខេត្តមួយចំនួនតូចប៉ុណ្ណោះ។ ៥៦% នៃរឿងក្តីដែលបានដោះស្រាយហើយគឺនៅខេត្តចំនួនពីរ គឺខេត្តកំពង់ចាម និងខេត្តស្វាយរៀង (*170+140 =310* ករណី ) :

ក- ខេត្ត ៥ (២១%នៃខេត្តទាំងអស់)បានដោះស្រាយរឿងក្តីរួច ៧៥% (៤១៧/៥៥៣) ដោយមានមធ្យមភាគស្មើនឹងបួនដង (៨៣) លើសពីមធ្យមភាគនៅទូទាំងប្រទេស (២៣)។

ខ- ខេត្តចំនួន ៥ទៀត (២១%)ជាមធ្យមបានដោះស្រាយរឿងក្តីចំនួន ១៧ករណី ត្រូវជា ១៥%នៃរឿងក្តីដែលបានដោះស្រាយរួច (៨៥/៥៥៣)។

គ- មួយភាគបីនៃខេត្តទាំងអស់ (៨ខេត្ត) មានលទ្ធផលសម្រេចបានទាបណាស់ដោយជាមធ្យមមានតិចជាង ៥ករណី ដែលបានដោះស្រាយ ដែលត្រូវជា ៨%នៃរឿងក្តីដែលបានដោះស្រាយទាំងអស់ (៤៦/៥៥៣)។

ឃ-២៥%នៃខេត្តទាំងអស់ (៦ខេត្ត) មានលទ្ធផលសម្រេចបានទាបបំផុត ដោយមានរឿងក្តីតិចជាងមួយករណី ត្រូវបានដោះស្រាយ ពោលគឺដោះស្រាយបានប្រមាណជា ១ ករណីប៉ុណ្ណោះ។

នេះមានន័យថា ៥៨%នៃខេត្តទាំងអស់ (១៤ខេត្ត)បានដោះស្រាយតិចជាង ៩ ករណី។

ខេត្តដែលបានដោះស្រាយមួយករណី ឬគ្មានមួយករណីមានៈ ខេត្តសៀមរាបគ្មានករណីណាមួយត្រូវបានដោះស្រាយ (លើ៨ករណី) និងបានដោះស្រាយមួយករណីៈ ក្រុងព្រះសីហនុ (លើ៦២ករណី) រតនៈគីរី (លើ៤៦ករណី) បន្ទាយមានជ័យ (លើ៣៧ករណី) កំពង់ធំ (លើ២០ករណី) និងខេត្តមណ្ឌលគីរី(លើ១០ករណី)។ ជាថ្មីម្តងទៀត ខេត្តដែលមានប្រជាពលរដ្ឋជនជាតិដើមភាគតិចរស់នៅ បានលេចចេញនៅទីនេះ គឺបានដោះស្រាយរឿងក្តីតិចបំផុត គឺតែមួយករណីប៉ុណ្ណោះ។

**ចំនួនរឿងក្តីដែលបានដោះស្រាយដោយខេត្ត**

| ៦ ខេត្ត (២៥%) | ៨ ខេត្ត (៣៣%) | [illegible] | ៥ ខេត្ត (២១%) |
|---|---|---|---|
| ដោះស្រាយបាន ០១ករណី | ដោះស្រាយបាន ៣-៩ ករណី | [illegible] | ដោះស្រាយបាន ៣០-១៧០ ករណី |




ភាគរយនៃរឿងក្តីដែលបានដោះស្រាយដោយខេត្តទាំងឡាយ

សមត្ថភាពការងារប្រែប្រួលពីខេត្តមួយទៅខេត្តមួយ :

ក- មានតែខេត្តពីរប៉ុណ្ណោះ (៨%នៃខេត្តទាំងអស់)ដែលបានដោះស្រាយលើសពី ៥០%នៃរឿង ក្តីដែលបានទទួល ខេត្តកំពង់ចាម (៦៦.៦%) និងខេត្តស្វាយរៀង (៥២%)។ ខេត្តស្វាយរៀងគឺជាខេត្តដែលមានអត្រាខ្ពស់បំផុតទីពីរក្នុងរឿងនេះ ដោយមាន ១៤០ ករណី បានដោះស្រាយលើចំនួន ២៦៩ ករណី ដែលបានទទួល និងមានអត្រាទាបនៃរឿងក្តីដែលបានបដិសេធ (៤.៤%)។ ផ្ទុយមកវិញ ខេត្តកំពង់ឆ្នាំងបានទទួល ចំនួនរឿងក្តីតិច (១៨%) និងមានរឿងក្តីដែលបានបដិសេធខ្ពស់បំផុត ស្មើរតែមួយភាគបី (២៧.៧%)។ ការទិតៀនមួយក្នុងចំណោមការរិះគន់ជាច្រើនដល់គណៈកម្មការ សុិរយោដីគឺការបដិសេធរឿងក្តី។

ខ- ខេត្តចំនួន ៨ បានដោះស្រាយរឿងក្តីប្រមាណជាពី ២៥ ទៅ ៣៨% ក្នុងចំណោមរឿងក្តីដែលបានទទួល។

គ- ខេត្ត ចំនួន ៦ បានដោះស្រាយពី ១០ ទៅ ២២%នៃរឿងក្តីដែលបានទទួល។

ឃ- ខេត្តចំនួន ៨ បានដោះស្រាយរឿងក្តីតិចជាង ១០%នៃរឿងក្តីទាំងអស់ដែលបានទទួល។

ម្ដងទៀត ខេត្តរតនៈគីរី និងមណ្ឌលគីរីហាក់ដូចជាឋិតក្នុងចំណោមខេត្តដែលមានលទ្ធផលទាបបំផុត:

| ខេត្ត | ២ (៨,៣%) | ៨ (៣៣,៣៣%) | ៦ (២៥%) | ៨ (៣៣,៣៣%) |
|---|---|---|---|---|
| ភាគរយរឿងក្ដីដែលបានធ្វើការដោះស្រាយ | លើសពី ៥០% | ២៥-៣៨% | ១០-២២% | ០-១០% |

តារាង: ស្ថិតិនៃវិវាទដីធ្លីពីគណៈកម្មការសុរិយោដីខេត្ត-ក្រុង តាំងពីចាប់ផ្ដើមដំបូងរហូតដល់ចុងឆ្នាំ ២០០៤[២១៦]

| ខេត្ត | ចំនួនពាក្យបណ្ដឹង | រឿងក្ដីដែលបានដោះស្រាយ | % | រឿងក្ដីដែលបានបដិសេធ | % | រឿងក្ដីកំពុងចាត់ការ | % |
|---|---|---|---|---|---|---|---|
| ១ កំពង់ចាម | ៥៧៩ | ១៧០ | ២៩.៣៦ | ៦៣ | ១០.៨៨ | ៣៤៦ | ៥៩.៧៥ |
| ២.ស្វាយរៀង | ២៦៩ | ១៤០ | ៥២.០៤ | ១២ | ៤.៤៦ | ១១៧ | ៤៣.០១ |
| ៣.បាត់ដំបង | ២៧២ | ៤៧ | ១៧.២៧ | ២០ | ៧.៣៥ | ២០៥ | ៧៥.៣៦ |
| ៤.ឧត្ដរមានជ័យ | ៧៨ | ៣០ | ៣៨.៤៦ | ១៤ | ១៧.៩៤ | ៣៤ | ៤៣.៥៨ |
| ៥.ព្រៃវែង | ១០៤ | ៣០ | ២៨.៨៤ | ០២ | | ៧២ | ៦៩.២៣ |
| ៦.ក្រចេះ | ៧៧ | ២៣ | ២៩.៨៧ | ០៤ | | ៥០ | ៦៤.៩៣ |
| ៧.កំពត | ១០៣ | ២១ | ២០.៣៨ | ០៣ | | ៧៩ | ៧៦.៦៩ |
| ៨.កំពង់ស្ពឺ | ៥៧ | ១៩ | ៣៣.៣៣ | ០៧ | ១២.២៨ | ៣១ | ៥៤.៣៨ |
| ៩.កំពង់ឆ្នាំង | ១៨ | ១២ | ៦៦.៦៦ | ០៥ | ២៧.៧ | ០១ | ៥.៥ |
| ១០.ប៉ៃលិន | ៣៩ | ១០ | ២៥.៦៤ | ០១ | | ២៨ | ៧១.៧៩ |
| ១១.កណ្ដាល | ៤០ | ០៩ | ២២.៥ | ០៤ | ១០ | ២៧ | ៦៧.៥ |
| ១២.ភ្នំពេញ | ៩២ | ០៨ | ៨.៦៩ | ៥២ | ៥៦.៥២ | ៣២ | ៣៤.៧៨ |
| ១៣.ពោធិ៍សាត់ | ៣៦ | ០៧ | ១៩.៤៤ | ០០ | - | ២៩ | ៨០.៥៥ |
| ១៤.តាកែវ | ៥៦ | ០៦ | ១០.៧១ | ០៤ | ៧.១៤ | ៤៦ | ៨២.១៤ |
| ១៥.ព្រះវិហារ | ១៧ | ០៦ | ៣៥.២៩ | ០៤ | ២៣.៥២ | ០៧ | ៤១.១៧ |
| ១៦.ស្ទឹងត្រែង | ១៣ | ០៤ | ៣០.៧៦ | ០០ | - | ០៩ | ៦៩.២៣ |
| ១៧.កោះកុង | ២៧ | ០៣ | ១១.១១ | ១១ | ៤០.៧៤ | ១៣ | ៤៨.១៤ |
| ១៨.ក្រុងកែប | ១៩ | ០៣ | ១៥.៧៨ | ០០ | - | ១៦ | ៨៤.២១ |
| ១៩.ក្រុងព្រះសីហនុ | ៦២ | ០១ | ១.៦១ | ០០ | - | ៦១ | ៩៨.៣៨ |
| ២០.រតនៈគីរី | ៤៦ | ០១ | ២.១៧ | ០០ | - | ៤៥ | ៩៧.៨២ |
| ២១.បន្ទាយមានជ័យ | ៣៧ | ០១ | ៧.៧ | ០០ | - | ៣៦ | ៩៧.២៩ |
| ២២.កំពង់ធំ | ២០ | ០១ | ៥ | ០០ | - | ១៩ | ៩៥ |
| ២៣.មណ្ឌលគីរី | ១០ | ០១ | ១០ | ០១ | ១០ | ០៨ | ៨០ |
| ២៤.សៀមរាប | ០៨ | ០០ | | ០០ | | ០៨ | ១០០ |
| **សរុប** | **២០៧៩** | **៥៥៣** | **២៦.៥៩%** | **២០៧** | **៩,៩៥%** | **១៣១៩** | **៦៣.៤៤%** |

[២១៦] ប្រភព: របាយការណ៍របស់លេខាធិការគណៈកម្មការសុរិយោដី ឆ្នាំ ២០០៤ ។

និតិវិធី និងគុណភាពសេវា

នីតិវិធីនៅចំពោះមុខគណៈកម្មការសុរិយោដី គឺឥតមានបង់ថ្លៃទេ។ នៅពេលទទួលបានពាក្យបណ្តឹងមន្ត្រីត្រូវចុះទៅទីកន្លែងដែលមានវិវាទ ហើយអញ្ជើញអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដើម្បីសម្រុះសម្រួលរឿងក្តី។ ការចំណាយសម្រាប់ការធ្វើដំណើរគឺជាបញ្ហាដែលមន្ត្រី និងគូភាគីត្រូវប្រឈម។ អ្នកប្រើប្រាស់ប្រព័ន្ធនេះបានបង្ហាញឱ្យដឹងថា គណៈកម្មការសុរិយោដី អាចដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួល និងប្រើពេលវេលានិងលុយកាក់តិចជាងការប្តឹងទៅតុលាការ។ តែទោះជាយ៉ាងនេះក្តី ពួកគេបានរិះគន់គណៈកម្មការសុរិយោដីពីបញ្ហាមានភាពលម្អៀង អំពើពុករលួយ និងការខ្វះខាតជំនាញ។

រឿងក្តីខ្លះតម្រូវឱ្យជួបប្រជុំជាច្រើនលើកដើម្បីសម្រុះសម្រួល។ នៅពេលដែលគណៈកម្មការនៅថ្នាក់ស្រុក បរាជ័យក្នុងការសម្រុះសម្រួល រឿងក្តីត្រូវបញ្ជូនទៅថ្នាក់ខេត្ត។ តាមច្បាប់បើសិនជាវិវាទមានភាគីពាក់ព័ន្ធច្រើន ឬភាគី វិវាទជាអ្នកមានអំណាចលើសពីមន្ត្រីទទួលបន្ទុកក្នុងគណៈកម្មការស្រុក នោះរឿងក្តីនឹងត្រូវបានបញ្ជូនទៅដល់ការិយាល័យ គណៈកម្មការសុរិយោដីនៅថ្នាក់ខេត្ត។ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ខេត្តមិនអាចដោះស្រាយបាននោះ ករណីនឹងត្រូវតែបញ្ជូនទៅថ្នាក់ជាតិ។ រហូតមកដល់ពេលនេះ មិនទាន់មានរឿងក្តីណាមួយដែលបានសម្រេចដោយ គណៈកម្មការសុរិយោដីជាតិនៅឡើយទេ។

ដោយហេតុថា គណៈកម្មការសុរិយោដីពុំមានការកំណត់ពេលវេលាក្នុងការដោះស្រាយវិវាទ នោះអាចនាំឱ្យក្នុងករណីមួយចំនួន ភាគីត្រូវរង់ចាំរហូតដោយគ្មានដំណោះស្រាយឡើយ។

*លោកស្រី កក និងលោកស្រី ខខ ទាំងពីរនាក់រស់នៅក្នុងភូមិ ថ្លុកដូនសរ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ឆ្នាំង។ អ្នកទាំងពីរជាអ្នកជិតខាង តែអ្នកទាំងពីរពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីឡើយ។ នៅខែកក្កដា ឆ្នាំ ២០០៣ អ្នកទាំងពីរមានវិវាទលើព្រំដី។ លោកស្រី ខខ បានប្តឹងទៅមេឃុំដើម្បីរកដំណោះស្រាយ។ បន្ទាប់ពីទទួលបានបណ្តឹងហើយជំទប់ឃុំទី២ ដែលជាតំណាងឱ្យឃុំ បានអញ្ជើញគូភាគីមកធ្វើការសម្រុះសម្រួល តែលោកស្រី កក មិនព្រមចូលរួមក្នុងការសម្រុះសម្រួលទេ ដោយអះអាងថាគាត់មិនទុកចិត្តលើជំទប់ទី២ឡើយ។ នៅខែសីហា ឆ្នាំ ២០០៣ លោកស្រី កក បានដាក់ពាក្យប្តឹងទៅគណៈកម្មការសុរិយោដីស្រុក ប្រឆាំងនឹងលោកស្រី ខខ ដោយអះអាងថា លោកស្រី ខខ បានរំលោភលើទ្រព្យសម្បត្តិរបស់គាត់។ បន្ទាប់ពីទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដី បានអញ្ជើញចុងចម្លើយ គឺលោកស្រី ខខ ចំនួនពីរដងដើម្បីមកសាកសួរ។ គណៈកម្មការនេះមិនបានធ្វើការប្រជុំសម្រុះសម្រួលឡើយ។ លោកស្រី កក មានការខកចិត្តយ៉ាងខ្លាំងជាមួយគណៈកម្មការសុរិយោដីនេះ ដោយគាត់យល់ថា គណៈកម្មការសុរិយោដីមិនបានធ្វើអ្វីទាំងអស់សម្រាប់គាត់។ រហូតមកដល់ពេលនេះ វិវាទនេះនៅកំពុងរង់ចាំការដោះស្រាយពីគណៈកម្មការសុរិយោដីដដែល។ ភាគីនៃវិវាទចង់ឱ្យរឿងក្តីនេះ បញ្ជូនមកអាជ្ញាធរឃុំសម្រាប់ការសម្រុះសម្រួលវិញ ពីព្រោះពួកគេមិនចង់ឱ្យករណីវិវាទនេះនៅតែបន្តទៅថ្នាក់ខេត្តឡើយ។*

សមត្ថភាពគណៈកម្មការសុរិយោដីក្នុងការជំនះលើអតុល្យភាពរវាងគូភាគី

គណៈកម្មការសុរិយោដីបានទទួលវិវាទជាច្រើនរវាងអ្នកភូមិ និងរវាងអ្នកភូមិនិងភាគីអ្នកមានអំណាចនានា (ដូចជាសម្បទានិក ក្រុមហ៊ុន យោធា រដ្ឋ អ្នកមានទ្រព្យសម្បត្តិ មន្ត្រី ឋានៈខ្ពស់... ។ល។)

នៅពេលដែលវិវាទកើតឡើងរវាងអ្នកភូមិ និងមិនមានភាគីមានអំណាចពាក់ព័ន្ធ នោះវិវាទអាចមានឱកាសច្រើនសម្រាប់គូភាគីក្នុងការសម្រុះសម្រួលនិងឈានដល់ការព្រមព្រៀងគ្នា។ ផ្ទុយទៅវិញ នៅពេលមានប្រយោជន៍ នយោបាយ និងសេដ្ឋកិច្ចនៅពីក្រោយវិវាទ នោះវាមានការលំបាកច្រើនក្នុងការដោះស្រាយ។ តែទោះជាយ៉ាងនេះក្តី ក្នុងករណីខ្លះមន្ត្រីគណៈកម្មការសុរិយោដីខិតខំប្រឹងប្រែងជំនះលើឥទ្ធិពលនយោបាយដែលនៅពីក្រោយរឿងក្តី ដើម្បីឈានដល់ការព្រមព្រៀងគ្នា។ ឧទាហរណ៍មួយនៃរឿងនេះបានកើតឡើងនៅក្នុងគណៈកម្មការសុរិយោដីក្នុងខេត្តកំពង់ឆ្នាំង។

ឧទាហរណ៍៖ រឿងក្តីត្រូវបានដោះស្រាយដោយគណៈកម្មការសុរិយោដីស្រុក នៅពេលគណៈកម្មការសុរិយោដី អាចជំនះលើឥទ្ធិពលនយោបាយនៅពីក្រោយរឿងក្តី ៖

*ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីស្រុក នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*[២១៧]

- ***ថ្ងៃទី ២១ មករា ២០០៥***
- ***រឿងហេតុ :*** *វិវាទដីធ្លី (ដីធ្លីមិនបានចុះបញ្ជី)*
- ***លទ្ធផល :*** *ដោះស្រាយរួច*
- *វិវាទចាប់ផ្តើមតាំងពីឆ្នាំ ២០០២ រវាងលោក AA និងលោកស្រី BB ស្នាក់នៅភូមិចាស់ ឃុំតាំងក្រសាំង ស្រុកទឹកផុស។ លោកស្រី BB បានកាប់ឆ្ការលើដីមួយកន្លែងនៅភូមិចាស់ ក្នុងទសវត្សរ៍ទី ៨០ និងបានធ្វើស្រែចំការលើដីនោះ។ ក្នុងឆ្នាំ ១៩៨៣ គាត់បានកាប់ឆ្ការលើដីមួយកន្លែងទៀតនៅភូមិ អូគ្គុល។ នៅឆ្នាំ ២០០២ លោក AA បានចាប់ផ្តើមទាមទារថា ដីដែលបានកាប់ឆ្ការដោយលោកស្រី BB នៅក្នុងភូមិ អូគ្គុល ជារបស់គាត់ ពីព្រោះគាត់ធ្លាប់បានធ្វើជាម្ចាស់លើដីនោះ នៅមុនឆ្នាំ ១៩៧៥ និងបានសុំឱ្យលោកស្រី BB ចែករំលែកផលស្រូវជាមួយគាត់ ប៉ុន្តែលោកស្រី BB បានបដិសេធ។ ក្រោយពីការបដិសេធ លោក AA បានប្តឹងរឿងនេះទៅអាជ្ញាធរភូមិ និងឃុំដើម្បីឱ្យរកដំណោះស្រាយ។ រឿងក្តីនេះមិនអាចដោះស្រាយបាននៅថ្នាក់ឃុំ ក៏បានបន្តមកដល់គណៈកម្មការសុរិយោដីស្រុក នៅឆ្នាំ២០០៤។ មានការជួបប្រជុំសម្រុះសម្រួលជាច្រើនលើករួចមកហើយ តែគូភាគីមិនបានព្រមព្រៀងគ្នាឡើយ។ នៅចុងឆ្នាំ ២០០៤ លោកស្រី BB បានប្តឹងរឿងនេះមកកាន់តុលាការខេត្តកំពង់ឆ្នាំង ដែលបានបង្វិលរឿងនេះត្រលប់ទៅគណៈកម្មការសុរិយោដីស្រុកវិញ ពីព្រោះវិវាទនេះគឺជារឿងលើដីធ្លីមិនទាន់បានចុះបញ្ជី។*
- *ចាប់តាំងពីរឿងក្តីត្រូវបានបង្វិលមកកាន់គណៈកម្មការសុរិយោដីស្រុកវិញ គណៈកម្មការសុរិយោដីស្រុកបានធ្វើ ការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ ដើម្បីដោះស្រាយវិវាទ។ គណៈកម្មការសុរិយោដីស្រុកបានសង្កេតឃើញថា គូភាគីមានគណបក្សនយោបាយខុសគ្នានៅពីក្រោយ ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ (ម្ខាងនៅពីក្រោយដោយ "គ.ប្រ.ជ.ក" និងម្ខាងទៀតដោយ "ហ្វ៊ុនស៊ិនប៉ិច")។ ហេតុនេះ គណៈកម្មការសុរិយោដីស្រុកជឿថា ផ្លូវតែមួយគត់ក្នុងការដោះស្រាយរឿងក្តី គឺត្រូវបញ្ចុះបញ្ចូលអ្នកដែលមានឥទ្ធិពលលើគូភាគីទាំងពីរ ដើម្បីជួយក្នុងការសម្រុះសម្រួល។ ប៉ុន្មានសប្តាហ៍ក្រោយមក គូភាគីបានឈានដល់ការព្រមព្រៀងគ្នា។ បន្ទាប់មកគណៈកម្មការសុរិយោដីស្រុក រួមជាមួយនឹងក្រុមប្រឹក្សាឃុំបានកំណត់ថ្ងៃសម្រាប់ដោះស្រាយរឿងក្តីម្តងទៀត។*
- *គណៈកម្មការសុរិយោដីស្រុក បានធ្វើការជួបប្រជុំសម្រុះសម្រួលនៅថ្ងៃទី ២១ មករា ២០០៥ នៅកន្លែងដែលវិវាទបានកើតឡើង។ ប្រធានគណៈកម្មការសុរិយោដីស្រុក សមាជិកក្រុមប្រឹក្សាឃុំ និងគូភាគីបានចូលរួមក្នុង ការជួបប្រជុំនេះ។ ការសម្រុះសម្រួលបានប្រើពេលអស់រយៈពេល ១ ម៉ោង។*
- *នៅពេលចាប់ផ្តើម ប្រធានបានស្វាគមន៍អ្នកចូលរួម និងបានគូសបញ្ជាក់ថាគាត់ជឿជាក់យ៉ាងខ្លាំងថា គូភាគីនឹងឈានទៅរកដំណោះស្រាយដែលព្រមព្រៀងគ្នាមួយ។ បន្ទាប់មក គាត់បានសួរទៅគូភាគីនូវជំហររបស់ ពួកគេក្នុងការសម្រុះសម្រួល។ គូភាគីបាននិយាយថា ពួកគេបានព្រមព្រៀងគ្នារួច ហើយថា លោកស្រី BB យល់ព្រមផ្តល់ដីនៅក្នុងភូមិអូគ្គុលទៅឱ្យលោក AA សម្រាប់ជាថ្នូរនឹងការដោះដូរដីមួយកន្លែងនៅក្នុងភូមិចាស់។*
- *ក្រោយពីមានការព្រមព្រៀងពីគូភាគីទាំងពីររួចមក គណៈកម្មការបានចាប់ផ្តើមវាស់វែងដីសម្រាប់គូភាគី។ គូភាគីបានព្រមព្រៀងគ្នាក្នុងការចៀសវាងមិនឱ្យមានវិវាទតទៅថ្ងៃមុខទៀត។*

---

[២១៧] ករណីនេះត្រូវបានសង្កេតដោយក្រុមការងារលើកកម្ពស់ការសម្រុះសម្រួល។ អត្តសញ្ញាណរបស់ភាគីមិនត្រូវបានបញ្ចេញឡើយ ដើម្បីជាប្រយោជន៍ដល់ជីវិតឯកជនរបស់ភាគី។

ក្នុងការដោះស្រាយវិវាទ វាហាក់ដូចជាមានការលំបាកសម្រាប់គណៈកម្មការសុរិយោដី ក្នុងការជំនះលើវិសមភាពផ្នែកសេដ្ឋកិច្ចរវាងគូភាគី។ យោងតាមបទសម្ភាសន៍បានបង្ហាញថា រឿងក្តីដែលបានដោះស្រាយដោយគណៈកម្មការសុរិយោដីស្ទើរតែទាំងអស់ គឺជាវិវាទរវាងអ្នកភូមិគ្នាឯង គឺមិនមែនជាវិវាទដែលកើតឡើងរវាងអ្នកភូមិ និងភាគីអ្នកមានអំណាចទេ[២១៨]។

ការលំបាកធ្ងន់ធ្ងរមួយទៀតសម្រាប់មន្ត្រីគណៈកម្មការសុរិយោដី គឺការបណ្តេញចេញដោយបង្ខំឬវិវាទដីធ្លី ដែលមានកើតចេញពីការធ្វើសម្បទានលើដី ដែលប្រជាពលរដ្ឋកំពុងរស់នៅជាយូរមកហើយ ដោយសារតែសម្បទានដីធ្លី ត្រូវបានផ្តល់ជូនដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ហើយមន្ត្រីនៃគណៈកម្មការសុរិយោដីជាមន្ត្រីមានឋានៈទាបជាង និងមិនហ៊ានតទល់នឹងសេចក្តីសម្រេចខាងនយោបាយរបស់រដ្ឋាភិបាលទេ។

គណៈកម្មការសុរិយោដី មិនមានការកំណត់ពេលច្បាស់លាស់ ក្នុងការចេញសេចក្តីសម្រេច ឬការសម្រុះសម្រួលឡើយ។ ការដែលមានពេលវេលាច្បាស់លាស់ នឹងធ្វើឱ្យគណៈកម្មការនេះបំពេញការងារកាន់តែមានប្រសិទ្ធិភាព និងជំនឿទុកចិត្តពីពលរដ្ឋថែមទៀត។ ភាពយឺតយ៉ាវខាងនីតិវិធីអាចត្រូវគេមើលឃើញថា ជាការបដិសេធយុត្តិធម៌ ដោយសារគូភាគីមិនអាចដឹងថារឿងក្តីនឹងត្រូវបានដោះស្រាយនៅថ្ងៃណាឡើយ។ រឿងក្តីទាំងអស់ដែលបានបញ្ជូនទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបង្វិលមកឱ្យថ្នាក់ស្រុក ឬថ្នាក់ខេត្តវិញ ដោយគ្មានការសម្រេចអ្វីទាំងអស់។ ស្ថានភាពនៃការពន្យារពេលនេះ អាចជះឥទ្ធិពលកាន់តែអាក្រក់សម្រាប់ភាគីខ្លះ នៅពេលភាគីម្ខាងមានវិធានការបន្តសកម្មភាព ដែលអាចបង្កការខូចខាតដល់អចលនវត្ថុដូចជាការកាប់ឆ្ការព្រៃជាដើម។

នៅតាមខេត្តមួយចំនួនដែលក្រុមសិក្សាស្រាវជ្រាវ បានទៅដល់គណៈកម្មការសុរិយោដីមិនមានសមត្ថភាព ក្នុងការដោះស្រាយរឿងវិវាទដីធ្លីសំខាន់ៗ និងធ្ងន់ធ្ងរទាក់ទងនឹងដីធ្លីមិនទាន់ចុះបញ្ជីទេ ជាពិសេសនៅពេលដែលមានការពាក់ព័ន្ធនឹងភាគីមានអំណាច ដូចជាសម្បទានិក យោធា មន្ត្រីជាន់ខ្ពស់ និងអ្នកមានទ្រព្យសម្បត្តិជាដើម។

ស្ថានភាពនេះមានភស្តុតាងបញ្ជាក់កាន់តែច្បាស់ថែមទៀត នៅក្នុងខេត្តដែលមានប្រជាពលរដ្ឋជនជាតិដើមភាគតិចរស់នៅ។ ការទន្ទ្រានយកដីសមូហភាព ដោយអ្នកមកពីខាងក្រៅត្រូវបានហាមឃាត់ដោយច្បាប់។ តែទោះជាយ៉ាងនេះក្តីមានរឿងក្តីការទន្ទ្រានយកដីសមូហភាព ដោយអ្នកខាងក្រៅដោយខុសច្បាប់តាមច្រើនរូបភាព។ រឿងក្តីប្រភេទនេះទាំងអស់កំពុងរង់ចាំការ ដោះស្រាយនៅមុខគណៈកម្មការសុរិយោដី។ ក្នុងខេត្តរតនៈគិរី ក្នុងចំណោមរឿងក្តីចំនួន ៤៦ករណី មានតែមួយករណីប៉ុណ្ណោះ ដែលត្រូវបានដោះស្រាយរួច ដោយឡែកនៅខេត្តមណ្ឌលគិរី មានមួយករណីលើ ១០ករណី ដែលត្រូវបានដោះស្រាយរួចដែរ។

### ២.៦.៣. ការចាយតម្លៃ

ប្រជាពលរដ្ឋដែលបានធ្វើបទសម្ភាសន៍ ក្នុងការស្ទង់មតិរបស់ *IRL* បានផ្តល់ចម្លើយទាក់ទងនឹងគណៈកម្មការសុរិយោដីដូចមានខាងក្រោម:

[២១៨] ព័ត៌មាននេះត្រូវបានបញ្ជាក់បន្ថែមដោយ លោក Gorge Cooper និងលោកស្រី Patricia Baars ធ្វើការឱ្យអង្គការ ជី ធី ហ្សេត នៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។




## វាយតំលៃយន្តការដោះស្រាយវិវាទក្រៅតុលាការ

ការវាយតំលៃគណៈកម្មការសុរិយោដី

**ជាវិជ្ជមាន :**

- គណៈកម្មការសុរិយោដីមានគុណសម្បត្តិល្អ ត្រឹមតែការចំណាយ និង ប្រើពេលវេលាតិចជាង ធៀបនឹងការចំណាយ និងពេលវេលានៅតុលាការ ។

**ជាអវិជ្ជមាន :**

- គណៈកម្មការសុរិយោដីត្រូវបានមើលឃើញថាមានភាពអវិជ្ជមានដែរ ដែលជាពិសេសគឺលើក ឡើងដោយអតិថិជនដែលបានទៅរកពួកគេអោយជួយដោះស្រាយដោយផ្ទាល់ ។
- ការទៅរកគណៈកម្មការសុរិយោដីគឺមានតិចជាងតុលាការឬប៉ូលិស និង ការទៅរកអាជ្ញាធរឃុំ-សង្កាត់ ។ មាន១ ក្នុងចំណោមស្ត្រី ២០នាក់ និងជនជាតិភាគតិច ដែលធ្លាប់ប្រើប្រាស់គណៈកម្មការសុរិយោដី ។
- ជាងនេះទៅទៀត គឺមានកំរិតនៃការពេញចិត្តទាបនៅឡើយ ។
- គណៈកម្មការសុរិយោដីត្រូវបានគេដឹងថាមិនមានភាពយុត្តិធម៌ទេ និងពុករលួយថែមទៀតផង ។
- លើសពីនេះទៅទៀត អតិថិជនទាំងនោះនិយាយថាបុគ្គលិកសុរិយោដីក៏ពុករលួយដែរ ធ្វើអោយពួកគេមិនពេញចិត្តជាមួយនឹងលទ្ធផលដែលរឿងក្ដីរបស់ពួកគេ ហើយ និងទំនាក់ទំនងរបស់ពួកគេជាមួយនិងគូប្រឆាំងពេលបច្ចុប្បន្នកាន់តែតានតឹងជាងមុនទៅទៀត ។

Page 15

UNDP

អ្នកចូលរួមនៃសិក្ខាសាលានៅថ្នាក់មូលដ្ឋាន និងវេទិកាជាតិស្តីពីសិទ្ធិទទួលបានយុត្តិធម៌ បានលើកឡើងនូវមតិដូចខាងក្រោមនេះ ទាក់ទិននឹងការងាររបស់គណៈកម្មការសុរិយោដី :

| | ចំណុចល្អ | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|---|
| | - បណ្តឹងធ្វើដោយឥតគិតថ្លៃ<br>- ចំណាយតិច និងជិតសម្រាប់ប្រជាពលរដ្ឋ (ថ្នាក់ស្រុក)<br>- សម្រុះសម្រួលដោយមិត្តភាព និងរក្សានូវទំនាក់ទំនងល្អរវាងគូភាគី<br>- ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិរបស់គូភាគីក្នុងការឈានទៅរកការព្រមព្រៀងគ្នា<br>- អនុវត្តតាមច្បាប់<br>- ស៊ើបអង្កេត និងប្រមូលភស្តុតាងមុនពេលដោះស្រាយរឿងក្តី<br>- ការដោះស្រាយធ្វើឡើងនៅទីកន្លែងវិវាទ | - បក្សពួកនិយម និងអំពើពុករលួយ<br>- ដំណោះស្រាយមានព្រំដែនកំណត់ ពីព្រោះគណៈកម្មការមិនអាចកាត់សេចក្តីបាន<br>- ពិបាកខ្លាំងណាស់សម្រាប់គណៈកម្មការក្នុងការដោះស្រាយប្រសិនបើភាគីមួយជាអ្នកមាន ឬអ្នកមានអំណាច<br>- កង្វះនីតិវិធី<br>- ប្រើពេលវេលាវែង និងមានតម្លៃខ្ពស់<br>- ខ្វះខាតធនធានមនុស្ស ហិរញ្ញវត្ថុ និងសំភារៈសម្រាប់ធ្វើបំពេញការងារ<br>- ប្រជាពលរដ្ឋមិនចង់ចូលរួម ដោយសារ គាត់មិនបានយល់ពីនីតិវិធី<br>- មិនមានដំណើរការល្អលើការវាស់វែងដីធ្លី | - សុំឱ្យមានសិទ្ធិធ្វើសេចក្តីសម្រេចនៅថ្នាក់ស្រុក<br>- ផ្សព្វផ្សាយនីតិវិធីដល់ប្រជាពលរដ្ឋអំពីគណៈកម្មការនៅតាមមូលដ្ឋាន<br>- បណ្តុះបណ្តាលបន្ថែមដល់មន្ត្រីគណៈកម្មការសុរិយោដី<br>- បង្កើនធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ និងកែលំអនីតិវិធី<br>- អន្តរាគមន៍ភ្លាមៗពីថ្នាក់ជាតិក្នុងករណីវិវាទជាមួយក្រុមហ៊ុនសម្បទាន<br>- លុបបំបាត់បក្សពួកនិយម និងអំពើពុករលួយ<br>- ដំណោះស្រាយគួរតែធ្វើឡើងលឿនជាងមុន<br>- គណៈកម្មការសុរិយោដីខេត្តគួរតែចេញប័ណ្ណកម្មសិទ្ធិសម្រាប់ប្រជាពលរដ្ឋ |

ពុំមានពេលវេលាកំណត់ច្បាស់លាស់ៈ ដើមបណ្តឹងនិងចុងចម្លើយនៃករណីវិវាទរឿងក្តីមិនទាន់ចុះបញ្ជី មិនអាចប្តឹងទៅតុលាការបានទេ លើកលែងតែពួកគេបានព្យាយាមដោះស្រាយចប់សព្វគ្រប់ តាមនីតិវិធីរបស់គណៈកម្មការសុរិយោដីសិន។ តែដោយហេតុតែគណៈកម្មការនេះ ពុំមានក្របខ័ណ្ឌច្បាប់កំណត់ អំពីពេលវេលាដោះស្រាយច្បាស់លាស់ ហើយគណៈកម្មការសុរិយោដីថ្នាក់ជាតិមកទល់ពេលនេះ មិនទាន់បានសម្រេចជាស្ថាពរករណីណាមួយនៅឡើយទេនោះ ដូចនេះប្រជាពលរដ្ឋ និងសហគមន៍នានាមិនអាចទាមទារនូវសិទ្ធិ និងការការពារអចលនវត្ថុរបស់គេតាមផ្លូវតុលាការបានឡើយ។ តុលាការបានបញ្ជូនរឿងក្តី ទាក់ទិននឹងដីមិនទាន់ចុះបញ្ជីជាច្រើន មកគណៈកម្មការសុរិយោដីវិញ។ កង្វះនូវការកំណត់ពេលវេលាក្នុងការដោះស្រាយវិវាទនេះ គឺជាចំណុចខ្សោយរបស់គណៈកម្មការសុរិយោដី ដែលអាចចាត់ទុកថាជាការរំលោភលើសិទ្ធិរបស់ ប្រជាពលរដ្ឋ ដែលធានាដោយរដ្ឋធម្មនុញ្ញ ពោលគឺសិទ្ធិកម្មសិទ្ធិលើដីធ្លី ពីព្រោះបើមិនមានដំណោះស្រាយឬការដោះស្រាយ ពុំទាន់ពេលនោះភាគីម្ខាងទៀត ដែលមានសកម្មភាពខុសច្បាប់អាចបន្តសកម្មភាពខុសច្បាប់របស់ខ្លួន ក្នុងការកាប់បំផ្លាញអ្វីៗនៅលើដីវិវាទ មុននឹងដំណោះស្រាយត្រូវបានផ្តល់ជូនដល់ភាគី។

**បដិសេធមិនទទួលរឿងក្តី:** នៅទូទាំងប្រទេសករណីវិវាទដីធ្លី ដែលត្រូវបដិសេធដោយគណៈកម្មការសុរិយោដីជាមធ្យមគឺ ១០%។ តែនៅខេត្តខ្លះទៀត ចំនួនជាមធ្យមនេះអាចខ្ពស់ជាងអត្រានេះ ដែលចំនួនរឿងក្តីដែលបដិសេធ ខ្ពស់ជាងចំនួនដែលបានដោះស្រាយ។ នេះជាករណីនៅក្រុងភ្នំពេញ ដែលមានរហូតដល់ទៅ ៥៦ % នៃរឿងក្តីដែលបានប្តឹងមកគណៈកម្មការសុរិយោដីត្រូវបានបដិសេធ (៥២/៩២)។ នៅខេត្តកោះកុងរឿងក្តី ដែលត្រូវបដិសេធគឺ ៤០% (១១/២៧) និងខេត្តកំពង់ឆ្នាំងរឿងក្តីដែលត្រូវបានបដិសេធគឺ ២៧% (៥/១៨)។ ច្បាប់បានចែងថា ភាគីអាចតវ៉ាលើការបដិសេធរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ដោយប្តឹងទៅគណៈកម្មការនៅថ្នាក់ខេត្ត។ តែដោយសារតែពុំមានពេលវេលាកំណត់អំពីរយៈពេលដែលគណៈកម្មការនេះត្រូវឆ្លើយតបដោយសម្រេចឬបដិសេធ ហើយក៏ពុំមានបទបញ្ញត្តិចែងច្បាស់ អំពីសិទ្ធិប្តឹងទៅតុលាការលើការបដិសេធនេះនោះនាំឱ្យសិទ្ធិទទួលបានយុត្តិធម៌ ក្នុងការធ្វើម្ចាស់កម្មសិទ្ធិលើដីធ្លី និងសិទ្ធិផ្សេងៗទៀតរបស់គូភាគីអាចត្រូវបានគេបដិសេធនិងរំលោភ។

**ប្រើប្រាស់វិធានការព្រហ្មទណ្ឌ:** យោងតាមច្បាប់ភូមិបាល បើសិនជាមានការរំលោភលើសិទ្ធិកម្មសិទ្ធិលើដីធ្លីម្ចាស់អចលនៈវត្ថុនោះ អាចប្តឹងទាមទារទៅតុលាការជាករណីព្រហ្មទណ្ឌបាន។ ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុច្ចរិត ទោះបីជាមិនទាន់បានធ្វើប័ណ្ណ ឬការកាន់កាប់កំពុងមានទំនាស់ក៏ដោយ អាចឱ្យជនរងគ្រោះប្តឹងជាករណីព្រហ្មទណ្ឌបាន (មាត្រា ២៤៧ និង២៥៣)។ នៅក្នុងករណីជាច្រើន ជាពិសេសករណីដែលពាក់ព័ន្ធនឹងការរំលោភលើសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដីធ្លី ដូចជានាំឱ្យមានការដេញចេញដោយបង្ខំ ការកាប់បំផ្លាញព្រៃ និងការកាប់ឈើជាដើម។ ក្នុងការអនុវត្តជាក់ស្តែង តាមព័ត៌មានទទួលបានពីអ្នកចូលរួមក្នុងសិក្ខាសាលា បានឱ្យដឹងថាចៅក្រមបញ្ជូនពាក្យបណ្តឹងដីធ្លីមិនទាន់ចុះបញ្ជីទៅគណៈកម្មការសុរិយោដី។ ទោះជាយ៉ាងនេះក្តី ករណីវិវាទដីធ្លីមិនទាន់ចុះបញ្ជីជាច្រើន ត្រូវបានប្តឹងទៅតុលាការជាករណីព្រហ្មទណ្ឌ ដោយអ្នកមានអំណាច ឬអ្នកមានទ្រព្យសម្បត្តិច្រើនប្រឆាំងនឹងអ្នកភូមិទន់ខ្សោយ។

## ២.៧. ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ

### ២.៧.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ គឺជាយន្តការដែលបានបង្កើតឡើងដោយច្បាប់ សម្រាប់ដោះស្រាយវិវាទការងាររួម។ ច្បាប់ការងារ (ឆ្នាំ១៩៩៧) បានចែងពីការសម្រុះសម្រួល និងការដោះស្រាយដោយចេញសេចក្តីបង្គាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលថាជាយន្តការមានអាណត្តិដោះស្រាយវិវាទការងារ មុនពេលវិវាទត្រូវបានប្តឹងទៅតុលាការ។ ដូចនេះកម្មករ និងនិយោជកត្រូវព្យាយាមដោះស្រាយវិវាទ តាមរយៈយន្តការនេះជាមុនសិន មុននឹងប្តឹងទៅតុលាការ។

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាជំហានទីពីរនៃនីតិវិធី បន្ទាប់ពីការសម្រុះសម្រួលត្រូវបរាជ័យ (ច្បាប់ការងារ មាត្រា ៣០៩)។ នៅក្នុងជំហានទីពីរនេះ គូភាគីមានជម្រើស ៣: ក-បន្តធ្វើតាមនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរួម ប្រសិនបើមាននីតិវិធីបែបនេះ ខ-នីតិវិធីផ្សេងទៀតដែលបានព្រមព្រៀងដោយភាគីនៃវិវាទ ឬ គ-នីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលបានកំណត់នៅក្នុងច្បាប់។

ប្រសិនបើគូភាគីជ្រើសរើសយកនីតិវិធីដែលបានកំណត់ដោយច្បាប់ ពួកគេត្រូវជ្រើសរើសសមាជិកអាជ្ញាកណ្តាលចេញពីបញ្ជីដែលបានផ្តល់ដោយក្រសួង។ អ្នកទាំងនោះគឺជាមនុស្សដែលមានកិត្តិយស។ អាជ្ញាកណ្តាលគួរតែធ្វើតាមគោលការណ៍សមធម៌ ជំនាញ និងរក្សាការសម្ងាត់។

ច្បាប់ការងារបានចែងកំណត់ច្បាស់លាស់ នូវពេលវេលាក្នុងការដោះស្រាយរឿងក្តី។ អាជ្ញាកណ្តាលមានរយៈពេល ១៥ថ្ងៃ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន។ គូភាគីអាចជ្រើសរើស ថាតើពួកគេចង់បានសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ឬមិនជាប់កាតព្វកិច្ច។ ប្រសិនបើគូភាគីបានជ្រើសរើសយកជំរើសជាប់កាតព្វកិច្ច នោះពួកគេមានរយៈពេល ៨ថ្ងៃ ក្នុងការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់អាជ្ញាកណ្តាល។ ប្រសិនបើសេចក្តីបង្គាប់មិនត្រូវបានគេប្តឹងឧទ្ធរណ៍ ដោយភាគីណាមួយទេ វានឹងត្រូវតែដាក់ឱ្យអនុវត្តភ្លាម ( មាត្រា ៣១៤ )។ ករណីជាប់កាតព្វកិច្ចនេះដែរ បើសិនជាមានភាគីណាមួយមិនព្រមគោរពតាម នោះភាគីម្ខាងទៀតអាចប្តឹងទៅតុលាការ ដើម្បីអនុវត្តសេចក្តីបង្គាប់នេះបាន។ នៅតុលាការ ភាគីអាចប្តឹងបដិសេធមិនទទួលស្គាល់សេចក្តីបង្គាប់បាន លុះណាតែមានអំណះអំណាងបញ្ជាក់ថា សេចក្តីបង្គាប់នោះពិតជាមិនសុក្រិត ដោយផ្អែកលើមូលដ្ឋានច្បាប់ជាគោល។ ច្បាប់ការងារបានធានាថាការសម្រុះសម្រួល និងការសម្រេចដោយសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវធ្វើឡើងដោយឥតមានបង់ថ្លៃទេ ( មាត្រា ៣១៦ )។

**តារាង៖ មូលដ្ឋានច្បាប់**

| | ច្បាប់ការងារ ( ឆ្នាំ ១៩៩៧ ) |
|---|---|
| វិវាទបុគ្គល | មាត្រា ៣០០ : វិវាទបុគ្គល គឺជាវិវាទដែលកើតមានឡើងរវាង និយោជក និងកម្មករ និយោជិតម្នាក់ ឬច្រើននាក់ ឬអ្នករៀនធ្វើការម្នាក់ ឬច្រើននាក់តាមរឿងរៀង១ខ្លួន ហើយទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាហ្វឹកហ្វឺនកម្មករនិយោជិត ឬបទប្បញ្ញត្តិការងារនៃអនុសញ្ញារួមព្រមទាំងច្បាប់បញ្ញត្តិជាធរមានផង។ មុននឹងប្តឹងទៅតុលាការ គ្រប់រឿងវិវាទបុគ្គលអាចឱ្យភាគីណាមួយផ្តើមគំនិតនាំយកទៅប្តឹងអធិការការងារនៃខេត្ត ក្រុងខ្លួនឱ្យធ្វើការផ្សះផ្សាជាមុនសិន។<br><br>មាត្រា ៣០១ : ការព្រមព្រៀង ដែលបានធ្វើឡើងនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់។ ក្នុងករណីដែលគ្មានការសះជានឹងគ្នា សាមីភាគីអាចប្តឹងទៅសាលាក្តី មានសមត្ថកិច្ចនៅក្នុងរយៈពេល ២ខែ ពុំនោះទេសិទ្ធិប្តឹងនេះ នឹងត្រូវផុតកំណត់។ |
| វិវាទរួម : ដំណាក់កាលសម្រុះសម្រួល | មាត្រា ៣០២ : វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ និងបុគ្គលិករបស់ខ្លួនមួយចំនួនអំពីរឿងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយការវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម។<br><br>មាត្រា ៣០៣ : បើក្នុងអនុសញ្ញាគ្មានបានគ្រោងនីតិវិធីសម្រាប់ដោះស្រាយទេ ភាគីត្រូវជូនដំណឹងអំពីវិវាទការងាររួមទៅអធិការកិច្ចការងារនៃខេត្ត ក្រុងខ្លួន។ ប៉ុន្តែចំពោះវិវាទការងាររួមដែលភាគីពុំបានឱ្យដំណឹងមកខ្លួនទេនោះ អធិការការងារអាចចាត់ការផ្សះផ្សាតាមនីតិវិធី ដែលមានបញ្ញត្តិទុកក្រោយពីបានដំណឹងអំពីវិវាទនោះភ្លាម។<br><br>មាត្រា ៣០៤ : រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ចាត់តាំងអ្នកផ្សះផ្សាម្នាក់ ក្នុងរយៈពេលសែសិបប្រាំបីម៉ោង គិតចាប់ពីពេលបានទទួលពាក្យបណ្តឹង ឬបានដឹងដោយខ្លួនឯងពីវិវាទការងាររួម។<br><br>មាត្រា ៣០៧ : ការព្រមព្រៀងសះជាដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សាមានតម្លៃ និងអានុភាពដូចគ្នានឹងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលឱ្យគេតំណាងខ្លួន។ |

| | |
|---|---|
| | ប៉ុន្តែប្រសិនបើភាគីភាគីតំណាងកម្មករនិយោជិត ពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀងនេះមិនជាប់កាតព្វកិច្ច ទាំងចំពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលឱ្យគេតំណាងខ្លួន ។ |
| វិវាទរួមៈ ដំណាក់កាលអាជ្ញាកណ្តាល | មាត្រា ៣០៩ : ក្នុងករណីដែលការផ្សះផ្សាពុំបានសះជា វិវាទការងារត្រូវដាក់ឱ្យដោះស្រាយតាម :<br>ក- ឬមួយនីតិវិធីដែលមានចែងក្នុងអនុសញ្ញារួមអំពីអាជ្ញាកណ្តាល ប្រសិនបើមាន<br>ខ- ឬមួយនីតិវិធីផ្សេងទៀតដែលមានការយល់ព្រមពីភាគីទាំងអស់នៃវិវាទ<br>គ- ឬមួយក៏នីតិវិធីអំពីអាជ្ញាកណ្តាលដែលមានចែងក្នុងផ្នែកនេះ ។ |
| សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ | មាត្រា ៣១១ : សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវជ្រើសរើសក្នុងចំណោមចៅក្រម សមាជិកនៃគណៈកម្មការប្រឹក្សាការងារ ហើយនិងជាទូទៅបណ្តាសស្បុរជនដែលគេស្គាល់ថាមានគុណសម្បត្តិខាងផ្លូវចរិយា និងមានសមត្ថភាពខាងសេដ្ឋកិច្ច និងសង្គមកិច្ច ហើយមាននាមក្នុងបញ្ជីតែងតាំងរៀងរាល់ឆ្នាំដោយប្រកាស ក្រសួងទទួលបន្ទុកវិស័យការងារ ។ |
| ភារកិច្ច | មាត្រា ៣១២ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ ។<br><br>ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬអនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះ ដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់ ។<br><br>ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានអំណាចទូលាយដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ច នៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួន ក្នុងការវិវាទ ។<br><br>ក្រុមប្រឹក្សានេះមានអំណាចអង្កេតបានគ្រប់យ៉ាង នៅទីកន្លែងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចមានអំណាចចាត់ឱ្យគូភាគីជូនឯកសារ ឬពត៌មានខាងសេដ្ឋកិច្ច គណនេយ្យស្ថិតិហិរញ្ញវត្ថុ ឬរដ្ឋបាលដែលមានប្រយោជន៍ ក្នុងការបំពេញបេសកកម្មខ្លួន ។ ក្រុមប្រឹក្សានេះអាចសុំឱ្យអ្នកជំនាញការជួយបានទៀតផង ។<br><br>សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និងឯកសារទាំងឡាយ ដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មខ្លួន ។<br>ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែប្រព្រឹត្តទៅដោយបិទទ្វារ ។ |
| នីតិវិធី | មាត្រា ៣១៣ : ក្នុងរយៈពេល ដប់ប្រាំថ្ងៃ រាប់ពីថ្ងៃដែលខ្លួនបានទទួលសំណុំរឿង ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបញ្ជូនសេចក្តីសម្រេចរបស់ខ្លួនទៅ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារហើយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារចាត់ការឱ្យដំណឹងទៅភាគីភ្លាម ។ ភាគីមានសិទ្ធិប្តឹងជំទាស់នឹងដំណោះស្រាយរបស់អាជ្ញាកណ្តាលនេះ ដោយជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារតាមសំបុត្រអនុសិដ្ឋ ឬតាមមធ្យោបាយដែលទុកជាបានការផ្សេងទៀត ក្នុងរយៈពេលប្រាំបីថ្ងៃពេញចាប់ពីថ្ងៃទទួលដំណឹង ។ |

| | |
|---|---|
| | មាត្រា ៣១៤ : សេចក្តីសន្និដ្ឋាននៃដំណោះស្រាយរបស់អាជ្ញាកណ្តាល ដែលគ្មានភាគីណាប្តឹងជំទាស់ទេ អាចយកទៅអនុវត្តបានភ្លាម ។<br>ដំណោះស្រាយរបស់អាជ្ញាកណ្តាល ដែលអាចយកទៅអនុវត្តបានហើយត្រូវតម្កល់ទុក និងចុះបញ្ជីកាទៅតាមបែបបទដូចគ្នានឹងអនុសញ្ញារួមដែរ ។<br>មាត្រា ៣១៥ : កំណត់ហេតុព្រមព្រៀងសះជា និងដំណោះស្រាយរបស់អាជ្ញាកណ្តាល ដែលគ្មាននរណាប្តឹងជំទាស់ទេនោះ ត្រូវបិទផ្សាយក្នុងទីស្ថានទាំងឡាយនៃសហគ្រាស ដែលមានកើតវិវាទ និងក្នុងការិយាល័យនៃអធិការដ្ឋានការងារនៃខេត្ត ក្រុង ។<br>មាត្រា ៣១៦ : នីតិវិធីនៃការផ្សះផ្សា និងអាជ្ញាកណ្តាលត្រូវធ្វើដោយឥតគិតថ្លៃ ។ |
| **ប្រកាស** | **បទបញ្ញត្តិនីតិវិធីទាក់ទិនការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល** |
| បទបញ្ញត្តិ | - ប្រកាស លេខ ៣១៨ (២០០១) ស្តីពីនីតិវិធីដោះស្រាយវិវាទបុគ្គល<br>- ប្រកាស លេខ ៣១៧ (២០០១) ស្តីពីនីតិវិធីដោះស្រាយវិវាទការងាររួម |
| ដែលមិននិយាយភាសាខ្មែរ | - ប្រកាស លេខ ៣១៧ (២០០២) ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល<br>មាត្រា ៣២ : ក្រុមអាជ្ញាកណ្តាលត្រូវសម្រេចសេចក្តី លើវិវាទការងាររួមដែលដាក់មកខ្លួនដោយយោងទៅតាមមាត្រា៣០៩ កថាខ័ណ្ឌ គ នៃច្បាប់ស្តីពីការងារ ។<br>មាត្រា ៣៣ : អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណា ទៅលើវិវាទមួយត្រូវកម្រិតត្រឹមតែបញ្ហាទាំងឡាយណា ដែលមានក្នុងកំណត់ហេតុផ្សះផ្សាមិនសះជា រួមទាំងបញ្ហាជាផលពិបាកផ្ទាល់នៃវិវាទនោះ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ ។<br>មាត្រា ៣៦ : ក្រុមអាជ្ញាកណ្តាល ត្រូវព្យាយាមឱ្យបានសម្លេងឯកច្ឆន្ទ ក្នុងការសម្រេចសេចក្តីរបស់ខ្លួន ។ ប្រសិនបើសម្លេងឯកច្ឆន្ទមិនអាចរកបានទេ ក្រុមអាជ្ញាកណ្តាលត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនតាមភាគច្រើន ។<br>មាត្រា ៤៩ : ក្នុងករណីដែលអាជ្ញាកណ្តាលមិនអាចនិយាយភាសាខ្មែរ ស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ដែលស្នើឈ្មោះអាជ្ញាកណ្តាលរូបនេះជាអ្នកទទួលខុសត្រូវចំពោះតាមការចំណាយសមស្របទៅលើការបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ ។ |
| | **សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ (ស្ថានភាព ឆ្នាំ ២០០៥)** |
| សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំតុលាការ | មាត្រា ១ : នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតែស្ថាប័នតុលាការទេដែលមានសិទ្ធិសម្រេចយុត្តិធម៌ ដោយមានសមត្ថកិច្ចសម្រេចលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។ តុលាការរួមមាន:<br>- តុលាការកំពូល<br>- សាលាឧទ្ធរណ៍<br>- តុលាការជាន់ដំបូង<br>- តុលាការពិសេស |

| | |
|---|---|
| | មាត្រា២០ : សាលាឧទ្ធរណ៍មានសមត្ថកិច្ចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងតវ៉ាបដិសេធសេចក្តីសម្រេចរបស់អាជ្ញាកណ្តាល ។<br><br>សាលាឧទ្ធរណ៍ក៏មានសមត្ថកិច្ចសម្រេច លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចរបស់តុលាការ ដែលបដិសេធមិនផ្តល់ឱកាសដល់សេចក្តីសម្រេច ដែលធ្វើឡើងដោយអាជ្ញាកណ្តាលផងដែរ ។<br><br>មាត្រា ៤៨ : គ្រប់តុលាការជាន់ទាបទាំងអស់ ត្រូវមានតុលាការការងារមួយស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ដើម្បីសម្រេចវិវាទបុគ្គលរវាងនិយោជិត និងនិយោជកនៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាការងារ ។<br><br>តុលាការការងារក៏មានសមត្ថកិច្ចសម្រេចពីនីត្យានុកូលភាពនៃការធ្វើកុបកម្មផងដែរ ។<br><br>តុលាការការងារមានសមត្ថកិច្ចដោះស្រាយវិវាទ ដែលកើតឡើងក្នុងពេលអនុវត្តមាត្រានៃច្បាប់ ការងារពីសិទ្ធិបង្កើតសហជីព ។<br><br>មាត្រា ៥០ : នីតិវិធីបណ្តឹងចំពោះមុខតុលាការការងារ មិនមានការបង់ថ្លៃទេ ។ |

ក្របខ័ណ្ឌស្ថាប័ន

ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ ត្រូវបានបង្កើតឡើងនៅភ្នំពេញ ហើយមានដែនសមត្ថកិច្ចគ្របដណ្តប់លើវិវាទការងាររួមទាំងអស់នៅទូទាំងប្រទេស ។ ក្រុមប្រឹក្សានេះអាចរៀបចំឱ្យមានការដោះស្រាយវិវាទ នៅតាមខេត្តនានាដែលចាំបាច់ ។ និងរាប់ទាំងការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីកម្មវិធីអង្គការការងារអន្តរជាតិ (ILO) ។ អង្គការ ILO បានបណ្តុះបណ្តាលអាជ្ញាកណ្តាល ដែលមានសក្តានុពលខ្ពស់បច្ចេកទេស ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ក៏ដូចជាច្បាប់ការងារផងដែរ ។

ចំនួន និងសមត្ថភាពរបស់អាជ្ញាកណ្តាល

នៅក្នុងឆ្នាំ ២០០៤ មានអាជ្ញាកណ្តាល ២៧រូប ដែលត្រូវបានតែងតាំងក្នុងបញ្ជី ដែលចេញដោយក្រសួង ។ ពួកគេត្រូវបានជ្រើសរើសដោយក្រសួង (៩រូប) សហជីព (៩រូប) និង៩រូបទៀតដោយសមាគមនិយោជក ។ ពួកគេមានអាយុចាប់ពី ២៨ ដល់ ៦៧ឆ្នាំ ភាគច្រើនជាមនុស្សនៅក្មេងតែមានបទពិសោធន៍ ។ ទាំងអស់គ្នាមានសញ្ញាប័ត្រ ឬបរិញ្ញាប័ត្រច្បាប់ ឬសញ្ញាប័ត្រប្រហាក់ប្រហែល ។ ច្រើនជាងពាក់កណ្តាល (៥១.៨១%) មានសញ្ញាប័ត្រអនុបណ្ឌិត ឬ/និង បណ្ឌិតឬជាបេក្ខជនកំពុងរៀនយកបណ្ឌិត ។ ២៤រូប ជាជនជាតិខ្មែរ ១រូប ជាជនជាតិអង់គ្លេស និង ២រូបមានសញ្ជាតិពីរ ។ បច្ចុប្បន្នពួកគេធ្វើការជាទីប្រឹក្សាច្បាប់ នាយកមជ្ឈមណ្ឌល និងសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ ។ បើប្រៀបធៀបនឹងតួអង្គប្រតិបត្តិ នៃប្រព័ន្ធដទៃទៀត អាជ្ញាកណ្តាលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារមានការអប់រំខ្ពស់ជាងគេ ។

ពួកគេមិនមានប្រាក់បៀវត្សរ៍ទេ ប៉ុន្តែ ILO បានផ្តល់ប្រាក់ឧបត្ថម្ភដល់អាជ្ញាកណ្តាលក្នុងម្នាក់ ១០០ ដុល្លារអាមេរិកសម្រាប់ការដោះស្រាយរឿងក្តីមួយ ។ បើប្រៀបធៀបជាមួយនឹងតួអង្គប្រតិបត្តិដទៃ អាជ្ញាកណ្តាលទទួលបានប្រាក់ចំណូលខ្ពស់ជាងគេ ។ អ្វីដែលគួរឱ្យបារម្ភគឺនិរន្តរភាពរបស់ក្រុមប្រឹក្សានេះ ។ ដោយសារច្បាប់ធានា ក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្តល់សេវានេះដោយឥតគិតថ្លៃ ប៉ុន្តែមិនមានថវិកាបែងចែកដោយរដ្ឋ សម្រាប់គ្រប់គ្រងលើដំណើរការក្រុមប្រឹក្សាទេបច្ចុប្បន្ននេះទេ ។ នេះជាបញ្ហាដែលត្រូវដោះស្រាយ ។

តារាង: ប្រវត្តិរូបរបស់អាជ្ញាកណ្តាល

| អាយុ | សញ្ជាតិ | ការអប់រំ | តួនាទីបច្ចុប្បន្ន |
|---|---|---|---|
| ឆ្នាំកំណើត<br>១៩៣៨-១៩៧៧<br>អាយុ ៦៧- ២៨ | - ១ ជនជាតិអង់គ្លេស<br>- ១ ខ្មែរ-បារាំង<br>- ១ ខ្មែរ-នូវែលហ្សេឡង់<br>- ២៤ ខ្មែរ | - ១៣ មានបរិញ្ញាប័ត្រច្បាប់ ឬប្រហាក់ប្រហែល<br>- ១០ អនុបណ្ឌិត<br>- ១ បណ្ឌិតសេដ្ឋកិច្ច<br>- ៣បេក្ខជនបណ្ឌិត និងអនុបណ្ឌិត | - ទីប្រឹក្សាច្បាប់<br>- PMU-ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌<br>- អង្គការក្រៅរដ្ឋាភិបាល<br>- អង្គការអន្តរជាតិ |

## ២.៧.២. តម្រូវការយុត្តិធម៌នៅចំពោះមុខគណៈកម្មការសុរិយោដី

តម្រូវការយុត្តិធម៌ក្នុងសង្គមពីក្រុមប្រឹក្សាអាជ្ញាកណ្តាល មានការកើនឡើងនៅក្នុងឆ្នាំ ២០០៤ បើធៀប នឹងចំនួនរឿងក្តីទទួលបាននៅក្នុងឆ្នាំ ២០០៣។ នៅក្នុងឆ្នាំ ២០០៣ ក្រុមប្រឹក្សាអាជ្ញា កណ្តាលបានទទួលរឿងក្តីចំនួន ៣១ ករណី តែនៅឆ្នាំ ២០០៤ រឿងក្តីកើនដល់ ១១៤ ករណី។ ៣ ភាគ ៤ នៃរឿងក្តីទទួលបាននៅក្រុងភ្នំពេញ (៧៨.៦៣%)។ មានតែ ២១ % នៃពាក្យបណ្តឹងប៉ុណ្ណោះដែលប្តឹងមកពីខេត្តចំនួន ៦ ផ្សេងៗទៀត។ មានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្របដណ្តប់តែ ១ភាគ៣ (១/៣) នៃប្រទេសប៉ុណ្ណោះ ដូចនេះចាំបាច់ត្រូវតែពង្រីក ក្រុមប្រឹក្សានេះឱ្យបានទូលាយថែមទៀតនៅខេត្តមួយចំនួន។

នៅក្នុងខេត្តដទៃទៀត ដូចជាខេត្តកំពង់ចាម មណ្ឌលគិរី រតនៈគិរី និងខេត្តបាត់ដំបង មានក្រុមហ៊ុនជាច្រើន ដែលមានចំនួនកម្មករច្រើនគួរឱ្យកត់សំគាល់ ដែលកំពុងតែបំរើការងារនៅតាមក្រុមហ៊ុននានា ដូចជា ចំការកៅស៊ូ ចំការស្វាយចន្ទី រោងម៉ាស៊ីនកិនស្រូវ សណ្ឋាគារ និងកាស៊ីណូជាដើម។

**តារាង: រឿងក្តីដែលបានដោះស្រាយដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ (២០០៣-២០០៤)**

**គិតតាមទីកន្លែងនីមួយៗ**

| ឆ្នាំ | រឿងក្តី | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភ្នំពេញ = ១១៤/១៤៥ (៧៨.៦២%) | | | | | | | | ខេត្ត = ៣១/១៤៥ (២១,៣៨%) | | | | | |
| | សរុប | ៧ មករា | ចំការមន | ដង្កោ | ដូនពេញ | មានជ័យ | ឫស្សីកែវ | ទួលគោក | កំពង់ឆ្នាំង | កំពង់ស្ពឺ | កណ្តាល | សៀមរាប | ក្រុងព្រះសីហនុ | សៀមរាប |
| ២០០៣ | ៣១ | ០ | ០ | ៣ | ២ | ៧ | ៩ | ៥ | ០ | ១ | ៣ | ១ | ០ | ០ |
| ២០០៤ | ១១៤ | ០ | ០ | ២៦ | ៧ | ១៦ | ៣១ | ៨ | ២ | ០ | ២២ | ១ | ០ | ១ |
| សរុប | ១៤៥ | ០ | ០ | ២៩ | ៩ | ២៣ | ៤០ | ១៣ | ២ | ១ | ២៥ | ២ | ០ | ១ |

**ប្រចាំខែ (គិតតាមខែនីមួយៗ)**

| ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០០៣ | | | | | ៣ | ៧ | ២ | ០ | ២ | ៥ | ៤ | ៨ | ៣១ |
| ២០០៤ | ៤ | ៥ | ៨ | ៤ | ១៥ | ១៣ | ១២ | ១៤ | ៩ | ៧ | ១១ | ១២ | ១១៤ |
| ២០០៥ | ៦ | ១ | ១៤ | ៥ | ៦ | ៥ | | | | | | | ៣៧ |
| | | | | | | | | | | | | | ១៨២ |

តួនាទីដោះស្រាយវិវាទ

វិវាទរួមបានកើតមានឡើងកាន់តែញឹកញាប់ ប៉ុន្តែដើម្បីឈានទៅដល់យន្តការនេះ កម្មករត្រូវចូលរួមសហជីព។ ភាគច្រើនសហជីពត្រូវបានរៀបចំឡើងនៅកន្លែង ដែលមានរោងចក្រនៅជុំវិញភ្នំពេញ និងទីក្រុងទេសចរណ៍ដទៃទៀត។ នៅក្នុងរោងចក្រ ឬក្នុងក្រុមហ៊ុននៅតាមតំបន់ជនបទមានសហជីពតិចជាង ហើយកម្មករមិនបានយល់ដឹងពីសិទ្ធិរបស់ពួកគេទេ។ ហេតុដូច្នេះភាគច្រើននៃវិវាទ ដែលបានទទួលដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ គឺចេញមកពីភ្នំពេញ ក៏ដូចជាទីប្រជុំជនដទៃទៀតដែរ។

មានការកើនឡើងគួរឱ្យកត់សំគាល់នូវរឿងក្តី ដែលទទួលបានចាប់តាំងពីការបង្កើតមកនៅក្នុងឆ្នាំ ២០០៣ រហូតមកដល់ឥឡូវនេះ។ នៅក្នុងឆ្នាំ ២០០៣ ទទួលបានរឿងក្តី ៣១ករណី នៅពេលដែលក្នុងឆ្នាំ ២០០៤ ទទួលបាន ១១៤ ដែលមានន័យថាកើនលើសមុនចំនួន ៤ដង។ រឿងក្តីភាគច្រើនប្តឹងចេញពីក្រុងភ្នំពេញ និងខេត្តចំនួន ៦ ទៀត ដែលគ្របដណ្តប់ត្រឹម ២៥%នៃខេត្តទាំងអស់[២១៩]។

ក្នុងចំណោមរឿងក្តីទាំងអស់ដែលបានទទួលក្នុងឆ្នាំ ២០០៣ និង ២០០៤ មាន ៤៨/១៤៥ ករណី (៣៣.១០%) ដែលមានការព្រមព្រៀង ដោយដំណាក់កាលទីមួយនៃការសម្រុះសម្រួល និងស្ទើរតែពីរដង (៩៧/១៤៥) មានសេចក្តីបង្គាប់ត្រូវជាពីរភាគបីនៃរឿងក្តីសរុប ដែលបានទទួលដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ (៦៦.៨៩%) នៅក្នុងចំណោមសេចក្តីបង្គាប់ទាំងនេះមានចំនួន ៥៤ ករណីដែលបដិសេធចំពោះដោយភាគី ដែលត្រូវជា៨០%។ ក្នុងចំណោមយការបដិសេធទាំងនេះមានចំនួន ៤៣ ករណី (៤៣/៥៤) ត្រូវបានធ្វើការបដិសេធឡើងដោយភាគីនិយោជក។ ដូចនេះការបដិសេធឡើងដល់ទៅ ៥៥.៦៧% នៃរឿងដែលមានចេញសេចក្តីបង្គាប់ (៥៤/៩៧)។ មានត្រឹម តែ ៦ ករណី (៣.៣៥%) ដែលគូភាគីទាំងពីរព្រមព្រៀងគ្នាលើសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

**តារាង: រឿងក្តីនៅមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលការងាររៀបតាមលទ្ធផល[២២០]**

| ឆ្នាំ | រឿងក្តីដោយមានការព្រមព្រៀង | រឿងក្តីដោយមានសេចក្តីបង្គាប់ | សេចក្តីបង្គាប់ជាប់កាតព្វកិច្ច | ការបដិសេធ | | | |
|---|---|---|---|---|---|---|---|
| | | | | សរុប | ដោយនិយោជក | ដោយកម្មករ | ដោយភាគី ទាំងពីរ |
| ២០០៣ | ១៣ | ១៨ | ២ | ៩ | ៨ | ១ | ០ |
| ២០០៤ | ៣៥ | ៧៩ | ៤ | ៤៥ | ៣៥ | ៨ | ២ |
| សរុប | ៤៨ | ៩៧ | ៦ | ៥៤ | ៤៣ | ៩ | ២ |

ការប្រព្រឹត្តទៅ និងគុណភាពនៃសេវា

ភាគីទាំងឡាយដែលជាអ្នកប្រើប្រាស់ប្រព័ន្ធបានអះអាងថា សមាជិកអាជ្ញាកណ្តាលនៃក្រុមប្រឹក្សានេះ ជាអ្នកមានកិត្តិនាម និងនិយាមវិជ្ជាជីវៈខ្ពស់។

[២១៩] សូមមើល ឧបសម្ព័ន្ធ ៤

[២២០] ប្រភព៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ៖ របាយការណ៍ឆ្នាំ ២០០៤

រាល់សេចក្ដីបង្គាប់ទាំងអស់ ត្រូវបានបោះផ្សាយតាមរយៈការបោះពុម្ព និងបានផ្សាយជាសាធារណៈនៅក្នុងគេហទំព័រ (Website) របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលការងារ។ ទោះបីជាសវនាការមានលក្ខណៈសម្ងាត់ក្ដី តែសេចក្ដីបង្គាប់មានហេតុផលសមរម្យ និងធ្វើឡើងជាសាធារណៈ។ សេចក្ដីបង្គាប់ធ្វើឡើងយោងទៅលើច្បាប់ និងសមធម៌។

នេះគឺជាស្ថាប័នតែមួយគត់ ដែលយើងមិនបានទទួលការរិះគន់ពីរឿងអំពើពុករលួយ។

មានកាលកំណត់ពេលវេលាច្បាស់លាស់ សម្រាប់ដំណើរការនីតិវិធីនានា។

ចំណុចខ្សោយនៃប្រព័ន្ធនេះ ដូចបានចង្អុលប្រាប់ដោយកម្មករដូចមានខាងក្រោមនេះ :

ក-និយោជកភាគច្រើន មិនព្រមទទួលយកសេចក្ដីបង្គាប់ដែលជាប់កាតព្វកិច្ច ដែលកត្តានេះនាំឱ្យប្រសិទ្ធិភាពនៃសេចក្ដីសម្រេចត្រូវបាយថយចុះ។

ខ-ទោះបីជាពេលមានសេចក្ដីបង្គាប់មានជាប់កាតព្វកិច្ច ពេលខ្លះនិយោជកមិនអនុវត្តសេចក្ដីបង្គាប់។

គ-នៅពេលដែលសេចក្ដីសម្រេចមិនជាប់កាតព្វកិច្ច និយោជកបដិសេធលទ្ធផលដោយប្ដឹងទៅតុលាការ។

ឃ-មិនមានមធ្យោបាយ ក្នុងការដាក់ឱ្យអនុវត្តសេចក្ដីបង្គាប់ដោយផ្ទាល់ទេ នៅពេលមានសេចក្ដីបង្គាប់ជាប់កាតព្វកិច្ច ឬមិនមានការបដិសេធដោយគូភាគី។

ង-និរន្តភាពៈ នៅពេលអង្គការការងារអន្តរជាតិបញ្ចប់គម្រោងរបស់ខ្លួន វាមិនមានភាពច្បាស់លាស់ថា តើក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងបន្តការងារ ឬយ៉ាងណានោះទេ។

ច-ក្រុមប្រឹក្សាអាជ្ញាកណ្ដាលការងារ មាននៅតែក្នុងទីក្រុងភ្នំពេញ និងគួរតែត្រូវពង្រីកបន្ថែម។

នៅពេលអនាគត ចាំបាច់ក្នុងត្រូវផ្ដល់មូលនិធិ និងមធ្យោបាយសមស្រប ដើម្បីអភិវឌ្ឍក្រុមប្រឹក្សាអាជ្ញាកណ្ដាលការងារ និងជម្រុញការពង្រីកបន្ថែមទៅតាមបណ្ដាខេត្តនានា។

ច្បាប់ចែងពីការបកប្រែភាសាទៅជាភាសាបរទេស ប្រសិនបើអាជ្ញាកណ្ដាលម្នាក់មិននិយាយភាសាខ្មែរ ប៉ុន្តែមិនមានបទបញ្ញត្តិចែងពីការបកប្រែភាសាទៅជាភាសាជនជាតិដើមភាគតិចនោះទេ។ ដូចនេះ គួរតែមានបទបញ្ញត្តិ ដែលចែងពីបញ្ហានេះ ហើយគួរតែជាបន្ទុកជារបស់រដ្ឋ។

**ឧទាហរណ៍ៈ រឿងក្ដីបានព្រមព្រៀងគ្នានៅក្នុងដំណើរការសម្រុះសម្រួល**

***ការដោះស្រាយវិវាទដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាលការងារ នៅភ្នំពេញ ប្រទេសកម្ពុជា***[២២១]

- **ថ្ងៃទី ២៤ កុម្ភៈ ២០០៥**
- **រឿងហេតុ :** វិវាទរួមលើសេចក្ដីសម្រេចចិត្តអត្ថប្រយោជន៍ ៥០០ រៀល កាត់ពីអ្នកដែលមកធ្វើការយឺត ១០ នាទី
- **លទ្ធផល :** ត្រូវបានដោះស្រាយដោយការសម្រុះសម្រួលនៅមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល
- *រឿងក្ដីបានកើតឡើង ដោយរក្រុមហ៊ុន AAA (ដែលចាប់ពីពេលនេះទៅត្រូវហៅកាត់ថាក្រុមហ៊ុន) បានចេញសេចក្ដីជូនដំណឹងពីប្រាក់រង្វាន់សម្រាប់អ្នកមកធ្វើការ ដោយគ្មានអវត្តមានក្នុងមួយខែ ដោយបានចែងថា កម្មករដែលមកធ្វើការទៀតទាត់នៅថ្ងៃធ្វើការធម្មតាក្នុងខែ នឹងទទួលបានប្រាក់រង្វាន់ពីក្រុមហ៊ុនយ៉ាងតិច ៥ ដុល្លារក្នុងមួយខែ។ នៅក្នុងខែកុម្ភៈ ឆ្នាំ ២០០៤ ក្រុមហ៊ុនបានប្រកាសថា អ្នកដែលមកធ្វើការយឺតម៉ោងនឹងត្រូវកាត់ប្រាក់រង្វាន់របស់គេ។ បន្ទាប់មក "សហជីពយុវជនខ្មែរ" បានមកចរចារជាមួយក្រុមហ៊ុន សុំមិនឱ្យកាត់ប្រាក់រង្វាន់៥ដុល្លារទេ។ ក្រោយការចរចាក្រុមហ៊ុនយល់ព្រមមិនកាត់៥ដុល្លារទេ ប៉ុន្តែត្រូវកាត់ ៥០០រៀល សម្រាប់ការមកយឺតមួយលើក ក្នុងរយៈពេល ១០នាទី។ ការកាត់នេះបានចាប់ផ្ដើមពីខែមេសា*

[២២១] ករណីនេះត្រូវ បានសង្កេតដោយក្រុមការងារលើដំណើរការសម្រុះសម្រួល

ឆ្នាំ២០០៤។ ក្រុមហ៊ុនបានតវ៉ាថា ៥០០ រៀល គឺកាត់ចេញពីប្រាក់រង្វាន់ ប៉ុន្តែកម្មករតវ៉ាថា បានកាត់ពីប្រាក់ខែរបស់ពួកគេ។ បញ្ហានៃវិវាទគឺថា កម្មករទាមទារឱ្យក្រុមហ៊ុនឈប់កាត់លុយរបស់ពួកគេ ៥០០រៀល នៅពេលដែលពួកគេមកធ្វើការយឺត ១០នាទី។

- នៅពេលចរចា សហជីពបានស្នើទៅក្រុមហ៊ុនមិនឱ្យកាត់លុយ ៥០០ រៀលពីកម្មករដែលបានមកធ្វើការយឺតតិចជាង ១០នាទី ដោយសារមានកម្មករជាច្រើនត្រូវបានគេកាត់លុយ ៥០០ រៀល ហើយលុយ ៥០០រៀលនេះ មិនមែនចេញពីលុយ ៥ដុល្លារ នៃប្រាក់រង្វាន់ការងារទេ។ នៅពេលដែលក្រុមហ៊ុនបាននិយាយ ៥០០រៀលគឺចេញមកពីប្រាក់រង្វាន់ការងារ។ ក្រុមហ៊ុននិយាយថា ការកាត់នេះមិនអាចធ្វើឱ្យតិចជាង ៥០០រៀលទេ។ វិធាននេះត្រូវបាន អនុវត្តប្រហែលជិត ១ឆ្នាំទៅហើយ ហើយនៅពេលនោះ កម្មករទាំងអស់បានយល់ព្រមក្នុងរឿងនេះ។ ក្រុមហ៊ុននឹងអនុវត្តវិធានដដែលនេះ។
- ដោយសារគូភាគីមិនអាចឈានទៅរកការព្រមព្រៀងគ្នា តាមរយៈការសម្រុះសម្រួល អាជ្ញាកណ្តាលបានចាប់ផ្តើមដំណើរការ សម្រុះសម្រួលដោយបិទទ្វារជិតជួបជាមួយគូភាគីដាច់ដោយឡែកពីគ្នា។
  ក្រុមហ៊ុនបាននិយាយថា ពីមុនមានតែសហជីពមួយទេ គឺសហជីពយុវជនខ្មែរនៅក្នុងក្រុមហ៊ុន ហើយនៅពេលនោះយើងបាន ធ្វើការយ៉ាងមានប្រសិទ្ធិភាពជាមួយសហជីព។ ឥឡូវមកសហជីពដល់ទៅ ២ សហជីពយុវជនខ្មែរ និងសហជីពកម្មករសេរី។ ក្រុមហ៊ុនមិនអាចកាត់លុយតិចជាង ៥០០រៀល បានទេ ពីព្រោះបើយើងយល់ព្រមទទួល ៣០០ ឬ ៤០០ ឥឡូវនេះ សហជីព មួយទៀតនឹងមិនសប្បាយចិត្ត ហើយទាមទារសុំឱ្យនៅទាបជាងនេះទៀត។ នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមកាត់លុយ ៥០០រៀល ក្រុមហ៊ុនបានបិទប្រកាសផ្សាយនៅក្នុងក្រុមហ៊ុនអំពីរឿងនេះ ហើយប្រសិនបើកម្មករណាមិនសប្បាយចិត្ត ពួកគេអាចធ្វើបាតុកម្ម ប៉ុន្តែនៅពេលនោះមិនមានបាតុកម្មនោះទេ។ ឥឡូវអ្វីដែលក្រុមហ៊ុនអាចធ្វើបានគឺបង្កើតប្រអប់មួយ សម្រាប់អ្នកដែលមកធ្វើការយឺតឱ្យបង់ ៥០០រៀលដាក់ចូលក្នុងប្រអប់នោះ។ រៀងរាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ ក្រុមហ៊ុននឹងបើក ប្រអប់នោះ ហើយក្រុមហ៊ុនអាចបន្ថែមលុយខ្លះទៀត ដើម្បីទិញអំណោយតូចៗសម្រាប់កម្មករម្នាក់ៗ។
- ក្រោយការជួបប្រជុំជាមួយគូភាគី អាជ្ញាកណ្តាលបានហៅគូភាគីឱ្យមកធ្វើការសម្រុះសម្រួល។ ការសម្រុះសម្រួលនៅដំណាក់កាល នេះបានបរាជ័យ។ ប្រសិនបើគូភាគីមិនអាចឈានដល់ដំណោះស្រាយព្រមព្រៀងគ្នា អាជ្ញាកណ្តាលនឹងធ្វើការ សម្រេចដោយចេញ សេចក្តីបង្គាប់។ សេចក្តីបង្គាប់របស់អាជ្ញាកណ្តាលគឺមានប្រសិទ្ធិភាព ហើយមិនកែប្រែក្នុងរយៈពេលមួយឆ្នាំ។ ចុងក្រោយការ សម្រុះសម្រួលបានបរាជ័យ ហើយរង់ចាំការសម្រុះសម្រួលម្តងទៀត។
- ក្រោយមក គូភាគីបានមកម្តងទៀតធ្វើការសម្រុះសម្រួលនៅមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយពួកគេបានព្រមព្រៀងគ្នា បញ្ចប់រឿងក្តីដោយយល់ព្រមឱ្យកាត់លុយ ៥០០រៀល សម្រាប់អ្នកដែលមកធ្វើការយឺតជាង ១០ នាទី និងរក្សាលុយនោះ នៅក្នុងប្រអប់សម្រាប់ជប់លៀងដល់កម្មករទាំងអស់។ ហើយលុយរង្វាន់ ៥ដុល្លារ នៅតែផ្តល់ទៅឱ្យកម្មករជាប្រាក់រង្វាន់ ការងារដដែល។

## ២.៧.៣. ការវាយតម្លៃ

អ្នកចូលរួមក្នុងសិក្ខាសាលាបានវាយតម្លៃលើក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារដូចខាងក្រោម:

| | ចំណុចល្អ | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|---|
| ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ | - ចំណាយពេលតិច (១៥ថ្ងៃ)<br>- ឥតគិតថ្លៃ<br>- ឯករាជ្យក្នុងការធ្វើសេចក្តីសម្រេចលើរឿងក្តី<br>- សម្រេចដោយយោងលើគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ និងដោយសមធម៌ចំពោះគូភាគី | - សម្រាប់សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច គូភាគីមិនអាចប្តឹងរឿង នេះទៅតុលាការទេ។<br>- គ្មានអំណាចក្នុងការដាក់ឱ្យអនុវត្តសេចក្តីបង្គាប់ ឧទាហរណ៍ រឿងក្តីជាមួយសណ្ឋាគារ ក្រុមប្រឹក្សាបានបញ្ជាឱ្យនិយោជិតត្រលប់ទៅធ្វើការវិញ តែនិយោជកបដិសេធមិនឱ្យចូលធ្វើការ។<br>- និយោជកកម្រនឹងអនុវត្តតាម សេចក្តីបង្គាប់ | - សេចក្តីបង្គាប់ទាំងអស់ គួរតែជាប់កាតព្វកិច្ច<br>- ផ្តល់អំណាចថែមទៀតដល់អាជ្ញាកណ្តាលក្នុងការបង្ខំឱ្យគូភាគីអនុវត្តតាមសេចក្តីបង្គាប់របស់ក្រុមប្រឹក្សា<br>- បង្កើតយន្តការក្នុងការដាក់ឱ្យអនុវត្តសេចក្តីបង្គាប់ |

| | | | |
|---|---|---|---|
| | - ងាយស្រួលក្នុងការទទួលបានព័ត៌មានអំពីវិវាទរបស់គូភាគី<br>- មានតម្លាភាពក្នុងការដោះដូរឯកសារក្នុងពេលសវនាការ<br>- ជឿទុកចិត្ត និងទទួលយកបានដោយគូភាគីទាំងសងខាង<br>- សវនាការធ្វើឡើងដោយរៀបចំបានល្អ និងយោគយល់គ្នាទៅវិញទៅមក | ដែលយ៉ាងតិច ៩៥% នៃសេចក្តីបង្គាប់ត្រូវបានគេមិនអើពើ<br>- ១៥ ថ្ងៃសម្រាប់ក្រុមប្រឹក្សាក្នុងការសម្រេចសេចក្តី និងចេញសេចក្តីបង្គាប់ មានរយៈពេលខ្លីពេក( ជាពិសេសសម្រាប់ រឿងក្តីដែលមានភាពស្មុគ្រស្មាញ។<br>- ចំណេះដឹងរបស់គូភាគីអំពីច្បាប់នៅមានកម្រិត<br>- បន្ទប់សម្រាប់ធ្វើសវនាការមានភាពតូចចង្អៀតមិនគ្រប់គ្រាន់ទេ។ | - គួរតែមានពេលគ្រប់គ្រាន់នៅក្នុងដំណើរការសម្រាប់ការដោះស្រាយវិវាទរបស់ក្រុមប្រឹក្សា<br>- ផ្តល់ការបណ្តុះបណ្តាលសម្រាប់គូភាគី ទាំងនិយោជិត និងនិយោជក ឱ្យយល់ពីច្បាប់ការងារ<br>- គួរមានកញ្ចប់ថវិកាសម្រាប់ទ្រទ្រង់ក្រុមប្រឹក្សា។ |

យោងតាមទស្សនៈរបស់ជំនាញការអង្គការពលកម្មអន្តរជាតិ បានលើកឡើងអំពីប្រសិទ្ធិភាពយ៉ាងខ្ពស់ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ[២២២] ដោយមានរឿងក្តីមួយភាគបី (១/៣) ត្រូវបានដោះស្រាយដោយការស្រុះស្រួលរវាងគូភាគី និង ១/៣ ទៀតត្រូវបានដោះស្រាយដោយចេញសេចក្តីបង្គាប់ ហើយពុំមានករណីណាមួយដែលត្រូវបានបដិសេធ ដោយក្រុមប្រឹក្សាឡើយ។ សរុបគឺមានរឿងក្តីប្រមាណជា ២/៣ ត្រូវបានដោះស្រាយដោយគណៈក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ទោះបីជាករណីខ្លះ និយោជកប្តឹងបដិសេធចំពោះសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាក៏ដោយ តែនិយោជកនៅតែត្រូវដោះស្រាយវិវាទនៅកម្រិតណាមួយ។ ជាក់ស្តែងនិយោជកភាគច្រើនយល់ព្រមគោរពតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង ក្រោយពេលចេញសេចក្តីបង្គាប់។

## ២.៨. ប្រព័ន្ធតុលាការ

### ២.៨.១. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

យោងតាមរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ( មាត្រា ៣៩)។

ប្រព័ន្ធតុលាការត្រូវបានធានាដោយរដ្ឋធម្មនុញ្ញថាជាអំណាចឯករាជ្យ និងមានបេសកកម្មក្នុងការធានាភាពមិនលម្អៀង និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ (រដ្ឋធម្មនុញ្ញមាត្រា១២៨)។ អំណាចតុលាការមានយុត្តាធិការ គ្របដណ្តប់ទៅលើគ្រប់រឿងក្តីទាំងអស់។ អំណាចតុលាការត្រូវបានផ្តល់ឱ្យទៅតុលាការកំពូល និងតុលាការជាន់ទាបទាំងឡាយ។ យោងតាមរដ្ឋធម្មនុញ្ញ មានតែចៅក្រមទេដែលមានសិទ្ធិក្នុងការសម្រេចសេចក្តី ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់។

រដ្ឋធម្មនុញ្ញក៏បានធានាសិទ្ធិតាមផ្លូវតុលាការនូវសិទ្ធិមានមេធាវី និងសេរីភាព គោលការណ៍សច្ចធារណ៍នៃនិរទោស (រហូតតុលាការសម្រេចថាមានទោស) មិនមានការកាត់ទោសពីរដងក្នុងរឿងតែមួយ ។ល។

[២២២] ព័ត៌មាននេះបានទទួលពី លោក Hugo Van Noord ប្រធានទីប្រឹក្សាបច្ចេកទេសរបស់អង្គការពលកម្មអន្តរជាតិ ទទួលបន្ទុកគម្រោងដោះស្រាយវិវាទ (ខែមិថុនា ២០០៥)។

តារាង៖ មូលដ្ឋានច្បាប់

| | រដ្ឋធម្មនុញ្ញ (ឆ្នាំ ១៩៩៣ និងបានវិសោធនកម្មនៅឆ្នាំ ១៩៩៩) |
|---|---|
| សិទ្ធិតាមរដ្ឋធម្មនុញ្ញក្នុងការដាក់ពាក្យបណ្ដឹង | មាត្រា ៣៩ : ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ។ |
| មូលដ្ឋានដែលមានក្នុងរដ្ឋធម្មនុញ្ញសម្រាប់អំណាចតុលាការ | មាត្រា ១២៨ ថ្មី (មាត្រា ១០៩ ចាស់): <br>អំណាចតុលាការជាអំណាចឯករាជ្យ។ <br>អំណាចតុលាការធានារក្សាអនាគតិនិងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។ <br>អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់រួមទាំងរឿងក្ដីរដ្ឋបាលផង។ <br>អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ <br><br>មាត្រា ១២៩ ថ្មី (មាត្រា ១១០ ចាស់): ការជំរះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្ដី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្តសម្បជញ្ញៈរបស់ខ្លួន។ <br><br>មាត្រា ១៣០ ថ្មី (មាត្រា ១១១ ចាស់): គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬអំណាចប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ។ <br><br>មាត្រា ១៣២ ថ្មី (មាត្រា ១១៣ ចាស់): ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យ នៃអំណាចតុលាការ។ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ |

**រចនាសម្ព័ន្ធ និងការរៀបចំ**

យោងតាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការនៃរដ្ឋកម្ពុជា (ឆ្នាំ១៩៩៣) មានតុលាការ ៤ ក្នុងការជម្រះក្ដី គឺ : ក-តុលាការខេត្ត-ក្រុង ខ-តុលាការយោធា គ-សាលាឧទ្ធរណ៍ និង ឃ-តុលាការកំពូល។

តុលាការខេត្ត-ក្រុង មានទីតាំងនៅតាមទីរួមខេត្ត-ក្រុងនានា។ សាលាឧទ្ធរណ៍ និងតុលាការកំពូលមានទីតាំងតែនៅភ្នំពេញប៉ុណ្ណោះ។ ពុំមានតុលាការថ្នាក់ទាបសម្រាប់រឿងក្ដីរដ្ឋប្បវេណី ឬរឿងក្ដីព្រហ្មទណ្ឌលហុដូចពីមុនឡើយ។

យោងតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ (ឆ្នាំ១៩៩៣) ព្រះរាជអាជ្ញាជាអ្នកដើរតួតំណាងឱ្យរដ្ឋ នៅក្នុងបណ្ដឹងអាជ្ញា។ បណ្ដឹងអាជ្ញាមិនអាចត្រូវបានដោះស្រាយដោយការសម្រុះសម្រួលណាមួយឡើយ។

| | ច្បាប់ស្ដីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា - ២៩ មករា ១៩៩៣ |
|---|---|
| រចនាសម្ព័ន្ធ | មាត្រា ១ : សាលាជំរះក្ដីនៃរដ្ឋកម្ពុជាមាន : <br>- តុលាការខេត្ត ក្រុង <br>- តុលាការយោធា <br>- សាលាឧទ្ធរណ៍ <br>- តុលាការកំពូល <br>មាត្រា ២ : តុលាការខេត្ត-ក្រុង និងតុលាការយោធា ជាសាលាជំរះក្ដីជាន់ទាប។ <br>តុលាការខេត្ត-ក្រុង ដែលត្រូវតាំងនៅខេត្ត-ក្រុង មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត-ក្រុងទាំងនោះ។ |

| | |
|---|---|
| | តុលាការយោ ដែលត្រូវតាំងនៅក្រុងភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃរដ្ឋកម្ពុជាទាំងមូល។ |
| | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣** |
| សុពលភាព នៃតុលាការ | មាត្រា ៩៦ : នៅខេត្ត ឬក្រុងនីមួយៗ មានតុលាការមួយ ដែលសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃខេត្ត ឬក្រុងនោះ។ ក្នុងនាមជា "តុលាការផ្នែកព្រហ្មទណ្ឌ" តុលាការខេត្ត ឬក្រុងទទួលជំនុំជំរះបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ដើម្បីមានតម្លៃត្រឹមត្រូវតាមច្បាប់តុលាការព្រហ្មទណ្ឌ ក៏ដូចជាតុលាការរដ្ឋប្បវេណី ទាមទារឱ្យមានចៅក្រមមួយរូបរដ្ឋអាជ្ញារងមួយរូប និងក្រឡាបញ្ជីមួយរូបជាអ្នក ជំនួយការ។ |
| រឿងក្តី ព្រហ្មទណ្ឌ<br>- អាចដោះស្រាយដោយការស្រុះស្រួលគ្នា<br>- ការិយាល័យអយ្យការ<br>- ព្រះរាជអាជ្ញាជាដើមចោទក្នុងបណ្តឹងអាជ្ញា | មាត្រា ៧ : បណ្តឹងអាជ្ញា មិនអាចសម្រុះសម្រួលបានដោយកិច្ចការណាមួយឡើយ។ សាលាជំរះក្តីបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ដែលនឹងមានចែងក្នុងមាត្រាខាងមុខ កាលបើបានទទួលដឹងអំពីបទព្រហ្មទណ្ឌណាមួយហើយ ត្រូវជំនុំជំរះបទល្មើសព្រហ្មទណ្ឌនោះ។ ការមិនគោរពតាមគោល-ការណ៍នេះត្រូវទុកជាបទល្មើសមិនព្រមជំនុំជំរះ ហើយបទល្មើសនេះត្រូវផ្តន្ទាទោសជាវិន័យរដ្ឋបាល ឬ ដាក់គុកពី ៦ថ្ងៃ ដល់ ១ខែ។<br><br>មាត្រា ៨ : ការធ្វើបណ្តឹងអាជ្ញា និង ការជម្រុញបណ្តឹងអាជ្ញានេះឱ្យមានដំណើការជាមុខងាររបស់អយ្យការ។<br><br>មាត្រា ៥២ : ចំពោះមុខសាលាជំរះក្តីផ្នែកព្រហ្មទណ្ឌ រដ្ឋអាជ្ញាត្រូវជា "គូក្តីដើមជានិច្ច"។ ក្នុងន័យនេះ រដ្ឋអាជ្ញាធ្វើបណ្តឹងអាជ្ញា ដោយចោទប្រកាន់ជនជាប់ចោទ និង សុំឱ្យអនុវត្តច្បាប់លើជន នោះ។ |
| | **ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ (១៩៩៨)** |
| ត្រួតពិនិត្យធម្មនុញ្ញភាព | មាត្រា ១៥ : ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងក្របខណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់។<br><br>មាត្រា ១៩ : បុគ្គលដែលមានជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះ អាចលើកអំពីអធម្មនុញ្ញភាពនូវបទបញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថាប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវ័ន្តណាមួយរបស់គេជូនតុលាការបាន។<br><br>បើយល់ឃើញថាការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល១០ ថ្ងៃយ៉ាងយូរ។<br><br>តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានេះមិនអាចទទួលបាន។ |
| | **ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ១៩៩៣** |
| ប្រាក់ប្រដាប់ក្តី | មាត្រា ៣ : ប្រាក់ប្រដាប់ក្តីគឺជាពន្ធសរុប និងប្រាក់ចំណាយផ្សេងៗ ដែលត្រូវបង់ក្នុងរឿងក្តីនីមួយៗ ដែលបានចុះបញ្ជីនៅសាលាជំរះក្តីនៃរដ្ឋកម្ពុជា។ |

ប្រាក់ប្រដាប់ក្ដីត្រូវបង់ក្នុងរឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទការងារ និងវិវាទរដ្ឋបាល។ ប្រាក់នេះត្រូវគូក្ដីជាដើមបណ្ដឹងបង់មុនជាដរាប។ ប្រាក់នេះត្រូវជាបន្ទុកនៃគូក្ដី ដែលចាញ់ក្ដីនៅចុងក្រោយបង្អស់។

មាត្រា ៤ : ប្រាក់ប្រដាប់ក្ដីក្នុងរឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទការងារ និងវិវាទរដ្ឋបាល មានដូចតទៅ:

- ពន្ធចុះបញ្ជីក្ដី
- ពន្ធជំរះក្ដី
- ប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ
- ពន្ធចុះបញ្ជីប្រដាប់ត្រា

**សារាចរណ៍ស្ដីពីការអនុវត្តច្បាប់ស្ដីពីច្បាប់ប្រដាប់ក្ដី (១៩៩៣)**

យោលទៅនីតិវិធីដែលកំពុងអនុវត្តនៅក្នុងរឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម រដ្ឋបាល និងការងារ តុលាការត្រូវចាប់ផ្ដើមដោយការសម្រុះសម្រួល។ ប្រសិនបើការសម្រុះសម្រួលមិនបានជោគជ័យទេ ដើមបណ្ដឹងត្រូវបង់ប្រាក់ប្រដាប់ក្ដី ហើយនៅពេលនោះហើយដែលតុលាការមានអំណាចដើម្បីស៊ើបអង្កេត និងជំរះរឿងក្ដី។ បើដើមបណ្ដឹងមិនបានបង់ប្រាក់ប្រដាប់ក្ដីទេ តុលាការមិនមានអំណាចចាត់ការ និងជំរះរឿងក្ដីបានទេ លើកលែងតែមានការអនុគ្រោះចេញពីតុលាការ ដូចដែលមានចែងក្នុងច្បាប់នេះ។

ដើមបណ្ដឹងត្រូវបង់ប្រាក់ប្រដាប់ក្ដីនៅពេលចាប់ផ្ដើមចំនួន ៧.០០០ រៀល...

**សេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី (ស្ថានភាពឆ្នាំ ២០០៥)**

មាត្រា ៦២ : ១. ភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីខាងក្រោមនេះ ទៅតាមចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ:

ក. ចំនួនទឹកប្រាក់ចាំបាច់ដើម្បីធ្វើឱ្យតុលាការពិនិត្យភស្ដុតាង ការបញ្ជូនឯកសារ ឬសកម្មភាព ផ្សេងទៀតតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី

ខ. ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជីក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្ដុតាង ស្រាវជ្រាវតង្គហេតុ ឬសកម្មភាពផ្សេងទៀត ដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។

...

៤. ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីជាមុន តាមបញ្ញត្តិនៃកថាខ័ណ្ឌទីបីខាងលើនេះ តែសាម៉ីខ្លួនមិនបានបង់ជាមុននោះទេ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ ត្រូវមានប្រាក់ប្រដាប់ក្ដីនោះបាន។

...

មាត្រា ៦៣ : ក្រៅពីការកំណត់នៅក្នុងមាត្រា៦១ (ពន្ធនៃការដាក់ពាក្យសុំ)និងមាត្រា ៦២ (ប្រាក់ប្រដាប់ក្ដី តុលាការក្រៅពីពន្ធ) ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការកំណត់ថាសមរម្យ ដោយគិតពិចារណានូវលក្ខណៈនៃរឿងក្ដី ឬលទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ក្នុងចំណោមការកំណត់ក្នុងចំណុចខាងក្រោមនេះ ក៏ត្រូវចាត់ទុកជាប្រាក់ប្រដាប់ក្ដីដែរ។

| | |
|---|---|
| | មាត្រា ៦៤ : ១. ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី ។... |
| | មាត្រា ៦៩ : ចំពោះបុគ្គលដែលគ្មានលទ្ធភាពទ្រព្យធននឹងបង់ប្រាក់ ដែលចាំបាច់ដើម្បីរៀបចំ និងប្រព្រឹត្តិទៅនៃនីតិវិធីបណ្តឹង ឬបុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំង ក្នុងការទ្រទ្រង់ជីវភាព ដោយសារបង់ប្រាក់នេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះ លើបណ្តឹងតាមពាក្យសុំ។ ប៉ុន្តែបញ្ញត្តិ នេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់ជាគ្មានលទ្ធភាពនឹងឈ្នះក្តីសោះ ។ |

ក្របខ័ណ្ឌស្ថាប័ន

តាមច្បាប់ដើម្បីឱ្យតុលាការមានសុពលភាព ចាំបាច់ត្រូវមានចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ តែទោះជាយ៉ាងណាក្តី រដ្ឋធម្មនុញ្ញក៏បានចែងពីសិទ្ធមានមេធាវីរបស់ជនជាប់ចោទ ។

នៅក្នុងទូទាំងប្រទេស មានតុលាការខេត្ត-ក្រុងចំនួន ២១ គ្របដណ្តប់លើខេត្តទាំង ២៤។ អាស្រ័យហេតុនេះ មានតុលាការមួយឬពីរដែលមានសមត្ថកិច្ចគ្របដណ្តប់លើខេត្តលើសពីមួយ។ នោះគឺជារបាំងមួយ ក្នុងចំណោមរបាំងនានាសម្រាប់ការស្វែងរកយុត្តិធម៌ និងការលំបាកផ្នែកភូមិសាស្ត្រក្នុងការទៅរកតុលាការ។

មានព្រះរាជអាជ្ញាចំនួន ៦៨ រូប ដែលសុទ្ធតែជាបុរស មានស្ត្រីមួយតែម្នាក់។ មានចៅក្រម ១៣០ រូប ដែលមាន១១រូបជាស្ត្រី ក្នុងចំណោមបុរស ១១៩នាក់។ ក្រឡាបញ្ជីមានទាំងអស់ ៧៣៧រូប ដែលមានបុរស ៦០៧នាក់ និងស្ត្រី ១៣០នាក់។ កម្រិតនៃការអប់រំរបស់ចៅក្រម ព្រះរាជអាជ្ញា និង ក្រឡាបញ្ជីមានភាពខុសៗគ្នា។ អ្នកខ្លះត្រូវបានតែងតាំងមួយរយៈជាយូមកហើយហើយបានទទួលការបណ្តុះបណ្តាលតិចតួចប៉ុណ្ណោះ។ មានភាគតិចណាស់ដែលទទួលបានបញ្ចប់ការសិក្សាក្រោយឧត្តមសិក្សា។

**តារាងធនធានមនុស្ស** [២២៣]

| តុលាការខេត្ត | ព្រះរាជអាជ្ញា | | ចៅក្រម | | សរុប | ក្រឡាបញ្ជី | | |
|---|---|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | | បុរស | ស្ត្រី | សរុប |
| សរុប : ២១ | ៦៧ | ១ | ១១៩ | ១១ | ១៩៨ | ៦០៧ | ១៣០ | ៧៣៧ |
| មធ្យមភាគក្នុងខេត្តនីមួយៗ | ៣ | | ៥.៦ | | | | | |

ប្រាក់បៀវត្សរ៍របស់ចៅក្រម និងព្រះរាជអាជ្ញាបានកើនឡើងគួរឱ្យកត់សំគាល់ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការតំឡើងប្រាក់បៀវត្សរ៍នេះជាវិធានការមួយ រួមចំណែកដល់ការទប់ស្កាត់អំពើពុករលួយ និងលើកតម្កើងសេចក្តីថ្លៃថ្នូរ ក្នុងមុខងារតុលាការ។ ចៅក្រមអាចទទួលបានប្រាក់ខែពី ៣៧៥ ដល់ ៦២៥ដុល្លារអាមេរិក អាស្រ័យលើមុខតំណែងរបស់ពួកគេ។ ទោះបីជាយ៉ាងនេះក្តី ប្រាក់បៀវត្សរ៍របស់ក្រឡាបញ្ជីមិនទាន់ត្រូវបានតំឡើងនៅឡើយទេ។ កត្តានេះនាំឱ្យមានការរិះគន់ពីអតិថិជនដែលបានប្រើប្រាស់ប្រព័ន្ធនេះ ចំពោះអំពើពុករលួយនៅក្នុងដំណើរការក្តី ហើយករណីនេះក៏បានលើកឡើងដោយចៅក្រមផងដែរ ។

[២២៣] សូមមើលតារាងទាំងស្រុងក្នុង ឧបសម្ព័ន្ធ ៤

តារាង : បៀវត្សរ៍របស់មន្ត្រីតុលាការ[២២៤]

| ល.រ | តួនាទី | ប្រាក់ខែសុទ្ធ* | ប្រាក់ឧបត្ថម្ភ* |
|---|---|---|---|
| ចៅក្រម និងព្រះរាជអាជ្ញា | | | |
| ១ | ប្រធាន និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | --- | ២.៥០០.០០០ រៀល = ៦២៥ ដុល្លារអាមេរិក |
| ២ | ប្រធាន និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអនុប្រធាន និងអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល | --- | ២.២០០.០០០ រៀល= ៥៥០ |
| ៣ | អនុប្រធាន និងអគ្គព្រះរាជអាជ្ញារងអម សាលាឧទ្ធរណ៍ | --- | ២.០០០.០០០ រៀល = ៥០០ ដុល្លារអាមេរិក |
| ៤ | ប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង និងចៅក្រមនិង ព្រះរាជអាជ្ញាតុលាការកំពូល និងសាលាឧទ្ធរណ៍ | ប្រហែល ១៣១.១០០ រៀល | ១.៧០០.០០០ រៀល = ៤២៥ ដុល្លារអាមេរិក |
| ៥ | អនុប្រធានតុលាការ និងព្រះរាជអាជ្ញារងតុលាការខេត្ត-ក្រុង | ប្រហែល ១១៧.០០០ រៀល | ១.៥០០.០០០ រៀល = ៣៧៥ ដុល្លារអាមេរិក |
| ៦ | ចៅក្រមតុលាការខេត្ត-ក្រុង | ពី ៩៩.០០០ ទៅ ១១៤.០០០ រៀល | ១.៣០០.០០០ រៀល = ៣២៥ ដុល្លារអាមេរិក |
| ក្រលាបញ្ជី | | | |
| ៧ | ក្រលាបញ្ជី | ប្រហែល ៩០.០០០* | ប្រហែល ៤០.០០០ រៀល* = ១០ ដុល្លារ |

## ២.៨.២. តម្រូវការយុត្តិធម៌ពីនៅចំពោះមុខតុលាការ

តើបញ្ហាប្រភេទណាខ្លះដែលអ្នកប្តឹងទៅតុលាការ?

យោងតាមការស្ទង់មតិរបស់ *IRL* (តារាងទី២៧ ទំព័រ២៧) ប្រជាពលរដ្ឋនិយាយថាពួកគេទៅរកតុលាការនៅពេលពួកគេមានបញ្ហាទាំងឡាយដូចខាងក្រោមនេះ :

| បញ្ហា | ភាពញឹកញាប់ (ក្នុងចំណោមពលរដ្ឋ៥ក្រុម) |
|---|---|
| ១ រឿងក្តីព្រហ្មទណ្ឌ | (៥ក្រុម/៥ក្រុម) |
| ២ វិវាទដីធ្លី | (៥/៥) |
| ៣ លែងលះ | (៥/៥) |
| ៤ អំពើហិង្សាក្នុងគ្រួសារ | (៣/៥) |
| ៥ រឿងរដ្ឋប្បវេណី | (៤/៥) |
| ៦ វិវាទជណ្តើមកេរ្តិ៍មរតក | (២/៥) |
| ៧ វិវាទការងារ | (១/៥) |

២២៤ ជារៀងរាល់ឆ្នាំ តុលាការទទួលថវិកាប្រមាណ ៩០.០០០.០០០ រៀល ដើម្បីប្រើប្រាស់ក្នុងការិយាល័យ រដ្ឋបាល បេសកកម្ម និងការស៊ើបអង្កេត។ អនុក្រឹត្យឆ្នាំ ២០០២ ស្តីពីប្រាក់ឧបត្ថមដល់ចៅក្រម និងព្រះរាជអាជ្ញា។ សម្ភាសជាមួយលោក ប៉ាន ផល្លា ប្រធានក្រឡាបញ្ជីទទួលបន្ទុកគណនេយ្យតុលាការខេត្តព្រៃវែង។




បញ្ហារឿងក្តី:

តាមការពិត តម្រូវការដាក់ស្នើភាគច្រើនគឺទាក់ទិននឹងរឿងក្តីព្រហ្មទណ្ឌដែលមាន ៦២៣២ ករណី នៅពេលដែលរឿងក្តីរដ្ឋប្បវេណីមានត្រឹម ៥៨១១ ករណីប៉ុណ្ណោះ។

៤០%នៃរឿងក្តីរដ្ឋប្បវេណីទាក់ទងនឹងរឿងលែងលះ។ ស្ត្រីបានដាក់ពាក្យប្តឹង ៨០% នៃរឿងក្តីទាំងនោះ។ នេះជាបន្ទុកយ៉ាងធ្ងន់សម្រាប់ស្ត្រីដែលត្រូវធ្វើដំណើរមកទីរួមខេត្ត និងត្រូវចំណាយលើតម្លៃសម្រាប់នីតិវិធី តែតាមពិតរឿងក្តីលែងលះភាគច្រើន មានមូលហេតុចេញពីអំពើហិង្សាក្នុងគ្រួសារ និងភាពខ្វះការទទួលខុសត្រូវរបស់ប្តីក្នុងគ្រួសារ។

ទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ ស្ទើរតែមួយភាគបីនៃរឿងទាំងអស់ មានទាក់ទងនឹងបទល្មើសទ្រព្យសម្បត្តិ។ មួយភាគបួនគឺរឿងក្តីបង្ករបួសស្នាម។ បទល្មើសបន្ទាប់ពីនោះគឺបទរំលោភសេពសន្ថវៈ ជាបញ្ហាដ៏ធំដែលប្រជាពលរដ្ឋប្រឈម។ ដោយសារតែរឿងក្តីបង្ករបួសស្នាម ពាក់ព័ន្ធនឹងអំពើហិង្សាលើរូបរាងកាយក្នុងគ្រួសារ ស្ត្រីត្រូវប្រឈមមុខនឹងតម្លៃធ្វើកោសល្យវិច្ច័យ នាំឱ្យនេះជាបន្ទុកមួយទៀតសម្រាប់ជនរងគ្រោះ ដែលត្រូវបានទទួលរងគ្រោះពីរជាន់។

ទំហំរឿងក្តី:

តុលាការទទួលបានច្រើនជាង ១២.០០០ករណីក្នុងមួយឆ្នាំ សរុបទាំងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី។ របាយការណ៍ចុងក្រោយរបស់តុលាការរួមមានតួលេខដូចខាងក្រោម: ៥.៨១១ (៤៨%) រឿងក្តីរដ្ឋប្បវេណី និង ៦.២៣២ (៥២%) រឿងក្តីព្រហ្មទណ្ឌលើចំនួនរឿងក្តីសរុប ១២.០៤៣។

តារាងបញ្ជីនៃរឿងក្ដីច្រើនជាងគេដែលបានសម្រេចសេចក្ដីដោយតុលាការ នៅទូទាំងប្រទេសក្នុងឆ្នាំ២០០៣

| ល.រ | រឿងក្ដីរដ្ឋប្បវេណី | | ចំនួនរឿងក្ដី | ភាគរយ |
|---|---|---|---|---|
| ១ | ការលែងលះ | ដោយប្រពន្ធ (១៨៧៣) (៨០%) | ២៣៨៣/៥៨១១ | ៤០.៣២% |
| | | ដោយប្ដី(៤៧០) (២០%) | | |
| ២ | រំលោភកិច្ចសន្យា | | ១៥៨៣/៥៨១១ | ២៧.២៤% |
| ៣ | វិវាទដីធ្លី | | ៧៨២/៥៨១១ | ១៣.៤៦% |
| ៤ | សំបុត្រកំណើត និងសំបុត្រមរណៈភាព | | ២២៧/៥៨១១ | ៣.៩០% |
| ៥ | ទាមទារសំណងរដ្ឋប្បវេណី | | ២០០/៥៨១១ | ៣.៤៤% |
| ៦ | ផ្សេងៗ | | ៦៧៦ | ១១.៦៣% |
| | **សរុប** | | **៥.៨១១** | |
| **ល.រ** | **រឿងក្ដីព្រហ្មទណ្ឌ** | | **ចំនួនរឿងក្ដី** | **ភាគរយ** |
| ១ | បង្ករបួសស្នាម | | ១៤៩២/៦២៣២ | ២៣.៩៤% |
| ២ | ចោរកម្ម/ទទួលផលចោរកម្ម | | ៩៣៥/៦២៣២ | ១៥.០០% |
| ៣ | ប្លន់ | | ៧៥៤/៦២៣២ | ១២.០៩% |
| ៤ | រំលោភសេពសន្ថវៈ | | ៤៤០/៦២៣២ | ៧.០៦% |
| ៥ | មនុស្សឃាត (ពាក់ព័ន្ធនឹងរំលោភសេពសន្ថវៈ) | | ៤៣៨/៦២៣២ | ៧.០២% |
| ៦ | បរិហារកេរ្តិ៍ | | ៣២៩/៦២៣២ | ៥.២៧% |
| ៧ | រំលោភលើទំនុកចិត្ត | | ៣១២/៦២៣២ | ៥.០០% |
| ៨ | ឆបោក | | ២៩៣/៦២៣២ | ៤.៧០% |
| ៩ | បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ | | ២១៦/៦២៣២ | ៣.៦៤% |
| ១០ | ផ្សេងៗ | | ១០២៣/៦២៣២ | ១៦.៤១% |
| | **សរុប** | | **៦.២៣២** | |
| | **សរុបរួម** | | **១២.០៤៣** | |

## ២.៨.៣. សមត្ថភាពការងារ

- តុលាការមានសមត្ថភាពក្នុងការដោះស្រាយរឿងក្ដីដែលបានទទួលក្នុងឆ្នាំៗ គឺប្រែប្រួលពី ២២% ទៅ៩០%។
- ក្នុងករណីរឿងរដ្ឋប្បវេណី សមត្ថភាពការងារកាន់តែយឺតជាងរឿងព្រហ្មទណ្ឌទៅទៀត ដោយពុំមានក្របខ័ណ្ឌច្បាប់ចែងកំណត់អំពីរយៈពេលដែលតុលាការត្រូវដោះស្រាយជាក់លាក់។ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ក៏ពុំមាននីតិវិធីច្បាស់លាស់ លើកលែងតែនីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន។
- ក្នុងខេត្តដែលមានជនជាតិដើមភាគតិច ដូចជាក្នុងខេត្តរតនៈគីរី និងមណ្ឌលគីរី ចំនួនរឿងក្ដីដែលតុលាការបានទទួលក្នុងមួយឆ្នាំមានចំនួនតិចណាស់ (ប្រហែល២០ករណីក្នុងមួយឆ្នាំ) បើប្រៀបធៀបទៅខេត្តដទៃទៀត។ នេះមានន័យថា ដោយពួកគេមិនអាចប្ដឹងទៅតុលាការ បាននាំឱ្យពួកគេព្យាយាមដោះស្រាយវិវាទនៅមូលដ្ឋានក្នុងសហគមន៍របស់ពួកគេ។ សូម្បីរឿងក្ដីរដ្ឋប្បវេណីក៏មានចំនួនតិចដែរ។

តារាង សមត្ថភាពការងារក្នុងឆ្នាំ ២០០៣ របស់តុលាការដែលត្រូវបានជ្រើសរើស

| តុលាការ[២២៥] | អ្នកប្រតិបត្តិការ | រឿងក្ដីនៅសល់ពីឆ្នាំ ២០០២ | រឿងក្ដីថ្មីទទួលនៅឆ្នាំ ២០០៣ | សរុបក្នុងឆ្នាំ ២០០៣ | បានដោះស្រាយ/បានជម្រះ ភាគរយ(%) | នៅសល់ដល់ឆ្នាំ ២០០៤ ភាគរយ (%) |
|---|---|---|---|---|---|---|
| ភ្នំពេញ (ព្រះរាជអាជ្ញា= ៦ រូប ចៅក្រម= ១៣ រូប) | អយ្យការ | ៥៤៩ | ២២៣៩ | ២៧៨៨ | ២២២៩ = ៨០ % | ៥៥៩ = ២០ % |
| | ចៅក្រមជម្រះ | ៧២៩ | ១១១៥ | ១៨៤៤ | ១០១៣ =៥៥% | ៨៣១ =៤៥% |
| | រឿងក្ដីរដ្ឋប្បវេណី | ២៤១០ | ១៥៤៣ | ៣៩៥៣ | ១៤៩២=៣៨% | ២៤៦១ =៦២% |
| បាត់ដំបង (ព្រះរាជអាជ្ញា= ៣ រូប ចៅក្រម= ៦ រូប) | អយ្យការ | ១២៦ | ៨៤៨ | ៩៧៤ | ៨១០ = ៨៣% | ១៦៤ = ១៧% |
| | ចៅក្រមជម្រះ | ៥១ | ៤៩៧ | ៥៤៨ | ៤៩០ = ៨៩% | ៥៨ = ១១% |
| | រឿងក្ដីរដ្ឋប្បវេណី | ១១០ | ៥៥២ | ៦៦២ | ៥៧១= ៨៦% | ៩១ = ១៤% |
| កំពង់ស្ពឺ (ព្រះរាជអាជ្ញា= ២ រូប ចៅក្រម= ៣ រូប) | អយ្យការ | ១៦ | ២៤១ | ២៥៧ | ២៣៦ = ៩២% | ២១ = ៨% |
| | ចៅក្រមជម្រះ | ០៥ | ៧៦ | ៨១ | ៧៦ = ៨៤% | ៥ = ៦% |
| | រឿងក្ដីរដ្ឋប្បវេណី | ១៩៥ | ១៥៤ | ៣៤៩ | ៧៦ = ២២% | ២៧៣ = ៧៨% |
| កំពង់ឆ្នាំង (ព្រះរាជអាជ្ញា= ២ រូប ចៅក្រម= ៤ រូប) | អយ្យការ | ១០ | ២៩៥ | ៣០៥ | ២១៧ = ៧១% | ៨៨ = ២៩% |
| | ចៅក្រមជម្រះ | ៦៨ | ១១១ | ១៧៩ | ១២៣ = ៦៩% | ៥៦ = ៣១% |
| | រឿងក្ដីរដ្ឋប្បវេណី | ៩៣ | ២១៧ | ៣១០ | ១៩០ = ៦១% | ១២០ = ៣៩% |
| រតនៈគីរី (ព្រះរាជអាជ្ញា= ១ រូប ចៅក្រម= ៤ រូប) | អយ្យការ | ៤៩ | ៩៨ | ១៤៧ | ១៣៣ = ៩០% | ១៤ = ១០% |
| | ចៅក្រមជម្រះ | ០៧ | ៤២ | ៤៩ | ៣៨ = ៧៨% | ១១=២២% |
| | រឿងក្ដីរដ្ឋប្បវេណី | ០៧ | ៣២ | ៣៩ | ៣០ =៧៧% | ៩ =២៣% |
| មណ្ឌលគីរី (ព្រះរាជអាជ្ញា= ១ រូប ចៅក្រម= ៣ រូប) | អយ្យការ | ០០ | ២៥ | ២៥ | ២៤=៩៦% | ១ = ៤% |
| | ចៅក្រមជម្រះ | ០៧ | ១៦ | ២៣ | ១៤ = ៦១% | ៩ = ៣៩% |
| | រឿងក្ដីរដ្ឋប្បវេណី | ១៩ | ០៨ | ២៧ | ១៣ =៤៨% | ១៤ = ៥២% |

២២៥ ទាំងនេះជាឧទាហរណ៍គំរូនៃខេត្តមួយចំនួន

ក្រុមគោលដៅ

អ្នកក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ប្តឹងទៅតុលាការដើម្បីដោះស្រាយវិវាទនានាក្នុងករណីដូចខាងក្រោម៖

ក- ស្ត្រីបានដាក់ពាក្យ ៨០%នៃរឿងក្តីលែងលះ។ ការលែងលះមានដល់ ៤០%នៃរឿងក្តីរដ្ឋប្បវេណីទាំងអស់។

ខ- ស្ត្រីគឺជាជនរងគ្រោះក្នុងអំពើហិង្សាខាងយេនឌ័រ ដូចជាការបំពានផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការបង្ករបួសស្នាមក្នុងករណីរឿងក្តីអំពើហិង្សាក្នុងគ្រួសារ (៧%នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តទាក់ទងនឹងការរំលោភសេពសន្ថវៈ)។

គ- អ្នកដែលត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ជាញឹកញាប់គឺអ្នកក្រ។ នៅក្នុងពន្ធនាគារកម្រមានពិរុទ្ធជនជាអ្នកមានអំណាចណាស់។ អ្នកក្រីក្រប្រឈមមុខនឹងការចោទប្រកាន់ព្រហ្មទណ្ឌ ចំពោះបទល្មើសនានាដែលខ្លួនបានប្រព្រឹត្ត ឬដោយគេបំប្លែងរឿងផ្សេងៗ ក្នុងសង្គមឱ្យទៅជាបទល្មើសព្រហ្មទណ្ឌ។ អ្នកមានអំណាចមួយចំនួនបានប្រើប្រព័ន្ធព្រហ្មទណ្ឌ ក្នុងការចោទប្រកាន់អ្នកភូមិលើវិវាទភោគៈលើដីធ្លី។ កម្មករនិយោជិតខ្លះក៏ត្រូវបានប្រឈមនឹងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ដោយសារតែមានតវ៉ាផ្សេងៗក្នុងសង្គម។

ឃ- ជនជាតិដើមភាគតិច ឋិតនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌក្នុងនាមជាចុងចោទ។ ពួកគេត្រូវមានមេធាវីការពារ អ្នកបកប្រែ និងការគិតគូរដល់វប្បធម៌ របស់ពួកគេ។

**រឿងក្តីទាក់ទងនឹងបញ្ហាយេនឌ័រ**

**រឿងក្តីរដ្ឋប្បវេណី-ការលែងលះ**

ក្នុងចំណោមរឿងក្តីលែងលះច្រើនជាង ២៣៤៣ ករណី ដែលត្រូវបានដាក់ពាក្យប្តឹងទៅតុលាការ មានស្ត្រីជាដើមបណ្តឹងចំនួន ១.៨៧៣ករណីនៃបណ្តឹងទាំងអស់ ដែលត្រូវជា ៨០%នៃរឿងក្តីប្រភេទនោះ។ យោងតាមការសម្ភាសន៍ជាមួយចៅក្រម អំពើហិង្សាក្នុងគ្រួសារ និងភាពមិនទទួលខុសត្រូវក្នុងនាមជាឪពុក គឺជាមូលហេតុចម្បងនៃការលែងលះ ទោះបីជាមានរឿងក្តីនៃអំពើហិង្សាក្នុងគ្រួសារតិចតួច ត្រូវបានចោទប្រកាន់ជាបទព្រហ្មទណ្ឌ (ការបង្ករបួសស្នាម) ដោយតុលាការក្តី។

ប្តីប្រពន្ធភាគច្រើនមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍របស់ពួកគេទេ ដូចនេះប្រហែលតាមផ្លូវច្បាប់ ពួកគេមិនចាំបាច់ទៅរកតុលាការទេ។ ទោះជាយ៉ាងនេះក្តី នៅពេលស្ត្រីមិនអាចស្វែងរកការគាំទ្រពីមូលដ្ឋាន តែពួកគាត់ត្រូវរកអាជ្ញាធរផ្សេងៗទៀតដើម្បីជួយដោះស្រាយការបែងចែកទ្រព្យសម្បត្តិ អាហារកិច្ច និងការគ្រប់គ្រងកូនរបស់ពួកគេ។ បន្ទុកសម្រាប់ស្ត្រីត្រូវប្តឹងទៅតុលាការគឺការបង់ថ្លៃចំណាយផ្លូវច្បាប់[២២៦] ថ្លៃធ្វើដំណើរ ការធ្វើដំណើររបស់សាក្សី និងចំណាយខុសច្បាប់មួយចំនួន។ មេធាវីដែលយើងបានសម្ភាសន៍នៅមជ្ឈមណ្ឌលស្ត្រីមានវិបត្តិនៃកម្ពុជា *(CWCC)* បាននិយាយថា ស្ត្រីទាំងនោះត្រូវបង់ថ្លៃក្នុងការឱ្យគេចេញសាលក្រមដាក់ទោស និងបន្ទាប់មកត្រូវបង់ថ្លៃថែមទៀត សម្រាប់អនុវត្តសាលក្រម។ ក្នុងករណីមួយចំនួន ពួកគាត់ត្រូវបង់លុយថ្លៃធ្វើដំណើររបស់នគរបាលមកពីទីរួមខេត្ត មកកាន់ភូមិរបស់ខ្លួន ដើម្បីអនុវត្តសាលក្រមរបស់តុលាការ។

ការផ្តល់សេវាកម្មយុត្តិធម៌ឱ្យបានប្រសើរឡើង ជាតម្រូវការដ៏សំខាន់របស់ស្ត្រីដែរ។ សេចក្តីត្រូវការរបស់ស្ត្រីគឺចង់ឱ្យមានអាជ្ញាធរមានយុត្តាធិការនៅជិតពួកគេ ក្នុងការដោះស្រាយវិវាទអំពើហិង្សាក្នុងគ្រួសារ ការពារដល់សិទ្ធិកុមារ ផ្តល់អាហារកិច្ច និងបែងចែកទ្រព្យសម្បត្តិរួម ព្រមទាំងអនុវត្តសេចក្តីសម្រេចផងដែរ។

[២២៦] តាមក្រមរដ្ឋប្បវេណីថ្មី ស្ថានភាពរបស់ស្ត្រីអាចកាន់តែអាក្រក់និងធ្ងន់ធ្ងរថែមទៀត ដោយហេតុថា អ្នកប្តឹងត្រូវតែបង់ប្រាក់ប្រដាប់ក្តី ការធ្វើដំណើរ និងរាល់ចំណាយទាំងអស់របស់តុលាការទាក់ទងនឹងរឿងក្តីដែលខ្លួនប្តឹង។

**ទីតាំងទី៤៖ រឿងក្តីលែងលះមួយដែលត្រូវបានដោះស្រាយដោយតុលាការ**

- **តុលាការខេត្តកំពង់ស្ពឺ :** សវនាការថ្ងៃទី ៣ មិនា ឆ្នាំ ២០០៥
- **រឿងក្តីរដ្ឋប្បវេណី :** ករណីលែងលះ
- លោក OK អាយុ ១៩ បានរៀបការជាមួយនិងនាង SC នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៤។ ពួកគេរស់នៅក្នុងភូមិ ព្រៃសណ្តែក ឃុំភក្តី ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ មុនពេលរៀបការ ឪពុកម្តាយលោក OK និង ឪពុកម្តាយនាង SC បានព្រមព្រៀងគ្នាធ្វើផ្ទះមួយខ្នងឱ្យប្តីប្រពន្ធថ្មី ដោយឪពុកម្តាយនាង SC មានដី និងឪពុក-ម្តាយលោក OKចេញថ្លៃសម្ភារៈសម្រាប់សាងសង់ផ្ទះ។ ក្រោយពីរៀបការបានមួយរយៈខ្លីមក ប្តីប្រពន្ធក្មេងនេះ តែងកើតមានជម្លោះ ជារឿយៗ។ នៅខែធ្នូ ឆ្នាំ ២០០៤ នាង SC បានចុះចេញពីផ្ទះ ទៅរស់នៅជាមួយសាច់ញាតិរបស់នាងនៅឯភ្នំពេញ។
- ក្រោយនាង SC ចាកចេញពីផ្ទះ លោក OK និងឪពុកម្តាយខ្លួនបានដាក់ពាក្យប្តឹងសុំលែងលះទៅអាជ្ញាធរមូលដ្ឋាន។ ដំបូងពួកគេបានដាក់ពាក្យទៅមេភូមិធ្វើការសម្រុះសម្រួល។ បន្ទាប់មក មេភូមិបានបញ្ជូន រឿងនេះទៅឱ្យឃុំ ដែលជាកន្លែងដែលគូភាគីត្រូវបានគេហៅមកសម្រុះសម្រួល៣លើក ហើយភាគីនីមួយៗបង់លុយ ៥០០០រៀល។ ក្រោយការសម្រុះសម្រួលបានបរាជ័យនៅថ្នាក់ឃុំ រឿងក្តីត្រូវបានបញ្ជូនឡើងមកថ្នាក់ស្រុក ដែលបានហៅគូភាគីមកផ្សះផ្សាម្តងទៀត តែនៅតែមិនបានលទ្ធផលទេ។ នៅថ្នាក់មូលដ្ឋាន គូភាគីបានយល់ព្រមលែងលះ ប៉ុន្តែមិនយល់ព្រមលើការបែងចែកផ្ទះ។ ឪពុកម្តាយនាង SC ចង់ឱ្យគ្រួសាររបស់ OK រុះរើផ្ទះចេញពីដីរបស់ពួកគេ ហើយគ្រួសារ របស់លោក OK បានទាមទារយកផ្ទះនិងដី ដោយសារថាឪពុកម្តាយរបស់ SC បាន ប្រគល់ដីមកឱ្យគាត់ហើយនៅ មុនពេលរៀបការ។
- នៅចុងខែមករា ឆ្នាំ ២០០៥ ឪពុកម្តាយនាង SC បានដាក់ពាក្យប្តឹងមកកាន់តុលាការខេត្តកំពង់ស្ពឺ ដើម្បីសុំលែងលះ និងបែងចែកទ្រព្យសម្បត្តិ។ ចាប់តាំងពីពេលចាប់ផ្តើមបណ្តឹងរដ្ឋប្បវេណីនេះមក គូភាគីត្រូវបានគេ ហៅមកតុលាការ ៤ លើក ដែលពួកគេត្រូវចំណាយអស់ប្រហែល ៥០.០០០ រៀលក្នុងការធ្វើដំណើរទៅមកមួយលើក។
- នៅពេលចាប់ផ្តើម ចៅក្រមបានប្រកាសបើកសវនាការដោយមានអ្នកចូលរួមទាំងអស់ (ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី គូភាគី និងសាក្សី) និងបានជូនព័ត៌មានទៅគូភាគីអំពីសិទ្ធិរបស់ពួកគេនៅក្នុងពេលសវនាការ។ បន្ទាប់មក ចៅក្រមបានសាកសួរគូភាគីឱ្យពិចារណាឡើងវិញ ប្រសិនបើពួកគេអាចសម្រុះសម្រួលការលែងលះរបស់ពួកគេបាន នៅឱកាសចុងក្រោយនេះ មុនពេលចៅក្រមសម្រេចលើរឿងក្តី។ ភាគីទាំងពីរបដិសេធមិនព្រមសម្រុះសម្រួលទេ។
- ចៅក្រមបានសួរទៅដើមបណ្តឹងនាង SC ឱ្យនិយាយប្រាប់ពីមូលហេតុ និងគោលបំណងនៃបណ្តឹងរបស់ខ្លួន។ នាងបាននិយាយថាប្តីរបស់នាង លោក OK បានប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារមកលើរូបនាងញឹកញាប់ណាស់។ គាត់ប្រច័ណ្ឌនឹងនាង ហើយមិនព្រមឱ្យនាងទៅទីណា ឬនិយាយជាមួយបុរសណាទេ សូម្បីតែមិត្តភក្តិ ឬសាច់ញាតិ ក៏ដោយ។ រាល់ពេលប្តីនាងតែងវាយធ្វើបាបនាង សាច់ញាតិរបស់ប្តីនាងនៅទីនោះដែរ តែពួកគេមិនដែលបញ្ឈប់គាត់ទេ។ ប្តីនាងក៏បានព្រមាននាងមិនឱ្យប្រាប់គ្រួសារនាងពីរឿងនេះទេ បើមិនដូច្នោះទេ នាងនឹងត្រូវស្លាប់។ បន្ទាប់មកនាងក៏សម្រេចចិត្តចាកចេញចោលប្តីនាង។ ឥឡូវនេះនាងប្តឹងសុំលែងលះ និងទាមទារសិទ្ធិរបស់នាងលើផ្ទះ ដែលគ្រួសារប្តីនាងបានសាងសង់លើដីរបស់ឪពុកម្តាយនាង។
- ចៅក្រមបានសួរទៅចុងចម្លើយ លោក OK ថាតើគាត់មានការជំទាស់អ្វី។ គាត់បាននិយាយថា គាត់មិនដែលបានវាយធ្វើបាបលើរូបរាងកាយនាងទេ ប៉ុន្តែបានស្តីបន្ទោសនាងម្តងម្កាលដែរ។ គាត់បានដាក់ពាក្យប្តឹង ទៅអាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ និងស្រុក) សុំលែងលះ ពីព្រោះនាងបានចាកចោលផ្ទះ ដោយមិនបានប្រាប់គាត់បន្តិចសោះឡើយ។ គាត់បានសុំឱ្យចៅក្រមរកយុត្តិធម៌ឱ្យគាត់ពីរឿងដីនិងផ្ទះផង ដែលបានសាងសង់នៅមុនពេលរៀបការ។ គាត់បាននិយាយថា ឪពុកម្តាយរបស់ប្រពន្ធគាត់ធ្លាប់បាននិយាយថា ពួកគេនឹងឱ្យដីនេះដល់គាត់ជារៀងរហូត។
- ចៅក្រមបានសួរទៅឪពុករបស់ដើមចោទឱ្យនិយាយប្រាប់ពីអ្វីដែលគាត់បានដឹង។ គាត់បាននិយាយថា កូនស្រីរបស់គាត់ធ្លាប់មករកគាត់ឱ្យជួយពីព្រោះប្តីរបស់នាងវាយធ្វើបាបនាង។ បន្ទាប់មកគាត់ក៏បានប្រាប់នាងឱ្យត្រលប់ទៅផ្ទះប្តីនាងវិញ។

*គាត់បានប្រាប់នាងថា វាមិនមែនជាការល្អទេដែលនាងចាកចោលផ្ទះដោយសារតែវិវាទ បន្តិចបន្តួចជាមួយប្តីនាងនោះ ។ មុនពេលរៀបការ គ្រួសារលោក OK បានជូនគាត់ ៤០០.០០០ រៀល ។ ពីរឿងផ្ទះគាត់មានដី ហើយឪពុកម្តាយរបស់លោក OK បានចេញថ្លៃសម្ភារ: ។ ឥឡូវគាត់ចង់បានដីរបស់គាត់ត្រលប់មកវិញ ។*

*-ចៅក្រមបានសួរទៅឪពុករបស់ចុងចម្លើយ ឱ្យនិយាយប្រាប់ពីអ្វីដែលគាត់បានដឹង ។ គាត់បាននិយាយថាគាត់មិនដែលឃើញកូនប្រុសគាត់វាយធ្វើបាបនាង SC ទេ ប៉ុន្តែបានលេងសើចជាមួយនឹងនាងដែលបានទិញឆ្នោត ។ អំពីរឿងផ្ទះគាត់បានចេញថ្លៃសម្ភារ:សាងសង់ ។ ឥឡូវគាត់យល់ព្រមរុះរើផ្ទះចេញពីដីនោះវិញ និងប្រគល់ដីនោះទៅឱ្យនាង SC វិញ ។*

*-ក្រោយពីបានស្តាប់គូភាគីរួចមក ចៅក្រមបានសួរទៅព្រះរាជអាជ្ញា ថាតើគាត់មានអ្វីកត់សំគាល់ទេទៅលើរឿងហេតុ និងនីតិវិធី ។ ព្រះរាជអាជ្ញាបានសង្កេតឃើញថា គូភាគីបានទាមទារសុំលែងលះ និងបដិសេធមិនព្រមសះជា ។ អំពីរឿង ផ្ទះនិងដី គូភាគីក៏បានឈានដល់ការព្រមព្រៀងរួចហើយដែរ ។ ហេតុដូច្នេះ ចៅក្រមអាចធ្វើការសម្រេចបាន ។*

*-បន្ទាប់មក ចៅក្រមបានប្រកាសផ្អាកសវនាការ និងដកខ្លួនទៅសរសេរសាលក្រម (ប៉ុន្តែអ្វីដែលបានកើតឡើងនៅដំណាក់កាលនេះ គឺថាចៅក្រមហាក់ដូចជាបានសរសេរសាលក្រមរួចជាស្រេច ពីព្រោះគាត់មិនបានចូលទៅក្នុងបន្ទប់ ដើម្បីសរសេរសាលក្រមទេ ហើយគាត់បានអានសាលក្រមភ្លាមៗតែម្តង) ។*

*សាលក្រមរបស់តុលាការបានសម្រេចដូចតទៅ :*

- *បញ្ជាឱ្យគូភាគីលែងលះ*
- *បញ្ជាឱ្យនាង SC ឋិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃ*
- *លោក OK រុះរើផ្ទះចេញពីដី*
- *ផ្តល់ដីឱ្យទៅនាង SC វិញ ។*

### ការរំលោភសេពសន្ថវៈ និងរឿងក្តីផ្សេងទៀតនៃអំពើហិង្សាខាងយេនឌ័រ

ទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ ស្ត្រីប្រឈមមុខនឹងនីតិវិធីព្រហ្មទណ្ឌ ក្នុងនាមជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ការជួញដូរមនុស្ស និងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរផ្សេងៗទៀត ។ តាមពិតទៅ ៧% នៃរឿងក្តីព្រហ្មទណ្ឌ ទាក់ទងនឹងបទរំលោភសេពសន្ថវៈ ។ តែទោះបីជាយ៉ាងណាក្តី ឧបសគ្គដែលស្ត្រីបានប្រឈមបានបំបាក់ទឹកចិត្តរបស់ពួកគេ ក្នុងការប្តឹងទៅតុលាការ ។ ដំបូងជនរងគ្រោះត្រូវបង់ថ្លៃធ្វើកោសល្យវិច្ច័យដើម្បីធ្វើការពិនិត្យ[២២៧] ។ បន្ទាប់មកនាងត្រូវទទួលបន្ទុកចំណាយក្នុងការនាំសាក្សី និងសាច់ញាតិនានាទៅតុលាការ ។ ចុងក្រោយនាងមិនបានទទួលការគាំទ្រណាមួយឡើយ ទាំងផ្នែកហិរញ្ញវត្ថុ ស្មារតី និងទឹកចិត្ត ។ សំពាធពីជនដៃដល់ក្នុងរឿងក្តីរំលោភសេពសន្ថវៈ ឬអំពើហិង្សាក្នុងគ្រួសារ និងការលំបាកសម្រាប់ដោះស្រាយរឿងក្តីទាំងនេះ បានជម្រុញឱ្យស្ត្រីទទួលយកការសម្រុះសម្រួលនៅខាងក្រៅតុលាការ ។

### អ្នកក្រីក្រ និងប្រព័ន្ធតុលាការ

យោងតាមអ្នកដែលបានចូលរួមក្នុងសិក្ខាសាលា និងព័ត៌មានដែលទទួលបានពីតុលាការនៅក្នុងខេត្តកំពង់ស្ពឺ រឿងក្តីព្រហ្មទណ្ឌមួយចំនួនទាក់ទងនឹងការចាប់យកដី ដែលបានដាក់ពាក្យប្តឹងដោយអ្នកមានទ្រព្យសម្បត្តិ ប្រឆាំងនឹងអ្នកភូមិ ។ យោងតាមព្រះរាជអាជ្ញាមកពីខេត្តមណ្ឌលគិរី នៅក្នុងរឿងក្តីទាក់ទងនឹងព្រៃឈើមួយចំនួន ជនជាប់ចោទជាជនក្រីក្រ ត្រូវទទួលរងការចោទប្រកាន់ពីបទកាប់ឈើខុសច្បាប់ ប៉ុន្តែពុំមានករណីបែបនេះណាមួយទាក់ទងនឹងក្រុមហ៊ុន ឬអ្នកមានទ្រព្យសម្បត្តិឡើយ ។

[២២៧] សូមមើល ឧបសម្ព័ន្ធទី២ បន្ថែម

ដោយសារការខ្វះខាតមេធាវីការពារ នៅក្នុងករណីជាច្រើនតុលាការបង្ខំចិត្តសម្រេចសេចក្ដី ដោយគ្មានបានផ្ដល់អ្នកការពារផ្លូវច្បាប់ដល់ជនជាប់ចោទទេ សូម្បីតែក្នុងរឿងបទឧក្រិដ្ឋក្ដី។ នៅក្នុងខេត្តមួយចំនួនអង្គការក្រៅរដ្ឋាភិបាលបានជួយចេញថ្លៃលើកម្រៃលើមេធាវី។

ជនជាតិដើមភាគតិចប្រឈមមុខនឹងបញ្ហាទ្វេដងនៅចំពោះមុខប្រព័ន្ធតុលាការ។

នៅក្នុងខេត្តដែលមានជនជាតិដើមភាគតិចរស់នៅ សេវាយុត្តិធម៌មានភាពកម្រ នៅឆ្ងាយ និងមិនត្រូវបានស្គាល់ដោយជនជាតិដើមភាគតិចទេ។ ហេតុដូចនេះ ពួកគេមិនបានប្រើប្រាស់សេវានេះ ដើម្បីការពារសិទ្ធិលើអចលនវត្ថុរបស់ពួកគេ ប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដីដោយអ្នកខាងក្រៅ និងអំពើពុករលួយឡើយ។

ផ្ទុយទៅវិញ នៅពេលដែលជនជាតិដើមភាគតិចជាចុងចោទ នោះពួកត្រូវប្រឈមដោយគ្មានមេធាវី និងអ្នកបកប្រែ។ ជនជាតិដើមភាគតិចដែលជាប់ពន្ធនាគារ គេនៅឆ្ងាយពីសហគមន៍ និងសាច់ញាតិរបស់ខ្លួន ហើយខ្វះខាតការគាំទ្រក្នុងការការពារសិទ្ធិខ្លួន។

អ្នកចូលរួមក្នុងអង្គសិក្ខាសលានានា បានវាយតម្លៃចំពោះប្រព័ន្ធយុត្តិធម៌ផ្លូវការដូចខាងក្រោម :

## ២.៨.៤. ការវាយតម្លៃ

| ចំណុចល្អ | ចំណុចខ្វះខាត | អនុសាសន៍ |
|---|---|---|
| - សេចក្ដីសម្រេចផ្អែកលើច្បាប់<br>- អាចធ្វើសេចក្ដីសម្រេចគ្រប់ករណីទាំងអស់<br>- សេចក្ដីសម្រេចផ្អែកលើភស្តុតាង<br>- សេចក្ដីសម្រេចអាចដាក់ឱ្យអនុវត្តសម្រាប់ភាគីបាន<br>- ការស៊ើបអង្កេតត្រឹមត្រូវ<br>- មានច្បាប់ផ្សេងៗទាក់ទងនឹងការរៀបចំ និងដំណើរការរបស់តុលាការ<br>- ផ្ដល់ដំបូន្មានល្អដល់គូភាគី។ | - នៅឆ្ងាយពីប្រជាពលរដ្ឋ (មានតែនៅថ្នាក់ខេត្ត)<br>- ថ្លៃ និងប្រើពេលយូរ<br>- សេវាមិនល្អ និងពិបាកសម្រាប់ប្រជាពលរដ្ឋក្នុងការទៅរក និងទាក់ទង<br>- ជនរងគ្រោះដោយបទល្មើសព្រហ្មទណ្ឌបង់ថ្លៃពិនិត្យធ្វើ កោសល្យវិច័យ<br>- សេចក្ដីសម្រេចចាញ់-ឈ្នះ ដែលធ្វើឱ្យគូភាគីអាចក្លាយជាសត្រូវនឹងគ្នា<br>- ប្រជាពលរដ្ឋមិនទម្លាប់ជាមួយនឹងនីតិវិធី និងច្បាប់ ព្រមទាំងភាសាដែលប្រើនៅក្នុងតុលាការ<br>- អំពើពុករលួយ/បក្ខពួកនិយម<br>- សវនាការមិនមានតម្លាភាព<br>- ខ្វះមេធាវី<br>- គូភាគីត្រូវបានជម្រិតទារប្រាក់ដោយមន្ត្រីរបស់តុលាការ<br>- ការស៊ើបអង្កេតមិនបានគ្រប់គ្រាន់<br>- ចៅក្រម និងព្រះរាជអាជ្ញា មិនមានសមត្ថភាព | - ច្បាប់ និងនីតិវិធីគួរតែត្រូវបានអនុវត្តនៅក្នុងការធ្វើសេចក្ដីសម្រេច<br>- បង្កើនសមត្ថភាពចៅក្រម និងព្រះរាជអាជ្ញា<br>- ផ្សព្វផ្សាយព័ត៌មាន ស្ដីពីប្រព័ន្ធតុលាការ ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន<br>- ជនរងគ្រោះមិនគួរបង់ថ្លៃការត្រួតពិនិត្យធ្វើកោសល្យវិច័យ<br>- លុបបំបាត់អំពើពុករលួយ<br>- បង្កើនប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរបស់តុលាការ<br>- ធានាយុត្តិធម៌សម្រាប់អ្នកក្រីក្រ និងការទទួលបានជំនួយផ្នែកច្បាប់<br>- ការបកប្រែសម្រាប់ជនជាតិភាគតិចភ្នង<br>- តុលាការគួរតែត្រូវបានបង្កើតនៅថ្នាក់ស្រុក<br>- តុលាការឧទ្ធរណ៍គួរត្រូវបានបង្កើតនៅថ្នាក់ខេត្ត<br>- ដាក់ទោសដល់ចៅក្រមដែលប្រព្រឹត្តអំពើពុករលួយ<br>- កាត់បន្ថយការិយាធិបតេយ្យ និងត្រូវមានតម្លាភាព ព្រមទាំងដោះស្រាយរឿងក្ដីឱ្យបានលឿនជាងមុន<br>- គួរមានច្បាប់ឱ្យបានគ្រប់គ្រាន់ |

# ៣. ការផ្តល់សេវាច្បាប់

## ៣.១. ជំនួយការច្បាប់

ក្របខ័ណ្ឌស្ថាប័ននៃការផ្តល់ជំនួយការច្បាប់ក្នុងនីតិវិធីព្រហ្មទណ្ឌ

គ្រប់ចុងចោទទាំងអស់គួរតែទទួលបាននូវជំនួយការពីមេធាវីដើម្បីធានាថា យុត្តិធម៌ពិតជាត្រូវបានគេផ្តល់។ ចៅក្រម និងព្រះរាជអាជ្ញាមួយចំនួនបានរៀបរាប់ឱ្យដឹងថា ដោយសារមិនមានមេធាវីនៅក្នុងខេត្តខ្លះនៅក្នុងប្រទេស នាំឱ្យពួកគេបង្ខំចិត្ត ត្រូវតែកាត់សេចក្តីដោយគ្មានមេធាវី ដូចជានៅក្នុងខេត្តរតនៈគីរីជាដើម។

យោងតាមរបាយការណ៍របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៤) មានមេធាវីចំនួន ៣២៨នាក់ នៅទូទាំងប្រទេស ហើយមានតែ១៩៧នាក់ប៉ុណ្ណោះដែលកំពុងប្រកបរបរជាមេធាវី។ មានន័យថាមានមេធាវីប្រហែល ៨នាក់ ក្នុងខេត្តមួយ។ ដោយសារភាគច្រើនប្រមូលផ្តុំនៅក្នុងភ្នំពេញ នោះនាំឱ្យនៅខេត្តមួយចំនួនពុំមានមេធាវី។ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ផ្តល់មេធាវីដល់អ្នកជាប់ចោទដែលជាប់ឃុំឃាំង និងជនរងគ្រោះ។ អង្គការក្រៅរដ្ឋាភិបាលបានផ្តល់ មេធាវីនៅក្នុងខេត្តចំនួន ១០។ LAC គឺជាអង្គការក្រៅរដ្ឋាភិបាលដែលបានផ្តល់មេធាវី នៅក្នុងខេត្តជាច្រើន (៩ខេត្ត)។ ជាថ្មីម្តងទៀត ខេត្តមណ្ឌលគីរី និងរតនៈគីរីមានការខ្វះខាតមេធាវីយ៉ាងខ្លាំង។ ភាគរយនៃស្ត្រីជាមេធាវីមាន ១៦% នៃចំនួនសរុប (៥៣ លើ ៣២៨នាក់)។ កង្វះខាតស្ត្រីនៅក្នុងសេវារបស់តុលាការ គឺជាបន្ទុកទ្វេសម្រាប់ស្ត្រី ដែលត្រូវទៅរកតុលាការក្នុងនាមខ្លួន ជាជនរងគ្រោះ ឬជាដើមបណ្តឹង។

**តារាងនៃមេធាវីនៅព្រះរាជាណាចក្រកម្ពុជា**

| ឆ្នាំ | ១៩៩៨ | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | មិនា ២០០៥ |
|---|---|---|---|---|---|---|---|
| មេធាវីកំពុងប្រកបវិជ្ជាជីវៈ | ១១៤ | ១៦១ | ១៥៨ | ១៦៣ | ១៧៦ | ១៩៧ | ២២២ (ស្ត្រី ២១) |
| មេធាវីមិនប្រកបវិជ្ជាជីវៈ ដោយសារមានវិសមត្ថភាពមុខងារ | ០៥ | ០៦ | ០៤ | ០៤ | ០៥ | ០៦ | ១៤ (ស្រី ១) |
| មេធាវីកម្មសិក្សា | ៧៦ | ០៩ | ០៩ | ១៦ | ៣៨ | ៧២ | ១១២ (ស្រី ៣០) |
| មេធាវីមិនប្រកបវិជ្ជាជីវៈ | ១៤ | ៣៩ | ៤៨ | ៤៧ | ៤៥ | ៥០ | ៥៤ (ស្រី ៧) |
| មេធាវីដែលមិនមានសិទ្ធិប្រកបវិជ្ជាជីវៈ | ០១ | - | ០៣ | - | ០៣ | ០២ | ១១ (ស្រី ៣) |
| មេធាវីដែលមានសិទ្ធិប្រកបវិជ្ជាជីវៈត្រូវបានព្យួរ | - | - | ០១ | ០១ | ០១ | ០១ | ០១ ជាស្ត្រី |
| សរុប | ២១៤ | ២១៥ | ២២៣ | ២៣១ | ២៦៨ | ៣២៨ | ៤២៤ (ស្រី ៦៣) |

*ប្រភព: របាយការណ៍របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៤*

ការិយាល័យជំនួយផ្នែកច្បាប់ដែលមានវត្តមាននៅតាមខេត្ត/ក្រុង[២២៨]

| អង្គការក្រៅរដ្ឋាភិបាល | Adhoc | Bar | CDP | CLEC | CWCC | LAC | PPJJ |
|---|---|---|---|---|---|---|---|
| ចំនួនខេត្តដែលគ្មានមេធាវី | ២៣ | ២៣ | ២០ | ២៣ | ២៣ | ១៥ | ២២ |
| ចំនួនខេត្តសរុបដែលមានមេធាវី | ១ | ១ | ៤ | ១ | ១ | ៩ | ២ |
| បាត់ដំបង | | | មាន | | | មាន | មាន |
| កំពង់ចាម | | | មាន | | | មាន | |
| កណ្ដាល | | | | | | មាន | |
| កោះកុង | | | | | | មាន | |
| ក្រចេះ | | | | | | មាន | |
| ភ្នំពេញ | មាន | មាន | មាន | មាន | មាន | មាន | |
| ព្រៃវែង | | | | | | | មាន |
| សៀមរាប | | | មាន | | | មាន | |
| ក្រុងព្រះសីហនុ | | | | | | មាន | |
| ស្វាយរៀង | | | | | | មាន | |

## ៣.២. សិទ្ធិមានអ្នកបកប្រែ

| | | |
|---|---|---|
| រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ - ធ្វើវិសោធនកម្មឆ្នាំ ១៩៩៩ | មាត្រា៣១ : | ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។ |
| កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាបានឱ្យសច្ចាប័ន | មាត្រា ១៤ : | ...<br>៣. ក្នុងករណីនៃការសម្រេចវិនិច្ឆ័យទោសឧក្រិដ្ឋ ជនជាប់ចោទគ្រប់រូបមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលកិច្ចធានាខ្លះៗដូចជា:<br>ក. ការប្រាប់ឱ្យដឹងខ្លួនភ្លាមពីលក្ខណៈ និងហេតុផលនៃការផ្ដន្ទាទោសនេះ ហើយគេត្រូវ និយាយភាសាដែលសាមីខ្លួនអាចស្ដាប់បានគ្រប់គ្រាន់ ។<br>ខ. សាមីខ្លួនត្រូវមានពេលវេលា ព្រមទាំងសំភារៈគ្រប់គ្រាន់ ក្នុងការត្រៀមការពារខ្លួន និងធ្វើ ទំនាក់ទំនងជាមួយទីប្រឹក្សាដែលខ្លួនបានជ្រើសរើស ។<br>...<br>ឃ .ការជំនុំជំរះត្រូវធ្វើនៅចំពោះមុខសាមីជន ។ សាមីជនអាចឆ្លើយដោះសារដើម្បីការពារខ្លួនដោយខ្លួនឯង ឬអាចរកស្មាក្ដីឱ្យជួយការពារខ្លួនដោយខ្លួនឯង ។ សាមីជនត្រូវបានប្រាប់ឱ្យដឹងពីសិទ្ធិនេះ ប្រសិនជាខ្លួនមិនទាន់មានស្មាក្ដី ហើយត្រូវទទួលបាននូវជំនួយជាស្មាក្ដី ក្នុងករណីដែលផលប្រយោជន៍ប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើស្មាក្ដីនេះ ។ |

[២២៨] ប្រភព: សម្ភាសជាមួយអង្គការទាំងនេះ ។ សូមមើលតារាងក្នុងឧបសម្ព័ន្ធ ៤ ។

| | |
|---|---|
| | ...<br>ច. ត្រូវមានអ្នកបកប្រែដោយឥតគិតឈ្នួល ក្នុងករណីដែលសាមីជនមិនយល់ ឬមិនចេះភាសា ដែលប្រើប្រាស់នៅក្នុងតុលាការ ។<br>មាត្រា ២៧ : ក្នុងរដ្ឋទាំងឡាយ ដែលជាសមាជិកនៃកតិកាសញ្ញានេះ តែងតែមានប្រជាពលរដ្ឋភាគតិចសព្វបែបយ៉ាង ទាំងក្នុងវិស័យសាសនា និងវិស័យភាសា។ មនុស្សដែលជាសមាជិកនៃសង្គមភាគតិចទាំងនេះ មានសិទ្ធិក្នុងការគោរពទំនៀមទំលាប់វប្បធម៌ខ្លួន សិទ្ធិក្នុងការគោរព និងប្រារព្ធពិធីសាសនាខ្លួន ព្រមទាំងសិទ្ធិក្នុងការប្រើប្រាស់ភាសាកំណើតខ្លួន ទាំងនៅក្នុងសហគមន៍ខ្លួន ទាំងជាមួយសមាជិកដទៃទៀត ។ |
| **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣)** | មាត្រា ១៣៦ : បើជនជាប់ចោទ ឬសាក្សីជាមនុស្សគ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះ ក្រឡាបញ្ជីត្រូវសរសេរសំនួរ និងការកត់សំគាល់ផ្សេងៗ ឱ្យទៅជនជាប់ចោទ ឬសាក្សីទាំងនោះ ដើម្បីឱ្យឆ្លើយមកវិញជាលាយលក្ខណ៍អក្សរ ។ បើជនគ ថ្លង់ មិនចេះសរសេរអក្សរ ចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនម្នាក់ ដែលមានទំលាប់ទាក់ទងមនុស្សគ ថ្លង់ ដោយកាយវិការដើម្បីធ្វើជាអ្នកបកប្រែ ។ |
| **សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ (ស្ថានភាពឆ្នាំ ២០០៥)** | មាត្រា ១៣១ : ក្នុងករណីចាំបាច់ ចៅក្រមស៊ើបអង្កេតត្រូវហៅរកអ្នកបកប្រែ។ អ្នកបកប្រែត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា ខ្លួននឹងជួយដល់តុលាការ និងបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងឡាយ ។ ក្នុងករណីណាក៏ដោយអ្នកបកប្រែ មិនអាចត្រូវបានជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល អាវុធហត្ថ ភាគី ឬសាក្សីទេ ។<br><br>មាត្រា ១៦៥ : ...<br>មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ដែលបានស្បថស្រប តាមសាសនា ឬជំនឿ របស់ខ្លួនថានឹងជួយបកប្រែជូនតុលាការឱ្យបានត្រឹមត្រូវ ។<br><br>មាត្រា ២៧៣ : ក្នុងករណីដែលតុលាការបានទទួលបណ្តឹង ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរព្រះរាជអាជ្ញា ត្រូវកោះហៅឱ្យចូលរួមក្នុងសវនាការ:<br>- ជនជាប់ចោទ<br>- ដើមបណ្តឹងរដ្ឋប្បវេណី<br>- ជនរងគ្រោះ កាលណាជននេះមិនទាន់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅមុខចៅក្រមស៊ើបសួរ<br>- សាក្សី<br>- អ្នកជំនាញ<br>- អ្នកបកប្រែ<br>- អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី តាមព័ត៌មានដែលផ្តល់ឱ្យដោយជនជាប់ចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។<br><br>មាត្រា ៣០៦ : ក្នុងករណីចាំបាច់ប្រធានតុលាការ អាចហៅរកអ្នកបកប្រែ ។ អ្នកបកប្រែនេះត្រូវស្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការ និងបកប្រែចម្លើយឱ្យបានត្រឹមត្រូវ ។ នៅក្នុងករណីណាក៏ដោយអ្នកបកប្រែមិនអាចត្រូវបាន |

| | |
|---|---|
| | ជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល អាវុធហត្ថ គូភាគី ឬសាក្សីទេ។<br><br>មាត្រា ៣០៧ : កាលណាត្រូវសួរសំណួរដល់ជនថ្លង់ ត ក្រឡាបញ្ជីត្រូវសរសេរសំនួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយដោយលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនចេះអក្សរ ប្រធានតុលាការត្រូវរកអ្នកជំនាញ ឬអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះមកបកប្រែ។ |

## ៣.៣. អ្នកជំនាញៈ ធ្វើកោសល្យវិច័យដោយឥតគិតថ្លៃ

យោងតាមរដ្ឋធម្មនុញ្ញ ជនក្រីក្រមានសិទ្ធិទទួលបានការពិនិត្យព្យាបាលដោយឥតគិតថ្លៃ។ យោងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ តម្លៃនៃការធ្វើកោសល្យវិច័យគួរត្រូវបានបង់ដោយជនជាប់ចោទ ប្រសិនបើត្រូវបានរកឃើញថាមានទោសមែន។ បើមិនដូច្នេះទេ រដ្ឋត្រូវទទួលបន្ទុកលើការចំណាយនេះ។ ក្នុងការអនុវត្តជាក់ស្តែង ជនរងគ្រោះត្រូវបានស្នើសុំឱ្យបង់ប្រាក់ បើមិនដូច្នោះទេ ពួកគេនឹងមិនត្រូវបានគេពិនិត្យឡើយ[២២៩]។ ករណីនេះនាំឱ្យជនរងគ្រោះ ក្លាយជាជនរងគ្រោះទ្វេដងសម្រាប់ស្ត្រីរងគ្រោះដោយការរំលោភសេពសន្ថវៈ ឬរងរបួសស្នាម។ នេះជាការចំណាយយ៉ាងច្រើន រួមនឹងការចំណាយលើការធ្វើដំណើរពីភូមិ ដែលភាគីរស់នៅបើសិនជាពួកគេរស់នៅភូមិ ឬឃុំឆ្ងាយពីទីប្រជុំជននោះ។ ព្រះរាជអាជ្ញាមិនធ្វើដំណើរទៅភូមិនានាទេ។ ដូចនេះ ជនរងគ្រោះត្រូវតែធ្វើដំណើរជាច្រើនលើកមកកាន់ទីរួមខេត្ត-ក្រុង ត្រូវបាត់បង់ការរកចំណូលរាល់ពេលដែលគេមកទីរួមខេត្ត និងត្រូវចេញលុយលើការធ្វើដំណើរ និងម្ហូបអាហារសម្រាប់ខ្លួនគេនិងសាក្សីរបស់គេថែមទៀត។ និយាយឱ្យខ្លីមក តម្លៃធ្វើកោសល្យវិច័យ និងការចំណាយសម្រាប់សវនការ បានក្លាយជារបាំងចំពោះជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌ និងបង្កឱ្យមានការរងគ្រោះក្លាយជាជនរងគ្រោះទ្វេរដង។

ក្របខ័ណ្ឌច្បាប់:

**តារាងស្តីពីបទបញ្ញត្តិនានាទាក់ទិននឹងតម្លៃធ្វើកោសល្យវិច្ច័យ និងដោយឥតគិតថ្លៃ សម្រាប់ជនក្រីក្រ**

| សិទ្ធិ | បទបញ្ញត្តិនានា |
|---|---|
| ការពិនិត្យ និងពិគ្រោះយោបល់ដោយឥតគិតថ្លៃសម្រាប់អ្នកក្រីក្រ | **រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ធ្វើវិសោធនកម្ម ឆ្នាំ ១៩៩៩**<br>មាត្រា ៧២ : សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ |
| កោសល្យវិច្ច័យដោយឥតគិតថ្លៃសម្រាប់ជនរងគ្រោះ | **ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣)**<br>មាត្រា ៨៨ : ចំណាយផ្សេងៗក្នុងកោសលវិច្ច័យ ត្រូវបញ្ចូលជាមួយប្រាក់ប្រដាប់ក្តី ហើយដាក់ទៅក្នុងបន្ទុកជនជាប់ចោទ កាលបើអ្នកជាប់ចោទនោះត្រូវផ្តន្ទាទោសជាស្ថាពរនៅពេលខាងមុខ។ បើជនជាប់ចោទត្រូវបានរួចខ្លួន ប្រាក់ចំណាយក្នុងកោសលវិច្ច័យត្រូវនៅក្នុងបន្ទុករបស់រដ្ឋ។ |

[២២៩] នៅក្នុងខេត្តរតនៈគីរី ប្រធានតុលាការបានបញ្ជាក់ប្រាប់ក្រុមការងារថា មានករណីមួយចំនួនប្រជាពលរដ្ឋជាជនរងគ្រោះ បានកាន់លិខិតបញ្ជាក់អំពីភាពក្រីក្រ ដែលចេញដោយមេភូមិ។ ក្នុងករណីនេះ មន្ទីរពេទ្យអាចជួយពិនិត្យ និងធ្វើកោសល្យវិច្ច័យដោយឥតគិតថ្លៃ។

| | |
|---|---|
| សេចក្តីណែនាំ ស្តីពី ការចេញវិញ្ញាបនបត្រពេទ្យដោយក្រសួងសុខាភិបាល ឆ្នាំ ២០០១ | ១. អង្គភាពរដ្ឋ និងឯកជនដែលមានសិទ្ធិទទួលពិនិត្យព្យាបាល និងចេញវិញ្ញាបនបត្រពេទ្យ (កោសលវិច្ច័យ) គឺ:<br>ក. មន្ទីរពេទ្យជាតិ ដែលមានមន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យព្រះបាទនរោត្តមសីហនុ មន្ទីរពេទ្យព្រះកុសុមៈ មន្ទីរពេទ្យព្រះអង្គឌួង មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យគន្ធបុប្ផា មជ្ឈមណ្ឌលគាំពារមាតា និងទារក និងវិទ្យាស្ថានកំចាត់រោគរបេង។<br>ខ. មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ និងខេត្តក្រុង<br>គ. សេវាឯកជនដែលមានច្បាប់ត្រឹមត្រូវ។<br>៣. ការចេញវិញ្ញាបនប័ត្របញ្ជាក់ស្លាកស្នាមរបួស ពិការ (កោសលវិច្ច័យ) អាចធ្វើទៅបាន លុះត្រាតែមានការស្នើសុំពីក្រសួងយុត្តិធម៌ តុលាការខេត្ត-ក្រុង អធិការដ្ឋាន (ស្នងការដ្ឋាន) នគរបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធក្នុងការដោះស្រាយវិវាទ និងសាមីខ្លួនដែលពាក់ព័ន្ធក្នុងការបំពេញសំណុំលិខិតពាក្យបណ្តឹងនានា។ លិខិតស្នើសុំចេញវិញ្ញាបនបត្រខាងលើ ត្រូវធ្វើផ្ទាល់នៅមន្ទីរពេទ្យ ឬនៅសេវាឯកជនដូចមានចែងក្នុងចំណុច ក-ខ-គ ស្តីពីសមត្ថកិច្ច និងការទទួលខុស ត្រូវក្នុងការចេញវិញ្ញាបនបត្រពេទ្យ (កោសល្យវិច្ច័យ) ខាងលើ។ |
| សេចក្តីព្រាងក្រម នីតិវិធីព្រហ្មទណ្ឌ (ស្ថានភាពឆ្នាំ ២០០៥) | មាត្រា ១៥៧ : ប្រាក់ចំណាយក្នុងការធ្វើកោសល្យវិច្ច័យជាបន្ទុករបស់អ្នកស្នើសុំ។ ចំពោះការស្នើសុំធ្វើកោសលវិច្ច័យ ឬកោសល្យវិច្ច័យបន្ថែម ឬប្រតិកោសល្យវិច្ច័យរបស់ចៅក្រម ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលជាបន្ទុករបស់ថវិការដ្ឋ។ |

តម្លៃធ្វើកោសល្យវិច្ច័យៈ ជនរងគ្រោះទ្វេរដង

ការពិនិត្យធ្វើកោសល្យវិច្ច័យ មានភាពចាំបាច់នៅក្នុងរឿងក្តីមួយចំនួន ដូចជារឿងក្តីរំលោភសេពសន្ថវៈ និងការបង្ករបួសស្នាម ដូច្នេះព្រះរាជអាជ្ញាអាចមានភស្តុតាងក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការ។ នៅមន្ទីរពេទ្យ គ្រូពេទ្យស្នើសុំការចំណាយលើការធ្វើកោសល្យវិច្ច័យ ដើម្បីពិនិត្យជនរងគ្រោះ។ តម្លៃចំណាយទាំងនោះមានកម្រិតខ្ពស់ បើធៀបទៅនឹងចំណូលរបស់ប្រជាពលរដ្ឋនៅតាមជនបទ។ បើតាមព្រះរាជអាជ្ញា និងចៅក្រមដែលបានធ្វើបទសម្ភាសន៍ តម្លៃធ្វើកោសល្យវិច័យគឺមានពី ២០.០០០ រៀល (៥ ដុល្លារអាមេរិក) រហូតដល់ ៥០.០០០ រៀល (១៣ ដុល្លារអាមេរិក)។ នៅក្នុងរឿងក្តីខ្លះ តម្លៃមានកម្រិតខ្ពស់ជាងនេះ ហើយនៅពេលដែលមានអង្គការក្រៅរដ្ឋាភិបាល ចូលពាក់ព័ន្ធអង្គការនោះជាអ្នកបង់ថ្លៃនោះ[២៣០]។ សូម្បីតែចៅក្រម ព្រះរាជអាជ្ញា និងនគរបាល ក៏និយាយថា មានពេលខ្លះពួកគេបង់ថ្លៃនោះ ដើម្បីឱ្យគ្រូពេទ្យចេញលិខិតបញ្ជាក់របស់ពេទ្យឱ្យជនរងគ្រោះដែរ។ បើគិតទៅដល់ចំណូលជាមធ្យមរបស់បុគ្គលម្នាក់ នៅតំបន់ជនបទមានត្រឹមមួយដុល្លារនោះ ជនរងគ្រោះមិនអាចមានលុយបង់ថ្លៃធ្វើកោសល្យវិច្ច័យនេះបានទេ ព្រោះវាប្រហាក់ប្រហែលស្មើនឹងចំណូលពាក់កណ្តាលខែឯនោះ។

[២៣០] គ្រប់អង្គការក្រៅរដ្ឋាភិបាលដែលយើងខ្ញុំបានសម្ភាសជាមួយបានបញ្ជាក់ថា ពួកគេត្រូវតែបង់ថ្លៃធ្វើកោសល្យវិច្ច័យរវាងពី ២០០០០ ទៅ ២០០ ០០០ រៀល ដោយប្រែប្រួលពីខេត្តមួយទៅខេត្តមួយ (ADHOC, CWCC, VIGILANCE)

## ៤. តារាងសង្ខេប ស្ដីពីការផ្ដល់សេវាយុត្តិធម៌តាមស្ថាប័ននីមួយៗ

| ការផ្ដល់សេវាយុត្តិធម៌ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រភេទរឿងក្ដីដែលទទួល និង មុខងារ | ស្ថាប័នដែលមាន (នៅមូលដ្ឋាន) | ក្របខ័ណ្ឌច្បាប់ | ប្រភពផ្លូវច្បាប់ / ការទទួលយក | ធនធានមនុស្ស | ធនធានសម្ភារៈ / ហិរញ្ញវត្ថុ | វិធីធ្វើការងារ / លទ្ធផល | តម្លៃសម្រាប់ភាគី |
| **មេឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ** | - រឿងគ្រួសារផ្សេងៗ<br>- ប្រមូលមូលនិធិសម្រាប់កសាងផ្លូវ<br>- បញ្ហានៅមូលដ្ឋាន | ភូមិ | - ចាស់ទុំ : គ្មាន | - កិត្តិនាម | ជាច្រើន ពួកគេមាន កិត្តិនាម | មិនបានទទួលពីរដ្ឋទេ | - បញ្ចុះបញ្ចូល<br>- សម្រុះសម្រួល<br>- ធ្វើការជាមួយមេភូមិ | - ប្រែប្រួល |
| **គណៈកម្មាធិការវត្ត** | - រឿងទាក់ទងវត្ត និងព្រះសង្ឃ<br>- ចាំទ្រេបញ្ហានានានៅមូលដ្ឋាន និងគណៈកម្មាធិការនានា | ភូមិ | - គណៈកម្មាធិការវត្ត: ច្បាប់ភូមិបាល មាត្រា ២០ | - គណៈកម្មាធិការវត្ត : បោះឆ្នោតជ្រើសរើសដោយសហគមន៍ ឬ បានតែងតាំងដោយគណៈកម្មាធិការដែលមានពីមុន ។ល។ | បង្កើតឡើងដោយចាស់ទុំ ( ភាគច្រើនជាបុរស) | - មិនបានទទួលពីរដ្ឋទេ<br>- ប្រមូលមូលនិធិ | - គោលការណ៍ឯកច្ឆន្ទ (Consensus) | ? |
| **អាជ្ញាធរជនជាតិ ដើមភាគតិច (ចាស់ទុំ)** | ទាំងអស់ | សហគមន៍ជនជាតិដើមភាគតិច | ច្បាប់ភូមិបាល ( មាត្រា ២៣-២៧): ដីសហគមន៍ និងដីសមូហភាព និងត្រូវគ្រប់គ្រងដោយអាជ្ញាធររបស់ខ្លួនយោងតាមវិធានប្រពៃណីរបស់ខ្លួន | - ប្រាជ្ញា ផ្ដល់សេវាកម្មដល់សហគមន៍ និង<br>- មានកិត្តិនាម<br>- ចាស់ទុំត្រូវបានជ្រើសរើសដោយនីតិវិធីរបស់ខ្លួន | ប្រហែល ៥ នាក់ក្នុងសហគមន៍១ (បុរស និងស្ត្រី)<br>- និយាយភាសាជនជាតិដើមភាគតិច និងដឹងពីវប្បធម៌របស់ពួកគេ | មិនបានទទួលពីរដ្ឋទេ | សម្រុះសម្រួល និង<br>- សេចក្ដីសម្រេច<br>- បញ្ញត្តិនៃកសិកម្ម ពាណិជ្ជ និងរឿងផ្សេងៗទៀត<br>- ចេញជាបទបញ្ជា និងជាអាជ្ញាធរ | - ភាគីដែលខុសត្រូវតែបង់ថ្លៃទៅឱ្យម្ខាងទៀត និងរៀបចំពិធីសម្រាប់ចាស់ទុំ និងសហគមន៍ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **មេភូមិ** | - គ្រប់ប្រភេទរឿងក្តីនៅមូលដ្ឋាន | - ភូមិ | - ច្បាប់ក្រុមប្រឹក្សាឃុំ-សង្កាត់<br>- អាជ្ញាធរប្រតិភូកម្មពីក្រុមប្រឹក្សាឃុំ | - ភាគច្រើនចេញមកពីពេលយូរមកហើយ<br>- ឥឡូវច្បាប់ក្រុមប្រឹក្សាឃុំចែងថា ពួកគេត្រូវតែត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំ | - មានមេភូមិម្នាក់ | -ប្រាក់បៀវត្សរ៍ប្រចាំខែ : ២២.០០០រៀល = ៥.៥ ដុល្លារនាំឱ្យក្នុងមួយឆ្នាំគាត់ទទួលបាន ៦៦ ដុល្លារ<br>- ប្រើប្រាស់ថវិកាជាតិ | - សម្រុះសម្រួល<br>- បញ្ជូនរឿងក្តីទៅឱ្យក្រុម ប្រឹក្សាឃុំ និងនគរបាល | ប្រែប្រួល |
| **ក្រុមប្រឹក្សាឃុំ** | - គ្រប់ប្រភេទរឿងក្តីនៅមូលដ្ឋាន រួមទាំង អំពើហិង្សាក្នុងគ្រួសារ ដីធ្លី និងផ្សេងៗ<br>- ប្រហែល ២៥ ក្នុងមួយឃុំក្នុងមួយឆ្នាំ សរុប:៤០.៥២៥ករណី | - ឃុំ | - ច្បាប់ស្តីពីការគ្រប់គ្រងឃុំ-សង្កាត់( ឆ្នាំ ២០០១) បានផ្តល់សមត្ថកិច្ចខ្លះទៅក្រុមបឹក្សាដើម្បីសម្រុះសម្រួលរឿងក្តី<br>- ក្រុមប្រឹក្សាឃុំ-សង្កាត់ មិនមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទ | ជ្រើសរើសក្នុង ៥ ឆ្នាំម្តងដោយការបោះឆ្នោតតាមនយោបាយ | - ពី ៥ ទៅ ១១ សមាជិកក្រុមប្រឹក្សាក្នុងឃុំនីមួយៗ | - ប្រាក់បៀវត្សរ៍ :<br>- ប្រធានក្រុមប្រឹក្សាឃុំ : ១០០.០០០ រៀល = ២៥ ដុល្លារ អាមេរិក សមាជិក: ១៧.៥ ដុល្លារ<br>- អ្នកផ្សះផ្សា (គម្រោង របស់ CLEC) ១ ដុល្លារក្នុងមួយករណីជូនដល់ អ្នកផ្សះផ្សាម្នាក់ (៣ ដុល្លារក្នុងមួយករណី) | - សម្រុះសម្រួល<br>- បញ្ជូនរឿងក្តីទៅឱ្យក្រុម ប្រឹក្សាឃុំ និងនគរបាល គណៈកម្មការសុរិយោដី តុលាការ និងអាជ្ញាធរផ្សេងទៀត | ប្រែប្រួល<br>- គណៈកម្មាធិការសម្រាប់សន្តិភាព (គម្រោងរបស់ BFD) យកថ្លៃ ១០.០០០ ៛ ក្នុងភាគីម្ខាងៗ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **នគរបាល** | រឿងក្តីព្រហ្មទណ្ឌអំពើហិង្សាក្នុងគ្រួសារថែមទាំងរឿងរដ្ឋប្បវេណីនិងដីធ្លីផងដែរ | - ឃុំ<br>- ស្រុក<br>- ខេត្ត<br>- ជាតិ | - ស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌ<br>- មិនមានសមត្ថកិច្ចក្នុង ការដោះស្រាយវិវាទ<br>- សម្រុះសម្រួលរឿងក្តីរដ្ឋប្បវេណី ឬអនុវត្តរឿងក្តីរដ្ឋប្ប-វេណីនៅក្រៅអំណាចតុលាការ | តែងតាំងដោយក្រសួងមហាផ្ទៃ<br>- រដ្ឋាភិបាល | នគរបាល ៥-៧ នាក់ក្នុងមួយឃុំខ្លះមានកម្រិត អប់រំទាប | ប្រហែល ១៥ ដុល្លារ | - ស៊ើបអង្កេត<br>- បញ្ជូនរឿងក្តីទៅនគរបាល ស្រុក<br>- សម្របសម្រួលដោះស្រាយរវាងគូភាគី | ប្រែប្រួល<br>- វាអាស្រ័យលើចំនួន ឬតម្លៃ នៃការដោះដូរ ឬការដោះស្រាយ |
| **អភិបាលស្រុក** | រឿងក្តីទៅមូលដ្ឋានជាច្រើនប្រភេទ រួមទាំងវិវាទដីធ្លី | - ស្រុក | ឧបសម្ព័ន្ធរបស់ប្រកាស ០៣១ (ឆ្នាំ ១៩៩៨) : ដើរតួនាទីជានគរបាលយុត្តិធម៌ និងនគរបាលរដ្ឋបាល<br>- (៥) ការសម្រុះសម្រួលរឿងក្តីរដ្ឋប្បវេណី និង ដាក់ពិន័យលើ បទល្មើសតូចតាច<br>- អង្គភាពយុត្តិធម៌ | តែងតាំងដោយក្រសួង មហាផ្ទៃ<br>- រដ្ឋាភិបាល | អភិបាលស្រុកម្នាក់និងអភិបាលរង ៥នាក់<br>- អង្គភាពយុត្តិធម៌មួយ | ប្រាក់បៀវត្សន៍ : | - សម្រុះសម្រួល<br>- បញ្ជូនរឿងក្តីទៅក្រុម ប្រឹក្សាឃុំនគរបាលតុលាការ និងអភិបាលខេត្ត | - គូភាគីនិយាយថាពួក គេត្រូវបង់លុយខ្លះ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **អភិបាលខេត្ត** | រឿងក្តីទៅមូលដ្ឋាន រួមទាំងវិវាទ ដីធ្លី | - ខេត្ត | ច្បាប់ប្រកាស០៣១ (១៩៩៤)<br>- ទទួលបណ្តឹង និងផ្ទេរ ទៅស្ថាប័នមានសមត្ថកិច្ច | តែងតាំងដោយក្រសួង មហាផ្ទៃ | អភិបាលខេត្តម្នាក់ អភិបាលរង ៧<br>- អភិបាលរងទីពីរទទួលបន្ទុក | - ប្រាក់បៀវត្សន៍ : អភិបាល ១២០.០០០ + ប្រាក់ឧបត្ថម្ភ ៧៤០.០០០ = ៨៦០.០០០ អភិបាលរង : ១២០.០០០ + ៦១៥.០០០ | - សម្រុះសម្រួល<br>- បញ្ជូនរឿងក្តីទៅក្រុមប្រឹក្សាឃុំ ទករបាល តុលាការ និងរាជ្ញាធរជាតិ<br>- អន្តរាគមន៍ចំពោះយោធា អំណាចនយោបាយ និងអាជ្ញាធរជាតិ | |
| **គណៈកម្មការសុរិយោដី** | ដីធ្លីមិនទាន់ចុះបញ្ជី | - ស្រុក<br>- ខេត្ត<br>- ជាតិ | ច្បាប់ភូមិបាល ២០០១ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ គណៈកម្មការសុរិយោដី ឆ្នាំ ២០០២ | តែងតាំងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង<br>- រដ្ឋាភិបាល | - ២៤ការិយាល័យខេត្ត<br>- មិនមាននៅគ្រប់ស្រុកទេ តែស្រុកភាគច្រើន | - ប្រាក់បៀវត្សន៍ : ប្រហែល ១២០.០០០ រៀល = ៣០ ដុល្លារ | - ថ្នាក់ស្រុក និងខេត្ត : សម្រុះសម្រួល<br>- ថ្នាក់ជាតិ : កាត់សេចក្តី | - តាមច្បាប់គតគិតថ្លៃ<br>- តែជាក់ស្តែង តម្លៃ (ថត ចម្លង ការធ្វើដំណើរ ។ល។) + ការចំណាយផ្សេងៗទៀត |
| **ក្រុមប្រឹក្សាអាជ្ញាកណ្តាលការងារ** | វិវាទការងាររួម | - ភ្នំពេញ | ច្បាប់ការងារ ១៩៩៧<br>- ប្រកាស ៣១៧ ទីតិវិធីក្នុងការដោះស្រាយវិវាទរួម | | បណ្តុះបណ្តាលដោយ អង្គការ ILO និង ជ្រើសរើសដោយ តួភាគី (អាណត្តិនៃ | - ក្នុង១ករណី ១០០ ដុល្លារក្នុងអាជ្ញាកណ្តាលម្នាក់បង់ដោយអង្គការ | - ដំណាក់កាលទីមួយ : ការចរចារ<br>- ដំណាក់កាលទីពីរ: សេចក្តីបង្គាប់ | - មិនមានការបង់ថ្លៃឡើយ<br>- (គ្មានអំពើពុករលួយ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | - ប្រកាស ៣៣៨ ស្ដីពី ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ២០០២ | | អាជ្ញាកណ្ដាលមាន ១ ឆ្នាំ) | ILO | | ត្រូវបានគេរាយការណ៍ប្រាប់ទេ) |
| **ព្រះរាជអាជ្ញា និងតុលាការ** | - រឿងក្ដីព្រហ្មទណ្ឌ<br>- ការអនុវត្តសាលក្រម( គ្រប់រឿងក្ដី) | - ខេត្ត/ក្រុង<br>- ភ្នំពេញ : ឧទ្ធរណ៍ និង កំពូល | រដ្ឋធម្មនុញ្ញ<br>ច្បាប់<br>- ព្រះរាជក្រមស្ដីពីការបង្កើតក្រសួងយុត្តិធម៌ ១៩៩៦<br>- ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃតុលាការ ១៩៩៣ | តែងតាំងដោយឧត្តម ក្រុមប្រឹក្សានៃអង្គ ចៅក្រម | | - ប្រាក់ខែចៅក្រម<br>- ព្រះរាជអាជ្ញា :<br>- ក្រឡាបញ្ជី | ធ្វើសេចក្ដីសម្រេច<br>- ការលែងលះ : មានដំណាក់កាល<br>. ផ្សះផ្សា | - តម្លៃតុលាការសម្រាប់រឿងក្ដីរដ្ឋប្បវេណី: ៧០.០០០ ៛ = ១.៧៥ ដុល្លារ<br>- ការពិនិត្យកោសល្យវិច័យ : ២០.០០០ ៛ - ១០០.០០០៛ (៥-៥០ ដុល្លារ)<br>- ការចំណាយ ផ្សេងៗ<br>- ការចំណាយ ក្រៅច្បាប់ត្រូវបានគេរាយការណ៍ ដើម្បីចេញសេចក្ដី សម្រេច និងអនុវត្តសាលក្រម។ល។ |

# ជំពូក IV
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជំពូកនេះជាសេចក្តីសន្និដ្ឋាន និងអនុសាសន៍យោងទៅលើការវិភាគទាំងឡាយដូចបានរៀបរាប់នៅក្នុងជំពូកមុនៗ។ ជំពូកទីមួយ បានរៀបរាប់ពីកម្មវត្ថុ វិធីសាស្ត្រស្រាវជ្រាវប្រភព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ។ ជំពូកទីពីរ បានវិភាគពីតម្រូវការយុត្តិធម៌នៅក្នុងសង្គម និងជំពូកទីបី បានធ្វើការសិក្សាពីការផ្តល់សេវាយុត្តិធម៌។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ត្រូវបានរៀបចំឡើងដូចមានខាងក្រោម។ ដំបូងគឺទាក់ទងនឹងបញ្ហាចម្បង និងដំណោះស្រាយរយៈពេលវែង ដើម្បីរកដំណោះស្រាយចំពោះរាល់មូលហេតុនៃបញ្ហាទាំងនោះ ដែលជាទូទៅនៅក្រៅប្រព័ន្ធតុលាការ។ បន្ទាប់មកគឺការវាយតម្លៃលើស្ថាប័ន និងយន្តការដែលជាអ្នកផ្តល់សេវាយុត្តិធម៌នីមួយៗ។ ចុងក្រោយគឺការលើកជាអនុសាសន៍ជាក់លាក់មួយចំនួន ដើម្បីកែលំអសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច។

## មា តិ កា


១. សេចក្តីសន្និដ្ឋាន.......២៥៥
១.១. បញ្ហា និងវិវាទចម្បងៗ និងដំណោះស្រាយរយៈពេលវែង.......២៥៥
១.១.១. វិវាទដែលមាននៅក្នុងសង្គម.......២៥៥
១.១.២. ការប្រើប្រាស់អំណាចហួសកម្រិត និងការរំលោភសិទ្ធិបុគ្គល.......២៥៦
១.១.៣. កង្វះខាតការអនុវត្តសិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌.......២៥៧
១.១.៤. ជនជាតិដើមភាគតិច.......២៥៩
១.១.៥. គម្លាតរវាងតម្រូវការយុត្តិធម៌ជាសក្តានុពល និងតម្រូវការយុត្តិធម៌ជាក់ស្តែង.......២៦០
១.២. ការវាយតម្លៃលើការផ្តល់សេវាយុត្តិធម៌.......២៦២
២. អនុសាសន៍.......២៦៣
២.១. ពង្រឹង និងបង្កើតយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានា.......២៦៣
២.១.១. ពង្រឹងយន្តការដោះស្រាយវិវាទនៅមូលដ្ឋាននានានៅនឹងថ្នាក់មូលដ្ឋាន.......២៦៣
២.១.២. បង្វិតអំណាចយុត្តាធិការឱ្យទៅជិតប្រជាពលរដ្ឋ: យុត្តិធម៌នៅមូលដ្ឋាន.......២៦៤
២.១.៣. ទទួលស្គាល់ និងពង្រឹងច្បាប់ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេ.......២៦៦
២.២. កែលំអយន្តការដោះស្រាយវិវាទក្រៅតុលាការ.......២៦៨
២.២.១. គណៈកម្មការសុរិយោដី.......២៦៨
២.២.២. ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយវិវាទការងារ.......២៦៩

២.៣. កែលំអប្រព័ន្ធយុត្តិធម៌ផ្លូវការ ..... ២៦៩
២.៣.១. តុលាការ ..... ២៦៩
២.៣.២. នគរបាលយុត្តិធម៌ ..... ២៧១
២.៣.៣. សេវាច្បាប់ ..... ២៧១
២.៤. បង្កើនសមត្ថភាព និងផ្តល់អំណាចដល់ប្រជាពលរដ្ឋដើម្បីចូលរួមកែលំអសេវាកម្មយុត្តិធម៌ ..... ២៧១
២.៥. បង្កើតឱ្យមានយន្តការដើម្បីសម្របសម្រួលក្នុងការផ្តល់សេវាយុត្តិធម៌ ..... ២៧២
៣. តារាងសង្ខេប ស្តីអំពីកម្មវិធីទទួលបានយុត្តិធម៌ ដោយផ្តោតលើជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ..... ២៧៤
៤. តារាងសង្ខេប ស្តីអំពីតម្រូវការ និងការផ្តល់សេវាយុត្តិធម៌សម្រាប់ជនក្រីក្រ ស្ត្រី និងជនជាតិដើមភាគតិច ..... ២៨០